ក្រសួងសុខាភិបាល

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ

# ឯកសារស្ដីពី
# ការគ្រប់គ្រងនិងថែទាំជម្ងឺកាមរោគ
# ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា



ឆ្នាំ ២០០៣

# មាតិការឿង

**អារម្ភកថា**

**ជំពូកទី១:**

បញ្ហាសុខាភិបាលសាធារណៈធ្ងន់ធ្ងរដែលបណ្តាលមកពីជំងឺកាមរោគ

**ជំពូកទី២:**

ការប្រើប្រាស់គំនូសបំព្រួញដើម្បីថែទាំព្យាបាលជំងឺកាមរោគដោយប្រើចង្កោមរោគសញ្ញា

**ជំពូកទី៣:**

ការស្រង់ប្រវត្តិជំងឺ និងការពិនិត្យអ្នកជំងឺ

**ជំពូកទី៤:**

ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល

**ជំពូកទី៥:**

ការអប់រំអ្នកជំងឺ

**ជំពូកទី៦:**

ការគ្រប់គ្រងថែទាំដៃគូរួមភេទ

**ឧបសម្ព័ន្ធ**

អក្ខរានុក្រម

# បញ្ហាសុខភាពសាធារណៈដ៏ធ្ងន់ធ្ងរ
# ដែលបណ្តាលមកពីជម្ងឺកាមរោគ

## ការគ្រប់គ្រងថែទាំជំងឺកាមរោគ

### ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា សំរាប់ថ្នាក់មណ្ឌលសុខភាព

**ជំពូកទី ១**

# បញ្ហាសុខភាពសាធារណៈដ៏ធ្ងន់ធ្ងរ ដែលបណ្តាលមកពីជម្ងឺកាមរោគ

# ជំពូកទី១

## បញ្ហាសុខភាពសាធារណៈដ៏ធ្ងន់ធ្ងរដែលបណ្តាលមកពីជម្ងឺកាមរោគ

ជំងឺកាមរោគ ជាជម្ងឺដែលកើតមានជាញឹកញាប់ ។ ជម្ងឺដែលគេស្គាល់ច្រើនជាងគេមានជម្ងឺប្រមេះទឹកបាយ(gonorrhea) ជម្ងឺស្វាយ (syphylis) និង ជំងឺអេដស៍(AIDS) ក៏ប៉ុន្តែនៅមានជម្ងឺជាង ២០ទៀត ដែលជាជំងឺកាមរោគ ។ យោងតាមការប៉ាន់ប្រមាណរបស់អង្គការសុខភាពពិភពលោក មានករណីកាមរោគចំនួន ៣៣៣ លានកើតឡើងនៅលើពិភពលោក ។ ប្រហែល ១ លានករណីកាមរោគ កើតជារៀងរាល់ថ្ងៃ ។ ទំនាក់ទំនងរវាងមេរោគអេដស៍ និងកាមរោគដទៃៗទៀតកាន់តែធ្វើឱ្យគេចាត់វិធានការណ៍បង្ការ និងទប់ស្កាត់ជម្ងឺកាមរោគដែលអាចព្យាបាលជា ថែមទៀត។

**មាតិកា**


ការចំលងនៃជំងឺកាមរោគ..................................៣

អត្រានៃជំងឺកាមរោគ.....................................១៥

ការរាតត្បាតនៃមេរោគអេដស៍ និងជំងឺអេដស៍.......១៧

ទំនាក់ទំនងរវាងកាមរោគនិង មេរោគអេដស៍ និងជំងឺអេដស៍ ................................................១៩

ការលំបាកក្នុងការប្រយុទ្ធនឹងកាមរោគ.................២៣

ការរំលឹកឡើងវិញ..........................................២៨

សំនួរ និងលំហាត់............................................៣០

ចំលើយ........................................................៣២


ជំពូកនេះរួមមានពត៌មានស្តីអំពីផលប៉ះពាល់នៃជម្ងឺកាមរោគ និងការរាតត្បាតនៃជំងឺកាមរោគ។ វាមានការផ្តល់ការពិភាក្សាអំពីបែបបទនៃការចំលងជម្ងឺកាមរោគ និង កត្តាជីវសាស្ត្រទាក់ទងនឹងការប្រព្រឹត្ត និង កត្តាសង្គមដែលជះឥទ្ធិពលដល់ការចំលងនៃកាមរោគ ។ ផលវិបាកនៃជម្ងឺកាមរោគ និងទំនាក់ទំនងរវាងកាមរោគទៅនឹងការចំលងមេរោគអេដស៍ ក៏ត្រូវបានពិភាក្សាផងដែរ ។ ជំពូកនេះត្រូវបានបញ្ចប់ដោយការពិភាក្សាអំពីកត្តាសំខាន់ៗ ក្នុងការបង្ការ និងទប់ស្កាត់ជំងឺកាមរោគ ព្រមទាំងការធ្វើឱ្យការទប់ស្កាត់កាមរោគកាន់តែមានលក្ខណៈល្អប្រសើរថែមទៀត។

# ការចំលងនៃជំងឺកាមរោគ

## បែបផែននៃការចំលងជំងឺកាមរោគ

- **ការរួមភេទដោយសិកបញ្ចូលដែលមិនបានប្រើមធ្យោបាយបង្ការជំងឺកាមរោគ**



*ការរួមភេទដោយសិកបញ្ចូល លិង្គទៅក្នុងទ្វារមាស*



*ការរួមភេទដោយសិកបញ្ចូល លិង្គទៅក្នុងទ្វារលាមក*



*ការរួមភេទដោយការប៉ះពាល់ ប្រដាប់ភេទនិងមាត់*

- **ពីម្ដាយទៅទារក**







- ក្នុងពេលមានគភ៌ ឬ
- ពេលសំរាល ឬ
- ក្រោយពេលសំរាលតាមរយៈទឹកដោះ

- **បញ្ចូលឈាម ឬ ការប៉ះពាល់ឈាម ឬ ផលិតផលឈាម**







រាល់ការរួមភេទដោយសិកបញ្ចូលដែលមិនបានប្រើមធ្យោបាយបង្ការ មិនមែនសុទ្ធតែបណ្តាលឱ្យមានការចំលងជំងឺកាមរោគពីអ្នកកើតជំងឺកាមរោគទៅដៃគូរបស់ខ្លួននោះទេ ។ ការដែលបុគ្គលម្នាក់ឆ្លង ឬ មិនឆ្លងជំងឺកាមរោគនោះ ត្រូវទទួលរងនូវឥទ្ធិពលអំពីកត្តាជាច្រើនដូចជា កត្តាជីវសាស្ត្រ សង្គម និង កត្តាទាក់ទងនឹងការប្រព្រឹត្ត ។

## ***កត្តានានា ដែលជះឥទ្ធិពលដល់ការចំលងជំងឺកាមរោគ***

### **<u>ស្ត្រីភេទ</u>**

មានកត្តាជីវសាស្ត្រ ២ ដែលធ្វើឱ្យស្ត្រីងាយឆ្លងជំងឺកាមរោគ គឺ :

- ផ្ទៃភ្នាសសើមនៅទ្វារមាសមានទំហំធំធេង
- អិចតូពីនៃមាត់ស្បូនដែលមាននៅលើស្ត្រីវ័យក្មេង




កាមរោគអាចចូលទៅរាងកាយបានយ៉ាងងាយស្រួលតាមរយៈផ្ទៃភ្នាសសើម ដូច្នេះស្ត្រីមានផ្ទៃភ្នាសសើមយ៉ាងធំធេងដែលអាចឆ្លងមេរោគបាន ប្រសិនបើស្ត្រីនោះរួមភេទជាមួយដៃគូដែលកើតជំងឺកាមរោគ ។ អិចតូពី (ectopy) មាត់ស្បូន គឺ ជាស្ថានភាពមួយដែលមានកោសិកាងាយនឹងទទួលនូវការឆ្លងកាមរោគនៅលើផ្ទៃនៃមាត់ស្បូន។ វាជាការធម្មតាទេ ចំពោះស្ថានភាពនេះនៅលើស្ត្រីក្មេងៗ ហើយស្ត្រីក្មេងៗទាំងនោះងាយនឹងទទួលរងនូវការឆ្លងកាមរោគជាងស្ត្រីចាស់ៗ។

### **<u>បុរស</u>**

បុរសដែលមិនបានកាត់ស្បែកគ្របក្បាលលិង្គ (uncircumcised) ងាយកើតកាមរោគជាងបុរសដែលកាត់ស្បែកគ្របក្បាលលិង្គ ( circumcised) ។ បុរសដែលមិនបានកាត់ស្បែកគ្របក្បាល

លិង្គមានការលំបាក ក្នុងការបង្ការកុំឱ្យផ្នែកខាងក្នុងនៃស្បែកគ្របក្បាលលិង្គពីការប៉ះពាល់វត្ថុរាវសរីរៈ ( body fluids) ។



ស្បែកគ្របក្បាលលិង្គ —

## *កត្តាទាក់ទងនឹងការប្រព្រឹត្តិដែលជះឥទ្ធិពលដល់ការចំលងជំងឺកាមរោគ*

កត្តាដែលទាក់ទងនឹងការប្រព្រឹត្តិជាច្រើនអាចជះឥទ្ធិពលដល់ការឆ្លងជំងឺកាមរោគក្នុងពេលរួមភេទ ។ការប្រព្រឹត្តិទាំងឡាយណាដែលបង្កើនឱកាសដល់ការឆ្លងត្រូវចាត់ទុកថា ជាកត្តាប្រព្រឹត្តិដែលប្រឈមមុខនឹងគ្រោះថ្នាក់ ។ ការប្រព្រឹត្តិប្រឈមមុខនឹងគ្រោះថ្នាក់ធ្វើឱ្យមនុស្សងាយនឹងប៉ះពាល់ជាមួយអ្នកដែលកើតជម្ងឺកាមរោគ ។ ការប្រឈមមុខនឹងគ្រោះថ្នាក់កើនឡើង ប្រសិនបើគ្មានការប្រើប្រាស់ស្រោមអនាម័យ នៅពេលរួមភេទតាមយោនី ឬតាមរន្ធគូថដោយស៊កបញ្ចូល ។

ការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ក្នុងការចំលងកាមរោគ គឺជាការប្រព្រឹត្ត ដែលនាំអោយបុគ្គលប៉ះពាល់ជាមួយឈាម ទឹកកាម សារធាតុរាវដែលបញ្ចេញដោយទ្វារមាស ឬដំបៅប្រដាប់បន្តពូជដែលមានមេរោគ។

## *ការប្រព្រឹត្តិរួមភេទរបស់បុគ្គលម្នាក់ៗ* **( personal sexual behavior)**

ការប្រព្រឹត្តិរួមភេទរបស់បុគ្គលម្នាក់ៗ ដែលប្រឈមមុខនឹងការចំលងកាមរោគរួមមានៈ

- រួមភេទជាមួយអ្នកដទៃក្រៅពីដៃគូរួមភេទទៀងទាត់ ដោយមិនប្រើនូវមធ្យោបាយបង្ការជំងឺ
- ផ្លាស់ប្តូរដៃគូរួមភេទញឹកញាប់
- មានដៃគូរួមភេទលើសពីម្នាក់
- រួមភេទជាមួយដៃគូរួមភេទដែលជួបដោយចៃដន្យ ដូចជា ស្ត្រីរកស៊ីផ្លូវភេទ និងអតិថិជនរបស់ស្ត្រីទាំងនោះ

- មានកើតជំងឺកាមរោគកាលពីឆ្នាំកន្លងទៅ
- ផ្តោះប្តូរការរួមភេទដើម្បីប្រាក់ វត្ថុ ឬ ផលប្រយោជន៏ផ្សេងៗ
- ផ្តោះប្តូរការរួមភេទដើម្បីគ្រឿងញៀន ឬ ផ្តោះប្តូរគ្រឿងញៀនដើម្បីរួមភេទ
- ប្រើប្រាស់នូវសារធាតុដែលធ្វើឱ្យទ្វារមាសស្ងួត (vaginal drying agent)

ការផ្លាស់ប្តូរដៃគូរួមភេទក្នុងពេលថ្មីៗ ហើយញឹកញាប់ ការមានដៃគូរួមភេទលើសពីម្នាក់ ឬ រួមភេទជាមួយដៃគូជួបដោយចៃដន្យ ឬ រួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទ ឬ ជាមួយភ្ញៀវរបស់ស្ត្រីរកស៊ីផ្លូវភេទ ធ្វើឱ្យបុគ្គលម្នាក់ងាយជួបប្រទះនឹងអ្នកដែលកើតជំងឺកាមរោគ ។ ប្រសិនបើមនុស្សម្នាក់ធ្លាប់កើតជំងឺកាមរោគក្នុងឆ្នាំកន្លងទៅ អ្នកនោះអាចប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជម្ងឺកាមរោគដូចលើកមុន ប្រសិនបើគេមិនអាចផ្លាស់ប្តូរនូវការប្រព្រឹត្តិរបស់ខ្លួនបានទេនោះ ។ ការផ្តោះប្តូរការរួមភេទដើម្បីប្រាក់ កើតឡើងចំពោះមនុស្សច្រើនប្រភេទ រួមមាន ស្ត្រីរកស៊ីផ្លូវភេទ និងអ្នកដែលទិញការរួមភេទពីស្ត្រីទាំងនោះផង (ហៅថា អតិថិជន ឬ ភ្ញៀវ) ។ វាក៏រួមបញ្ចូលផងដែរនូវអ្នកដែលមិនមែនជាអ្នករកស៊ីផ្លូវភេទ ក៏ប៉ុន្តែអាចផ្តល់ ឬ ទទួលយកវត្ថុមានតំលៃអ្វីមួយជាថ្នូរនឹងការរួមភេទ ។

ការប្រព្រឹត្តិទាំងនេះប្រឈមមុខនឹងការឆ្លងពីព្រោះបុគ្គលទាំងនេះ មានទំនោរឆ្លង ឬ ចំលងជំងឺកាមរោគ យ៉ាងញឹកញាប់ ។ ការប្រើប្រាស់សារធាតុដែលធ្វើឱ្យទ្វារមាសស្ងួត ( drying agent) សំដៅលើការប្រព្រឹត្តិច្រើនបែប ។ នៅកន្លែងខ្លះនៃពិភពលោក ស្ត្រីប្រើប្រាស់ស្មៅ ឬ សារធាតុផ្សេងៗទៀតដាក់ក្នុងទ្វារមាស ដើម្បីឱ្យទ្វារមាសនោះស្ងួត ឬ តូចចង្អៀត ។ ធ្វើបែបនេះអាចបណ្តាលឱ្យរលាកទ្វារមាស ( vaginal irritation) ដែលអាចបណ្តាលឱ្យមានការរហែកតូចៗ ( micro-lesions ) នៅលើជញ្ជាំងទ្វារមាស ( vaginal wall) ហើយជួយសំរួលដល់ការចំលងជំងឺកាមរោគ ។

## ការប្រព្រឹត្តិប្រឈមមុខនឹងគ្រោះថ្នាក់

**ការប្រព្រឹត្តិរួមភេទរបស់បុគ្គលម្នាក់ៗ**

- រួមភេទ ជាមួយអ្នកដទៃដែលពុំមែនជាដៃគូទៀងទាត់ដោយមិនប្រើមធ្យោបាយបង្ការ
- ផ្លាស់ប្តូរដៃគូរួមភេទញឹកញាប់
- មានដៃគូរួមភេទលើសពីម្នាក់
- រួមភេទជាមួយដៃគូរួមភេទ ដែលជួបដោយចៃដន្យ ( ស្ត្រីរកស៊ីផ្លូវភេទ និងអតិថិជន)
- ធ្លាប់មានកើតកាមរោគកាលពីឆ្នាំកន្លងទៅ
- ផ្តោះប្តូរការរួមភេទដើម្បីប្រាក់ វត្ថុឬផលប្រយោជន៏
- ផ្តោះប្តូរការរួមភេទដើម្បីគ្រឿងញៀន ឬ ផ្តោះប្តូរគ្រឿងញៀន ដើម្បីការរួមភេទ។
- ប្រើប្រាស់សារធាតុដែលធ្វើឱ្យទ្វារមាសស្ងួត

**កត្តាប្រព្រឹត្តរបស់បុគ្គលដែលប្រឈមមុខនឹងគ្រោះថ្នាក់ផ្សេងទៀត**

- ចោះទំលុះស្បែក
- ប្រើប្រាស់សុរា គ្រឿងញៀនដទៃៗទៀតមុន ឬ ក្នុងពេលរួមភេទ
- ការបញ្ចូលឈាមដែលមានភ្នាក់ងារបង្កកាមរោគ

**ការប្រព្រឹត្តិរបស់ដៃគូរួមភេទ**

- រួមភេទជាមួយអ្នកដទៃដោយមិនប្រើមធ្យោបាយបង្ការជំងឺ
- កើតកាមរោគ
- ផ្ទុកមេរោគអេដស៏
- ចាក់គ្រឿងញៀន
- រួមភេទជាមួយបុរស ( សំរាប់ដៃគូរួមភេទប្រុស)

## *ការប្រព្រឹត្តិរបស់បុគ្គលផ្សេងៗទៀតដែលប្រឈមមុខនឹងគ្រោះថ្នាក់*

ការប្រព្រឹត្តិទាក់ទងនឹងបុគ្គលផ្សេងៗទៀត ដែលប្រឈមមុខនឹងគ្រោះថ្នាក់មាន:

- ការចាក់ទំលុះស្បែក
- ការប្រើគ្រឿងញៀន ឬជាតិសុរាមុនពេល ឬ ក្នុងពេលរួមភេទ និង
- ការបញ្ចូលឈាម

ការចាក់ទំលុះស្បែកសំដៅទៅលើការប្រព្រឹត្តិច្រើនប្រភេទដែលរួមមាន ការយកម្ជុលមិនបានស្ងោររំងាប់មេរោគមកចាក់ថ្នាំ ឬ សាក់ស្បែក ឆ្លូតស្បែក ឬ ចោះទំលុះស្បែក និងការកាត់ស្បែកស្រោបក្បាលលិង្គ ដោយប្រើកាំបិតរួមគ្នា ។ ការផឹកជាតិសុរា ឬប្រើគ្រឿងញៀនអាចមាន ឥទ្ធិពលអាក្រក់ដល់ការប្រើប្រាស់ស្រោមអនាម័យ ។ ការបញ្ចូលឈាមទាំងឡាយណាដែលធ្វើទៅមុនឆ្នាំ ១៩៨៨ ជាទូទៅ ពុំចោទជាបញ្ហាធំដុំទេ។

### ការប្រព្រឹត្តរបស់ដៃគូរួមភេទ

ទោះបីជាបុគ្គលម្នាក់ពុំមានការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់ក្តី ក៏អ្នកនោះអាចប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងផងដែរ ប្រសិនបើ ដៃគូរួមភេទរបស់គាត់ :

- រួមភេទជាមួយអ្នកដទៃទៀតដោយពុំប្រើនូវមធ្យោបាយបង្ការ
- កើតជំងឺកាមរោគ
- មានផ្ទុកមេរោគអេដស៍
- ចាក់គ្រឿងញៀន ឬ
- រួមភេទជាមួយបុរស ( ដៃគូរួមភេទជាបុរស) ។

ប្រសិនបើដៃគូរួមភេទនោះ មានការប្រព្រឹត្តណាមួយក្នុងចំណោមការប្រព្រឹត្តិទាំងនេះ នោះគាត់ងាយនឹងប៉ះពាល់ ឬ ងាយទទួលរងនូវការឆ្លងជំងឺកាមរោគ ដូច្នេះគេងាយនឹងចំលងជំងឺកាមរោគផងដែរ ។

**ភាគរយនៃបុរសដែលបានរួមភេទជាមួយនារីរកស៊ីផ្លូវភេទក្នុងរយៈពេល ១ខែកន្លងមក នៅប្រទេសកម្ពុជា**



## *ការប្រព្រឹត្តដែលអាចបង្ការខ្លួនពីការឆ្លងជំងឺកាមរោគ (Protective behavior)*

| **ការប្រព្រឹត្តដែលអាចបង្ការខ្លួនពីការឆ្លងជំងឺកាមរោគ** |
| --- |
| ■ *ការប្រើប្រាស់ស្រោមអនាម័យ* |
| ■ *សកម្មភាពរួមភេទដែលប្រឈមមុខនឹងការចំលងទាប* |
| *ឧទាហរណ៍ : ការប្រឆីកប្រដាប់បន្តពូជឱ្យគ្នាទៅវិញទៅមក (mutual masturbation)* |



ក្នុងករណីជាច្រើន អ្នកអាចនឹងរកឃើញនូវការប្រព្រឹត្តផ្ទាល់ខ្លួនរបស់អ្នកជំងឺនៅពេលដែលអ្នកសាកសួរគាត់ ។ ការប្រើប្រាស់ពត៌មានទាំងនេះ ដើម្បីគ្រប់គ្រងថែទាំអ្នកជំងឺនឹងត្រូវបានលើកយកមកពិភាក្សានៅក្នុង ជំពូកទី ៣ និងទី៥ ។

**ការប្រើប្រាស់ស្រោមអនាម័យជានិច្ចជាមួយនារីរកស៊ីផ្លូវភេទ**
**ក្នុងរយៈពេល ៣ ខែ កន្លងមក (នៅប្រទេសកម្ពុជា)**




ការប្រព្រឹត្តដែលអាចបង្ការខ្លួន កាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគ ។ ការប្រើប្រាស់ស្រោមអនាម័យ បន្ថយនូវការប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគ ដោយបង្ការនូវការប៉ះពាល់ជាមួយវត្ថុរាវបញ្ចេញដោយទ្វារមាស (vaginal fluids) ទឹកកាម ឬ ឈាម ។

ប្រសិនបើប្រើប្រាស់បានត្រឹមត្រូវ ស្រោមអនាម័យមានប្រសិទ្ធិភាពលើសពី ៩៥% ក្នុងការបង្ការការចំលងជំងឺកាមរោគ ។ ការរួមភេទមួយចំនួនដូចជាការរួមភេទតាមទ្វារមាស ឬ តាមរន្ធគូថ គឺជាការប្រព្រឹត្តដែលប្រឈមមុខនឹងការឆ្លងខ្ពស់ ។ ការប្រព្រឹត្តនានា ដែលបង្ការនូវការប៉ះពាល់វត្ថុរាវសរីរៈនានា ដូចជា ការប្រឆឹកប្រដាប់បន្តពូជគ្នាទៅវិញទៅមក ( mutual masturbation) គឺមានការប្រឈមមុខនឹងការឆ្លងទាបជាងការប្រព្រឹត្តខាងលើច្រើនណាស់។

## ***ក្រុមដែលងាយប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លង ( Vulnerable groups)***

| ក្រុមដែលងាយប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លង |
| --- |
| • ស្ត្រីរកស៊ីផ្លូវភេទ និង អតិថិជនរបស់គេ<br>• ក្រុមមនុស្សវ័យជំទង់ដែលកំពុងមានសកម្មភាពផ្លូវភេទ<br>• បុរស ឬ ស្ត្រី ដែលមានដៃគូរួមភេទច្រើន<br>• បុរស ឬ ស្ត្រី ដែលស្ថិតនៅឆ្ងាយពីដៃគូរួមភេទទៀងទាត់របស់ខ្លួនក្នុងរយៈពេលយូរ ។ |

នៅក្នុងសហគមន៍ជាច្រើនមានក្រុមមនុស្សមួយចំនួន ដែលងាយទទួលរងនូវការប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគ ដោយសារពួកគេជួបប៉ះពាល់នឹងអ្នកកើតជំងឺកាមរោគជាញឹកញាប់ ឬ ដោយសារគេងាយនឹងឆ្លងជំងឺកាមរោគរាល់ពេលដែលគេប៉ះពាល់នឹងមេរោគទាំងនោះ (ឧទាហរណ៍ ស្ត្រីវ័យក្មេង) ។ ដោយសារមូលហេតុផ្សេងៗ អ្នកទាំងនោះមានការស្ទាក់ស្ទើរក្នុងចិត្ត ក្នុងការទៅកាន់មជ្ឈមណ្ឌលថែទាំសុខភាព ដើម្បីទទួលនូវការព្យាបាល ។

ដូច្នេះយើងត្រូវការខិតខំប្រឹងប្រែងជាពិសេស ដើម្បីឱ្យមានសេវាថែទាំសំរាប់ពួកគេ និងធ្វើឱ្យពួកគេអាចទទួលយកបាននូវសេវាទាំងនោះ។

## ផលវិបាកនៃជំងឺកាមរោគ



គេអាចចៀសវាងនូវ ផលវិបាកខាងក្រោមនេះបាន ប្រសិនបើគេផ្តល់ការព្យាបាលត្រឹមត្រូវឱ្យបានមុន ផលវិបាកទាំងនេះកើតឡើង ។

### ផលវិបាកចំបងៗនៃជំងឺកាមរោគលើស្ត្រី និង កុមារ

- ✓ ការឈឺចុកចាប់ពោះរ៉ាំរ៉ៃ
- ✓ ជំងឺរលាកប៉ែលវីស
- ✓ គ្មានសមត្ថភាពបន្តពូជ (Infertility)
- ✓ ការស្លាប់បណ្តាលមកពីការរាតត្បាតនៃមេរោគនៅក្នុងឈាម(Sepsis) គភ៌ក្រៅស្បូន ឬ មហារីកមាត់ស្បូន
- ✓ ការរលូតកូន កើតកូនមកស្លាប់ (still birth) ឬ កូនស្លាប់ក្រោយពេលសំរាល ( perinatal death)
- ✓ ជំងឺរលាកភ្នែកដែលអាចបណ្តាលឱ្យភ្នែកទារកខ្វាក់ ឬ ជំងឺរលាកសួត (pneumonia) លើទារកទើបនឹងកើត ។

**ជំងឺរលាកប៉ែលវីស និងកង្វះសមត្ថភាពក្នុងការបន្តពូជ:**

ប្រសិនបើគ្មានការព្យាបាលទេ 45-85% នៃស្ត្រីដែលកើតជំងឺរលាកប៉ែលវីស អាចក្លាយទៅជាអ្នកគ្មានសមត្ថភាពក្នុងការបន្តពូជ។ ស្ត្រីជាច្រើនបាត់បង់នូវសមត្ថភាពក្នុងការបន្តពូជរបស់ខ្លួន ដោយមិនទាំងដឹងខ្លួនថាធ្លាប់កើតជំងឺរលាកប៉ែលវីសផង។



**កង្វះសមត្ថភាពក្នុងការបន្តបពូជ**

(infertility)

គឺជាផលវិបាកមួយនៃ ជំងឺកាមរោគដែលអាចកើតមាន ហើយអាចបង្ការដោយការព្យាបាលជំងឺកាមរោគដែលអាចព្យាបាលឱ្យជាសះស្បើយ ឱ្យបានរួសរាន់និងមានប្រសិទ្ធិភាព ។



**ជំងឺរលាកប៉ែលវីស និងគភ៌ក្រៅស្បូន**

ជំងឺរលាកប៉ែលវីស បង្កើនគ្រោះថ្នាក់នៃការប្រឈមមុខនឹងគ្រោះថ្នាក់ នៃការបង្កគភ៌ក្រៅស្បូនចំនួន ៧ ទៅ ១០ ដង ខ្ពស់ជាងស្ត្រីធម្មតា ។



**កាមរោគនៃទារកទើបនឹងកើត:**

នៅក្នុងប្រទេសមួយចំនួនជំងឺរលាកភ្នែកទារកទើបនឹងកើត(Ophthalmia) ប៉ះពាល់ ៥% នៃទារក។ បើគ្មានការព្យាបាលទេនោះ ជំងឺនេះតែងតែធ្វើឱ្យទារកបាត់បង់គំឃើញពី ១% ទៅ ៦% នៃករណី ។ មេរោគក្លាមីឌីយ៉ា ក៏អាចរាលដាលដល់សួតទារកទើបនឹងកើត ហើយបណ្តាលឱ្យកើតជាជំងឺរលាកសួតផងដែរ ។



ជំងឺរលាកប៉ែលវីស (PID) គឺជាការរលាកស្បូន, ដៃស្បូន និង អូវែរ ។ ជួនកាលជំងឺរលាកប៉ែលវីស រាលដាលទៅកាន់ផ្នែកខាងក្រោមនៃពោះ។ មូលហេតុចំបងៗនៃជំងឺរលាកប៉ែលវីសលើស្ត្រី គឺមេរោគប្រមេះទឹកបាយ និង ជំងឺបង្កដោយមេរោគក្លាមីឌីយ៉ា ។ ជារឿយៗ ការឈឺចាប់ដែលកើតឡើងនៅពេលមានជំងឺ PID គឺរោគសញ្ញាទីមួយដែលស្ត្រីកត់សំគាល់ឃើញ។ ប្រសិនបើដៃស្បូនមានការខូចខាតទៅហើយនោះ នៅពេលដែលស្ត្រីនោះមានការឈឺចាប់ នោះគេមិនអាចកែសំរួលការខូចខាតនេះមករកសភាពដើមបានទេ។ ដោយហេតុថាជំងឺ PID ធ្វើឱ្យមានការសន្លាក (scar) និង ធ្វើឱ្យដៃស្បូនរួមតៀ្បត នោះវាបង្កើនគ្រោះថ្នាក់នៃការមានគភ៌ក្រៅស្បូន (ដែលជាលក្ខណៈមួយអាចបង្កអោយមានគ្រោះថ្នាក់ដល់ជីវិតនៃស្ត្រី) ។ ប្រសិនបើគភ៌ប្រព្រឹត្តនៅដៃស្បូន ដៃស្បូនអាចបែកបណ្តាលឱ្យមានការហូរឈាមយ៉ាងច្រើន ។ គភ៌ក្រៅស្បូនគឺជាមូលហេតុនៃការស្លាប់នៃម្តាយចំនួនពី ១ % ដល់ ៥ % ជំងឺប្រមេះទឹកបាយនិងជំងឺបង្កដោយមេរោគក្លាមីឌីយ៉ាក៏អាចបង្កឱ្យមានការរលាកភ្នែក ការរលាកសួតនៃទារកទើបនឹងកើត។ ជំងឺស្វាយដែលកើតឡើងពេលមានគភ៌អាចរាលដាលទៅដល់សុក និងឆ្លងទៅទារកក្នុងផ្ទៃ។ ស្ត្រីមានផ្ទៃពោះហើយកើតជំងឺស្វាយ លើសពី៤0%នឹងមានការរលូតកូន កើតកូនមកស្លាប់។ បញ្ហានេះកាន់តែធ្ងន់ធ្ងរថែមទៀត នៅពេលដែលពុំមានការព្យាបាលម្តាយទារកក្នុងរយៈពេល ២0អាទិត្យដំបូង។

| **ផលវិបាកសំខាន់ ៗ នៃជំងឺកាមរោគលើបុរស** |
| --- |
| ♦ ការរួមតេ្បៀតបង្ហូរនោម<br>♦ គ្មានសមត្ថភាពបន្តពូជ (Infertility) |




ជំងឺប្រមេះទឹកបាយនិងជំងឺបង្កដោយមេរោគក្លាមីឌីយ៉ា អាចបង្កឱ្យមានផលវិបាកធ្ងន់ធ្ងរទៅលើបុរស ជំងឺនេះអាចរាលដាលពីបង្ហូរនោម (បណ្តាលឱ្យមានការរលាកបង្ហូរនោម) ទៅកាន់អេពីឌីឌីម (បណ្តាលឱ្យមានការរលាកអេពីឌីឌីម) ។ ការរលាកទាំងនេះអាចបណ្តាលឱ្យមានការរួមតេ្បៀតបង្ហូរនោម និងបាត់បង់សមត្ថភាពបន្តពូជ។

ចំពោះបុរស និង ស្ត្រី ជំងឺស្វាយដែលពុំបានទទួលការព្យាបាលបណ្តាលឱ្យកើតជាផលវិបាកលើសរសៃប្រសាទ និង ឬ បណ្តាលឱ្យស្លាប់បាន។

# អត្រាប្រេវ៉ាឡង់នៃជំងឺកាមរោគ ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ
# នៅប្រទេសកម្ពុជា ឆ្នាំ ១៩៩៦-២០០១




| | Gonorrhea | Chlamydia | Syphilis RPR | Trichomonas |
|---|---|---|---|---|
| Sex worker 96 | 23.2% | 22.5% | 13.8% | 5.4% |
| Sex worker 01 | 14.2% | 12.1% | 2.8% | 2.1% |

# អត្រាប្រេវ៉ាឡង់នៃជំងឺកាមរោគ ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ
# នៅតាមបណ្តាខេត្តមួយចំនួន ឆ្នាំ ២០០១



**ការប៉ាន់ប្រមាណ ករណីជម្ងឺកាមរោគថ្មី ក្នុងចំណោមមនុស្សពេញវ័យ នៅឆ្នាំ ១៩៩៩**




### តើស្ថិតិស្តីពីជំងឺកាមរោគមានភាពត្រឹមត្រូវដល់កំរិតណា?

ការប៉ាន់ស្មានករណីជំងឺកាមរោគមានកំរិតខ្ពស់ជាង ចំនួនរបាយការណ៍ស្តីអំពីកាមរោគសំរាប់ជាតិទាំងមូល ពីព្រោះរបាយការណ៍ទាំងនេះពុំតំណាងឱ្យអ្នកកើតជំងឺកាមរោគពិតប្រាកដទេ ។ ស្ថិតិស្តីពីជំងឺកាមរោគពឹងផ្អែកជារឿយៗទៅលើចំនួនមនុស្ស ដែលមកទទួលការព្យាបាលនៅតាមមណ្ឌលថែទាំសុខភាព ។

របាយការណ៍ស្តីអំពីករណីកាមរោគទាំងនេះ មានទំនោរទៅរកការប៉ាន់ស្មានជំងឺកាមរោគក្នុងកំរិតទាប ដោយសារមូលហេតុជាច្រើន ដូចជា:

- ភាពគ្មានរោគសញ្ញានៃជំងឺកាមរោគ ដូច្នេះអ្នកកើតជំងឺពុំទៅស្វែងរកការព្យាបាល
- មជ្ឈមណ្ឌលថែទាំសុខភាពស្ថិតនៅឆ្ងាយពេក
- ការទៅពិគ្រោះជំងឺជាមួយអ្នកផ្តល់សេវាថែទាំផ្សេងៗទៀត ដូចជា អ្នកលក់ថ្នាំពេទ្យនិងគ្រូឱសថបុរាណជាដើម

♦ ប្រពន្ធ័ពតិមានសុខាភិបាលផ្នែកសាធារណៈ និងឯកជនពុំទាន់មានប្រសិទ្ធិភាព ។

**មូលហេតុនៃការប៉ាន់ស្មានអត្រាផ្ទុកជំងឺកាមរោគមានកំរិតទាប**

♦ បុរស និង ស្ត្រីដែលផ្ទុកជំងឺកាមរោគអាចពុំមានរោគសញ្ញា ដូច្នេះ ពួកគេពុំទៅស្វែងរកការព្យាបាលទេ

♦ អ្នកជំងឺពុំអាចទៅទទួលការថែទាំពីគ្លីនិកជំងឺកាមរោគ ដែលអាចរាយការណ៍ករណីជំងឺកាមរោគបាន

♦ អ្នកជំងឺអាចទៅពិគ្រោះជំងឺ ជាមួយអ្នកផ្តល់សេវាថែទាំសុខភាពផ្សេងៗទៀត ក្រៅពីសេវាសារធារណៈ ។

ដោយសារមានករណីជំងឺកាមរោគដែលពុំបង្ហាញជារោគសញ្ញានោះ ការរាយការណ៍អំពីករណីកាមរោគ អាចមានកំរិតទាប។ ឧទាហរណ៍ :ស្ត្រីចំនួន ៧០% និង បុរសលើសពី ៧០% ដែលកើតជំងឺកាមរោគដែលបង្កដោយមេរោគក្លាមីឌីយ៉ាអាចពុំមានរោគសញ្ញា ហើយស្ត្រីចំនួន ៨០% និងបុរសចំនួនលើសពី ៧០% ដែលកើតជំងឺប្រមេះទឹកបាយអាចពុំមានរោគសញ្ញាឡើយ។

របាយការណ៍ករណីជំងឺកាមរោគរាប់បញ្ចូលតែជំងឺមួយមុខ នៅពេលដែលមានការកើតជំងឺច្រើនក្នុងពេលជាមួយគ្នា ដូចជាការឆ្លងជំងឺប្រមេះទឹកបាយជាមួយនឹងជំងឺបង្កដោយមេរោគក្លាមីឌីយ៉ាជាដើម។ នៅបណ្តាប្រទេសមួយចំនួន ប្រភពថែទាំកាមរោគដំបូងគេដែលមនុស្សជាច្រើនទៅស្វែងរកការថែទាំនោះ ពុំមែនជាសេវាសុខាភិបាលសាធារណៈទេ។ ប្រភពថែទាំផ្សេងៗ ទៀតរួមមាន ឱសថការី គ្រូឱសថបុរាណ អ្នកលក់ថ្នាំពេទ្យ ឬ គ្លីនិកឯកជន ។ ជាទូទៅប្រភេទសេវាទាំងនេះ ពុំរាយការណ៍ករណីជំងឺកាមរោគដែលខ្លួនបានជួបប្រទះមកអាជ្ញាធរសុខាភិបាលថ្នាក់ជាតិទេ។

## ***ការរាតត្បាតនៃមេរោគអេដស៍ និង ជំងឺអេដស៍***

ការឆ្លងមេរោគអេដស៍ (HIV) ដែលបង្កឱ្យកើតជាជំងឺអេដស៍ គឺធ្វើឡើងតាមរយៈការប្រព្រឹត្ត ដូចគ្នានឹងការប្រព្រឹត្តដែលនាំឱ្យកើត កាមរោគដទៃទៀតដែរ។ ពុំទាន់មានការព្យាបាលណាមួយ ដែលអាចធ្វើឱ្យជាសះស្បើយជំងឺអេដស៍នៅ

អង្គការសុខភាពពិភពលោក ទស្សន៍ទាយថាការរាតត្បាតនៃមេរោគអេដស៍ និងជំងឺអេដស៍នឹងកើនឡើង ក្នុងសន្ទុះមួយយ៉ាងលឿននៅក្នុងបណ្តាប្រទេសនាទ្វីបអាស៊ី ។ ចំនួននៃការឆ្លងមេរោគអេដស៍ នៅក្នុងទ្វីបអាស៊ី ត្រូវបានគេរំពឹងថាកើនឡើងទ្វេជាពីរក្នុងឆ្នាំ ២០០១។

ឡើយទេ  ដូច្នេះជំងឺនេះ ជាជំងឺដែលបណ្ដាលឱ្យគ្រោះថ្នាក់ដល់ជីវិតមនុស្ស ។

- ♦ នៅឆ្នាំ ១៩៩៦ អង្គការសុខភាពពិភពលោកបានប៉ាន់ស្មានថាមានមនុស្សពេញវ័យនិងកុមារចំនួន ២៧.៩ លាន នាក់ឆ្លងមេរោគអេដស៍នៅទូទាំងពិភពលោក ។
- ♦ សមាមាត្រនៃករណីស្ត្រីផ្ទុកមេរោគអេដស៍កំពុងតែកើនឡើងជាលំដាប់ ។
- ♦ នៅឆ្នាំ ២០០០ គេទស្សន៍ទាយថានឹងមានមនុស្សចំនួន ៣០ ដល់ ៤០លាន នាក់នឹងឆ្លងមេរោគអេដស៍ ហើយ ៩០ ភាគរយនៃអ្នកទាំងនោះ គឺជាអ្នករស់នៅលើពិភពលោក ។
- ♦ នៅក្នុងកំឡុងឆ្នាំ ២០០០ គេទស្សន៍ទាយថានឹងមានមនុស្ស ២ លាននាក់ នឹងកើតជំងឺអេដស៍ ។
- ♦ នៅប្រទេសកម្ពុជានាឆ្នាំ ២០០០ អ្នកផ្ទុកមេរោគអេដស៍ អាចនឹងឡើងហួសពី ១៥០ ០០០ ហើយអត្រាប្រេវ៉ាឡង់នៃការផ្ទុកមេរោគនេះ ស្មើនឹង ២-៣ % ក្នុងចំណោមមនុស្សពេញវ័យ ។

តារាងខាងក្រោមនេះបង្ហាញ  អំពីការប៉ាន់ស្មានអត្រាប្រេវ៉ាឡង់នៃជម្ងឺកាមរោគ  ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ នៅតាមបណ្ដាប្រទេសមួយចំនួន នៃទ្វីបអាស៊ី នៅឆ្នាំ ១៩៩៩-២០០០ និង ២០០១ ។

**អត្រាប្រេវ៉ាឡង់ជំងឺកាមរោគ  ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ  នៃប្រទេសនានានៅក្នុងតំបន់**




| | Gonorrhea | Chlamydia | Syphilis |
|---|---|---|---|
| □ Laos | 13.6 | 34.8 | 0.4 |
| ■ Philippines | 25.0 | 36.0 | 12.0 |
| ■ Indonesia | 30.9 | 23.9 | 12.9 |
| ■ Bangladesh | 25.0 | 35.0 | 32.0 |
| ■ Kerala, India | 9.2 | 15.8 | 16.7 |
| ■ Cambodia 96 | 23.2 | 22.5 | 13.8 |
| ■ Cambodia 01 | 14.2 | 12.1 | 2.8 |

Sources: Lao NCCA 2001, FHI/Philippines 1999, Otto B et al, AusAID Project, 1999
Bangladesh National AIDS/STD Program, 2001, FHI/DFID partners India 2000

## ទំនាក់ទំនងរវាងកាមរោគ និង មេរោគអេដស៍ និង ជំងឺអេដស៍

មេរោគអេដស៍ងាយឆ្លងតាមរយៈការរួមភេទពីមនុស្សម្នាក់ទៅកាន់មនុស្សម្នាក់ទៀត ដោយមិនបានប្រើមធ្យោបាយបង្ការនៅពេលដែលអ្នកទាំងនោះកើតជំងឺកាមរោគណាមួយផ្សេងទៀត ។ ជំងឺកាមរោគដែលដើរតួយ៉ាងសំខាន់ក្នុងអន្តរកម្មនេះមានជំងឺសង់ក្រ៊ួ (Chancroid), ជម្ងឺបណ្ដាលមកពីមេរោគក្លាមីឌីយ៉ា, ជំងឺប្រមេះទឹកបាយ, ជំងឺស្វាយ និង ជំងឺដែលបណ្ដាលមកពីមេរោគទ្រីកូម៉ូណាស់។ យោលទៅតាមជំងឺនិមួយៗ ជំងឺកាមរោគទាំងនេះ អាចធ្វើឱ្យអ្នកជំងឺងាយឆ្លងមេរោគអេដស៍បានពី ២-៩ ដង លើសពីមនុស្សធម្មតា ប្រសិនបើអ្នកនោះប៉ះពាល់នឹងមេរោគអេដស៍។

សូម្បីតែជំងឺកាមរោគដែលមិនបង្កឱ្យមានដំបៅ ក៏អាចបង្កើនការប្រឈមមុខនឹងគ្រោះថ្នាក់នៃការចំលងមេរោគបានដែរ ។ បញ្ហានេះមកពីកាមរោគធ្វើឱ្យមានគោលិកាសកើនឡើងយ៉ាងច្រើននៅតំបន់ប្រដាប់បន្តពូជ។ គោលិកាស គឺជាគោលដៅនិងជាប្រភពចំលងមេរោគអេដស៍ ។ មូលហេតុមួយទៀត គឺការរលាកប្រដាប់បន្តពូជមកពីជំងឺកាមរោគអាចធ្វើឱ្យមានការដាច់ដោចតូចៗបំផុត (microscopicuts) នៅប្រដាប់បន្តពូជដោយបង្កើតជាកន្លែងដែលអាចឱ្យមេរោគអេដស៍ចូលទៅក្នុងរាងកាយបានយ៉ាងងាយ ។

**ពេលមេរោគជ្រៀតចូលមកក្នុងរាងកាយមនុស្ស តើគោលិកា ស មានប្រតិកម្មយ៉ាងណាដែរ ?**



ជំងឺកាមរោគដែលមិនបង្កឱ្យមានជាដំបៅ មានញឹកញាប់ជាងជំងឺដែលបង្កជាដំបៅ ដូច្នេះវាអាចជាប់ពាក់ពន្ធ័នឹងការឆ្លងច្រើនជាងគេ។ នេះគឺជាការព្រួយបារម្ភមួយយ៉ាងធំសំរាប់តំបន់អាស៊ីប៉ាស៊ីហ្វិក និងជាពិសេសគឺសំរាប់ប្រទេសកម្ពុជាយើងដែរ ដែលមានជំងឺកាមរោគដែលមិនបង្កជាដំបៅញឹកញាប់នោះ។

ការស្រាវជ្រាវនានា បង្ហាញឱ្យឃើញថាការប្រយុទ្ធនឹងជំងឺកាមរោគមានឥទ្ធិពលទៅលើការរាតត្បាតនៃមេរោគអេដស៍។ ការព្យាបាលអ្នកជំងឺកាមរោគផ្តល់ឱកាសដ៏ល្អមួយសំរាប់បុគ្គលិកសុខាភិបាលក្នុងការជួបផ្ទាល់ជាមួយអ្នកជំងឺកាមរោគដែលមានការប្រព្រឹត្តរបស់ខ្លួន ជាកត្តាជំរុញឱ្យពួកគេប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់នឹងការឆ្លងមេរោគអេដស៍។ ការព្យាបាលអ្នកជំងឺកាមរោគផ្តល់ឱកាសដ៏ល្អមួយសំរាប់បុគ្គលិកសុខាភិបាល ក្នុងការជួបផ្ទាល់ជាមួយអ្នកជំងឺកាមរោគដែលមានការប្រព្រឹត្តរបស់ខ្លួនជាកត្តាជំរុញឱ្យពួកគេប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់នឹងការឆ្លងមេរោគអេដស៍។

**ទំនាក់ទំនងរវាងការឆ្លងមេរោគអេដស៍ និងកាមរោគដទៃៗទៀត**




ក្នុងចំណោមជំងឺកាមរោគដែលបង្កើនគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ជំងឺកាមរោគដែលបង្កជាដំបៅ (រួមមានជំងឺស្វាយ និងជំងឺ chancroid ជះឥទ្ធិពល យ៉ាងខ្លាំងក្លាទៅលើការឆ្លងមេរោគអេដស៍ ។

ការធ្វើឱ្យប្រសើរឡើងនូវសេវាថែទាំជំងឺកាមរោគអាចមានឥទ្ធិពលដោយផ្ទាល់ និងខ្លាំងក្លាលើការរាតត្បាតនៃជំងឺអេដស៍ ។

## ការប៉ាន់ស្មានពីចំនួនកុមារ និងយុវវ័យដែលផ្ទុកមេរោគអេដស៍ ឬ កើតជម្ងឺអេដស៍ រហូតមកដល់ចុងឆ្នាំ ២០០២




**សរុប: ៤២ លាននាក់**

## ការប៉ាន់ស្មានចំនួនកុមារ និងយុវវ័យដែលបានឆ្លងមេរោគអេដស៍នៅក្នុង ឆ្នាំ ២០០២




**សរុប: ៥ លាននាក់**

***ជោគជ័យនៃកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគ***

*ការសិក្សានាពេលថ្មីៗនេះ បានបង្ហាញឱ្យឃើញថាកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគដែលប្រកបដោយប្រសិទ្ធិភាព ដែលប្រើប្រាស់នូវវិធីថែទាំព្យាបាលកាមរោគពឹងផ្អែកលើចង្កោមរោគសញ្ញា បានកាត់បន្ថយនូវអត្រាអាំងស៊ីដង់នៃការឆ្លងមេរោគអេដស៍នៅក្នុងសហគមន៍ បាន ប្រហែល ៤២ %ក្នុងកំឡុងពេល ២ ឆ្នាំ ។*

ជំងឺកាមរោគ បង្កើនការប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ហើយអ្នកផ្ទុកមេរោគអេដស៍ ក៏ងាយនឹងទទួលឆ្លងនូវគ្រោះថ្នាក់ក្នុងការឆ្លងមេរោគជាច្រើនមុខផងដែរ។ ជាទូទៅការប្រែប្រួលក្នុងរាងកាយនៃអ្នកផ្ទុកមេរោគអេដស៍ ធ្វើឱ្យអ្នកទាំងនោះងាយនឹងទទួលរងនូវការឆ្លងមេរោគទូទៅនានា អ្នកទាំងនេះអាចងាយមានភាពស៊ាំនៃថ្នាំទៅនឹងការព្យាបាលកាមរោគ ហើយជំងឺកាមរោគអាចវិវត្តយូរជាងអ្នកធម្មតា។



## ការលំបាកក្នុងការបង្ការ និង ទប់ស្កាត់ជំងឺកាមរោគ

### កត្តានានាដែលជះឥទ្ធិពលដល់ការផ្តល់សេវាថែទាំជំងឺកាមរោគប្រកបដោយប្រសិទ្ធិភាព

**ការផ្តល់សេវាថែទាំជំងឺកាមរោគត្រូវទទួលឥទ្ធិពលអំពីៈ**

— *កត្តាសង្គម*

— *ភាពគ្មានរោគសញ្ញា*

— *ការព្យាបាលពុំបានចប់សព្វគ្រប់*

— *ការលំបាកក្នុងការព្យាបាលដៃគូរួមភេទ*

**— កត្តាសង្គម**

មានកត្តាសង្គមមួយចំនួនដែលជះឥទ្ធិពលលើការទទួលការថែទាំជំងឺកាមរោគដែលអាចព្យាបាលបានប្រកបដោយប្រសិទ្ធិភាពដូចជាៈ

- កង្វះខាតមជ្ឈមណ្ឌលថែទាំសុខភាពសមស្រប
- មជ្ឈមណ្ឌលថែទាំសុខភាពយកតំលៃថ្លៃពេក
- មជ្ឈមណ្ឌលថែទាំសុខភាពនៅឆ្ងាយពេក
- មជ្ឈមណ្ឌលថែទាំសុខភាព ខ្វះឱសថដែលមានប្រសិទ្ធិភាពប្រើប្រាស់
- អ្នកជំងឺចូលចិត្តទៅពិគ្រោះជំងឺ ជាមួយសេវាផ្សេងក្រៅពី សេវាថែទាំសុខភាពសាធារណៈ ដូចជា គ្រូឱសថបុរាណជាដើម និង
- ការមាក់ងាយរបស់សង្គម ចំពោះអ្នកកើតជំងឺកាមរោគ ធ្វើឱ្យអ្នកជំងឺជាច្រើនលាក់លៀមនូវអ្វីដែលគេយល់ថាជារឿងខ្មាស់អៀន ហើយស្ទាក់ស្ទើរក្នុងការទៅស្វែងរកការព្យាបាល ។

*ជារឿយៗ មនុស្សជៀសវាងមិនព្រមទៅទទួលការថែទាំនៅតាម មណ្ឌលសុខភាពទេ ។ ពួកគេចូលចិត្តទៅស្វែងរកការព្យាបាលពីអ្នកលក់ថ្នាំដោយផ្ទាល់តែម្តង ។ នេះគឺ ជាបញ្ហាដែលតែងតែកើតមានចំពោះការថែទាំជំងឺកាមរោគ ហើយធ្វើឱ្យមានភាពស៊ាំទៅនឹងថ្នាំអង់ទីប៊ីយោទិកកាន់តែខ្លាំងឡើង ។*

ជំងឺកាមរោគ ដែលពុំបង្កជារោគសញ្ញា ជះឥទ្ធិពលដល់ការចំលង ពីព្រោះអ្នកជំងឺពុំបានដឹងថា ខ្លួនមានបញ្ហាសុខភាពឡើយហើយ ពុំបានទៅស្វែងរកការព្យាបាលដែរ ។ យោលទៅតាមប្រភេទជំងឺបុរសជាង ៧០% ហើយស្ត្រី ៧០-៨០% ពុំមានរោគសញ្ញាអ្វីឡើយនៅពេលដែលខ្លួនឆ្លងជំងឺកាមរោគ ណាមួយនោះ ។

## — ភាពគ្មានរោគសញ្ញា

អ្នកជំងឺមិនអាចដឹងខ្លួនថា ខ្លួនគេមានជំងឺកាមរោគទេ ពីព្រោះជំងឺកាមរោគនោះ ពុំបានលេចចេញជារោគសញ្ញាអ្វីឡើយ ។

## — ការព្យាបាលពុំបានចប់សព្វគ្រប់

ការព្យាបាលជំងឺកាមរោគ ពុំបានធ្វើទៅបានចប់សព្វគ្រប់ ទោះបីជា អ្នកជំងឺបានទទួលការព្យាបាលនៅឯមជ្ឈមណ្ឌលថែទាំសុខភាពហើយក្តី មូលហេតុមួយចំនួននៃបញ្ហានេះមានៈ

- ការព្យាបាលមានតំលៃថ្លៃពេក
- ការព្យាបាលពុំអាចធ្វើទៅបាន
- ការព្យាបាលមានរយៈពេលជាច្រើនថ្ងៃទើបចប់សព្វគ្រប់ ហើយអ្នកជំងឺភ្លេចព្យាបាលខ្លួនឯង
- អ្នកជំងឺជឿថា ការព្យាបាលតែមួយរយៈជាការគ្រប់គ្រាន់សំរាប់ធ្វើឱ្យជាសះស្បើយជំងឺរបស់ខ្លួន ហើយជាពិសេសគឺនៅពេលដែលរោគសញ្ញានោះបាត់ទៅវិញ។ អ្នកជំងឺពុំសូវឱ្យតំលៃទៅលើសេវាថែទាំដែលគាត់ទទួលនៅឯមណ្ឌលសុខភាពទេ ។

## — ការព្យាបាលដៃគូរួមភេទ

ជាការសំខាន់គេត្រូវព្យាបាលដៃគូរួមភេទនៃអ្នកជំងឺកាមរោគ ដើម្បីបង្ការកុំឱ្យមានការរាលដាលនៃជំងឺជាបន្តទៅទៀត ឬកុំឱ្យមានការឆ្លងជំងឺសារជាថ្មីឡើងវិញ។ ក៏ប៉ុន្តែគេពុំអាចព្យាបាលដៃគូរួមភេទបានដោយសារមូលហេតុជាច្រើនដូចជាៈ

- អ្នកជំងឺមានការមិនស្រួលក្នុងចិត្ត ឬពុំអាចប្រាប់ដៃគូរួមភេទរបស់ខ្លួនអំពីជំងឺកាមរោគ
- ដៃគូរួមភេទពុំព្រមទទួលយកនូវការព្យាបាល ឬពុំចង់ទៅទទួលការព្យាបាលនៅឯមន្ទីរពេទ្យ
- ការកំនត់រកដៃគូរួមភេទជាការលំបាកពេក និង
- អ្នកជំងឺពុំអាចកំនត់រកឃើញនូវដៃរួមភេទរបស់ខ្លួន បើសិនអ្នកជំងឺនេះជាអ្នករកស៊ីផ្លូវភេទ។

## ការគ្រប់គ្រងថែទាំជំងឺកាមរោគ

ដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺកាមរោគ យុទ្ធសាស្ត្រជាក់ស្តែងក្នុងការគ្រប់គ្រងថែទាំជំងឺកាមរោគ ត្រូវយកចិត្តទុកដាក់ផ្តោតទៅលើទិដ្ឋភាពជាច្រើនក្នុងការប្រយុទ្ធនឹងជំងឺកាមរោគ ។

| ការបង្ការ និងទប់ស្កាត់ជាប់ពាក់ព័ន្ធនៅនឹង: |
|---|
| ❖ ការធ្វើរោគវិនិច្ឆ័យឱ្យបានទាន់ពេលវេលា និង ការព្យាបាលសមស្រប<br>❖ ការអប់រំអ្នកជំងឺ និងដៃគូរួមភេទរបស់គាត់<br>❖ ការជំរុញការប្រើប្រាស់ស្រោមអនាម័យ<br>❖ ការផ្តោតទៅលើក្រុមដែលងាយប្រឈមមុខនឹងគ្រោះថ្នាក់ (ជាពិសេស ស្ត្រីរកស៊ីផ្លូវភេទ និង អតិថិជនរបស់គាត់) |

### ការធ្វើរោគវិនិច្ឆ័យបានទាន់ពេលវេលា និង ការព្យាបាលសមស្រប

ការធ្វើរោគវិនិច្ឆ័យបានទាន់ពេលវេលា និង ការព្យាបាលសមស្របជួយឱ្យ :

— យើងកាត់បន្ថយការចំលងកាមរោគពីអ្នកដែលកំពុងកើតទៅកាន់អ្នកដទៃទៀត

— កាត់បន្ថយឱកាសក្នុងការបង្កជាផលវិបាកធ្ងន់ធ្ងរដែលបណ្តាលមកពីជំងឺកាមរោគ

ដើម្បីសំរេចបំណងនេះ គេចាំបាច់ព្យាបាលអ្នកជំងឺទាំងអស់ប្រកបដោយប្រសិទ្ធិភាព ក្នុងពេលដែលពួកគេមកកាន់មជ្ឈមណ្ឌលថែទាំសុខភាពជាលើកដំបូង ។ នេះមានន័យថា ការល្អបំផុតត្រូវមានសេវាថែទាំជំងឺកាមរោគ នៅតាមមជ្ឈមណ្ឌលថែទាំសុខភាពទាំងអស់ ។ ដើម្បីឱ្យការងារធ្វើរោគវិនិច្ឆ័យ និងការព្យាបាលមានប្រសិទ្ធិភាពបំផុតមជ្ឈមណ្ឌលថែទាំសុខភាព ត្រូវការនូវការផ្គត់ផ្គង់ឱសថចាំបាច់សំរាប់ ប្រើប្រាស់ ។

ដៃគូរួមភេទដែលស្គាល់ទាំងអស់ (ឧទាហរណ៍ : សង្សារស្រ្តីរកស៊ីផ្លូវភេទ) ត្រូវទទួលការព្យាបាលជំងឺកាមរោគ។ ទោះបីជាអ្នកទាំងនោះពុំមានរោគសញ្ញាណាមួយក៏ដោយ ដូច្នេះគេត្រូវលើកទឹកចិត្ត (ជួយគាត់ទៅតាមលទ្ធភាព) អ្នកជំងឺឱ្យជូនដំណឹងដល់ដៃគូគាត់ ។

## ការអប់រំ និង ដៃគូរួមភេទ

ជាការសំខាន់ គេត្រូវលើកទឹកចិត្តឱ្យមនុស្សប្រកាន់យកនូវការប្រព្រឹត្តរួមភេទដែលពុំសូវប្រឈមមុខនឹងគ្រោះថ្នាក់ ហើយត្រូវជួយអ្នកដែលប្រឈមមុខនឹងគ្រោះថ្នាក់នឹងការឆ្លងមេរោគអេដស៍ដោយសារការប្រព្រឹត្តរួមភេទ។ គោលបំណងនៃការអប់រំជំងឺកាមរោគគឺ :

- ផ្តល់ការគាំទ្រឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្តរបស់ខ្លួនដើម្បីឱ្យគេបានជាសះស្បើយពីជំងឺ
- ចៀសវាងចំលងជំងឺទៅអ្នកដទៃៗទៀត និង
- បង្ការការឆ្លងជំងឺនានាពេលអនាគត ។

## ការជំរុញការប្រើប្រាស់ស្រោមអនាម័យ

ប្រសិនបើ ប្រើវាបានត្រឹមត្រូវនិងទៀងទាត់ស្រោមអនាម័យអាចជួយបង្ការការរាលដាលនៃជំងឺកាមរោគនិងមេរោគអេដស៍បាន។ មនុស្សដែលមានសកម្មភាពផ្លូវភេទទាំងអស់គួរតែដឹងអំពីវិធីប្រើប្រាស់ស្រោមអនាម័យ។ អ្នកផ្តល់សេវាថែទាំធ្វើយ៉ាងណាឱ្យអ្នកជំងឺមានសមត្ថភាពប្រើប្រាស់ស្រោមអនាម័យ ដូច្នេះគេត្រូវតែមានអារម្មណ៍ស្រួលក្នុងចិត្តក្នុងការពិភាក្សាអំពីស្រោមអនាម័យ និងបង្ហាញអំពីការប្រើប្រាស់វា ។

## ការផ្តោតលើក្រុមដែលងាយរងគ្រោះថ្នាក់ក្នុងការឆ្លង

ជាការសំខាន់ សេវាថែទាំកាមរោគត្រូវតែផ្តោតលើការផ្តល់សេវាថែទាំដល់ក្រុមដែលងាយទទួលរងនូវគ្រោះថ្នាក់នៃការឆ្លង។ អ្នករកស៊ីផ្លូវភេទនិងអតិថិជនរបស់អ្នកទាំងនោះ មានការប្រឈមមុខខ្ពស់បំផុតក្នុងការឆ្លងកាមរោគ។ ដៃគូស្និតស្នេហ៍និងទៀងទាត់របស់អ្នកទាំងនេះ ក៏ប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងខ្ពស់ដែរ។ ក្រុមដែលងាយទទួលរងនូវគ្រោះថ្នាក់នៃការឆ្លងដទៃ ៗ ទៀតអាចមានអ្នកដែលធ្វើការនៅឆ្ងាយពីផ្ទះ យុវជន ឬ អ្នកដែលប្រើប្រាស់ម្ជុលសឺរ៉ាំងដែលពុំបានស្ងោររំងាប់មេរោគ។ ក្រុមមនុស្សដែលងាយទទួលរងគ្រោះថ្នាក់នៃការឆ្លងពុំសូវមានលទ្ធភាពទទួលសេវាថែទាំកាមរោគទេ ដូច្នេះសេវាទាំងនេះត្រូវផ្តោតទៅលើក្រុមទាំងនេះ ដើម្បីឱ្យមានប្រសិទ្ធិភាព។

## ការប្រើប្រាស់ស្រោមអនាម័យ  អត្រាប្រេវ៉ាឡង់មេរោគអេដស៍  និង  ជំងឺកាមរោគ ក្នុងចំណោមនារីរកស៊ីផ្លូវភេទនៅក្នុងប្រទេសកម្ពុជា  ១៩៩៦-២០០១




## វិធីគ្រប់គ្រងថែទាំជំងឺកាមរោគ  ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា
**(Syndromic approach)**

វិធីគ្រប់គ្រងថែទាំករណីកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ត្រូវរៀបរៀងដោយគួបផ្សំយុទ្ធសាស្ត្រទាំងនេះ ចូលគ្នាក្នុងបំណងផ្តល់នូវការថែទាំជំងឺកាមរោគ មួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងបញ្ចូលគ្នា ។

**យុទ្ធសាស្ត្រសំខាន់ៗនៃការគ្រប់គ្រងករណីកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា**

- ធ្វើរោគវិនិច្ឆ័យ  និងព្យាបាលអ្នកជំងឺកាមរោគឱ្យបានរួសរាន់
- អប់រំអ្នកជំងឺ និងប្រជាជនទូទៅ
- ព្យាបាលនិងអប់រំដៃគូរួមភេទនៃអ្នកជំងឺកាមរោគ
- ផ្តោតទៅលើ  ក្រុមដែលងាយទទួលរងនូវគ្រោះថ្នាក់នៃការឆ្លង ។

→ **ការគ្រប់គ្រងថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញា**

## ការរំលឹកសាឡើងវិញ

### ការចំលងនៃជម្ងឺកាមរោគ

- កាមរោគនិងមេរោគអេដស៍ឆ្លងតាមបែបផែនចំលងដូចគ្នា
- មានកត្តាជាច្រើនដែលជះឥទ្ធិពលដល់ការចំលងកាមរោគ ហើយមនុស្សមួយចំនួនមានការប្រឈមមុខនឹងគ្រោះថ្នាក់ក្នុងការឆ្លងជំងឺកាមរោគខ្ពស់ជាងអ្នកផ្សេងៗទៀត ឬ មិនព្រមទៅទទួលការព្យាបាលប្រកបដោយប្រសិទ្ធិភាពទេ
- អ្នកជំងឺកាមរោគ ដែលពុំបានទទួលការព្យាបាលអាចមានរោគសញ្ញានិងមានផលវិបាកធ្ងន់ធ្ងរ
- ជំងឺកាមរោគអាចបណ្តាលឱ្យគ្មានសមត្ថភាពក្នុងការបន្តពូជចំពោះបុរសនិងស្ត្រី គភ៌ក្រៅស្បូនចំពោះស្ត្រី បញ្ហាមួយចំនួនចំពោះគភ៌ និងកំណើតទារក និងឆ្លងទៅទារកទើបនឹងកើត ។

### អត្រានៃជំងឺកាមរោគ

- ជំងឺកាមរោគបង្កើនជាបន្ទុកដ៏ធ្ងន់ធ្ងរមួយមកលើបុគ្គលនិងសេវាសុខាភិបាល
- មានក្រុមមនុស្សមួយចំនួនដែលងាយទទួលរងនូវគ្រោះថ្នាក់ ជាពិសេសក្នុងការឆ្លងជំងឺកាមរោគ
- ក្នុងប្រទេសភាគច្រើន របាយការណ៏ករណីជំងឺកាមរោគមានក៏រិតទាបជាងការពិត

### ទំនាក់ទំនងរវាង ជំងឺកាមរោគ និង មេរោគអេដស៍ និង ជំងឺអេដស៍

- កាមរោគមានទំនាក់ទំនងជាមួយការរាលដាលនៃជំងឺអេដស៍
- មានទំនាក់ទំនងយ៉ាងជិតស្និតរវាងការឆ្លងជំងឺកាមរោគ (ជាពិសេសគឺបង្កឱ្យមានដំបៅនៅនឹងប្រដាប់បន្តពូជ) និងការឆ្លងមេរោគអេដស៍ ។ ការឆ្លងមេរោគអេដស៍ធ្វើឱ្យអ្នកជំងឺងាយឆ្លងជំងឺកាមរោគដទៃៗទៀតនិងអាចធ្វើឱ្យជំងឺកាមរោគក្លាយទៅជាស៊ាំនឹងការព្យាបាល ។
- កម្មវិធីដែលថែទាំជំងឺកាមរោគប្រកបដោយប្រសិទ្ធិភាព អាចមានឥទ្ធិពលកាត់បន្ថយការឆ្លងមេរោគអេដស៍បានយ៉ាងលឿន ។

## ការលំបាកក្នុងការបង្ការ និងទប់ស្កាត់កាមរោគ

លក្ខណៈសំគាល់នៃកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគ ដែលប្រកបដោយប្រសិទ្ធិភាព មានការធ្វើរោគវិនិច្ឆ័យរួសរាន់ និងការព្យាបាលប្រកបដោយប្រសិទ្ធិភាព ការអប់រំក្នុងបំណងពង្រឹងបន្ថែមលើការថែទាំនិងការបង្ការជំងឺកាមរោគ និងការផ្តល់សេវាថែទាំជាបន្ថែមសំរាប់ដៃគូរួមភេទនៃអ្នកជំងឺកាមរោគ និងការផ្តល់សេវាថែទាំជំងឺកាមរោគផ្តោតទៅលើក្រុមនានាដែលងាយរងនូវការឆ្លង ជាពិសេសស្ត្រីរកស៊ីផ្លូវភេទ ។

វិធីគ្រប់គ្រងថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញាគឺជាដំណោះស្រាយជាក់ស្តែងចំពោះបញ្ហាប្រយុទ្ធនឹងកាមរោគ ។

## សំនួរ និង លំហាត់

### ១.១ សំនួរ

ប្រសិនបើអ្នកចង់ផ្តល់សេវាថែទាំជំងឺកាមរោគប្រកបដោយប្រសិទ្ធិភាព តើអ្នកយល់ថាមានមធ្យោបាយណាដែលអាចដោះស្រាយបញ្ហាដែលទាក់ទងនឹងជំងឺកាមរោគ ដែលពុំបណ្តាលឱ្យលេចចេញជារោគសញ្ញា ដែរឬទេ?

### ១.២ សំនួរ

១) តើអ្នកយល់ថាជំងឺកាមរោគបង្កើនការប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ប៉ុន្មានដង? តើមានការប្រែប្រួលទៅតាមប្រភេទនៃជំងឺកាមរោគដែរឬទេ?

២) ពត៌មានដែលមាននៅទំព័រទី ២២ និង ទី ២៣ នឹងណែនាំឱ្យដឹងថាដំបៅនៅលើប្រដាប់បន្តពូជគឺជាកត្តា ចំបងសំរាប់ការចំលងនៃមេរោគអេដស៍ ក៏ប៉ុន្តែសូម្បីតែជំងឺកាមរោគដែលមិនបង្កឱ្យមានដំបៅក៏អាចជំរុញ ឱ្យមានការចំលងមេរោគអេដស៍បានដែរ។ តើវាជំរុញឱ្យមានការចំលងដោយវិធីណា?

៣) នៅពេលដែលមនុស្សម្នាក់ផ្ទុកមេរោគអេដស៍ តើវាមានឥទ្ធិពលដល់ការចំលងនៃកាមរោគដទៃទៀត យ៉ាងដូចម្តេចដែរ?

### ១.៣ លំហាត់

**គំរោងស្រង់ស្ថិតិ** (Statistics project)

ដោយដឹងអំពីអត្រានៃជំងឺកាមរោគនិងការឆ្លងមេរោគអេដស៍នៅក្នុងតំបន់ជាការមានប្រយោជន៏ គេត្រូវស្វែងយល់ជាបន្ថែមអំពីស្ថិតិ ដែលមានសំរាប់ប្រទេស ខេត្ត ឬ សហគមន៏ របស់អ្នកផ្ទាល់។

លំហាត់នេះត្រូវធ្វើជាក្រុមទើបល្អ។ ប្រសិនបើអ្នកពុំអាចធ្វើជាក្រុមបានទេ សូមលើកយករបកគំឃើញរបស់អ្នកមកពិភាក្សាជាមួយសហសេវិកនិងអ្នកត្រួតពិនិត្យណែនាំរបស់អ្នក អ្នកសំរួលវគ្គ ឬអ្នកត្រួតពិនិត្យណែនាំរបស់អ្នកអាចជួយអ្នកក្នុងការប្រមូលយកស្ថិតិ ឬរបាយការណ៏ដែលមានស្រាប់ ។ ការធ្វើគំរោងនេះមានបីជំហាន ការប្រមូលពតិមាន ការបកស្រាយពតិមាននិងការធ្វើសេចក្តីសន្និដ្ឋាន ។

## ជំហានទី ១ ការប្រមូលពត៌មាន

ក- សូមពិចារណាលើប្រភេទពតិមានស្តីអំពីជំងឺកាមរោគ ដែលប្រទេសឬខេត្តរបស់អ្នកមាននិងបញ្ជាក់ពីមូលហេតុរបស់វា។

ខ- ប្រមូលពតិមានស្តីពីជំងឺកាមរោគ និងការផ្ទុកមេរោគអេដស៍សំរាប់ប្រទេសខេត្ត ឬសហគមន៍របស់អ្នក។ សូមទៅកាន់សេវាថែទាំសុខភាពនៅមូលដ្ឋានអ្នកដើម្បីរកមើលរបាយការណ៍ស្តីអំពីចំនួនអ្នកដែលទទួលការព្យាបាលកាមរោគ និងពិនិត្យមើលក្រែងមានការអង្កេតពិសេសៗនានាដែលប្រើប្រាស់តេស្តមន្ទីរពិសោធន៍នានា អ្នកសំរួលវគ្គ ឬអ្នកត្រួតពិនិត្យណែនាំអាចជួយអ្នកក្នុងការធ្វើស្ថិតិ ឬ រកពតិមានផ្សេងៗទៀតបាន។

គ- ប្រមូលពតិមានស្តីអំពីការប៉ាន់ស្មានករណីជំងឺកាមរោគ ឬការផ្ទុកមេរោគអេដស៍។ ក្នុងករណីខ្លះការប៉ាន់ស្មាន ទាំងនេះអាចជាប្រភពពតិមានតែមួយបែបគត់ដែលអ្នកអាចរកបាន។

## ជំហានទី ២ ការបកស្រាយពត៌មាន

ឃ- ដោយពឹងផ្អែកលើពតិមានដែលអ្នកទទួលបាន តើនរណាជាអ្នកដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងកាមរោគជាងគេ? តើមានក្រុមពិសេសណាដែរឬទេ ដែលប្រឈមមុខនឹងការឆ្លងខ្ពស់ជាងក្រុមដទៃ?

ង- តើអ្នកយល់ថាស្ថិតិ ឬការប៉ាស្មាន់នេះមានភាពត្រឹមត្រូវដល់កំរិតណា?

ច- តើអ្នកយល់ថាស្ថិតិមានទំនោរទៅរកការប៉ាន់ស្មានទាប ចំពោះករណីជំងឺកាមរោគចំពោះស្ត្រីដែរឬទេ? ហេតុអ្វីបានជាអ្នកយល់យ៉ាងដូច្នេះ តើបញ្ហានេះមានទំហំប៉ុនណាដែរ?

## ជំហានទី ៣ ការធ្វើសេចក្តីសន្និដ្ឋាន

ឆ- សូមគូរក្រាហ្វិក ឬ ធ្វើតារាងងាយៗ ដែលបង្ហាញឱ្យឃើញអំពីពតិមានដែលអ្នកប្រមូលបាន។

ជ- រៀបចំបញ្ជីសន្និដ្ឋានដែលទាញចេញពីពតិមានដែលអ្នកបានប្រមូលបាន។

## ចំលើយ

### ១.១ សំនួរ

បញ្ហាដែលទាក់ទងនឹងជំងឺកាមរោគដែលពុំបង្កជារោគសញ្ញាគឺជាការលំបាកបំផុតមួយក្នុងចំណោមការលំបាកនានាក្នុងការផ្តល់សេវាថែទាំជំងឺកាមរោគប្រកបដោយសុវត្ថិភាព។ មានវិធីជាច្រើនដែលត្រូវបានយកមកសាកល្បងប្រើប្រាស់ ឬ ពិនិត្យពិចារណាសំរាប់អនុវត្តក្នុងកន្លែងផ្សេងៗ ពីគ្នា។

ក- បង្កើនសមត្ថភាពបុគ្គលឱ្យចេះតាមដានរកមើលរោគសញ្ញាមិនប្រក្រតីនានា ដែលបញ្ជាក់ថាអាចមានជំងឺកាមរោគ ហើយលើកទឹកចិត្តបុគ្គលទាំងនោះឱ្យទៅត្រួតពិនិត្យសុខភាព។

ខ- បង្កើនការយល់ដឹងរបស់អ្នកជំងឺ អំពីការប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងដែលទាក់ទងនឹងការប្រព្រឹត្ត ហើយលើកទឹកចិត្តគាត់ឱ្យទៅត្រួតពិនិត្យសុខភាពនៅពេលដែលខ្លួនយល់ថាអាចឆ្លងកាមរោគ។

គ- ផ្តល់នូវការថែទាំជំងឺកាមរោគឱ្យបានទៀងទាត់ ដល់ក្រុមដែលមានការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងខ្ពស់ ធ្វើយ៉ាងណាឱ្យពួកគេអាចទទួលផលប្រយោជន៍អំពីសេវាបង្ការការចំលងជំងឺកាមរោគដោយស្មគ្រ័ចិត្ត។ ឧទាហរណ៍ ៖ ស្ត្រីរកស៊ីផ្លូវភេទត្រូវមកទទួលការថែទាំទៅគ្លីនិកជំងឺកាមរោគ២ ដងក្នុង មួយខែ ទោះបីជាពួកគេមាន ឬគ្មានរោគសញ្ញាកាមរោគពិតប្រាកដក្តី។

### ១.២ សំនួរ

ក- អាចឆ្លើយត្រឹមត្រូវ ប្រសិនបើអ្នកបានអានទំព័រទី ១៨ ដែលប្រាប់ថាជំងឺ Chancroid ជំងឺដែលបង្កដោយមេរោគក្លាមីឌីយ៉ា, ជំងឺប្រមេះទឹកបាយ, ជំងឺស្វាយ និងជំងឺដែលបង្កដោយមេរោគទ្រីកូម៉ូណាស់ អាចបង្កើនការប្រឈមមុខនឹងគ្រោះថ្នាក់នៃការចំលងមេរោគអេដស៍បានពី ២-៩ ដង ខ្ពស់ជាងធម្មតា។

**ការប្រឈមមុខនឹងគ្រោះថ្នាក់នៃជំងឺទាំងនេះមានដូចខាងក្រោមនេះ**

| បង្កើនការប្រឈមមុខនឹងគ្រោះថ្នាក់នៃ | |
|---|---|
| **ជំងឺ** | **ការចំលងមេរោគអេដស៍** |
| ស្វាយ | ៣-៩ ដង |
| ប្រមេះ | ៣-៥ ដង |
| ក្លាមីឌីយ៉ា | ៣-៥ ដង |

សូមកត់សំគាល់ថា ឯកសារបណ្តុះបណ្តាលស្តីអំពីវិធីគ្រប់គ្រង់ថែទាំករណីជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាពុំមានបញ្ចូលជំងឺដំបៅពងបែក (ឬ អ៊ែប៉ែសទេ) ទោះបីជាវាបង្កើនការប្រឈមមុខនឹងគ្រោះថ្នាក់នៃការចំលងមេរោគបានទ្វេដង ក៏ដោយក្តី។ ជានិច្ចកាលអ្នកត្រូវលើកទឹកចិត្តអ្នកជំងឺដែលមានដំបៅអ៊ែប៉ែសនេះ ឱ្យចៀសវាងរួមភេទ នៅពេលដែលដំបៅមិនទាន់ជាសះស្បើយ ។

ខ- មានមូលហេតុពីរដែលធ្វើឱ្យជំងឺកាមរោគដែលមិនបង្កជាដំបៅ បង្កើនការប្រឈមមុខនឹងគ្រោះថ្នាក់នៃការចំលងមេរោគអេដស៍:

- វត្តមាននៃភ្នាក់ងារកាមរោគ (វីរុស ឬបាក់តេរី) នៅក្នុងចរន្តឈាមនៅកន្លែងកើតជំងឺជំរុញឱ្យប្រព័ន្ធភាពស៊ាំនៃរាងកាយបង្កើនចំនួនគោសិកាសនៅកន្លែងនោះ ដែលជាគោលដៅនិងប្រភពនៃមេរោគអេដស៍ ។
- ការរលាកប្រដាប់បន្តពូជអាចបណ្តាលឱ្យមានការដាច់រហែកតូចៗបំផុត ដែលអាចឱ្យមេរោគអេដស៍ជ្រៀតចូលក្នុងរាងកាយបាន ។

គ- ការឆ្លងមេរោគអេដស៍ អាចមានឥទ្ធិពលពីលើការចំលងកាមរោគបង្កឱ្យមានភាពស៊ាំទៅនឹងការព្យាបាល និង ធ្វើឱ្យអ្នកជំងឺងាយទទួលរងការឆ្លងកាមរោគផ្សេងៗទៀត ។

# ការប្រើប្រាស់គំនូសបំព្រួញ
# ដើម្បីធ្វើការគ្រប់គ្រងនិងថែទាំជម្ងឺកាមរោគ

## ការគ្រប់គ្រងថែទាំជំងឺកាមរោគ

### ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា   សំរាប់ថ្នាក់មណ្ឌលសុខភាព

**ជំពូកទី ២ :**

# ការប្រើប្រាស់គំនូសបំព្រួញ

# ដើម្បីធ្វើការគ្រប់គ្រងនិងថែទាំជម្ងឺកាមរោគ

# ជំពូកទី ២

## ការប្រើប្រាស់គំនូសបំព្រួញសំរាប់គ្រប់គ្រងថែទាំ ជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា

ជំពូកនេះណែនាំអ្នកឱ្យស្គាល់ ការគ្រប់គ្រងថែទាំករណីជំងឺកាមរោគដោយពឹងផ្អែកលើចង្កាមរោគសញ្ញា គុណប្រយោជន៍របស់វា លើសពីវិធីគ្រប់គ្រងថែទាំករណីជំងឺកាមរោគមុនៗ និងលក្ខណៈសំខាន់ៗនៃការគ្រប់គ្រងថែទាំជំងឺដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ដែលមានសារៈប្រយោជន៍សំរាប់ស្ថានភាពនៃមណ្ឌលសុខភាព ។

មុននឹងចាប់ផ្តើមសិក្សាជំពូកនេះ អ្នកត្រូវបញ្ចប់ការសិក្សាជំពូកទី១ ដែលធ្វើឱ្យអ្នកយល់ដឹងអំពីផលប៉ះពាល់នៃការរាតត្បាត និងឧបសគ្គក្នុងការកាត់បន្ថយការចំលងនៃជំងឺកាមរោគ ។

ជំពូកក្រោយៗទៀត នឹងជួយអ្នកឱ្យពង្រីកការយល់ដឹងអំពីគំនូសបំព្រួញ បានកាន់តែច្រើនថែមទៀត ហើយធ្វើការសិក្សាគំនូសបំព្រួញនិមួយៗបានលំអិត ។

យើងសូមណែនាំអ្នកឱ្យទុកគំនូសបំព្រួញទាំង ៥ នៅជិតខ្លួននៅពេលដែលអ្នកសិក្សាជំពូកនេះ ។

**មាតិកា**


- វិធីមុនៗក្នុងការធ្វើរោគវិនិច្ឆ័យជំងឺកាមរោគ .................................. ៣
- ការគ្រប់គ្រងថែទាំករណីជំងឺកាមរោគដោយពឹងផ្អែកចង្កោមរោគសញ្ញា....... ៥
- លក្ខណៈនៃវិធីធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើចង្កោមរោគសញ្ញា.............. ៦
- ការរំលឹកសារឡើងវិញ .............២០
- សំណួរ និងលំហាត់ ...............២២
- ចំលើយ ............................. ២៥


**ចូរចងចាំ :** ***គុណភាពនៃការគ្រប់គ្រងថែទាំករណីជំងឺកាមរោគពឹងផ្អែកលើខ្លួនអ្នកផ្ទាល់ ។***

## វិធីមុនៗពីរយ៉ាងសំរាប់ធ្វើរោគវិនិច្ឆ័យជំងឺកាមរោគ

| វិធីមុនៗពីរយ៉ាងសំរាប់ធ្វើរោគវិនិច្ឆ័យជំងឺកាមរោគ | | |
|---|---|---|
| ♦ ***រោគវិនិច្ឆ័យមូលហេតុ*** | : | ប្រើប្រាស់តេស្តមន្ទីរពិសោធន៍ ដើម្បីរកភ្នាក់ងារបង្ករោគ |
| ♦ ***រោគវិនិច្ឆ័យគ្លីនិក*** | : | ប្រើប្រាស់នូវបទពិសោធន៍គ្លីនិក ដើម្បីរករោគសញ្ញា ដែលជាលក្ខណៈសំគាល់ជំងឺកាមរោគជាក់លាក់ណាមួយ ។ |

អ្នកផ្តល់សេវាថែទាំ ជាទូទៅប្រើប្រាស់វិធីមួយក្នុងចំណោមវិធីពីរ នៅពេលដែលខ្លួនធ្វើរោគវិនិច្ឆ័យជំងឺកាមរោគគឺរោគវិនិច្ឆ័យមូលហេតុ ឬរោគវិនិច្ឆ័យគ្លីនិក ។

***រោគវិនិច្ឆ័យមូលហេតុ*** : រោគវិនិច្ឆ័យមូលហេតុ អាចឱ្យអ្នកផ្តល់សេវាថែទាំធ្វើរោគវិនិច្ឆ័យបានត្រឹមត្រូវច្បាស់លាស់ ហើយព្យាបាលជំងឺជាក់លាក់ណាមួយជូនអ្នកជំងឺ ។ ក៏ប៉ុន្តែអ្នកផ្តល់សេវាថែទាំជាច្រើន ពុំមានបរិក្ខារសំរាប់ពិនិត្យមើលភ្នាក់ងារបង្ករោគទេ ដូច្នេះពួកគេធ្វើរោគវិនិច្ឆ័យគ្លីនិក ។

| បញ្ហាទាក់ទងនឹងការធ្វើរោគវិនិច្ឆ័យមូលហេតុ |
|---|
| ♦ គេត្រូវការនូវបុគ្គលិកជំនាញ និងបរិក្ខារទំនើបសាំញ៉ាំ ដើម្បីកំណត់រកភ្នាក់ងារបង្កជំងឺកាមរោគ ។ |
| ♦ ការធ្វើតេស្តសំរាប់ធ្វើរោគវិនិច្ឆ័យមានតំលៃថ្លៃហើយត្រូវប្រើពេលយូរ ។ |
| ♦ គេមិនបានចាប់ផ្តើមព្យាបាលទេរហូតដល់ទទួលបានលទ្ធផល តេស្ត ។ |
| ♦ ពុំមានកន្លែងនិងបរិក្ខារសំរាប់ធ្វើតេស្តប្រើប្រាស់នៅថ្នាក់មណ្ឌលសុខភាពដែលនៅទីនោះអ្នកជំងឺជាច្រើនមកស្វែងរកការព្យាបាល។ |

ការធ្វើរោគវិនិច្ឆ័យរកមូលហេតុមានតំលៃថ្លៃ ហើយត្រូវរង់ចាំលទ្ធផលនៃតេស្ត ។ ការយឺតយ៉ាវ នេះ បង្កើតជាបញ្ហាពីព្រោះ ៖

- ការព្យាបាលមិនបានចាប់ផ្តើមធ្វើភ្លាមៗទេ អ្នកជំងឺដែលឆ្លងកាមរោគបន្តចំលង ជំងឺទៅអ្នកដទៃៗទៀត ។
- ទំនុកចិត្តរបស់អ្នកជំងឺលើបុគ្គលិកសុខាភិបាលធ្លាក់ស្រុតចុះ ដែលអាចប៉ះពាល់ដល់ឆន្ទះអ្នកជំងឺក្នុងការទទួលការព្យាបាលឱ្យបានចប់សព្វគ្រប់ការវិលត្រឡប់មកវិញដើម្បីតាមដានជំងឺ ឬបញ្ជូនដៃគូរួមភេទអ្នកជំងឺ។ ក៏ប៉ុន្តែអ្នកផ្តល់សេវាជាច្រើនពុំមានទីកន្លែង និងឧបករណ៍សំរាប់រកឱ្យឃើញភ្នាក់ងារបង្ករោគទេ ដូច្នេះពួកគេធ្វើរោគវិនិច្ឆ័យគ្លីនិកដោយពឹងផ្អែកយ៉ាងខ្លាំងលើបទពិសោធន៍របស់បុគ្គលិកសុខាភិបាល ស្តីអំពីករណីប្រហាក់ប្រហែលគ្នាដែលជួបមានកន្លងមក ។

| បញ្ហាទាក់ទងនឹងរោគវិនិច្ឆ័យគ្លីនិក |
| --- |
| ❖ រោគវិនិច្ឆ័យគ្លីនិកមានភាពត្រឹមត្រូវបានតែ ៥០ % នៃករណីជំងឺកាមរោគតែប៉ុណ្ណោះ<br>❖ ពុំបានចាប់អារម្មណ៍ទៅលើការឆ្លងជំងឺពីរបែបក្នុងពេលតែមួយទេ ។<br>❖ ជំងឺដែលព្យាបាលខុស ឬមិនបានព្យាបាលអាចបណ្តាលឱ្យមានផលវិបាក និងបន្តការចំលងតទៅទៀត ។ |

ក្នុងការប្រើប្រាស់វិធីធ្វើរោគវិនិច្ឆ័យគ្លីនិក គ្រូពេទ្យព្យាបាលជំងឺកាមរោគដែលមានមេរោគបង្កតែមួយ ដោយពឹងផ្អែកទៅលើរោគសញ្ញាគ្លីនិក ។ ក៏ប៉ុន្តែ ជំងឺផ្សេងៗទៀតអាចបង្ករោគសញ្ញាដូចគ្នានេះដែរ ហើយគ្រូពេទ្យអាចជ្រើសរើសជំងឺមកព្យាបាលខុស ។ លើសពីនេះទៀត ការឆ្លងជំងឺផ្សេងៗកើតឡើងជាញឹកញាប់ ហើយគេត្រូវព្យាបាលអ្នកជំងឺដែលមានជំងឺច្រើនបែបនោះមួយម្តងៗ ។ ការខកខានមិនបានព្យាបាលជំងឺណាមួយអាចបណ្តាលឱ្យមានផលវិបាក ហើយបង្កឱ្យមានការចំលងជំងឺកាមរោគនោះទៀត ។

## ការធ្វើរោគវិនិច្ឆ័យគ្លីនិកដោយប្រើនូវវិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា

*តើវិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាជួយបំពេញកង្វះខាតនៃវិធីមុនៗ ដូចម្ដេចខ្លះ ?*

ផលប្រយោជន៍សំខាន់នៃវិធីគ្រប់គ្រងថែទាំកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា គឺវាអាចផ្ដល់សេវាថែទាំកាមរោគចាប់តាំងពីកន្លែងដែលអ្នកជំងឺមកជួបនឹងយើងជាលើកដំបូង ។ ដូច្នេះ អ្នកជំងឺមិនចាំបាច់ទៅកាន់គ្លីនិកឯកទេស ឬ មន្ទីរពេទ្យធំៗនោះទេ ។ នៅពេលដែលមានឱសថសំរាប់ប្រើប្រាស់ គេក៏អាចព្យាបាលអ្នកជំងឺនៅពេលដែលគាត់មកជួបយើងតាំងពីលើកដំបូងផងដែរ។

ផលប្រយោជន៍មួយទៀត នៃវិធីគ្រប់គ្រងថែទាំកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា គឺមានការផ្ដោតទៅលើការកើតជំងឺផ្សេងៗក្នុងពេលជាមួយគ្នាតែម្ដង ។

នៅទីបញ្ចប់ វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាផ្ដល់នូវឱកាសឱ្យយើងអប់រំអ្នកជំងឺស្ដីពីការបញ្ជូនដៃគូរួមភេទឱ្យមកទទួលការថែទាំ និងការបង្ការជំងឺកាមរោគនាអនាគត ។ ការផ្ដល់ជូននូវស្រោមអនាម័យ និងការលើកទឹកចិត្តឱ្យប្រើស្រោមអនាម័យ ក៏ជាផ្នែកមួយនៃការគ្រប់គ្រងថែទាំករណីជំងឺកាមរោគផងដែរ ។

| សារៈប្រយោជន៍ចំបងៗនៃវិធីគ្រប់គ្រងថែទាំ<br>ជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា |
| --- |
| ♦ ការថែទាំព្យាបាលជំងឺកាមរោគពេញលេញ ត្រូវបានផ្តល់ជូនឱ្យអ្នកជំងឺនៅពេលដែលគាត់មកជួបលើកដំបូង ។<br><br>♦ អាចធ្វើការព្យាបាលបានយ៉ាងរហ័ស និងទូលំទូលាយ ។<br><br>♦ អ្នកជំងឺត្រូវបានព្យាបាលជំងឺដែលកើតឡើងជាមួយគ្នា ដោយគ្របយកមូលហេតុសំខាន់ៗនៃចង្កោមរោគសញ្ញាណាមួយ ។ |

## លក្ខណៈនៃវិធីគ្រប់គ្រងថែទាំកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា

| លក្ខណៈសំខាន់នៃវិធីគ្រប់គ្រងថែទាំកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា |
| --- |
| ❖ ប្រមូលភ្នាក់ងារបង្ករោគសំខាន់ៗ ដាក់ជាក្រុមៗតាមចង្កោមរោគសញ្ញាគ្លីនិកដែលវាបង្កឡើង ។<br><br>❖ យកគំនូសបំព្រួញមកប្រើប្រាស់ ។<br><br>❖ ព្យាបាលជូនអ្នកជំងឺនូវហេតុផលសំខាន់ៗទាំងអស់នៃចង្កោមរោគសញ្ញា ។<br><br>❖ អប់រំអ្នកជំងឺជុំវិញការប្រើប្រាស់ស្រោមអនាម័យ និងសង្កត់ធ្ងន់លើសារៈសំខាន់នៃការបញ្ជូនដៃគូឱ្យមកទទួលការព្យាបាល ។ |

នៅក្នុងជំពូកនេះ យើងនឹងពិភាក្សាអំពីលក្ខណៈដំបូងទាំងបីនៃការគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាដែលបានរៀបរាប់ដូចខាងក្រោមនេះគឺ ចង្កោមរោគសញ្ញាគ្លីនិក ការប្រើគំនូសបំព្រួញ និងការព្យាបាលមូលហេតុទាំងអស់នៃចង្កោមរោគសញ្ញា ។ ការអប់រំអ្នកជំងឺ និងការបញ្ជូនដៃគូរួមភេទទៅទទួលការថែទាំនឹងត្រូវលើកយកមកពិភាក្សានៅក្នុងជំពូកក្រោយៗទៀត ។



ការគ្រប់គ្រងថែទាំជំងឺកាមរោគនៅថ្នាក់មណ្ឌលសុខភាព

## **ការកំណត់រកចង្កោមរោគសញ្ញា (Identifying the syndromes)**

ចង្កោមរោគសញ្ញា (syndrome) គឺជាក្រុមនៃរោគសញ្ញា (symptoms) ដែលអ្នកជំងឺពិពណ៌នាប្រាប់យើង រួមផ្សំនឹងសញ្ញាដែលអ្នកផ្តល់សេវាថែទាំសង្កេតឃើញនៅពេលពិនិត្យអ្នកជំងឺ។ ទោះបីជាកាមរោគបង្កឡើងដោយមេរោគ (organisms) ជាច្រើនក៏ដោយ ក៏មេរោគទាំងនោះបង្កឱ្យមានចង្កោមរោគសញ្ញាក្នុងចំនួនមានកំរិតតែប៉ុណ្ណោះ ។ ការប្រើប្រាស់វិធីគ្រប់គ្រងថែទាំកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា អាចឱ្យអ្នករកឃើញចង្កោមរោគសញ្ញាណាមួយក្នុងចំណោមចង្កោមរោគសញ្ញាទាំងឡាយនោះ ហើយព្យាបាលវាឱ្យបានសមស្រប ។

តារាងខាងក្រោមនេះសង្ខេបនូវរោគសញ្ញា (symptoms) និងសញ្ញា (signs) នៃចង្កោមរោគសញ្ញាទាំង ៥ (syndromes) និងមូលហេតុ ឬ ភ្នាក់ងារបង្ករោគរបស់វា ។

**សំណួរ ?**
**២.១**

| ចង្កោមរោគសញ្ញាទាំង ៥ | | | |
|---|---|---|---|
| ***ចង្កោមរោគសញ្ញា*** | ***រោគសញ្ញាដែលពិពណ៌នាដោយអ្នកជំងឺ*** | ***សញ្ញាដែលសង្កេតឃើញដោយអ្នកផ្តល់សេវាថែទាំ*** | ***មូលហេតុដែលមានញឹកញាប់ជាងគេ*** |
| • ការធ្លាក់ស / ហូរខ្ទុះតាមទ្វារមាស (vaginal discharge) | • ការធ្លាក់សខុសប្រក្រតី<br>• រមាស់ទ្វារមាស<br>• នោមឈឺ<br>• ឈឺចាប់ពេលរួមភេទ | • ការហូរខ្ទុះពីទ្វារមាស / ធ្លាក់សខុសប្រក្រតី | ***ជំងឺរលាកទ្វារមាស***<br>• ទ្រីកូម៉ូណាស់<br>• ផ្សិតកង់ឌីដាស់<br>***ជំងឺរលាកមាត់ស្បូន***<br>• ជំងឺប្រមេះទឹកបាយ<br>• ជំងឺបង្កដោយក្លាមីឌីយ៉ា |
| • ការហូរខ្ទុះតាមបង្ហូរនោម (urethral discharge) | • ហូរខ្ទុះពីបង្ហូរនោម<br>• នោមឈឺ<br>• នោមញឹក | • ហូរខ្ទុះពីបង្ហូរនោម (បើចាំបាច់ត្រូវឱ្យអ្នកជំងឺច្បូតបង្ហូរនោម) | • ជំងឺប្រមេះទឹកបាយ<br>• ជំងឺបង្កដោយក្លាមីឌីយ៉ា |
| • ដំបៅលើប្រដាប់បន្តពូជ (genital ulcer) | • ដំបៅលើប្រដាប់បន្តពូជ | • ដំបៅលើប្រដាប់បន្តពូជ<br>• កូនកណ្តុរក្រលៀនរីកមាឌធំ | • ជំងឺស្វាយ<br>• chancroid<br>• ជំងឺដំបៅពងបែកលើប្រដាប់បន្តពូជ (genital herpes) |
| • ការឈឺចាប់នៅផ្នែកខាងក្រោមនៃពោះ (Lower abdominal pain) | • ឈឺចាប់នៅពេលរួមភេទ<br>• ឈឺចុកចាប់នៅផ្នែកខាងក្រោមនៃពោះ | • ធ្លាក់សមិនប្រក្រតី<br>• ឈឺចុកចាប់នៅផ្នែកខាងក្រោមនៃពោះពេលស្ទាប<br>• សីតុណ្ហភាពលើសពី ៣៨ °C | • ជំងឺប្រមេះទឹកបាយ<br>• ជំងឺបង្កដោយក្លាមីឌីយ៉ា<br>• បាក់តេរីអាណាអេរ៉ូប៊ីផ្សេងៗ |
| • ជំងឺសិរមាន់លើប្រដាប់បន្តពូជ (vaginal warts) | • ដុះសាច់លើតំបន់ប្រដាប់បន្តពូជ | • ដុះសាច់/ ដុំពកមានដុះសាច់ដូចបន្ទានៅលើប្រដាប់បន្តពូជឬមានសណ្ឋានដូចផ្កាស្ពៃ | • វីរុសឈ្មោះ "human papilloma virus " |

## ការប្រើប្រាស់គំនូសបំព្រួញ

សូមទុកគំនូសបំព្រួញនានា ជាមួយអ្នកនៅពេលចាប់ផ្តើមសិក្សាផ្នែកនេះ ។

នេះគឺជា **"ប្រអប់ស្ថិតិបញ្ហាគ្លីនិក"** ដែលចាប់ផ្តើមដោយរោគសញ្ញាណាមួយ។វានាំមុខគំនូសបំព្រួញ ហើយមានផ្លូវចេញតែមួយគត់ ។

**"ប្រអប់សំរាប់ធ្វើការសំរេចចិត្ត"** ប្រាប់អ្នកឱ្យធ្វើការសំរេចចិត្ត ។ ដើម្បីធ្វើដូច្នេះបានអ្នកត្រូវស្រង់ប្រវត្តិ ឬពិនិត្យអ្នកជំងឺជាមុនសិន ។ ប្រអប់សំរាប់ធ្វើការសំរេចចិត្ត ជានិច្ចកាលមានផ្លូវចេញពីរ មួយគឺផ្លូវចេញសំរាប់ចំលើយថា មាន មួយ ទៀតសំរាប់ចំលើយថា ទេ ។




ផ្លូវចេញនិមួយៗនាំទៅរក **ប្រអប់សំរាប់ធ្វើសកម្មភាព** ដូចប្រអប់នេះដែរ ។ នេះគឺជាប្រអប់ដែលប្រាប់អ្នកអំពីរបៀបដោះស្រាយបញ្ហា ។

## តើគំនូសបំព្រួញជាអ្វី ?

គំនូសបំព្រួញ (flow-chart) ប្រៀបបាននឹងផែនទីដែលណែនាំអ្នកឱ្យធ្វើការសំរេចចិត្ត និងធ្វើសកម្មភាពនានា ជាបន្តបន្ទាប់ក្នុងការថែទាំជំងឺកាមរោគ ។ ការសំរេចចិត្ត ឬការធ្វើសកម្មភាពនិមួយៗស្ថិតនៅក្នុងប្រអប់មួយដែលមានសញ្ញាព្រួញបាញ់ចេញទៅកាន់ប្រអប់មួយផ្សេងទៀត ដែលមានការសំរេចចិត្ត ឬសកម្មភាពមួយទៀត ។

អ្នកផ្តល់សេវាថែទាំសុខភាព ត្រូវចាប់ផ្តើមដោយសួរអ្នកជំងឺអំពីការត្អូញត្អែររបស់គាត់ ហើយជ្រើសរើសគំនូសបំព្រួញដែលសមស្រប ។ ដោយចាប់ផ្តើមពីប្រអប់គ្លីនិកនៅលើបង្អស់ អ្នកផ្តល់សេវាថែទាំត្រូវបន្តអនុវត្តតាមក៏រិតនិមួយៗចុះមកក្រោម រហូតដល់ចុងបញ្ចប់នៃមែកធាងដែលហៅថា ច្រកចេញ (exit path) ដែលមានការណែនាំឱ្យធ្វើសកម្មភាព ។

## សារៈប្រយោជន៍នៃការប្រើប្រាស់គំនូសបំព្រួញ

| ផលប្រយោជន៍នៃការប្រើប្រាស់គំនូសបំព្រួញ |
|---|
| • គេអាចយកទៅប្រើប្រាស់នៅគ្រប់ពេល និងគ្រប់ទីកន្លែងថែទាំសុខភាពទាំងអស់<br>• វាណែនាំឱ្យធ្វើការសំរេចចិត្តបានច្បាស់លាស់<br>• គេមិនចាំបាច់បញ្ជូនករណីភាគច្រើនទេ<br>• មានការបង្កើតគោលការណ៍ណែនាំគំរូស្តីពីការព្យាបាល ។ |

មានភាពងាយស្រួលក្នុងការកំណត់រកឱ្យឃើញចង្កោមរោគសញ្ញាផ្សេងៗ ដូច្នេះគេអាចរៀបរៀងបង្កើតគំនូសបំព្រួញសំរាប់ចង្កោមរោគសញ្ញានិមួយៗ ។ គំនូសបំព្រួញសំរាប់ចង្កោមរោគសញ្ញានិមួយៗ ណែនាំដល់អ្នកផ្តល់សេវាថែទាំឱ្យប្រុងប្រយ័ត្នក្នុងការធ្វើសកម្មភាព ឬសំរេចចិត្តនានាឱ្យសមស្របទៅតាមចង្កោមរោគសញ្ញានោះ ។ អ្នកផ្តល់សេវាថែទាំដែលប្រើប្រាស់គំនូសបំព្រួញត្រូវទទួលការណែនាំច្បាស់លាស់អំពីវិធីព្យាបាលជំងឺជូនដល់អ្នកជំងឺរបស់ខ្លួន ។

នៅពេលដែលបានទទួលការបណ្តុះបណ្តាលរួចហើយ អ្នកផ្តល់សេវាថែទាំនឹងយល់ថា មានភាពងាយស្រួល ។ បុគ្គលិកសុខាភិបាលនៃផ្នែកផ្សេងៗ ដែលបំរើការងារនៅតាមកន្លែងថែទាំសុខភាពណាក៏ដោយ ក៏អាចធ្វើការគ្រប់គ្រងថែទាំករណីជំងឺកាមរោគប្រកបដោយប្រសិទ្ធិភាព ដោយប្រើប្រាស់នូវគំនូសបំព្រួញបានដែរ ។




*ផលប្រយោជន៍មួយក្នុងចំណោម ផលប្រយោជន៍នានានៃការប្រើប្រាស់ វិធីគ្រប់គ្រងថែទាំជំងឺកាមរោគ ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា គឺការអាចព្យាបាលអ្នកជំងឺបានភ្លាមៗ តែម្តង ។*

## ជំហាននានាក្នុងការប្រើប្រាស់គំនូសបំព្រួញ

| ជំហាននានាក្នុងការប្រើប្រាស់គំនូសបំព្រួញ |
|---|
| • កំណត់បញ្ហាគ្លីនិក (សួររករោគសញ្ញាដែលអ្នកជំងឺមាន)<br>• ជ្រើសរើសយកគំនូសបំព្រួញដ៏សមស្របមកប្រើ ដោយពិនិត្យមើលប្រអប់បញ្ហាគ្លីនិក ដែលនៅខាងលើបង្អស់ ។<br>• ជារឿយៗ គំនូសបំព្រួញនឹងសុំឱ្យអ្នកស្រង់ប្រវត្តិ និងពិនិត្យអ្នកជំងឺ<br>• សូមប្រើប្រាស់លទ្ធផលដែលបានមកពីការពិនិត្យនិងស្រង់ប្រវត្តិជំងឺដើម្បីធ្វើការសំរេចចិត្ត (ជារឿយៗ ដោយជ្រើសរើសយក "មាន" ឬ "គ្មាន")<br>• យោលទៅតាមការសំរេចចិត្តរបស់អ្នក អាចមានប្រអប់ដែលត្រូវពិចារណា ។<br>• សូមធ្វើតាមសញ្ញាព្រួញមួយជំហានម្តងៗ រហូតដល់អ្នកឈានដល់ចុងបញ្ចប់នៃច្រកចេញ ។ |

***ចូរចងចាំ:***

***សូមអនុវត្តតាមគំនូសបំព្រួញមួយជំហានម្តងៗ ។ មិនត្រូវរំលងជំហាន ណាមួយទេ ។***



ការស្វាគមន៍



ការសាកសួរនិងស្តាប់



ការពិនិត្យ



ការសំរេចចិត្ត



ការយោគយល់និងការលើកទឹកចិត្ត

## ការព្យាបាលផ្អាក់ងារបង្ករោគទាំងអស់

ផ្ទុយពីការធ្វើរោគវិនិច្ឆ័យគ្លីនិក ឬរកមូលហេតុដែលខិតខំរកឱ្យឃើញភ្នាក់ងារបង្ករោគតែមួយនោះ ការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើចង្កោមរោគសញ្ញារួមបញ្ចូលនូវការព្យាបាលភ្នាក់ងារបង្ករោគទាំងអស់ ។ នេះមានន័យថា ប្រសិនបើមានឱសថចាំបាច់យកមកប្រើប្រាស់នោះ ការព្យាបាលចង្កោមរោគសញ្ញានឹងធ្វើឱ្យលែងចំលងជំងឺបានយ៉ាងឆាប់រហ័ស ដូច្នេះពួកគេពុំអាចចំលងជំងឺទៅមនុស្សម្នាក់ទៀតបានឡើយ ។

ប្រអប់ខាងក្រោមនេះ ពិពណ៌នាអំពីការសិក្សាករណីមួយដើម្បីបង្ហាញឱ្យឃើញអំពីដំណើរការការប្រព្រឹត្តិទៅនៃការគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ។

នៅក្នុងឧទាហរណ៍នេះ អ្នកផ្តល់សេវាថែទាំកំណត់រកឃើញនូវមូលហេតុដែលបង្កឱ្យមានរោគសញ្ញាលើអ្នកជំងឺច្រើនជាងគេ ហើយផ្តល់ការព្យាបាលជំងឺទាំងនោះដែលបង្កឱ្យមានផលវិបាកនិងសំណល់ធ្ងន់ធ្ងរ ។

### *ការហូរខ្ទុះតាមបង្ហូរនោម*

*អ្នកជំងឺម្នាក់ត្អូញត្អែរអំពីការហូរខ្ទុះចេញពីលិង្គរបស់គាត់ ។ នៅពេលពិនិត្យ អ្នកអាចបញ្ជាក់ច្បាស់ថាមានការហូរខ្ទុះចេញពីបង្ហូរនោមរបស់គាត់ ។*

*ភាគច្រើននៃការហូរខ្ទុះតាមបង្ហូរនោមបង្កឡើងដោយជំងឺប្រមេះទឹកបាយនិងជំងឺបង្កដោយមេរោគក្លាមីឌីយ៉ា ដូច្នេះការព្យាបាលត្រូវតែមានប្រសិទ្ធិភាពសំរាប់មូលហេតុទាំងពីរនេះ ។*

*មានមូលហេតុផ្សេងៗទៀតដែលបង្កឱ្យមានការហូរខ្ទុះតាមបង្ហូរនោម ដូចជាការឆ្លងមេរោគ Ureaplasma urealyticum និង Trichomonas vaginalis ។ តើត្រូវព្យាបាលជំងឺទាំងនេះដែរឬទេ ?*

*មិនចាំបាច់ទេ ពីព្រោះជំងឺទាំងពីរនេះមិនសូវមានញឹកញាប់ ហើយមិនបណ្តាលឱ្យមានផលវិបាកទេ ។ ការព្យាបាលរបស់វាមិនជាការបន្ទាន់ទេ ។ ក៏ប៉ុន្តែជំងឺប្រមេះទឹកបាយនិងជំងឺបង្កដោយក្លាមីឌីយ៉ាកើតមានជាញឹកញាប់ ។ វាមិនគ្រាន់តែបង្កឱ្យមានផលវិបាកប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងជួយសំរួលដល់ការចំលងនៃមេរោគអេដស៍ផងដែរ ។ ហេតុដូច្នេះ ជាការសំខាន់គេត្រូវព្យាបាលជំងឺទាំងពីរនេះជូនអ្នកជំងឺ ។*

**លំហាត់ ២.២**

## ការឆ្លើយតបទៅនឹងការទិតៀនទាំងនានាចំពោះវិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា

យើងនឹងពិនិត្យមើលសាកល្បងឆ្លើយទៅនឹងការទិតៀនសំខាន់នានា ចំពោះវិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ។ ប្រសិនបើអ្នកបានធ្វើលំហាត់ ២.៣ ចប់សព្វគ្រប់ហើយ អ្នកអាចគិតឃើញអំពីបញ្ហាទាំងនេះហើយ ។

| ការទិតៀនញឹកញាប់ជាងគេលើវិធីគ្រប់គ្រងថែទាំជំងឺកាមរោគ<br>ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា |
|---|
| • វិធីគ្រប់គ្រងជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ពុំមានលក្ខណៈវិទ្យាសាស្ត្រទេ ។<br>• ការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើចង្កោមរោគសញ្ញាមានលក្ខណៈងាយប្រើពេកសំរាប់គ្រូពេទ្យ សូម្បីតែគិលានុបដ្ឋាក-យិកាក៏អាចប្រើវាបានដែរ ។<br>• វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាមិនយកជំនាញ និងបទពិសោធន៍គ្លីនិករបស់គ្រូពេទ្យមកប្រើទេ ។<br>• យកល្អ ដំបូងត្រូវព្យាបាលមូលហេតុញឹកញាប់ជាងគេឱ្យអ្នកជំងឺសិនបន្ទាប់មកប្រសិនបើរោគសញ្ញាពុំធូរស្រាលទេ សឹមព្យាបាលមូលហេតុទីពីរទៀត ។<br>• វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាបណ្តាលឱ្យមានការខាតបង់ឱសថច្រើន ពីព្រោះអ្នកជំងឺទទួលការព្យាបាលច្រើនហួស ។<br>• វិធីគ្រប់គ្រងថែទាំករណីជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាជំរុញឱ្យកើតមានភាពស៊ាំនៃមេរោគទៅនឹងថ្នាំអង់ទីប៊ីយោទិក។<br>• គួរតែបញ្ចូលតេស្តមន្ទីរពិសោធន៍ល្អៗ និងសាមញ្ញៗ ដូចជាការបំពាក់ពណ៌ក្រាមទៅក្នុងការធ្វើរោគវិនិច្ឆ័យកាមរោគផង ។<br>• វិធីគ្រប់គ្រងថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ជាវិធីដែលមានតំលៃថោក សំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍តែប៉ុណ្ណោះ ។ |

**លំហាត់ ២.៣**

*វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ពុំមានលក្ខណៈវិទ្យាសាស្ត្រទេ :*

ផ្ទុយទៅវិញ វាត្រូវរៀបរៀងឡើងដោយពឹងផ្អែកលើការសិក្សាផ្នែកអេពីដេមីសាស្ត្រ ដែលធ្វើឡើងនៅតាមបណ្ដាលប្រទេសរីកចំរើន និងកំពុងអភិវឌ្ឍន៍នានា ។ ដើម្បីវាយតំលៃអំពីភាពត្រឹមត្រូវនៃការធ្វើរោគវិនិច្ឆ័យចង្កោមរោគញ្ញា ការសិក្សាអំពីតំលៃ (validation studies) ត្រូវបានធ្វើឡើងដោយប្រៀបធៀបការធ្វើរោគវិនិច្ឆ័យដោយប្រើចង្កោមរោគសញ្ញា ទៅនឹងការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកជំនួយពីមន្ទីរពិសោធន៍ ។ ការសិក្សាទាំងនេះបានបង្ហាញឱ្យឃើញថាការធ្វើរោគវិនិច្ឆ័យដោយប្រើចង្កោមរោគសញ្ញា មានប្រសិទ្ធិភាពប្រហាក់ប្រហែលគ្នានឹងការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកជំនួយពីមន្ទីរពិសោធន៍ផងដែរ ហេតុនេះវាពិតជាមានភាពត្រឹមត្រូវ ។ ដូច្នេះហើយ បានជាការធ្វើរោគវិនិច្ឆ័យជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាត្រូវបានគេយកទៅកែសំរួល ដើម្បីប្រើប្រាស់នៅតាមប្រទេសជាច្រើននៅលើសកលលោក ។

*ការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើចង្កោមរោគសញ្ញាមានលក្ខណៈងាយប្រើពេកចំពោះគ្រូពេទ្យ វាសមស្របសំរាប់ឱ្យគិលានុដ្ឋាក-យិកាប្រើប្រាស់ តែប៉ុណ្ណោះ :*

ភាពងាយស្រួលពុំមែនរារាំងគ្រូពេទ្យកុំឱ្យប្រើប្រាស់នូវបរិក្ខារពិនិត្យជំងឺផ្សេងៗដូចជា ប្រដាប់ស្ទង់កំដៅខ្លួន ឬស្ពែគូស្កុបនោះទេ ។ នេះគឺជាសារៈប្រយោជន៍ដ៏ធំមួយ សំរាប់ការប្រយុទ្ធនឹងជំងឺកាមរោគ ប្រសិនបើអ្នកផ្តល់សេវាថែទាំផ្សេងៗទៀតក្រៅពីវេជ្ជបណ្ឌិតអាចប្រើប្រាស់វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយប្រើចង្កោមរោគដើម្បីធ្វើរោគវិនិច្ឆ័យ ។ ដំណើរការធ្វើរោគវិនិច្ឆ័យ និងព្យាបាលដ៏សមរម្យនេះធ្វើឱ្យបុគ្គលិកសុខាភិបាលចំណាយពេលវេលា ដើម្បីយកមកធ្វើការអប់រំអ្នកជំងឺឱ្យផ្លាស់ប្តូរការប្រព្រឹត្តិ ។

*វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាមិនយកជំនាញ និងបទពិសោធន៍គ្លីនិករបស់គ្រូពេទ្យមកប្រើទេ :*

គ្រូពេទ្យជាច្រើនពឹងផ្អែកយ៉ាងខ្លាំងទៅលើការធ្វើរោគវិនិច្ឆ័យតាមរយៈរោគសញ្ញា ។ អ្នកទាំងនោះពិបាកនឹងទទួលសារភាពថា ការប្រើប្រាស់ការវិនិច្ឆ័យរោគតាមបែបគ្លីនិកនោះអាចនឹងបង្កឱ្យមានបញ្ហា ។ ការសិក្សានានាបង្ហាញឱ្យឃើញថា ការធ្វើរោគវិនិច្ឆ័យតាមបែបគ្លីនិកមានភាពត្រឹមត្រូវតែ ៥០ % តែប៉ុណ្ណោះ ហើយថែមទាំងមិនបានព្យាបាលជំងឺផ្សេងៗ ដែលកើតឡើងក្នុងពេលជាមួយគ្នា (mixed infection) បានទេ ។




*យកល្អត្រូវព្យាបាលមូលហេតុញឹកញាប់ជាងគេមុនសិន បន្ទាប់មកប្រសិនបើរោគសញ្ញានោះពុំធូរស្រាលទេទើបព្យាបាលមូលហេតុទីពីរទៀត :*

អ្នកជំងឺដែលមិនបានជាសះស្បើយ មិនវិលត្រលប់មកមណ្ឌលសុខភាពវិញទេ ហើយអាចថែមទាំងទៅស្វែងរកការព្យាបាលនៅកន្លែងដទៃទៀតផង ជាហេតុបណ្តាលឱ្យការព្យាបាលនោះ ពុំមានភាពសមស្របទេ ។ ពួកគេអាចក្លាយទៅជាបាត់រោគសញ្ញា ក៏ប៉ុន្តែ នៅតែមានជំងឺកាមរោគដែលបានទទួលការព្យាបាលពុំបានចប់សព្វគ្រប់នៅឡើយ ហើយប្រសិនបើពួកគេមានការរួមភេទដែលមិនបានប្រើមធ្យោបាយបង្ការ ពួកគេអាចចំលងជំងឺជាបន្តទៅទៀត ។

*វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាធ្វើឱ្យខាតបង់ឱសថច្រើន ពីព្រោះមានការព្យាបាល អ្នកជំងឺដោយផ្តល់ឱសថច្រើនហួសក៏រិត :*

ការសិក្សានានា បានបង្ហាញឱ្យឃើញថា វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាធ្វើឱ្យការថែទាំជំងឺកាមរោគមានតំលៃថោកក្នុងរយៈពេលយូរអង្វែង ។ បច្ចេកវិទ្យាជំនាញនិងហេត្ថារចនាសម្ព័ន្ធដែលត្រូវការដើម្បីធ្វើរោគវិនិច្ឆ័យមូលហេតុមានតំលៃថ្លៃ ។ ការព្យាបាលដែលទទួលបរាជ័យ ឬការធ្វើរោគវិនិច្ឆ័យគ្លីនិកខុស ដែលបណ្តាលឱ្យមានការព្យាបាលមិនសមស្រប ឬមិនបានចប់សព្វគ្រប់ធ្វើឱ្យតំលៃនៃការព្យាបាលកាន់តែថ្លៃឡើង ពីព្រោះអាចបណ្តាលឱ្យមានផលវិបាកនានា និងអាចបន្តចំលងជំងឺតទៅទៀត ។

*វិធីគ្រប់គ្រងថែទាំករណីជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាជំរុញឱ្យកើតមានទូវភាពស៊ាំនៃមេរោគទៅនឹងថ្នាំអង់ទីប៊ីយោទិក :*

ភាពស៊ាំរបស់មេរោគទៅនឹងថ្នាំអង់ទីប៊ីយោទិកកើតមានឡើង ប្រសិនបើ អ្នកជំងឺមិនលេបថ្នាំឱ្យបានគ្រប់គ្រាន់ដើម្បីព្យាបាលជំងឺរបស់ខ្លួនឱ្យបានជាសះស្បើយ ។ នៅក្នុងវិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាវិញ អ្នកផ្តល់សេវាថែទាំត្រូវបានលើកទឹកចិត្តឱ្យផ្តល់នូវការព្យាបាលគំរូ ដោយប្រើប្រាស់នូវឱសថដែលមានប្រសិទ្ធិភាពខ្ពស់បំផុតសំរាប់ចង្កោមរោគសញ្ញាណាមួយ ។

អ្នកផ្តល់សេវាថែទាំក៏ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់វិធីព្យាបាល ដោយប្រើឱសថតែមួយកំរិត (dose) ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ជាហេតុធ្វើឱ្យចៀសវាងបាននូវបញ្ហាមិនគោរពវេជ្ជបញ្ជា ។ ការប្រាស្រ័យទាក់ទងល្អរវាងអ្នកផ្តល់សេវាថែទាំនិងអ្នកជំងឺនឹងធ្វើឱ្យអ្នកជំងឺបន្តប្រើប្រាស់ឱសថដែលបានណែនាំក្រោយពេលដែលគាត់ចាកចេញពីមណ្ឌលសុខភាព។

*គួរបញ្ចូលតេស្តមន្ទីរពិសោធន៍ល្អនិងសាមញ្ញ។ ដូចជាការបំពាក់ពណ៌ក្រាម **(Gram stain)** ទៅក្នុងការធ្វើរោគវិនិច្ឆ័យជំងឺកាមរោគ*

ប្រសិនបើ អ្នកបញ្ចូលការធ្វើតេស្តមន្ទីរពិសោធន៍ទៅក្នុងដំណើរការធ្វើរោគវិនិច្ឆ័យជំងឺកាមរោគនោះ អ្នកជំងឺត្រូវរង់ចាំលទ្ធផលតេស្ត ហើយអាចមិនព្រមវិលត្រលប់មកទទួលការព្យាបាលទេ ។ ម្យ៉ាងទៀត នៅពេលដែលគាត់រង់ចាំ គាត់នៅតែជាអ្នកអាចផ្ទុកកាមរោគដដែល ហើយផលវិបាកក៏អាចកើតមានឡើងផងដែរ ។ គួរធ្វើការបំពាក់ពណ៌ក្រាមតែនៅពេលដែលមានមីក្រូទស្សន៍ ដែលអាចពិនិត្យបានលឿន និងបានត្រឹមត្រូវទៀងទាត់តែប៉ុណ្ណោះ ។

*វិធីគ្រប់គ្រងថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ជាវិធីដែលមានតំលៃថោកសំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍តែប៉ុណ្ណោះ*

វិធីថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ត្រូវប្រើប្រាស់ទូទាំងពិភពលោកសំរាប់ថែទាំបញ្ហាសុខភាពជាច្រើន (ឧទាហរណ៍ ជំងឺផ្លូវដកដង្ហើម) ។ ទោះបីជាមានការបំបាត់ចោលនូវតំលៃនៃតេស្តមន្ទីរពិសោធន៍ក៏ដោយ ក៏ការលើកកំពស់ដល់ការព្យាបាលបញ្ចូលគ្នា ពុំធ្វើឱ្យវិធីថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញាមានតំលៃថោកនោះទេ ។

# ការរំលឹកសារឡើងវិញ

## វិធីមុនៗសំរាប់ធ្វើរោគវិនិច្ឆ័យជំងឺកាមរោគ

- ទោះបីជានៅក្នុងប្រព័ន្ធថែទាំសុខភាពដែលមានរចនាសម្ព័ន្ធត្រឹមត្រូវយ៉ាងណាក៏ដោយ ក៏នៅតែមានបញ្ហានានាក្នុងការពឹងផ្អែកលើការធ្វើរោគវិនិច្ឆ័យមូលហេតុ និងគ្លីនិកនៃជំងឺកាមរោគដែរ
- រោគវិនិច្ឆ័យមូលហេតុមានតំលៃថ្លៃហើយត្រូវចំណាយពេលយូរ ។ វាទាមទារឱ្យមានប្រភពធនធានពិសេសៗផ្សេងៗ ហើយជារឿយៗ នាំទៅរកការយឺតយ៉ាវក្នុងការព្យាបាល ។
- ក្នុងការធ្វើរោគវិនិច្ឆ័យគ្លីនិក គេងាយនឹងធ្វើរោគវិនិច្ឆ័យកាមរោគមួយចំនួនខុសណាស់ ហើយមិនបានគិតដល់ជំងឺផ្សេងៗដែលកើតឡើងក្នុងពេលជាមួយគ្នាទេ ។

## វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា

- វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ជាវិធីដ៏មានប្រសិទ្ធិភាពសំរាប់ប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកាមរោគ ពីព្រោះវិធីនេះផ្តល់នូវការព្យាបាលទាន់ពេលវេលាមានប្រសិទ្ធិភាពចាប់ពីពេលដែលអ្នកជំងឺមកកាន់មណ្ឌលសុខភាពដំបូង ។
- លក្ខណៈសំខាន់ៗនៃវិធីគ្រប់គ្រងថែទាំករណីជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាគឺ :
    * ការកំណត់ជាចង្កោមរោគសញ្ញាគ្លីនិក ដែលប្រមូលផ្តុំនូវភ្នាក់ងារបង្ករោគចំបងៗ នានា
    * ការប្រើប្រាស់គំនូសបំព្រួញ គឺអាចជួយឱ្យអ្នកផ្តល់សេវាថែទាំសុខភាពកំណត់រកឃើញនូវមូលហេតុដែលបង្កជាចង្កោមរោគសញ្ញាណាមួយជូនអ្នកជំងឺ ។
    * ការព្យាបាលយ៉ាងរួសរាន់នូវមូលហេតុសំខាន់ៗទាំងអស់របស់ចង្កោមរោគសញ្ញា
    * ការធានាការព្យាបាលដៃគូរួមភេទរបស់អ្នកជំងឺ អប់រំអ្នកជំងឺឱ្យគោរពតាមវេជ្ជបញ្ជា និងអំពីការកាត់បន្ថយការប្រឈមមុខនឹងគ្រោះថ្នាក់ និងការជំរុញការប្រើប្រាស់ស្រោមអនាម័យ ។

## ការប្រើប្រាស់គំនូសបំព្រួញ

- គំនូសបំព្រួញ គឺជាឧបករណ៍ជាមូលដ្ឋានរបស់ការគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ។
- គំនូសបំព្រួញងាយស្រួលប្រើ បើសិនយើងធ្វើតាមវាជាជំហានៗ ដូច្នេះអ្នកផ្តល់សេវានៅតាមផ្នែកផ្សេងៗ អាចប្រើប្រាស់វាបាន ។
- ការប្រើប្រាស់គំនូសបំព្រួញធ្វើឱ្យការព្យាបាលមានលក្ខណៈរហ័ស និងអាចយកទៅប្រើប្រាស់បានយ៉ាងទូលំទូលាយ ។
- គំនូសបំព្រួញអាចធ្វើឱ្យបុគ្គលិកសុខាភិបាលបញ្ចូលការអប់រំ និងការជំរុញការប្រើប្រាស់ស្រោមអនាម័យជាមួយនឹងការព្យាបាលជំងឺកាមរោគ ។

# សំណួរ និង លំហាត់

## ២.១ សំណួរ

តើអ្នកគ្រប់គ្រងថៃទាំជំងឺកាមរោគដោយពឹងផ្អែកលើប្រជាប់បន្តពូជយ៉ាងដូចម្តេច ? សូមគូសសញ្ញា(✓) នៅក្នុងប្រអប់ដែលស្ថិតនៅផ្នែកខាងមុខនៃចំលើយនិមួយៗខាងក្រោមនេះ :

ព្យាបាលមូលហេតុតែមួយឱ្យអ្នកជំងឺសិន ហើយសុំឱ្យអ្នកជំងឺវិលត្រលប់មកជួបអ្នកវិញ។ ប្រសិន បើជំងឺមិនបានធូរស្រាលទេ ទើបអ្នកព្យាបាលមូលហេតុទីពីរទៀត ។

ព្យាបាលមូលហេតុទាំងពីរឱ្យអ្នកជំងឺភ្លាមតែម្តង ។

បញ្ជូនអ្នកជំងឺ ដើម្បីធ្វើរោគវិនិច្ឆ័យរកមូលហេតុ ។

## ២.២ លំហាត់

*<u>គំរោងស្វ័យសិក្សា</u>* ***(self-study project)***

ខាងក្រោមនេះគឺជាចំណុចគន្លឹះខ្លះៗសំរាប់ឱ្យអ្នកពង្រីកសមត្ថភាពរបស់អ្នកនៅពេលដែលអ្នកសិក្សាបន្តទៅទៀត ។

១. សូមទុកគំនូសបំព្រួញនៅជិតដៃរបស់អ្នកគ្រប់ពេលវេលាទាំងអស់ ។ ប្រសិនបើអាចធ្វើបាន សូមបិតវានៅលើតុឬនៅលើជញ្ជាំងដែលជាកន្លែងងាយមើលឃើញវា ។

២. សូមគិតអំពីសារៈប្រយោជន៍ និងឧបសគ្គនានាក្នុងការយកការគ្រប់គ្រងថៃទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាទៅអនុវត្តនៅមណ្ឌលសុខភាពរស់អ្នក ។ សូមពិភាក្សាបញ្ហាទាំងនោះនៅក្នុងវគ្គបណ្តុះបណ្តាល ឬ ក៏រៀបចំការពិភាក្សាបញ្ហានោះជាមួយអ្នកត្រួតពិនិត្យណែនាំរបស់អ្នក ។

៣. ប្រសិនបើសហសេវិកណាម្នាក់របស់អ្នក បានប្រើវិធីគ្រប់គ្រងថៃទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញារួចហើយសូមខិតខំលៃលករៀបចំការសង្កេតមើលគាត់ពិនិត្យអ្នកជំងឺ។ អ្នកអាចដកស្រង់យកគំនិតដ៏មានតំលៃនានា ដែលអាចជួយឱ្យការសិក្សារបស់អ្នកកាន់តែមានលក្ខណៈ

ងាយស្រួលជាងមុន ។ សូមចងចាំថា ប្រការដ៏ល្អបំផុតនោះ គឺអ្នកត្រូវសុំការអនុញ្ញាតពីអ្នកជំងឺជានិច្ច ដើម្បីសង្កេតមើលការពិនិត្យជំងឺ ហើយត្រូវគោរពនូវការសំងាត់ផ្ទាល់ខ្លួនរបស់អ្នកជំងឺគ្រប់ពេលវេលាទាំងអស់ ។

## ២.៣ លំហាត់

នៅពេលពិភាក្សាអំពីការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើចង្កោមរោគសញ្ញាជាមួយអ្នកដទៃ យើងឃើញថា មានអ្នកខ្លះទំនងជាមានការខ្វាយខ្វល់ប្រហាក់ប្រហែលគ្នា ។ ខាងក្រោមនេះគឺជាការអធិប្បាយ (comments) ផ្សេងៗដែលយើងឮជាញឹកញាប់ ។ សូមកត់ត្រា ចុះថាតើអ្នកយល់ស្រប ឬមិនយល់ស្របទៅនឹងចំណុចនិមួយៗ ហើយប្រាប់អំពីមូលហេតុផង ។

"វិធីគ្រប់គ្រងជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ពុំមានលក្ខណៈវិទ្យាសាស្ត្រទេ"

" ការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើចង្កោមរោគសញ្ញាមានលក្ខណៈងាយប្រើពេកសំរាប់គ្រូពេទ្យសូម្បីតែគិលានុបដ្ឋាក-យិកាក៏អាចប្រើវាបានដែរ"

" យកល្អ ដំបូងត្រូវព្យាបាលមូលហេតុញឹកញាប់ជាងគេឱ្យអ្នកជំងឺសិន បន្ទាប់មកប្រសិនបើរោគសញ្ញាពុំធូរស្រាលទេ ទើបព្យាបាលមូលហេតុទីពីរទៀត"

"វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា បណ្តាលឱ្យមានការខាតបង់ខ្ជះខ្ជាយឱសថ ពីព្រោះអ្នកជំងឺទទួលការព្យាបាលច្រើនហួស"

"វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ជំរុញឱ្យមានភាពស៊ាំនៃមេរោគទៅនឹងថ្នាំអង់ទីប៊ីយោទិក"

" គួរតែបញ្ចូលតេស្តមន្ទីរពិសោធន៍ល្អៗ និងសាមញ្ញៗដូចជាការបំពាក់ពណ៌ក្រាមទៅក្នុងការធ្វើរោគវិនិច្ឆ័យកាមរោគផង"

# ចំលើយ

## *២.១ សំណួរ*

ចំណុចទី ២ គឺជាចំលើយត្រឹមត្រូវ “ការព្យាបាលមូលហេតុទំាងពីរឱ្យអ្នកជំងឺ” ។ គេពុំអាចធ្វើការបែងចែកឱ្យដាច់ពីគ្នា និងបានត្រឹមត្រូវនូវមូលហេតុដែលបង្កឱ្យកើតដំបៅនៅលើប្រដាប់បន្តពូជដោយពឹងផ្អែកលើការពិនិត្យគ្លីនិកបានទេ ដូច្នេះការជ្រើសរើសដ៏សមស្របបំផុតនេះគឺការព្យាបាលភ្នាក់ងារបង្ករោគទាំងពីរឱ្យបានឆាប់រហ័សដែលធ្វើឱ្យអ្នកជំងឺលែងក្លាយជាអ្នកចំលងជំងឺតទៅទៀត ។

ការជ្រើសរើសចំលើយទី ១ ជួបនឹងបញ្ហាដែលកើតមានជាមួយការធ្វើរោគវិនិច្ឆ័យ និងព្យាបាលតាមបែបគ្លីនិក ។ ប្រសិនបើអ្នកជំងឺពុំបានជាសះស្បើយដោយសារការព្យាបាលលើកទីមួយទេនោះ គេអាចនឹងចំលងជំងឺបន្តទៅអ្នកដទៃៗទៀតបាន ។ ក៏អាចមានគ្រោះថ្នាក់បន្ថែមទៀតដែរ គឺអ្នកជំងឺអាចស្វែងរកការព្យាបាលនៅកន្លែងដទៃទៀត ហើយគេអាចទទួលការថែទាំពុំបានសមស្រប។

ប្រសិនអ្នកជ្រើសរើសយកចំលើយចុងក្រោយ (បញ្ជូនអ្នកជំងឺដើម្បីធ្វើរោគវិនិច្ឆ័យរកមូលហេតុ) សូមចងចាំថា យើងបានសង្កត់ធ្ងន់រួចមកហើយលើបញ្ហាច្រើនដែលអាចកើតមានឡើងដោយសារការយឺតយ៉ាវក្នុងការព្យាបាល ទោះបីជាមានតេស្តប្រើប្រាស់ស្រាប់ក្តី ។

# ការស្រង់ប្រវត្តិជម្ងឺ និងការពិនិត្យអ្នកជម្ងឺ

# ការគ្រប់គ្រងថែទាំជំងឺកាមរោគ

## ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា សំរាប់ថ្នាក់មណ្ឌលសុខភាព

ជំពូកទី ៣

# ការស្រង់ប្រវត្តិជំងឺ

# និងការពិនិត្យអ្នកជំងឺ

# ជំពូកទី ៣

## ការស្រង់ប្រវត្តិជំងឺ និង ការពិនិត្យអ្នកជំងឺ

ជំពូកនេះនឹងផ្តោតជាសំខាន់ទៅលើភាពស្ទាត់ជំនាញដ៏សំខាន់ពីរក្នុងការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើចង្កោមរោគសញ្ញា : ការស្រង់ប្រវត្តិជំងឺ និង ការពិនិត្យអ្នកជំងឺ ។ ជំពូកនេះនឹងជួយអ្នកក្នុងការធ្វើអោយប្រសើរឡើងដល់ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងនិងការពិនិត្យជំងឺ ។

ទោះបីជាអ្នកមានបទពិសោធន៍ច្រើនក្នុងការសាកសួរអ្នកជំងឺក៏ដោយ ក៏ការសាកសួរមនុស្សម្នាក់ដែលមានរោគសញ្ញាកាមរោគ អាចនឹងជួបប្រទះការលំបាកជាមិនខាន ។ ដោយហេតុថារោគសញ្ញាទាំងនោះកើតឡើងនៅតំបន់ប្រដាប់បន្តពូជ ហើយអ្នកជំងឺត្រូវតែរៀបរាប់ពីការប្រព្រឹត្តផ្លូវភេទរបស់គេ សេចក្តីអៀនខ្មាសនឹងធ្វើឱ្យអ្នកជួបប្រទះនឹងការលំបាកជាមិនខាន ។ វគ្គបណ្តុះបណ្តាលនេះនឹងជួយអ្នកឱ្យទទួលបាននូវពត៌មាននានា ដែលអ្នកត្រូវការនៅពេលស្រង់ប្រវត្តិជំងឺរបស់អ្នកជំងឺ ។ វាក៏នឹងជួយអ្នកក្នុងការពិនិត្យអ្នកជំងឺផងដែរ ។

ជាការសំខាន់ណាស់ គេត្រូវតែទទួលស្គាល់ថា ការស្រង់ប្រវត្តិជំងឺ និងការពិនិត្យអ្នកជំងឺមិនអាចរៀនបានស្រួល។ តែតាមរយៈការសិក្សានោះទេ ។ ដើម្បីឈានដល់កំរិតមួយដែលមានគុណភាពសមស្រប អ្នកចាំបាច់ត្រូវតែអនុវត្តប្រើប្រាស់ភាពស្ទាត់ជំនាញរបស់អ្នក ។ ផែនការធ្វើសកម្មភាពនៅផ្នែកខាងចុងនៃជំពូកនេះ នឹងប្រាប់នូវវិធីដើម្បីបង្កើននូវបទពិសោធន៍ទាំងនេះ ។ ការអនុវត្តជំនាញទាំងនេះគឺជាមធ្យោបាយដ៏ល្អបំផុតដើម្បីទទួលបាននូវបទពិសោធន៍ និងទំនុកចិត្តដែលអ្នកត្រូវការចាំបាច់ ។

**មាតិកា**


- ការស្រង់ប្រវត្តិជំងឺ និងការពិនិត្យអ្នកជំងឺ…………២
- ការប្រាស្រ័យទាក់ទងគ្នារវាងបុគ្គលនិងបុគ្គលដែលមានប្រសិទ្ធិភាព………………...៣
- ការប្រមូលពត៌មានស្តីពីជំងឺកាមរោគ……………..១៧
- ការរំលឹកសាឡើងវិញ……….២៨
- សំណួរ និងលំហាត់………...៣១
- ចំលើយ…………………..៤១

## ការស្រង់ប្រវត្តិជំងឺ និង ការពិនិត្យអ្នកជំងឺ

ការសាកសួរប្រវត្តិជំងឺ និងការពិនិត្យអ្នកជំងឺ គឺជាផ្នែកមួយដ៏សំខាន់ ក្នុងការគ្រប់គ្រងដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ពីព្រោះវាអាចនាំទៅរកការធ្វើរោគវិនិច្ឆ័យនិងការព្យាបាល វាជួយឱ្យអ្នកវាយតំលៃអំពីការប្រឈមមុខនឹងគ្រោះថ្នាក់នៃការចំលង និងការឆ្លងកាមរោគនាអនាគត ហើយជួយអោយអ្នករកឃើញដៃគូរួមភេទដែលអាចឆ្លងកាមរោគហើយត្រូវការនូវការព្យាបាលនេះ ។

| គោលបំណងរបស់ការសាកសួរប្រវត្តិជំងឺ និងការពិនិត្យអ្នកជំងឺ គឺ : |
|---|
| • ធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើចង្កោមរោគសញ្ញាជំងឺកាមរោគឱ្យបានត្រឹមត្រូវល្អ និងមានប្រសិទ្ធិភាព<br>• កំណត់អំពីការប្រឈមមុខនឹង គ្រោះថ្នាក់នៃការចំលង ឬ ឆ្លងកាមរោគ<br>• រកឃើញដៃគូរួមភេទដែលអាចឆ្លងជំងឺកាមរោគ ។ |

ដើម្បីប្រើប្រាស់គំនូសបំព្រួញប្រកបដោយប្រសិទ្ធិភាព អ្នកត្រូវមានលទ្ធភាពប្រមូលពត៌មានអោយបានត្រឹមត្រូវ និងគ្រប់គ្រាន់ដោយកែលំអភាពស្ទាត់ជំនាញ ក្នុងការសាកសួរនិងការពិនិត្យអ្នកជំងឺ ។

## ការប្រាស្រ័យទាក់ទងរវាងបុគ្គល និងបុគ្គលដែលមានប្រសិទ្ធិភាព

ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទង មានសារៈសំខាន់សំរាប់អ្នកផ្តល់សេវាថែទាំសុខភាពដែលមានភារៈកិច្ចព្យាបាលអ្នកជំងឺកាមរោគ ជាពិសេសនៅពេលដែលពត៌មានចាំបាច់នានា មានការប៉ះពាល់អារម្មណ៍អ្នកជំងឺ (sensitive) ឬធ្វើអោយអ្នកជំងឺអៀនខ្មាសមិនហ៊ាននិយាយប្រាប់ ។ ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងអាចប្រើប្រាស់ ឬ មិនប្រើប្រាស់ពាក្យសំដីហើយមានគោលបំណង :

- បង្កើតនូវភាពស្និទ្ធស្នាល ជាមួយអ្នកជំងឺដើម្បីធ្វើអោយគេមានអារម្មណ៍ស្រួលក្នុងចិត្ត ដើម្បីនិយាយអំពីបញ្ហាផ្ទាល់ខ្លួនរបស់គេ និង
- ដើម្បីទទួលបាននូវពត៌មានសមស្របឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន

ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងល្អ នឹងជួយអោយអ្នកជំងឺមានទំនុកចិត្តលើរបៀបដែលអ្នកយកមកដោះស្រាយបញ្ហារបស់គេ។ អ្នកប្រហែលជាបានគិតរួចហើយអំពីការលំបាកមួយចំនួនដែលពាក់ព័ន្ធក្នុងការសាកសួរអ្នកជំងឺដែលមានរោគសញ្ញាកាមរោគ។

នៅពេលទំនាក់ទំនងសាកសួរអ្នកជំងឺកាមរោគបុគ្គលិកសុខាភិបាលដែលល្អត្រូវមានលក្ខណៈវិជ្ជមាន, រួសរាយ រាក់ទាក់ និងមានលទ្ធភាពយល់ពីបញ្ហាអ្នកជំងឺ ។

អ្នកជំងឺជាច្រើនមានការខ្វល់ខ្វាយចិត្តរួចទៅហើយ នៅពេលមកកាន់គ្លីនិកកាមរោគ អារម្មណ៍ទាំងនេះមានលក្ខណៈធ្ងន់ធ្ងរកាន់តែខ្លាំងទៀត ចំពោះអ្នកជំងឺដែលមានរោគសញ្ញានៅតំបន់ប្រដាប់បន្តពូជ ឧទាហរណ៍ : ដំបៅ ឬ ធ្លាក់ស ឬ ហូរខ្ទុះមិនធម្មតា ។ តើអ្នកមានអារម្មណ៍យ៉ាងណាដែរ ប្រសិនបើអ្នកទៅកាន់គ្លីនិកកាមរោគ ដោយមានរោគសញ្ញាទាំងនេះ ? ចំពោះសំណួរនេះពុំមានចំលើយដែលត្រូវឬក៏ខុសនោះទេ ។ អ្នកជំងឺខ្លះនឹងមានការខ្វល់ខ្វាយចិត្ត ខ្មាសអៀន បារម្ភ ឬក៏ភិតភ័យរន្ធត់ ។ អានុភាពនៃអារម្មណ៍ទាំងនេះអាស្រ័យទៅតាមការយល់ដឹងរបស់អ្នកជំងឺ អំពីជំងឺកាមរោគ ជំនឿរបស់គេលើមូលហេតុនៃរោគសញ្ញា ភេទ អាយុ ស្ថានភាពក្នុងសង្គម ឬការដែលគេស្គាល់ ឬមិនស្គាល់អ្នកផ្តល់សេវាថែទាំ ។

ចំលើយចំពោះសំណួរខាងលើអាចមានច្រើន និងមានភាពប្លែកៗគ្នា ដូចអ្នកជំងឺដែលទៅកាន់មណ្ឌលសុខភាពដូច្នេះដែរ ។ លទ្ធផលដែលបណ្តាលមកពីអារម្មណ៍ព្រួយបារម្ភទាំងនេះគឺ អ្នកជំងឺកំរនឹងបង្ហាញនូវរោគសញ្ញាដែលបណ្តាលឱ្យគេបារម្ភណាស់ ។ អ្នកជំងឺដែលមានដំបៅនៅប្រដាប់បន្តពូជ ឬក៏ធ្លាក់សតែងតែត្អូញត្អែរ អំពីអាការៈឈឺក្បាល ឬក៏ឈឺបំពង់កទៅវិញនៅពេលដំបូង ។ ការស្វែងរកអោយឃើញនូវរោគសញ្ញាពិតប្រាកដពឹងផ្អែកទៅលើភាពស្ទាត់ជំនាញ អាកប្បកិរិយា ឬការលើកទឹកចិត្តរបស់អ្នកផ្តល់សេវាថែទាំសុខភាព ។ ជំហានដំបូង គឺ ត្រូវបង្កើតនូវភាពស្និទ្ធស្នាលល្អជាមួយអ្នកជំងឺ ។ នៅពេលដែលការងារនេះដំណើរការល្អហើយភាពស្ទាត់ជំនាញក្នុងការនិយាយជួយឱ្យអ្នកផ្តល់សេវាថែទាំទទួលបាននូវព័តមានសំខាន់ៗទាំងអស់ដែលខ្លួនត្រូវការ ។

## ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដើម្បីបង្កើតនូវភាពស្និទ្ធស្នាល

ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដើម្បីបង្កើតនូវភាពស្និទ្ធស្នាលជាមួយអ្នកជំងឺ គឺជាភាពស្ទាត់ជំនាញដំបូងបង្អស់ដែលអ្នក នឹងប្រើប្រាស់នៅពេលដែលអ្នកជំងឺមកជួបអ្នក ។ ភាពស្ទាត់ជំនាញទាំងនោះរួមមាន :

- ភាពស្ទាត់ជំនាញក្នុងការនិយាយស្តី (verbal skills) : របៀបដែលអ្នកនិយាយទៅកាន់អ្នកជំងឺ និងសាកសួរសំណួរផ្សេងៗ និង
- ភាពស្ទាត់ជំនាញដោយមិនប្រើពាក្យសំដី (non-verbal skills) : របៀបដែលអ្នកប្រកាន់អាកប្បកិរិយាចំពោះអ្នកជំងឺ ។

## *ការទៅពិគ្រោះជំងឺរបស់នាងវណ្ណថា ជាមួយគិលានុបដ្ឋាយិកា វ៉ានី*

វ៉ានី គឺ ជាគិលានុបដ្ឋាយិកាម្នាក់នៅក្នុងគ្លីនិកកាមរោគ ក្នុងតំបន់ដែលនាងវណ្ណថា រស់នៅ។ ព្រឹកនេះ វ៉ានី មានការងាររវល់យ៉ាងខ្លាំងហើយនាងហាក់ដូចជាអស់កំលាំងខ្លាំងណាស់។ នាងកំពុងតែសរសេរកំណត់ហេតុរបស់អ្នកជំងឺ ហើយមានគិលានុបដ្ឋាយិកាចុះបញ្ជីម្នាក់ទៀតឈរនៅក្បែររង់ចាំនាងបញ្ចប់ការងារ ។ នាងវណ្ណថា បានចូលទៅក្នុងបន្ទប់ ។ អ្នកស្រីវ៉ានីបានក្រឡេកមើលនាងមួយភ្លែតរួចនិយាយថា ” *ចាំមួយភ្លែត* ” ។ នាងវណ្ណថា ដើរអូសជើងចុះឡើងៗនៅពេលកំពុងតែឈរហើយសំលឹងមើលក្រោមទៅកំរាលឥដ្ឋ។ នៅពេលអ្នកស្រីវ៉ានីបញ្ចប់ការសរសេរ នាងក៏ផ្អែកខ្នងទៅលើកៅអីដកដង្ហើមធំរួចដាក់ដៃទៅលើតុ ។ បន្ទាប់មកនាងសំឡឹងនាងវណ្ណថាយ៉ាងមុត ហើយសួរនាងថា ” *តើនាងមាន បញ្ហាអ្វី ?* ” វណ្ណថាឈរមួយកន្លែងសំឡឹងទៅដី និងយកជើងអូសដីចុះឡើងដោយជ្រួលច្រាលក្នុងចិត្ត ។ គិលានុបដ្ឋាយិកាចុះបញ្ជីយកសៀវភៅកំណត់ហេតុចេញរួចចាកចេញពីបន្ទប់ ។ អ្នកស្រីវ៉ានីសួរសំណួរម្តងទៀតដោយអារម្មណ៍មិនអត់ធ្មត់ ។ វណ្ណថាឆ្លើយថា ” *ចា៎ស អ្នកគ្រូពេទ្យ* ” *ខ្ញុំអឺ. . . មិនស្ងួវស្រួលខ្លួនសោះ. . . អឺគឺក្រពះរបស់ខ្ញុំ, វា. . .* ” ។ អ្នកស្រីវ៉ានីក៏ស្រែកថា ” ម្ចាស់ថ្លៃអើយ ! មួយថ្ងៃនេះខ្ញុំអត់ធ្វើអ្វីបានទេ ! ។ ពេលនេះ នាងវណ្ណថាក៏ចាប់ផ្តើមយំ ។



ការពិគ្រោះជំងឺរបស់នាងវណ្ណថាជាមួយគិលានុបដ្ឋាកយិកា វ៉ានី

**ភាពស្ទាត់ជំនាញក្នុងការនិយាយស្ដី**

- ទទួលស្វាគមន៍អ្នកជំងឺ
- ជៀសវាងបញ្ហានានាក្នុងការប្រាស្រ័យទាក់ទងដោយប្រើពាក្យ សំដី
- សូមសួរសំណួរ "បើក" និង " បិទ" ឱ្យមានប្រសិទ្ធិភាពល្អ
- ត្រៀមខ្លួនឆ្លើយតបចំពោះការរំភើបចិត្តរបស់អ្នកជំងឺ

## ការទទួលស្វាគមន៍អ្នកជំងឺ

ដំណាក់កាលដំបូង គឺត្រូវទទួលរាក់ទាក់អ្នកជំងឺនៅក្នុងលក្ខណៈស្និទ្ធស្នាល និងណែនាំខ្លួនអ្នកឱ្យគេស្គាល់។ វិធីដទៃផ្សេងទៀត សំរាប់ស្វាគមន៍អ្នកជំងឺត្រូវបានពិពណ៌នានៅក្នុងប្រអប់ខាងក្រោមៈ

**វិធីទទួលរាក់ទាក់អ្នកជំងឺ**

- ប្រើប្រាស់សំលេងដែលមានន័យស្វាគមន៍ញញឹមរាក់ទាក់
- ណែនាំខ្លួនអ្នកអោយអ្នកជំងឺស្គាល់
- អញ្ជើញអ្នកជំងឺអង្គុយ
- សំឡឹងទៅភ្នែករបស់អ្នកជំងឺ ប្រសិនបើគិតថាសមរម្យ
- លើកទឹកចិត្តអ្នកជំងឺឱ្យនិយាយដោយការសាកសួរសំណួរនានា។
- ងក់ក្បាលនៅពេលអ្នកជំងឺប្រាប់ ឬក៏និយាយថា "អឺ អឺ" ឬ" សូមប្រាប់ខ្ញុំបន្ថែមទៀត" ។
- សំដែងនូវការគោរពរាប់អាន និងយោគយល់ ។




ការស្វាគមន៍ទទួលអ្នកជំងឺ

## បញ្ហាដែលមានញឹកញាប់នៅក្នុងការប្រាស្រ័យទាក់ទងដោយការនិយាយស្តី

មានបញ្ហាមួយចំនួននៅក្នុងការប្រាស្រ័យទាក់ទងដោយការនិយាយស្តីដែលតែងតែកើតមានញឹកញាប់ ហើយអាចធ្វើអោយការគ្រប់គ្រងថែទាំករណីកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ពុំសូវមានប្រសិទ្ធិភាព ។ ជាការសំខាន់ណាស់ ដែលអ្នកត្រូវតែដឹងបញ្ហាទាំងនេះ ដើម្បីអ្នកអាចជៀសវាងបញ្ហាទាំងនោះឱ្យបានច្រើនបំផុតតាមតែអាចធ្វើទៅបាន ។

## វិធីជៀសវាងបញ្ហាដែលមានញឹកញាប់នៅក្នុងការប្រាស្រ័យទាក់ទង ដោយប្រើការនិយាយស្ដី

- ជានិច្ចកាលត្រូវតែចេះគួរសម
- ប្រើពាក្យពេចន៍ដែលអ្នកជំងឺអាចយល់បានដោយស្រួល
- សួរសំណួររបស់អ្នកអោយបានច្បាស់
- សួរសំណួរមួយម្ដងៗ
- ជៀសវាងប្រើសំណួរ " ដឹកនាំ " (leading)
- ជៀសវាងការវិនិច្ឆ័យមិនសមហេតុផល
- ស្នើសុំការអនុញ្ញាតពីអ្នកជំងឺមុននឹងពិភាក្សាអំពីបញ្ហាដែលប៉ះពាល់ទឹកចិត្តអ្នកជំងឺ (sensitive topics)

នៅពេលស្រង់ប្រវត្តិជំងឺ ជានិច្ចកាលសូមប្រើឃ្លាប្រយោគសំណួររបស់អ្នកឱ្យបានសមគួរ និង បង្ហាញនូវការគោរព ។ អ្នកគួរតែប្រើពាក្យពេចន៍ដែលអ្នកជំងឺអាចយល់បានដោយងាយស្រួល ។ អ្នកត្រូវតែប្រយ័ត្នប្រយែង ជៀសវាងប្រើពាក្យបច្ចេកទេសពេទ្យដែលធ្វើឱ្យអ្នកជំងឺមានការច្របូកច្របល់ ។ អ្នកគប្បីសួរសំណួរឱ្យបានច្បាស់លាស់ ។ នេះមានន័យថាសំណួរ គួរតែមានភាពជាក់លាក់ (specific) ដើម្បីឱ្យអ្នកជំងឺយល់ហើយឆ្លើយបានច្បាស់លាស់ ។ វិធីមួយទៀតដើម្បីកាត់បន្ថយនូវការច្រឡំគឺត្រូវសួរសំណួរមួយម្ដងៗ ។ ជួនកាលអ្នកផ្ដល់សេវាថែទាំបញ្ចូលសំណួរពីរទៅជាសំណួរតែមួយពីព្រោះគេចង់ប្រញាប់ ។ នេះអាចធ្វើអោយមានការភ័ន្តច្រឡំប្រសិនបើអ្នកជំងឺយល់ខុស ។ បញ្ហាដែលកើតមានជាញឹកញាប់មួយទៀត គឺ ការប្រើសំណួរដែលនាំមកនូវចំលើយ " ត្រឹមត្រូវ " ។ របៀបនេះគេហៅថា សំណួរដឹកនាំ ហើយអ្នកជំងឺអាចឆ្លើយតាមវិធីមួយចំនួន ពីព្រោះគេចង់យល់ស្របជាមួយគំនិតរបស់អ្នក ។ ជួនកាលវាជាការលំបាកណាស់ក្នុងការជៀសវាងប្រើសំនួរដឹកនាំ ប៉ុន្តែប្រសិនបើមានលទ្ធភាពអ្នកគួរតែអោយអ្នកជំងឺបញ្ចេញគំនិតចំលើយផ្ទាល់ខ្លួនរបស់គាត់ ។ ការប្រើពាក្យនៃសំណួរ គួរតែជៀសវាងឱ្យបាននូវការវិនិច្ឆ័យមិនសមរម្យ ។ ប្រសិនបើអ្នកជំងឺកាមរោគគិតថា អ្នកកំពុងតែវិនិច្ឆ័យគេនោះ គេនឹងពុំសូវឆ្លើយនឹងសំណួររបស់អ្នកទេ ហើយអ្នកនឹងពុំអាចប្រមូលបាននូវពត៌មានចាំបាច់ដើម្បីព្យាបាលគេ និងដៃគូ

របស់គេអោយជាសះស្បើយបានទេ ។ ការអប់រំឱ្យផ្លាស់ប្តូរការប្រព្រឹត្តក៏អាចជួបការលំបាកដែរ ។

ទីបញ្ចប់ ជានិច្ចកាលអ្នកគួរតែសុំការអនុញ្ញាតពីអ្នកជំងឺដើម្បីជជែកពីប្រធានបទដែលប៉ះពាល់ដល់ទឹកចិត្តអ្នកជំងឺ ។ ការសាកសួរ សំណួរទាក់ទងប្រវត្តិជំងឺកាមរោគ ឬ ក៏អំពីការប្រព្រឹត្តផ្លូវភេទអាចជួបប្រទះនឹងការលំបាក ។ ការបញ្ចូលសំណួរប្រភេទនេះ ដោយសុំការអនុញ្ញាតជាមុននឹងជួយធ្វើអោយអ្នកជំងឺទុកចិត្តអ្នកចំពោះការប្រាប់ពត៌មានផ្ទាល់ខ្លួនទាំងនេះ ។

## ការសួរសំណួរបើក និងសំណួរបិទ

| សំណួរបើក និង សំណួរបិទ |
|---|
| • សំណួរបើក - អ្នកជំងឺត្រូវសុំអោយផ្តល់ចំលើយក្នុងលក្ខណ:ពិពណ៌នារួមបញ្ចូលទាំងពត៌មានដែលគាត់ចង់បន្ថែមផង ។<br>ឧទាហរណ៍ :<br>" *តើអ្នកមានបញ្ហាអ្វីដែលមិនស្រួល ?*"<br>" *តើនៅពេលនេះអ្នកកំពុងប្រើថ្នាំអ្វីខ្លះ ?*"<br><br>• សំណួរបិទ - អ្នកជំងឺត្រូវសុំឱ្យឆ្លើយតបដោយប្រើពាក្យមួយ ម៉ាត់ ឬ ឃ្លាមួយយ៉ាងខ្លីជារឿយៗគឺ "*បាទ/ ចាស់* ឬទេ"។<br>ឧទាហរណ៍ :<br>" *តើការហើមនេះឈឺដែរឬទេ ?*"<br>" *តើអ្នកក្រមករដូវមែនដែរឬទេ ?*"<br>" *តើអ្នកអាយុប៉ុន្មាន ?*" |

ការស្រង់យកប្រវត្តិជំងឺ និង ប្រវត្តិផ្លូវភេទរបស់អ្នកជំងឺណាម្នាក់មានន័យថា អ្នកត្រូវប្រមូលយកនូវពត៌មានត្រឹមត្រូវក្នុងរយ:ពេលដ៏ខ្លីមួយ ។ មានវិធីពីរយ៉ាងដែលអ្នកអាចយកមកប្រើប្រាស់គឺសួរសំណួរបើក និងសំណួរបិទ ។ សំណួរបើកអនុញ្ញាតអោយអ្នកជំងឺពន្យល់អំពីបញ្ហា ឬអំពីអារម្មណ៍របស់គាត់ដោយសំដីរបស់គាត់ផ្ទាល់ និងប្រាប់អ្នកនូវរាល់អ្វីៗទាំងអស់ ដែលគេយល់ថាមានសារ:សំខាន់ ។ ក៏ប៉ុន្តែសំណួរបិទសួរអ្នកជំងឺ នូវសំណួរច្បាស់លាស់ជាក់លាក់ជាងមុនដែលតំរូវអោយឆ្លើយខ្លីៗ ជារឿយៗគឺ " បាទ/ *ចាស់* " ឬ " ទេ " ដោយពឹងផ្អែកលើពាក្យសំដី ឬ/និងគំនិតដែលអ្នកផ្តល់សេវាថែទាំជ្រើសរើសយកមកប្រើប្រាស់ ។

## ការសំភាសន៍ដែលប្រើប្រាស់សំណួរបិទ

<u>អ្នកជំងឺ</u> : ខ្ញុំមានការឈឺចាប់នៅនឹងពោះរបស់ខ្ញុំ ។

<u>អ្នកផ្តល់សេវាថែទាំ</u> : *ខ្ញុំសោកស្តាយណាស់ដោយដឹងបញ្ហានេះ ។*

*តើការឈឺចាប់នោះស្ថិតនៅកន្លែងណា ?*

<u>អ្នកជំងឺ</u> : នៅទីកន្លែងនេះនែ ។

<u>អ្នកផ្តល់សេវាថែទាំ</u> : *តើវាឈឺជាប់ជានិច្ចមែនដែរឬទេ ?*

<u>អ្នកជំងឺ</u> : ទេ ។

<u>អ្នកផ្តល់សេវាថែទាំ</u> : *តើស្ទាបទៅឈឺដែរឬទេ ?*

<u>អ្នកជំងឺ</u> : ចាស៎ ឈឺ ។

<u>អ្នកផ្តល់សេវាថែទាំ</u> : *តើការឈឺចាប់នេះមានតាំងពីពេលណាមក ?*

<u>អ្នកជំងឺ</u> : តាំងពីអាទិត្យកន្លងទៅ ។

## ការសំភាសន៍ដដែលនេះដោយប្រើសំនួរបើក

<u>អ្នកជំងឺ</u> : ខ្ញុំមានការឈឺចុកចាប់នៅនឹងពោះរបស់ខ្ញុំ ។

<u>អ្នកផ្តល់សេវាថែទាំ</u> : *ខ្ញុំសោកស្តាយណាស់ដោយដឹងអំពីបញ្ហានេះ។*

*សូមអ្នកប្រាប់ខ្ញុំអំពីការឈឺចាប់នេះផងមកមើល ។*

<u>អ្នកជំងឺ</u> : ចាស៎ , វាមានចាប់តាំងពីមួយសប្តាហ៍កន្លងទៅម្លេះ ។ ដំបូងខ្ញុំគ្រាន់តែមានអារម្មណ៍ថាឈឺនៅកន្លែងនេះពេលស្ទាបវា ក៏ប៉ុន្តែពេលខ្លះវាក៏ចាប់ផ្តើមឈឺខ្លាំងឡើងៗ ។ វាឈឺនៅពេលដែលខ្ញុំអង្គុយចុះ ឬងើបឈរ ។ វាមិនដូចជាការឈឺចាប់ដែលខ្ញុំតែងតែមានជារៀងរាល់ខែទេ ។

<u>អ្នកផ្តល់សេវាថែទាំ</u> : *តើមានបញ្ហាអ្វីខ្លះទៀតដែលរំខានដល់អ្នក ?*

<u>អ្នកជំងឺ</u> : ចាស៎ , មានបញ្ហាមួយទៀត ។ ការហូរទឹកសើមៗ ដែលខ្ញុំពុំធ្លាប់មានទេ ។ វាពុំឈឺទេ ក៏ប៉ុន្តែវារំខានណាស់ ។

<u>អ្នកផ្តល់សេវាថែទាំ</u> : *តើរដូវអ្នកមកយ៉ាងម៉េចដែរ ?*

<u>អ្នកជំងឺ</u> : ចាស៎ ! ខ្ញុំយល់ថា វាមកទៀងទាត់ទេ ហើយវាធ្វើអោយខ្ញុំឈឺចាប់បន្តិចបន្តួច ។ ក៏ប៉ុន្តែ ការឈឺនោះពេលនេះខុសពីមុន ។

នៅក្នុងឧទាហរណ៍ទីពីរ អ្នកផ្តល់សេវាថែទាំប្រមូលយកពត៌មានបានច្រើនជាងដោយប្រើប្រាស់នូវសំណួរបើក ។ អ្នកជំនាញការខាងសំភាសន៍អ្នកជំងឺកាមរោគ ក៏បានផ្តល់យោបល់ឱ្យអ្នកផ្តល់សេវាថែទាំអាចសួរថា *"តើមានអ្វីផ្សេងទៀតទេ?"* ឱ្យបានច្រើនផង ។ នេះគឺមកពីអ្នកជំងឺខ្លះ មានការអៀនខ្មាសពេក ជាហេតុធ្វើឱ្យគាត់ពិពណ៌នា អំពីរោគសញ្ញាដទៃៗទៀត ដែលពុំទាក់ទងនឹង កាមរោគដូចជា ឈឺក្បាលជាដើមមុននឹងមានអារម្មណ៍ស្រួលដើម្បីពិពណ៌នាអំពីរោគសញ្ញាដែល ទាក់ទងនឹងកាមរោគ ។

ការផ្តល់ឳកាសអោយអ្នកទាំងនោះ ពិពណ៌នាអំពីការត្អូញត្អែរប្លែកៗរបស់ខ្លួនជារឿយៗអាចបង្ហាញអោយយើងដឹងអំពីពត៌មានដែលមានសារៈប្រយោជន៍ ។

**ការប្រមូលពត៌មានក្នុងពេលស្រង់យកប្រវត្តិអ្នកជំងឺ**

ពេលចាប់ផ្តើមស្រង់ប្រវត្តិអ្នកជំងឺ ចុងបញ្ចប់នៃការស្រង់ប្រវត្តិអ្នកជំងឺ




សំណួរបើក សំណួរបិទ

តើអ្នកអាចប្រើប្រាស់នូវសំណួរទាំងពីរប្រភេទនេះដោយរបៀបណា ? ជារឿយៗ អ្នកជំងឺមានការរំខានចិត្តក្នុងការប្រាប់ឱ្យដឹងនូវពត៌មានអំពីសកម្មភាពផ្លូវភេទ (sexuality) ផ្ទាល់ខ្លួនរបស់គាត់ ដូច្នេះសំណួរបើកអាចមានសារៈប្រយោជន៍នៅពេលចាប់ផ្តើមដើម្បីជួយអ្នកជំងឺអោយមានអារម្មណ៍ស្រួលក្នុងចិត្តជាងមុន ។ ជាទូទៅ អ្នកនឹងប្រមូលយកបាននូវពត៌មានដោយប្រើសំនួរបើកបានច្រើនជាងប្រើសំណួរបិទ ហើយការភ្លេចយកពត៌មានសំខាន់ៗក៏អាចកើតឡើងផងដែរ ប្រសិនបើអ្នកឆាប់ប្រើសំណួរបិទនៅពេលចាប់ផ្តើមធ្វើសំភាសន៍អ្នកជំងឺពេក ។ នៅពេលដែលអ្នកបានប្រើប្រាស់នូវសំណួរបើកដើម្បីស្វែងយល់អំពីបញ្ហារបស់អ្នកជំងឺដូចដែលគាត់យល់ឃើញ ដូច្នេះហើយសំណួរបិទអាចមានប្រយោជន៍ក្នុងការស្រង់យកពត៌មានលំអិតនានាដែលអ្នកត្រូវការដឹងនោះ ។

## ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដោយមិនប្រើពាក្យពេចន៍
(non-verbal skills)

ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដោយមិនប្រើពាក្យពេចន៍ រួមមានអាកប្បកិរិយារបស់អ្នកចំពោះអ្នកជំងឺនិងទីតាំងដែលអ្នកធ្វើសំភាសន៍ធៀបទៅនឹងអ្នកជំងឺនោះ ។

**ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដែលមិនប្រើពាក្យពេចន៍**

- សូមរកទីកន្លែងស្ងាត់កំបាំងសំរាប់អ្នកជំងឺ
- សូមស្តាប់ដោយយកចិត្តទុកដាក់នូវអ្វីដែលអ្នកជំងឺ និយាយ
- សូមអង្គុយ ប្រសិនបើអ្នកជំងឺអង្គុយហើយសូមចាប់អារម្មណ៍លើចំងាយដែលអ្នកស្ថិតនៅជិតអ្នកជំងឺ ។

### សូមរកទីកន្លែងស្ងាត់កំបាំង (privacy) និង រក្សាការសំងាត់អោយអ្នកជំងឺ

គន្លឹះនៃការប្រាស្រ័យទាក់ទង ដោយមិនប្រើពាក្យពេចន៍ដែលមានប្រសិទ្ធិភាពនោះ គឺត្រូវសំដែងការគោរពចំពោះអ្នកជំងឺ ។ មធ្យោបាយដ៏សំខាន់មួយក្នុងចំណោមមធ្យោយទាំងឡាយ គឺធ្វើឡើងដោយផ្តល់នូវទីកន្លែងស្ងាត់កំបាំង និងរក្សាការសំងាត់អោយគាត់ ។ នេះមានន័យថា អ្នកត្រូវរៀបចំឱ្យមានកន្លែងស្ងាត់សំរាប់ធ្វើសំភាសន៍ កន្លែងណាដែលគ្មានការរំខានដល់អ្នក ។ គេពុំអាចសំភាសន៍អ្នកជំងឺនៅការិយាល័យបានទេ ការប្រើប្រាស់នូវរបាំងដែលមានតំលៃថោក ដូចជា ឡប់ឡែ ឬរាំងនន អាចជួយអ្នកបាន ។ អ្នកក៏អាច ខិតខំធ្វើការនិយាយតិចៗ នៅពេលអ្នកសំភាសន៍អ្នកជំងឺក៏បាន ។




## ការស្តាប់អ្នកជំងឺដោយយកចិត្តទុកដាក់

អ្នកជំងឺឆ្លើយបានកាន់តែច្រើននៅពេលដែលអ្នកផ្តល់សេវាថែទាំ បង្ហាញថាខ្លួនកំពុងស្តាប់អ្នកជំងឺនោះ ។ ចំពោះទំនៀមទំលាប់ជាច្រើនអ្នកអាចបង្ហាញអំពីការយកចិត្តទុកដាក់របស់អ្នកលើអ្វីដែលអ្នកជំងឺកំពុងនិយាយដោយឱនខ្លួនទៅមុខបន្តិចទៅអ្នកជំងឺ ។ អ្នកក៏អាចងក់ក្បាល ឬ ក៏និយាយម្តងម្កាលដែរដើម្បីលើកទឹកចិត្តគាត់ ។ សូមកុំដើរចុះឡើង សរសេរ ឬក៏កាត់សំដីរបស់អ្នកជំងឺនៅពេលដែលអ្នកជំងឺកំពុងនិយាយ ។

## ឥរិយាបថ (posture) ដែលត្រូវប្រកាន់

ការប្រកាន់ឥរិយាបថឱ្យត្រូវគ្នានឹងឥរិយាបថរបស់អ្នកជំងឺ ក៏អាចមានសារៈសំខាន់ផងដែរ (សូមអង្គុយប្រសិនបើអ្នកជំងឺអង្គុយហើយឈរនៅពេលដែលអ្នកជំងឺនោះឈរ) ។ អ្នកគប្បីគិតអំពីចំងាយដែលអ្នកអាចស្ថិតនៅជិតអ្នកជំងឺ ដោយគិតអំពីភាពស្និទ្ធស្នាល (privacy) របស់គាត់ជាមួយអ្នកផងដែរ ។ អ្នកគប្បីស្ថិតនៅឱ្យបានជិតអ្នកជំងឺទៅតាមលទ្ធភាពដែលប្រពៃណីទំនៀមទំលាប់អនុញ្ញាត ។ យកល្អជាងនេះអ្នកផ្តល់សេវាថែទាំត្រូវស្ថិតក្បែរតុ ចៀសវាងនៅខាងក្រោយតុទល់មុខអ្នកជំងឺ ។ ចំណុចទាំងនេះងាយស្រួលធ្វើទេ ក៏ប៉ុន្តែវាអាចឱ្យមានភាពខុសគ្នាយ៉ាងច្រើនក្នុងការទទួលបាន ឬ បាត់បង់ជំនឿទុកចិត្តពីសំណាក់អ្នកជំងឺ ។

## ភាពស្ទាត់ជំនាញក្នុងការប្រើពាក្យពេចន៍ផ្សេងៗទៀត

### ភាពស្ទាត់ជំនាញទាំង ៦ សំរាប់ធ្វើការប្រាស្រ័យទាក់ទងដោយប្រើពាក្យពេចន៍ប្រកបដោយប្រសិទ្ធិភាព

- ការជួយសំរួល
- ការតំរង់ទិស (direction)
- ការសង្ខេប និងផ្ទៀងផ្ទាត់ (summarising and cheking)
- ការសំដែងការយល់អារម្មណ៍ (Empathizing)
- ការធានាអះអាង (Reassuring)
- ការបង្ហាញភាពជាដៃគូ (Expressing partnership)

ជាបន្ថែមទៅលើការសាកសួរ ដែលប្រកាន់នូវការប្រព្រឹត្តមិនប្រើពាក្យពេចន៍ក្នុងលក្ខណៈវិជ្ជមាន (positive non-verbal behavior) សមស្របនិងមានការគោរព មានភាពស្ទាត់ជំនាញផ្សេងៗបន្ថែមទៀតដែលអាចមានសារៈប្រយោជន៍ក្រៃលែងនៅពេលសំភាសន៍អ្នកជំងឺកាមរោគ ។ វាអាចជួយអ្នកអោយជួយដោះស្រាយអារម្មណ៍ (emotion) រំភើបរបស់អ្នកជំងឺព្រមទាំងអាចប្រមូលយក នូវពត៌មានបានប្រកបដោយប្រសិទ្ធភាព ។ ការជួយសំរួល (facilitating) មានន័យថា ការប្រើពាក្យសំដី ឬ កាយវិការនានាដើម្បីលើកទឹកចិត្តអ្នកជំងឺឱ្យនិយាយបន្តទៀត ។ ការជួយសំរួលដែលមិនប្រើពាក្យពេចន៍ រួមមានការងក់ក្បាល និង ការធ្វើចិញ្ចើមអោយខ្ពស់នៅពេលអ្នកជំងឺនិយាយ ។ អ្នកផ្តល់សេវាថែទាំអាចប្រើផងដែរនូវពាក្យ-ឃ្លា ឬសំលេងផ្សេងៗទៀតដើម្បីលើកទឹកចិត្តអ្នកជំងឺឱ្យនិយាយបន្តទៅទៀត ។

### ការជួយសំរួលដល់ការនិយាយ

<u>អ្នកជំងឺ</u> : ខ្ញុំដូចជាមិនច្បាស់ក្នុងចិត្តទេ... វាហាក់ដូចជាពិបាកនិយាយដល់ហើយ

<u>អ្នកផ្តល់សេវាថែទាំ</u> : *ល្អណាស់ ! ខ្ញុំចាំស្តាប់ !*

<u>អ្នកជំងឺ</u> : បាទ ! គឺវាអញ្ចេះ......

<u>អ្នកផ្តល់សេវាថែទាំ</u> : *អ្នកថាម៉េច ?*

<u>អ្នកជំងឺ</u> : មានដំបៅមួយ......

ការតំរង់ទិស (directing) ជួយអោយអ្នកបង្ហាញនូវគំនិត និងផ្តល់ពត៌មានមួយម្តងៗ ។ វាគឺជាវិធីដ៏មានប្រយោជន៍ នៅពេលដែលអ្នកជំងឺណាម្នាក់មានភាពច្របូកច្របល់ ហើយមិនដឹងជាចាប់ផ្តើមនិយាយពីចំណុចណាមុន ឬ នៅពេលដែលគាត់និយាយលឿនហើយប្រាប់បញ្ហាដែលខ្លួនភ័យបារម្ភច្របល់ចូលគ្នា ។ ការតំរង់ទិស ក៏ជាមធ្យោបាយដ៏ល្អមួយដែលអនុញ្ញាតអោយអ្នកជំងឺប្រាប់អំពីកង្វល់ និងការព្រួយបារម្ភបានកាន់តែងាយ ។

**ការតំរង់ទិស**

<u>អ្នកជំងឺ</u> : ខ្ញុំមិនដឹងទេ ! វាកើតនៅកន្លែងនេះតាំងពី ៣ អាទិត្យ មកហើយ ។ តើឱ្យខ្ញុំនិយាយប្រាប់ប្តីខ្ញុំយ៉ាងម៉េចទៅ ? តើមានអ្នកណាដឹងទេ ? ខ្ញុំចង់ដឹងថាវាអាចព្យាបាលជាសះស្បើយដែរឬទេ ?

<u>អ្នកផ្តល់សេវាថែទាំ</u> : *យើងរកឱ្យឃើញបញ្ហាជាមុនសិនទើបយើងអាចដោះស្រាយវា ។ បន្ទាប់មកយើងអាចនិយាយអំពីបញ្ហាប្តីរបស់អ្នក ។*

ការសង្ខេប និងការផ្ទៀងផ្ទាត់អនុញ្ញាតអោយអ្នកផ្ទៀងផ្ទាត់មើលថា តើអ្នកបានយល់អ្នកជំងឺបានត្រឹមត្រូវដែរឬទេ ? ដើម្បីធ្វើបែបនេះ អ្នកត្រូវលើកយកអ្វីដែលអ្នកជំងឺបាននិយាយ មកនិយាយឡើងវិញដោយប្រើពាក្យពេចន៍របស់អ្នកផ្ទាល់ (paraphrase) ហើយសួរគាត់ថា ការនិយាយសង្ខេបរបស់អ្នកពិតជាត្រឹមត្រូវដែរឬទេ ។ សូមប្រើប្រាស់ភាពស្ទាត់ជំនាញនេះ នៅពេលដែលអ្នកជំងឺបាននិយាយប្រាប់អំពីបញ្ហាមួយចំនួនដែលអ្នកចង់បញ្ជាក់ឱ្យបានកាន់តែច្បាស់ ។

**ការសង្ខេប និង ការផ្ទៀងផ្ទាត់**

<u>អ្នកផ្តល់សេវាថែទាំ</u> : (សង្ខេប) ដូច្នេះអ្នកកំពុងខ្វល់អំពីអ្វីដែលត្រូវនិយាយប្រាប់ប្តីរបស់អ្នក ហើយអ្នកមានអារម្មណ៍អៀនខ្មាសដោយសារកើតជំងឺនេះណាស់ ។ អ្នកចង់ដឹងថាតើយើងអាច ព្យាបាលវាជាសះស្បើយដែរឬទេ ។
(ផ្ទៀងផ្ទាត់) តើនិយាយនេះ ត្រឹមត្រូវដែរឬទេ ?

<u>អ្នកជំងឺ</u> : ត្រូវហើយ តើខ្ញុំមានបញ្ហាអ្វី ?

ការបង្ហាញអំពីការយល់អារម្មណ៍ដោយប្រើពាក្យសំលេង ឬ កាយវិការដែលបង្ហាញថា អ្នកយល់អារម្មណ៍អ្នកជំងឺប្រហែលជាភាពស្ទាត់ជំនាញសំខាន់ជាងគេបំផុត នៅពេលដែលអ្នកប្រឈមមុខនឹងអារម្មណ៍របស់អ្នកជំងឺ ។ ឧទាហរណ៍ : ប្រសិនបើអ្នកកត់សំគាល់ឃើញថា អ្នកជំងឺណា

ម្នាក់មានអារម្មណ៍តានតឹង ឬ ខ្វល់ខ្វាយអ្នកអាចសំដែងនូវការយល់អារម្មណ៍របស់អ្នកដោយរៀបរាប់ប្រាប់អំពីអ្វីដែលអ្នកបានកត់សំគាល់ឃើញនោះ ។ ដោយសារ ការបង្ហាញអំពីការយល់អារម្មណ៍អ្នកអាចជួយឱ្យអ្នកជំងឺសំដែងនូវការភ័យខ្លាចរបស់ខ្លួន និង ធ្វើឱ្យការប្រាស្រ័យទាក់ទងកាន់តែមានលក្ខណៈស្និទ្ធស្នាលរវាងអ្នក និងអ្នកជំងឺ ។ ក៏ដូចជាការជួយសំរួលផងដែរវាក៏ជួយលើកទឹកចិត្តឱ្យអ្នកជំងឺនិយាយបន្តទៀតដែរ ។

| ការសំដែងការយល់អារម្មណ៍ |
| --- |
| អ្នកផ្តល់សេវាថែទាំ : ខ្ញុំអាចឃើញហើយថា អ្នកកំពុងតែមានការបារម្ភខ្លាំងណាស់ ។ |
| អ្នកជំងឺ : ចាស៎ ភាំខានខ្ញុំជាងមួយអាទិត្យហើយមកទល់នឹងពេលនេះ ។ ខ្ញុំបារម្ភតែខ្ញុំឈឺទេ ! |

ការធានាអះអាង (reassurance) គឺ ជាមធ្យោបាយដ៏មានសារៈប្រយោជន៍សំរាប់បង្ហាញអោយឃើញថា អ្នកយល់ព្រមទទួលយកនូវអារម្មណ៍របស់អ្នកជំងឺហើយបញ្ហានេះមិនមែនមាននៅដូច្នេះជារៀងរហូតទេ ។ អ្នកប្រើពាក្យពេចន៍ សំលេង ឬ កាយវិការ ដើម្បីបង្ហាញឱ្យឃើញអាចដោះស្រាយបញ្ហាបារម្ភរបស់អ្នកជំងឺបាន ។

| ការធានាអះអាង | |
| --- | --- |
| អ្នកផ្តល់សេវាថែទាំ | : ខ្ញុំអាចយល់បានថា អ្នកមានអារម្មណ៍ខ្វល់ខ្វាយអំពីរោគសញ្ញាបែបនេះ ។ នៅពេលដែលយើងរកឃើញនូវបញ្ហាភ្លាម យើងអាចខិតខំប្រឹងប្រែងចាប់ផ្តើមធ្វើការព្យាបាលឱ្យអ្នកបានធូរស្រាលជាងពេលនេះបាន ។ |
| អ្នកជំងឺ | : ល្អណាស់អញ្ចឹង ។ ដូច្នេះតើអ្នកគ្រូពេទ្យ ចង់ដឹងអំពីបញ្ហាអ្វីទៀតឬទេ ? |

ការបង្ហាញភាពជាដៃគូ (partnership) បញ្ជាក់ច្បាស់អំពីការប្តេជ្ញាចិត្តចូលរួមជួយអ្នកជំងឺ ។ ការប្តេជ្ញានេះ អាចធ្វើឡើងដោយអ្នកផ្តល់សេវាថែទាំផ្ទាល់ដូចមានបង្ហាញនៅក្នុងឧទាហរណ៍ខាងក្រោមនេះ ឬដោយក្រុមបុគ្គលិកដែលបំរើការងារនៅតាមមណ្ឌលសុខភាព។

**ការបង្ហាញភាពជាដៃគូ**

អ្នកផ្តល់សេវាថែទាំ : ការដែលអ្នកមកទទួលការព្យាបាលនៅទីនេះជាការត្រឹមត្រូវហើយ។មុននឹងអ្នកចាកចេញពីទីនេះខ្ញុំចង់បញ្ជាក់អោយបានច្បាស់លាស់ អ្នកទទួលបាននូវពត៌មានទាំងអស់ដែលអ្នកត្រូវការដើម្បីបង្ការការឆ្លងជំងឺជាបន្តទៅទៀត ។ ហើយយើងនឹងពិភាក្សារកមធ្យោបាយដ៏ល្អបំផុតសំរាប់ឱ្យអ្នកយកទៅពិភាក្សាជាមួយប្តីអ្នក ។

អ្នកជំងឺ : ចាស៎ សូមអរគុណ ! ខ្ញុំមិនចង់ឱ្យបញ្ហានេះកើតមាន ម្តងទៀតទេ ។

ពេលខ្លះអ្នកផ្តល់សេវាថែទាំដែលមានបទពិសោធន៍ ភាគច្រើនប្រើប្រាស់នូវភាពស្ទាត់ជំនាញណាមួយ ឬ លើសពីនេះក្នុងចំណោមភាពស្ទាត់ជំនាញទាំងនេះ ។ ចំណុចគន្លឹះក្នុងការសំភាសន៍អ្នកជំងឺដែលអាចកើតកាមរោគគឺត្រូវប្រើប្រាស់នូវភាពស្ទាត់ជំនាញទាំង ៦ ស្ទើរតែគ្រប់ពេលទាំងអស់ ។ សំណួរ ៣.៥ នឹងជួយឱ្យអ្នកមាន ទំលាប់ប្រើនូវភាពស្ទាត់ជំនាញនិមួយៗទាំងនេះ ។

## ការប្រមូលពត៌មានស្តីអំពីកាមរោគ

ការបង្កើនសមត្ថភាពរបស់អ្នកក្នុងការប្រមូលយកពត៌មាន ស្តីអំពីប្រវត្តិរបស់អ្នកជំងឺមានសារៈប្រយោជន៍ណាស់ពីព្រោះ

- វាជួយអោយអ្នកធ្វើរោគវិនិច្ឆ័យកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាបានត្រឹមត្រូវ និងមានប្រសិទ្ធិភាព (efficient) យោលទៅតាមពេលវេលាដែលមាន ។
- ពត៌មានទាំងនេះក៏ជាចំណុចចាប់ផ្តើមសំរាប់ការបញ្ជូន និង ព្យាបាលដៃគូរួមភេទផងដែរ និង សំរាប់ការស្វែងយល់អំពីការប្រឈមមុខនឹងគ្រោះថ្នាក់របស់អ្នកជំងឺក្នុងការចំលង ឬ ឆ្លងកាមរោគនាអនាគត ។

## ពត៌មានដែលអ្នកត្រូវការ

- ពត៌មានលំអិតទូទៅស្តីអំពីអ្នកជំងឺ
- ការពិពណ៌នាអំពីជំងឺបច្ចុប្បន្ន
- ប្រវត្តិជំងឺ (medical history)
- ប្រវត្តិនៃសកម្មភាពផ្លូវភេទ (sexual history)

នៅក្នុងផ្នែកនេះ យើងពិភាក្សាអំពីប្រភេទនៃពត៌មានដែលអ្នកត្រូវការប្រមូលយកជាផ្នែកមួយនៃការស្រង់ប្រវត្តិអ្នកជំងឺ។ យើងសង្ឃឹមថា អ្នកនឹងប្រើប្រាស់នូវភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដែលមាននៅក្នុងផ្នែកមុននៅពេលដែលអ្នកប្រមូលយកពត៌មានទាំងនេះ ។ យើងមានបំណងចង់បង្ហាញឱ្យឃើញថា ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងនេះមានសារៈសំខាន់ជាចាំបាច់សំរាប់ការស្រង់យកប្រវត្តិអ្នកជំងឺ ។ អ្នកអាចប្រើការណែនាំខាងក្រោមនេះដើម្បីចងចាំនូវប្រភេទសំណួរដែលត្រូវសួរសំរាប់បញ្ហានីមួយៗ(topic)។ មូលហេតុដែលនាំឱ្យមានការសាកសួរនូវសំណួរទាំងនេះ នឹងកាន់តែច្បាស់ក្រោយពេលដែលអ្នកបានសិក្សាជំពូកទី៤ ដែលពិពណ៌នាលំអិតអំពីគំនូសបំព្រួញសំរាប់ចង្កោមរោគសញ្ញា ។ ជាឧទាហរណ៍ បញ្ជីសំណួរសំរាប់វាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់ដែលណែនាំឱ្យសួរមានបញ្ចូលនៅក្នុងជំពូកនេះ ។ ការណែនាំស្តីពីការស្រង់ប្រវត្តិអ្នកជំងឺអាចយកទៅកែតម្រូវដើម្បីបញ្ចូលពត៌មានផ្សេងៗទៀត ដែលពិចារណាថាមានសារៈសំខាន់ ។ ជាឧទាហរណ៍ នៅកន្លែងខ្លះការដឹងថាអ្នកជំងឺបុរសម្នាក់មានកាត់ស្បែកគ្របក្បាលលិង្គចេញ ឬ ចំនួនមានគភ៌ដែលស្ត្រីមានដើម្បីដឹងអំពីការរលូត ឬពន្លូតកូនអាចជាបញ្ហាសំខាន់ដែលត្រូវដឹងផងដែរ ។

## ការណែនាំស្ដីពីការស្រង់ប្រវត្តិអ្នកជំងឺ

ពត៌មានលំអិតទូទៅ :

- អាយុ
- អាស័យដ្ឋាន
- ករិតវប្បធម៌
- មុខរបរ
- ចំនួនកូន
- ចំនួនដងនៃការមានផ្ទៃពោះ

ជំងឺបច្ចុប្បន្ន :

ការត្អូញត្អែរអំពីបញ្ហាបច្ចុប្បន្ន និងរយៈពេលដែលមានបញ្ហា

*ចំពោះបុរសៈ*

- ប្រសិនបើមានការហូរខ្ទុះតាមបង្ហូរនោមតើមានការឈឺចាប់ពេលនោមឬទេ ? តើមាននោមញឹកញាប់ដែរឬទេ ?
- ប្រសិនបើមានការហើមពងស្វាស តើធ្លាប់មានប្រវត្តិការប៉ះទង្គិចដែរឬទេ ?

*ចំពោះស្រ្តីៈ*

- ប្រសិនបើធ្លាក់ស តើមានការឈឺចាប់ពេលនោមដែរឬទេ ? តើមាននោមញឹកញាប់ដែរឬទេ ?
  ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់វិជ្ជមាន (សូមអានកំណត់សំគាល់ខាងក្រោមនេះ) ដែរឬទេ ?
- ប្រសិនបើមានការឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ តើមានហូរឈាម ឬហូរខ្ទុះតាមទ្វារមាសឬទេ ? តើការសំរាលកូនមានការពិបាកដែរឬទេ ? តើរដូវមកមិនទៀង ហើយមានការឈឺចាប់ដែរឬទេ ? តើមានបាត់ ឬក៏ក្រមករដូវដែរឬទេ ?

*ចំពោះបុរស និងស្ត្រីៈ*

- ប្រសិនបើមានដំបៅលើប្រដាប់បន្តពូជ តើដំបៅនោះឈឺដែរឬទេ ?មានកើតសាចុះសាឡើងដែរឬទេ ? មានសណ្ឋានដូចម្តេចដែរ ? ចាប់ផ្តើមមានដោយឯកឯងដែរឬទេ ? រោគសញ្ញាដទៃៗទៀតដូចជារមាស់ ឬពិបាកទ្រាំក្នុងខ្លួន ? មានហើមកូនកណ្តុរនៅក្រលៀន ?
- មានដុះសាច់នៅលើប្រដាប់បន្តពូជ ? មានសណ្ឋានដូចម្តេចដែរ ? ចាប់ផ្តើមមានដោយឯកឯងដែរឬទេ ?

<u>ប្រវត្តិជំងឺ</u> (medical history)

- តើធ្លាប់កើតកាមរោគដែរឬទេ ? ប្រភេទអ្វី ? នៅពេលណា ? តើមានបានទទួលការព្យាបាលដែរឬទេ ? ហើយការឆ្លើយតបនឹងការព្យាបាលយ៉ាងដូចម្តេច ? តើមានលទ្ធផលនៃការធ្វើតេស្តមុនៗ ណាខ្លះដែរឬទេ ?
- ជំងឺផ្សេងៗទៀត ប្រភេទអ្វី ? កាលបរិច្ឆេទ ? មានបានទទួលការព្យាបាលដែរឬទេ ហើយការឆ្លើយតបនឹងការព្យាបាលយ៉ាងដូចម្តេចដែរ តើមានលទ្ធផលនៃការធ្វើតេស្តដែរឬទេ ?
- ការប្រើប្រាស់ឱសថ
- ភាពមិនទទួលនឹងថ្នាំ (drug allergies)

<u>ប្រវត្តិផ្លូវភេទ</u> (sexual history)

- តើសព្វថ្ងៃកំពុងមានសកម្មភាពផ្លូវភេទដែរឬទេ ?
- តើធ្លាប់មានដៃគូថ្មីក្នុងរយៈពេលបីខែកន្លងទៅដែរឬទេ ?

ការវាយតំលៃចំពោះការប្រឈមមុខនឹងគ្រោះថ្នាក់ (សូមអានកំណត់សំគាល់ខាងក្រោម)

<u>កំណត់សំគាល់</u> : ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់ គឺជាសំណុំនៃសំណួរដែលត្រូវសួរអ្នកជំងឺដែលត្អូញត្អែរថាមានធ្លាក់ស ។ វាត្រូវបានបញ្ចូលទៅក្នុងគំនូសបំព្រួញដើម្បីជួយឱ្យអ្នកផ្តល់សេវាថែទាំធ្វើការសំរេចចិត្តអំពីទីកន្លែងដែលកើតជំងឺ ។ ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់នឹងត្រូវលើក យកមកពិភាក្សាឱ្យបានកាន់តែលំអិតថែមទៀតនៅជំពូកទី ៤ ។

**វិធីសួរសំណួរ ៖**

បន្ទាប់មកអ្នកត្រូវពិចារណាលើវិធីដែលអ្នកត្រូវសួរសំណួរ ដើម្បីប្រមូលយកនូវពត៌មានទាំងនេះ ។ ការបំលែងពត៌មាននៅទំព័រមុខនេះទៅជាសំណួរបិទជាការងាយ ក៏ប៉ុន្តែនោះមានន័យថាអ្នកត្រូវសួរសំណួរជាច្រើនដូចបង្ហាញនៅក្នុងការសិក្សាករណីខាងក្រោមនេះ ។ ម្យ៉ាងវិញទៀត ការសិក្សាករណីដដែលនេះ ក៏មានបញ្ចូលផងដែរនូវឧទាហរណ៍អំពីរបៀបដែលសួរសំណួរបើកមួយ ឬ ពីរ ដែលអាចជួយលើកទឹកចិត្តអ្នកជំងឺឱ្យផ្តល់ពត៌មានច្រើនបំផុត តាមដែលអ្នកត្រូវការ ។

**អ្នកស្រង់ប្រវត្តិផ្លូវភេទ**

*អ្នកផ្តល់សេវាថែទាំ* ៖ ពេលនេះខ្ញុំត្រូវការសួរអ្នកអំពីបញ្ហាផ្ទាល់ខ្លួនមួយចំនួន ដែលទាក់ទងទៅនឹងសកម្មភាពផ្លូវភេទរបស់អ្នក ។ ខ្ញុំដឹងថានេះជាការលំបាកនឹងយកមកនិយាយណាស់ ក៏ប៉ុន្តែខ្ញុំសូមធានាអះអាងថានឹងពុំមានអ្នកណាម្នាក់អាចដឹងរឿងនេះទេ។

*អ្នកជំងឺ* ៖ ហេតុអ្វីបានជាអ្នកត្រូវចង់ដឹងអំពីពត៌មានស្តីពីសកម្មភាពផ្លូវភេទរបស់ខ្ញុំ?

*អ្នកផ្តល់សេវាថែទាំ* ៖ នេះគឺជាសំណួរល្អណាស់ ។ វាចូលរួមចំណែកជួយឱ្យខ្ញុំអាចផ្តល់ការព្យាបាលជូនអ្នកឱ្យបានត្រឹមត្រូវ និង ជួយអោយយើងដឹងថាមានមនុស្សចំនួនប៉ុន្មាននាក់ទៀតដែលអាចកើតជំងឺដូចគ្នានេះ ។ តើអ្នកយល់ព្រមទេ ?

*អ្នកជំងឺ* ៖ បាទ យល់ព្រម ។

*អ្នកផ្តល់សេវាថែទាំ* ៖ តើអ្នកធ្លាប់រួមភេទក្នុងរយៈពេល៣ខែកន្លងមកដែរឬទេ ?

*អ្នកជំងឺ* ៖ បាទ ខ្ញុំគិតថាមាន ។

*អ្នកផ្តល់សេវាថែទាំ* ៖ សូមនិយាយអំពីបញ្ហានេះប្រាប់ខ្ញុំផងមើល !

*អ្នកជំងឺ* ៖ តើអ្នកត្រូវចង់ដឹងអំពីរឿងអ្វីខ្លះទៅ ?

*អ្នកផ្តល់សេវាថែទាំ* ៖ អូ ! គឺដូចជាធ្លាប់រួមភេទប៉ុន្មានដង? ជាមួយអ្នកណា ?

*អ្នកជំងឺ* ៖ អ៊ឺ... ធ្លាប់មានសង្សារពីរនាក់...អូ...ហើយមានសង្សារមួយទៀតដែលខ្ញុំតែងតែរួមភេទជាមួយ ប៉ុន្តែជាធម្មតានាងមិននៅជាមួយខ្ញុំទេ ?

*អ្នកផ្តល់សេវាថែទាំ* ៖ តើអ្នកបានរួមភេទជាមួយសង្សារចុងក្រោយដែរឬទេ?

*អ្នកជំងឺ* ៖ ខ្ញុំមិនអាចចងចាំបានទេ ខ្ញុំយល់ថាគឺកាលពីខែមុននោះហើយមើលទៅ ។

*អ្នកផ្តល់សេវាថែទាំ* ៖ ចុះជាមួយសង្សារពីរនាក់ទៀតរបស់លោកនោះ ?

*អ្នកជំងឺ* ៖ អ៊ឺ...ណារីគឺជាសង្សារសំណប់ចិត្តរបស់ខ្ញុំ ។ យើងបានរួមរក្សជាមួយគ្នា រយៈពេល២ខែកន្លងទៅហើយអ៊ឺ...ហើយយើងតែងតែរួមរក្សជាមួយគ្នាជាញឹកញាប់ដោយមិនបានប្រើប្រាស់ស្រោមអនាម័យទេ។

*អ្នកផ្តល់សេវាថែទាំ* : ចុះសង្សារមួយទៀតរបស់អ្នកនោះ
*អ្នកជំងឺ* : អ៊ឺ...ណារីមិនបានដឹងរឿងខ្ញុំ នឹងអ្នកដ៏ទៃទេ ។
*អ្នកផ្តល់សេវាថែទាំ* : ត្រឹមត្រូវហើយ ! ខ្ញុំសូមសន្យាថា នាងមិនចាំបាច់ត្រូវការដឹងទេ។ អ្នកមានសេចក្តីក្លាហានមែន ដោយបានប្រាប់អំពីបញ្ហាទាំងនេះ។
*អ្នកជំងឺ* : អ៊ឺ...ខ្ញុំតែងតែទៅជួបនាងរៀងរាល់ថ្ងៃអង្គារ...ក៏ប៉ុន្តែកាលពីថ្ងៃអង្គារមុនខ្ញុំពុំបានជួបនាងទេ ពីព្រោះពេលនោះខ្ញុំនៅជាមួយឪពុកម្តាយខ្ញុំ ។
*អ្នកផ្តល់សេវាថែទាំ* :តើអ្នកមានដឹងទេថា សង្សារណាមួយរបស់លោកមានធ្លាក់ស នៅពេលនេះ?
*អ្នកជំងឺ* : ទេ...ខ្ញុំពុំមានការប្រាកដក្នុងចិត្តទេ ។
*អ្នកផ្តល់សេវាថែទាំ* : ល្អណាស់ ! ក្រៅពីនេះតើអ្នកធ្លាប់មានសង្សារណាផ្សេងទៀតទេក្នុងរយៈពេល៣ខែចុងក្រោយនេះ ?
*អ្នកជំងឺ* : ទេ អត់ទេ ។
*អ្នកផ្តល់សេវាថែទាំ* : ល្អ ! អ្នកឆ្លើយបានល្អណាស់ ឥឡូវនេះខ្ញុំអាចដឹងថា តើការហូរខ្ទុះរបស់អ្នកនេះជាអ្វីបានហើយ... ។

**ការពិនិត្យអ្នកជំងឺ** (clinical examination)

គោលបំណងនៃការពិនិត្យអ្នកជំងឺ គឺត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីរោគសញ្ញាកាមរោគដែលអ្នកជំងឺបានពិពណ៌នា ដោយផ្ទៀងផ្ទាត់រកមើលសញ្ញានៃកាមរោគ ។ ផ្នែកនេះពន្យល់អំពីអ្វីដែលត្រូវធ្វើនៅ ពេលពិនិត្យអ្នកជំងឺស្ត្រី ។

ផ្នែកនេះផ្តោតទៅលើការពិនិត្យមើលចង្កោមរោគសញ្ញាទាំង៥ ។ វាពុំបានយកចិត្តទុកដាក់ លើកាមរោគដទៃៗទៀតដូចជាកមរមាស់ឬចៃ(scabies or lice) ទេ (ការព្យាបាលនៃជំងឺនេះ ត្រូវបានអនុវត្តជាធម្មតាជាប្រចាំទៅហើយ) ។

ការពិនិត្យផ្នែកលាក់កំបាំងនៃរាងកាយមនុស្សណាម្នាក់ទាមទារឱ្យមានការប៉ិនប្រសប់ (sensibility) និង ការគោរពពីសំណាក់អ្នកផ្តល់សេវាថែទាំ ។ អ្នកជំងឺអាចមានការអៀនខ្មាស ឬមានអារម្មណ៍មិនស្រួលក្នុងចិត្ត ។ នៅក្នុងផ្នែកនេះ យើងសង្ខេបជំហាននានាក្នុងការអនុវត្តការពិនិត្យអ្នកជំងឺដែលប្រកបដោយប្រសិទ្ធិភាព (efficient) និង មានអាកប្បកិរិយាវិជ្ជាជីវៈ ។ យើងសូមផ្តល់ជូននូវមធ្យោបាយនានាក្នុងការជួយឱ្យអ្នកជំងឺយល់អំពីសារៈសំខាន់នៃការពិនិត្យ និងជំនះនូវការអៀនខ្មាសរបស់ខ្លួន ។ ធ្វើរបៀបនេះអ្នកអាចផ្តល់នូវការធានារ៉ាប់រងជូនដល់អ្នកជំងឺ ។

| លក្ខណៈសំខាន់ៗនៃការពិនិត្យអ្នកជំងឺ |
| --- |
| • សូមប្រកាន់អាកប្បកិរិយាវិជ្ជាជីវៈមុនពេលនិងក្នុងពេលពិនិត្យ<br>• សូមធ្វើការពិនិត្យដែលមានប្រសិទ្ធិភាព (efficient)<br>• សូមធានារ៉ាប់រងដល់អ្នកជំងឺធ្វើអោយគាត់បាត់នូវការភ័យបារម្ភ |

**ការប្រកាន់ភ្ជាប់នូវអាកប្បកិរិយាវិជ្ជាជីវៈ**

| ការប្រកាន់ភ្ជាប់នូវអាកប្បកិរិយាវិជ្ជាជីវៈនៅពេលពិនិត្យអ្នកជំងឺ |
| --- |
| • សូមធានាឱ្យបានភាពស្ងាត់កំបាំងជានិច្ច ។<br>• ពន្យល់អំពីអ្វីដែលអ្នកនឹងធ្វើ និង អំពីសារៈសំខាន់របស់វា<br>• ធ្វើការពិនិត្យដោយលក្ខណៈទុកចិត្តលើខ្លួនឯងដោយកុំបង្ហាញឱ្យឃើញអំពីភាពពុំច្បាស់លាស់ ឬ ការអៀនខ្មាស<br>• សូមកុំគំរោះគំរើយ ឬធ្វើការពិនិត្យដោយប្រឆាំងនឹងបំណង របស់អ្នកជំងឺ ។<br>• សូមប្រើប្រាស់នូវភាពស្ទាត់ជំនាញទាំងអស់ដែលមាននៅក្នុងជំពូកនេះ ។ |

អ្នកជំងឺអាចមានការអៀនខ្មាស ហើយអាចថែមទាំងមានការរារែកក្នុងការឱ្យអ្នកពិនិត្យប្រដាប់បន្តពូជរបស់ខ្លួន ។ បញ្ហានេះ គឺជាការពិតជាពិសេសចំពោះស្ត្រី ។ ដើម្បីជំនះនូវបញ្ហានេះ ការប្រកាន់អាកប្បកិរិយាវិជ្ជាជីវៈរបស់អ្នកផ្តល់សេវាថែទាំ ត្រូវចាប់ផ្តើមដោយការធានាឱ្យមានភាពស្ងាត់កំបាំងក្នុងការពិនិត្យអ្នកជំងឺ ។ បន្ទាប់មកអ្នកគប្បីពន្យល់អ្វីដែលនឹងកើតឡើងនៅពេលពិនិត្យ និងអំពីសារៈសំខាន់របស់វា ។ អ្នកគប្បីបង្ហាញឱ្យឃើញថា អ្នកមានទំនុកចិត្តលើខ្លួនឯងនិងមានសមត្ថភាព ក៏ប៉ុន្តែនៅតែដឹង (sensitive) អំពីតំរូវការនិងការខ្វល់ខ្វាយរបស់អ្នកជំងឺដែរ ។ យកល្អបំផុតអ្នកជំងឺត្រូវមានលទ្ធភាពក្នុងការជ្រើសរើសអោយអ្នកផ្តល់សេវាថែទាំ ដែលមានភេទ

ដូចគ្នាធ្វើការពិនិត្យគាត់ ។ អ្នកផ្តល់សេវាថែទាំខ្លះអាចមានការខ្មាសអៀន ឬបារម្ភអំពីការពិនិត្យជាពិសេស គឺនៅពេលដែលពួកគេទើបតែអនុវត្តវិធីពិនិត្យនេះជាលើកដំបូង ។ ការសំខាន់គឺត្រូវចៀសវាងបង្ហាញថា គ្មានភាពច្បាស់លាស់ ឬខ្មាសអៀន ពីព្រោះវាអាចជះឥទ្ធិពលដល់ដំណើរការនៃការប្រមូលយកពត៌មាន ។

ជាអកុសល នៅពេលខ្លះអ្នកផ្តល់សេវាថែទាំប្រកាន់អាកប្បកិរិយាទទឹងទទែង(rough) នៅពេលពិនិត្យ ពីព្រោះពួកគេប្រញាប់បញ្ចប់កិច្ចការរបស់គេ។ នេះគឺធ្វើឱ្យមានឥទ្ធិពលមិនល្អ (counter-productive) ពីព្រោះវាប៉ះពាល់ដល់ការរក្សាអោយមានការទំនាក់ទំនងល្អជាមួយអ្នកជំងឺដែលមានសារៈសំខាន់សំរាប់ការគ្រប់គ្រងថែទាំករណីកាមរោគ ។ ទោះបីជាការពិនិត្យពិតជាមានសារៈសំខាន់សំរាប់ការឈានទៅរកការធ្វើរោគវិនិច្ឆ័យក៏ដោយ ក៏យើងពុំត្រូវបង្ខិតបង្ខំអ្នកជំងឺឱ្យយល់ព្រមឱ្យយើងពិនិត្យអោយសោះ ។

នៅទីបញ្ចប់ ការប្រកាន់នូវអាកប្បកិរិយាវិជ្ជាជីវៈមានន័យថាអ្នកអាចប្រើប្រាស់នូវភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដែលមានក្នុងជំពូកនេះ ដើម្បីរក្សាអោយមានការសន្ទនាគ្នាទៅវិញទៅមកជាមួយអ្នកជំងឺប្រកបដោយលទ្ធផលល្អ ។

## ជំហាននានា ក្នុងការពិនិត្យរករោគសញ្ញាតាមរោគនៅលើអ្នកជំងឺប្រុស

1. សុំអោយអ្នកជំងឺឈរ ស្រាតខោត្រឹមក្បាលជង្គង់ ដើម្បីអោយអ្នកជំងឺមានភាពនទលពីទ្រូងមកដល់ក្បាលជង្គង់ គេអាចពិនិត្យអ្នកជំងឺដែលកំពុងឈរ ទោះបីជាពេលខ្លះការពិនិត្យអ្នកជំងឺដេកមានភាពងាយស្រួលក៏ដោយ ។
2. ស្ទាបតំបន់ក្រលៀនដើម្បីរកមើលវត្តមាននៃការហើមប៉ោងនៃកូនកណ្ដុរ
3. ស្ទាបពងស្វាសដើម្បីរកមើលផ្នែកផ្សេងៗរបស់វា :
   * ពងស្វាស
   * បំពង់ទឹកកាម (spermatic cord)
   * អេពីឌីឌីម (epididymis)
4. ពិនិត្យមើលលិង្គដើម្បីរកមើលក្រែងមានកន្ទួល ឬដំបៅ ។ បន្ទាប់មកសុំអោយអ្នកជំងឺពន្លាត់ស្បែកគ្របក្បាលលិង្គ បើសិនជាមានដើម្បីពិនិត្យ:
   * ក្បាលលិង្គ
   * រន្ធបង្ហូរនោម
5. បើសិនជាមិនអាចរកឃើញការហូរខ្ទុះពីបង្ហូរនោមច្បាស់លាស់ទេ ចូរអ្នកសុំឱ្យអ្នកជំងឺច្បូតបង្ហូរនោម។
6. គេត្រូវតាមរកមើលហើយកត់ត្រាទុកនូវវត្តមាន ឬ អវត្តមាននៃ :
   * ដំបៅ
   * ការហូរខ្ទុះតាមបង្ហូរនោមដោយបញ្ជាក់ពីប្រភេទ: ពណ៌ និងបរិមាណនៃរំហៀរនោះទៀតផង។




ប្រដាប់បន្តពូជប្រុស

| ជំហាននានា  ក្នុងការពិនិត្យរកមើលរោគសញ្ញាកាមរោគនៅលើអ្នកជំងឺស្ត្រី |
| --- |
| 1. សុំអោយអ្នកជំងឺដោះសំលៀកបំពាក់ពីចង្កេះចុះក្រោមហើយដេកនៅលើគ្រែពិនិត្យជំងឺ ។ ដើម្បីជួយកុំអោយអ្នកជំងឺអៀន គេត្រូវយកក្រណាត់ទៅគ្របលើកន្លែងទាំងឡាយដែលគេមិនត្រូវការពិនិត្យ ។ បើសិនជាអ្នកជំងឺស្លៀកសំពត់គេអាចពិនិត្យដោយគ្រាន់តែដោះខោទ្រនាប់ចេញតែប៉ុណ្ណោះ ។<br>2. សុំអោយអ្នកជំងឺបត់ជង្គង់និងកន្ធែកជើងហើយគេចាប់ផ្តើមពិនិត្យយោនី រន្ធគូថ perineum និងរន្ធបង្ហូរនោម ។<br>3. ស្ទាបតំបន់ក្រលៀនដើម្បីរកមើលវត្តមាននៃការហើមប៉ោងនៃកូនកណ្តុរ<br>4. ស្ទាបពោះដើម្បីរកមើលដុំនៅអាងត្រគាក និងការឈឺចាប់ពោះ ។ គេត្រូវធ្វើដោយប្រុងប្រយ័ត្នកុំឱ្យមានការឈឺចាប់ដល់អ្នកជំងឺ ។<br>5. គេត្រូវតាមរកមើលហើយកត់ត្រាទុកនូវវត្តមាន ឬ អវត្តមាននៃ :<br>* ដំបៅ<br>* ការហូរខ្ទុះតាមទ្វារមាសដោយបញ្ជាក់ពីប្រភេទៈ ពណ៌ និងបរិមាណនៃរំហៀរនោះទៀតផង<br>* ការហូរខ្ទុះពីរន្ធបង្ហូរនោមស្ត្រី<br>6. ការពិនិត្យស្ទាបពោះដោយដៃទាំងពីរៈ ការស្ទាបពោះដោយប្រើដៃទាំងពីរ គឺដំបូងត្រូវរកការឈឺចាប់នៅផ្នែកខាងក្រោមនៃពោះ ឬដុំពោះដែលបណ្តាលមកពីការក្លាយរោគបង្កដោយពួកបាក់តេរីលើតួស្បូន ដៃស្បូន កន្សោមពង និងស្រោមពោះ ។<br>ឧទាហរណ៍ : រលាកដៃស្បូន, រលាកសរីរាង្គក្នុងអាងត្រគាក<br>***<u>បច្ចេកទេសនៃការពិនិត្យស្ទាបពោះដោយដៃទាំងពីរ</u>*** :<br>ម្រាមពីរនៃដៃស្តាំលូកចូលក្នុងទ្វារមាសហើយសំដៅរកស្បូន និងដៃឆ្វេងស្ទាបលើពោះ(ផ្នែកខាងក្រោមនៃពោះ)រកកំពូលស្បូន បន្ទាប់មកដៃស្តាំក្នុងទ្វារមាសធ្វើចលនាមាត់ស្បូនដើម្បីរកការឈឺនៅផ្នែកខាងក្រោមនៃពោះ ឬដុំពោះ ។ |




ការពិនិត្យស្ទាបពោះដោយដៃទាំងពីរ







ប្រដាប់បន្តពូជស្ត្រី

**ការរំលឹកសារឡើងវិញ :**

**ការស្រង់ប្រវត្តិជំងឺ និង ការពិនិត្យអ្នកជំងឺ :**

**<u>គោលបំណងនៃការស្រង់ប្រវត្តិ និង ពិនិត្យអ្នកជំងឺគឺ</u> :**

* ធ្វើរោគវិនិច្ឆ័យកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា អោយបានត្រឹមត្រូវនិងមានប្រសិទ្ធិភាព ។

* កំណត់បាននូវការប្រឈមមុខនឹងគ្រោះថ្នាក់នៃការចំលង ឬការឆ្លងកាមរោគរបស់អ្នកជំងឺ

* រកឱ្យឃើញនូវដៃគូរបស់អ្នកជំងឺដែលអាចនឹងមានជំងឺកាមរោគ ។

**<u>ការប្រាស្រ័យទាក់ទងរវាងបុគ្គលនិងបុគ្គលដែលមានប្រសិទ្ធិភាព</u> :**

*<u>ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងរួមមាន :</u>*

* ភាពស្ទាត់ជំនាញដោយប្រើពាក្យសំដី : វិធីដែលយើងនិយាយជាមួយនិងសួរអ្នកជំងឺ

* ភាពស្ទាត់ជំនាញដោយមិនប្រើពាក្យសំដី : អាកប្បកិរិយារបស់យើងចំពោះអ្នកជំងឺ ។

*<u>ភាពស្ទាត់ជំនាញដោយប្រើពាក្យសំដីរួមមាន :</u>*

* ជានិច្ចកាលត្រូវចេះគួរសមចំពោះអ្នកជំងឺ

* ប្រើពាក្យពេចន៍ដែលអ្នកជំងឺយល់បាន

* សួរនូវសំណួរអោយបានច្បាស់

* សួរសំណួរម្តងមួយៗ

* ចៀសវាងសួរសំណួរនាំមុខ

* ចៀសវាងការវិនិច្ឆ័យផ្នែកសីលធម៌

* សុំការអនុញ្ញាតពីអ្នកជំងឺដើម្បីនិយាយពីរឿងដែលអាចធ្វើឱ្យគេឆាប់ខឹង (sensitive topics) ។

*ភាពស្ទាត់ជំនាញដោយមិនប្រើពាក្យសំដីរួមមាន :*

* ស្វាគមន៍រាក់ទាក់ជាមួយអ្នកជំងឺ
* ផ្តល់នូវទីកន្លែងស្ងាត់កំបាំងជូនអ្នកជំងឺ
* ស្តាប់ដោយប្រុងប្រយ័ត្ននូវអ្វីដែលអ្នកជំងឺនិយាយ
* អ្នកត្រូវអង្គុយ ប្រសិនបើអ្នកជំងឺអង្គុយ ហើយត្រូវប្រុងប្រយ័ត្នលើរឿងថា តើអ្នកអង្គុយជិតអ្នកជំងឺដល់កំរិតណា ។ គេអាចសួរសំនួរបើក ឬសំនួរបិទ ។ ត្រូវប្រើសំណួរទាំងពីរប្រភេទ ដោយធ្វើយ៉ាងណាអោយទទួលបាននូវពត៌មានជាអតិបរិមា ។ គេចាប់ផ្តើមដោយសំណួរបើកសិន បន្ទាប់មកត្រូវបន្តដោយសំនួរបិទដើម្បីទទួលយកពត៌មានលំអិតជាក់លាក់នានា ។

*ភាពស្ទាត់ជំនាញដោយប្រើពាក្យសំដីផ្សេងៗទៀត ពិពណ៌នាអំពីវិធីសំរាប់អ្នកផ្តល់សេវាថែទាំសុខភាពនិយាយជាមួយអ្នកជំងឺរួមមាន :*

- ការជួយសំរួល
- ការតំរង់ទិស
- សង្ខេបនិងផ្ទៀងផ្ទាត់
- ការបង្ហាញនូវការយល់អារម្មណ៍
- ការធានាគាំរបំរង
- និងការបង្ហាញភាពជាដៃគូ

**ការប្រមែប្រមូលពត៌មានសំរាប់ធ្វើរោគវិនិច្ឆ័យកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា :**

*ការស្រង់យកប្រវត្តិជំងឺ :*

ដើម្បីធ្វើរោគវិនិច្ឆ័យកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ជាការសំខាន់គេត្រូវការទទួលឱ្យបាននូវពត៌មានជាអតិបរិមា ។ គេត្រូវប្រើមធ្យោបាយមួយដើម្បីធានាឱ្យបានថា គេបានទទួលគ្រប់នូវរាល់ពត៌មានដែលគេចង់បាន ។

ការស្រង់ប្រវត្តិជំងឺមានសារៈសំខាន់ផងដែរ ព្រោះវាជួយអោយអ្នកផ្តល់សេវាថែទាំសុខភាព :

- វាយតំលៃពីការប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគរបស់អ្នកជំងឺ
- រកឃើញនូវដៃគូដែលអាចត្រូវការព្យាបាល
- ផ្តល់នូវការអប់រំអំពីការបង្ការកាមរោគ រួមទាំងការជំរុញការប្រើស្រោមអនាម័យផងដែរ ។

*ការពិនិត្យគ្លីនិក* :

អ្នកផ្តល់សេវាថែទាំសុខភាពត្រូវប្រកាន់យកអាកប្បកិរិយាវិជ្ជាជីវៈនៅពេលពិនិត្យដោយ :

* ត្រូវធានាឱ្យបានភាពស្ងាត់កំបាំងជូនអ្នកជំងឺនៅគ្រប់កាលៈទេសៈ
* ពន្យល់អំពីអ្វីដែលខ្លួនកំពុងធ្វើ និងសារៈសំខាន់របស់វា
* ធ្វើការពិនិត្យដោយបង្ហាញនូវភាពទុកចិត្ត ។ គេមិនត្រូវបង្ហាញនូវភាពមិនច្បាស់លាស់ ឬ អៀនប្រៀនទេ ។
* គេមិនត្រូវគំរោះគំរើយ ឬ ធ្វើការពិនិត្យដោយគ្មានការយល់ព្រមពីអ្នកជំងឺទេ ។
* ប្រើប្រាស់រាល់ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងទាំងឡាយដែលមានក្នុងជំពូកនេះ ។ ការធ្វើតាមបញ្ជីផ្ទៀងផ្ទាត់សំរាប់ពិនិត្យជំងឺនឹងធានាឱ្យគេប្រមូលបានគ្រប់នូវពត៌មានទាំងឡាយដែល ត្រូវការសំរាប់ធ្វើរោគវិនិច្ឆ័យ ។

## សំណួរ និងលំហាត់

### ៣.១ សំណួរ

មានភាពឆ្គងនៅក្នុងសំណួរទាំង៦ ខាងក្រោមនេះ ។ សូមពិចារណាលើសំណួរដែលអ្នកមាន នៅពេលដែលឆ្លើយនឹងសំណួរទាំងនេះ បន្ទាប់មកសូមរកមធ្យោបាយកែលំអសំណួរទាំងនេះ ។

" ឈ្មោះ ? "

" សូមប្រាប់អំពីប្រវត្តិជំងឺរបស់អ្នក "

" តើអ្នកធ្លាប់មានដៃគូរួមភេទប៉ុន្មាននាក់ ? ពេលណា ? ហើយពួកគេជានរណា ?

" តើអ្នកធ្លាប់បានរួមភេទជាមួយបុរសផ្សេងៗក្រៅពីប្តីរបស់អ្នកដែរឬទេ ? "

" តើរោគសញ្ញាទាំងនេះកើតឡើងតែនៅពេលដែលមានរដូវ តើមែនដែរឬទេ ? "

" តើអ្នកមាន régles ធម្មតាដែរឬទេ ? "

### ៣.២ លំហាត់ :

ចូរអ្នករៀបរាប់អោយបានច្រើនជាអតិបរិមា នូវរាល់ភាសាទូទៅដែលអ្នកដឹងថា គេប្រើសំរាប់ពាក្យវេជ្ជសាស្រ្តទាំងនេះ ។ ចូរកុំគិតត្រឹមតែពាក្យពេចន៍ដែលនិយាយពីស្ថានភាពជំងឺតែមួយមុខ តែត្រូវគិតពាក្យពេចន៍ ឬឃ្លាដែលប្រជាជនប្រើប្រាស់សំរាប់រៀបរាប់រឿងទាំងនេះ ។

| ពាក្យវេជ្ជសាស្រ្ត | ពាក្យដែលប្រើប្រាស់ដោយប្រជាជន |
|---|---|
| ការហូរខ្ទុះតាមទ្វារមាសរបស់ស្រ្តី | |
| ការឈឺចាប់នៅពេលនោម | |
| ការរលាកទ្វារមាស | |
| ការឈឺនៅផ្នែកខាងក្រោមនៃពោះ នៅលើស្រ្តី | |
| ការឈឺចាប់នៅពេលរួមភេទ | |
| ការរមាស់នៅប្រដាប់បន្តពូជ | |
| ដំបៅនៅលើប្រដាប់បន្តពូជ | |
| ការនោមមិនចេញ | |

***សំណួរសំរាប់រិះគិត*** **:**

មើលនូវតារាងនៃពាក្យពេចន៍ ប្រជាជនប្រើដែលអ្នកបានបំពេញ ។ តើអ្នកយល់ថា អ្នកអាចប្រើប្រាស់ពាក្យពេចន៍ទាំងនេះទេនៅពេលអនុវត្តន៍ ? បើមិនអាចហេតុអ្វី ? ចូរអ្នកគិតគូរពីពាក្យពេចន៍ដែលប្រជាជនប្រើសំរាប់រៀបរាប់ពីប្រភេទផ្សេងៗនៃការរួមភេទ ដូចជា ការរួមភេទធម្មតា និងស្ត្រីរកស៊ីផ្លូវភេទ ។

**៣.៣ សំណួរ**

បើសិនជាអ្នកទើបតែរៀនអំពីសំណួរបើក និងសំណួរបិទជាលើកដំបូង, សំណួរទាំងឡាយខាងក្រោមនឹងជួយអ្នកក្នុងការផ្ទៀងផ្ទាត់ពីចំណេះដឹងរបស់អ្នក ។

ក. ចូរគូសសញ្ញា(✓)ក្នុងប្រអប់ដើម្បីបញ្ជាក់ថាសំណួរខាងក្រោមនេះជាសំណួរបើកឬសំណួរបិទ :

| | បើក | បិទ |
|---|---|---|
| តើអ្នកមានហូរខ្ទុះឬទេ ? | ☐ | ☐ |
| តើអ្នករៀបការហើយឬនៅ ? | ☐ | ☐ |
| តើមានបញ្ហាអ្វីខ្លះដែលរំខានដល់អ្នក ? | ☐ | ☐ |
| តើមានឈឺឬទេ ? | ☐ | ☐ |
| តើអ្នកមានប្រើស្រោមអនាម័យឬទេ? | ☐ | ☐ |
| តើរំហៀរនោះថ្លា ឬ ល្អក់ ? | ☐ | ☐ |
| តើការឈឺចាប់នេះមានសភាពដូចម្តេច ? | ☐ | ☐ |
| ចូរអ្នកប្រាប់ខ្ញុំពីរដូវរបស់អ្នក | ☐ | ☐ |

ខ. ខាងក្រោមនេះ គឺជាចំលើយចំនួន ៤ ។ ដើម្បីបញ្ជាក់ថា ឃ្លាណាខ្លះជាឃ្លាពិត ឬ មិនពិត សូមគូសសញ្ញា (✓) នៅក្នុងប្រអប់ ។

| | ពិត | មិនពិត |
|---|---|---|
| • សំណួរបិទមានប្រយោជន៍ណាស់នៅពេលចាប់ផ្តើមសួរ | ☐ | ☐ |
| • សំណួរបើកនឹងជួយអោយអ្នកជំងឺឆ្លើយដោយប្រើប្រាស់ពាក្យពេចន៍ និង គំនិតខ្លួនផ្ទាល់ គឺអាចជួយឱ្យអ្នកផ្តល់សេវាថែទាំសុខភាពអាចយល់បានច្បាស់ពីអ្នកជំងឺ | ☐ | ☐ |

- ការស្រង់ប្រវត្តិជំងឺដែលល្អតែងចាប់ផ្តើមដោយសំណួរបើក ហើយបន្តទៅសំណួរបិទ ☐ ☐
- សំណួរបិទនឹងជួយអ្នកអោយរកឃើញរោគសញ្ញាជាក់លាក់បាន ☐ ☐

គ. តើសំណួរបើកបែបណាដែលគួរសួរទៅកាន់អ្នកជំងឺបានច្រើនជង ? ហេតុអ្វី ?

### ៣.៤ សំណួរ

សូមអ្នកព្យាយាមកំណត់រកនូវជំនាញទំនាក់ទំនងដែលអ្នកផ្តល់សេវាថែទាំប្រើប្រាស់ក្នុងការសិក្សាខាងក្រោម ។ ចូរគូសបន្ទាត់ពីក្រោមឧទាហរណ៍ដែលអ្នករកឃើញ ហើយសរសេរថា ជាជំនាញអ្វីនៅក្នុងជួរបន្ទាត់នេះ ។ ឃ្លាទីមួយយើងបានគូសសំរាប់អ្នករួចហើយ ។

| | | |
|---|---|---|
| *អ្នកគ្រូសុខា* | *: សួស្តី, សូមអញ្ជើញអង្គុយ, ខ្ញុំឈ្មោះ សុខា <u>ចុះអ្នកឈ្មោះអីដែរ</u> ?* | សំណួរបើក - ការបង្កការងាយស្រួល |
| *នាងណាត្រី* | *: ណាត្រី* | |
| *អ្នកគ្រូសុខា* | *: នាងមានការអ្វីដែរ ?* | |
| *នាងណាត្រី* | *: ចាស, ម្សិលមិញខ្ញុំមុតដៃពេលកំពុងកាប់គល់អុសចាស់ៗ ។ មើលនែ វាជ្រៅណាស់ណ៎ា !* | |
| *អ្នកគ្រូសុខា* | *: <u>អូ ! ជ្រៅមែន ប៉ុន្តែនាងមកទីនេះដើម្បីឱ្យខ្ញុំលាងសំអាតវា អញ្ជឹងជាការត្រឹមត្រូវហើយណាត្រី ។ ខ្ញុំអាចជួយលាង ហើយរុំវាបានយ៉ាងស្រួល</u>... តើនាងនៅឆ្ងាយពីទីនេះទេ ?* | |
| *នាងណាត្រី* | *: អូរ ! តែ៥គីឡូម៉ែត្រ តើជិតទេ !* | |
| *អ្នកគ្រូសុខា* | *: មិនអីទេអញ្ជឹង (គាត់ក៏លាង និង រុំរបួស) <u>ឥឡូវតើនាងមានរឿងអ្វីរំខាននាងទៀតទេ</u> ?* | |
| *នាងណាត្រី* | *: ចាស, មានរឿងផ្សេងទៀត (នាងសើចតិចៗ)* | |
| *អ្នកគ្រូសុខា* | *: <u>ខ្ញុំយល់ថានាងដូចជាអៀនក្នុងការនិយាយរឿងនេះ</u>* | |
| *នាងណាត្រី* | *: ពិតមែនហើយ គឺនៅនឹងទ្វាររបស់ខ្ញុំហ្នឹងណា ! (នាងអោនឡួចនិយាយខ្សឹបៗ)* | |

អ្នកគ្រូសុខា : អញ្ចឹង ហ្អ៎ !

នាងណាត្រី : ចាស៎, វាដូចជាដំបៅយ៉ាងម៉េចទេ ?

អ្នកគ្រូសុខា : ហើយនាងព្រួយពីរឿងដំបៅហ្នឹងឬ ?

នាងណាត្រី : ចាស៎, ខ្ញុំមានដំបៅនៅកន្លែងហ្នឹងមែន, ប៉ុន្តែវាគ្មានអ្វីឈឺទេ តែវាគ្រាន់តែមិនល្អមើលប៉ុណ្ណោះទេ។ ខ្ញុំដូចជាព្រួយដែរ ! ខ្ញុំចង់និយាយថា ខ្ញុំមានមិត្តប្រុសម្នាក់គាត់បាននិយាយប្រាប់ខ្ញុំថាគាត់មិនធ្លាប់គេងជាមួយអ្នកផ្សេងទេ... ខ្ញុំយល់ថាប្រហែលជាឆ្លងមកពីមិត្តប្រុសរបស់ខ្ញុំ ឬ ក៏ឆ្លងពីភ្ញៀវរបស់ខ្ញុំផ្សេងៗទៀតហើយមើលទៅ ។

អ្នកគ្រូសុខា : មើល, ឥឡូវសូមរៀបរាប់រឿងដំបៅនេះបន្ថែមទៀតមើល !

នាងណាត្រី : និយាយពីអ្វី ? វាអត់ឈឺផងហ្នឹង ......

អ្នកគ្រូសុខា : តើនាងមានដំបៅពីអង្កាល ?

នាងណាត្រី : អូ ! ១ខែ ហើយមើលទៅ ។ មិត្តភក្តិខ្ញុំនិយាយថា គ្មានអ្វីគួរឱ្យព្រួយទេ, ប៉ុន្តែខ្ញុំគិតថាវាឆ្លងពីមិត្តរបស់ខ្ញុំ ...... បើសិនជាខ្ញុំរកឃើញថាគាត់ឆ្លងពីស្រីណាហើយ... នោះខ្ញុំច្បាស់ជា...

អ្នកគ្រូសុខា : ណាត្រីឯងច្បាស់ជាបារម្ភនឹងប្រភពដែលចំលងដំបៅហើយ ប៉ុន្តែខ្ញុំយល់ថា យើងត្រូវកំណត់ថាវាជាស្វីសិន ។ ហើយខ្ញុំ ក៏គិតថាយើងក៏ត្រូវនិយាយអំពី វិធីបង្ការកុំអោយវាកើតម្តងទៀតដែរ ប៉ុន្តែដំបូងខ្ញុំចង់ពិនិត្យមើលដំបៅនោះសិន ខ្ញុំដឹងហើយរឿងនេះវាជារឿងខ្មាសអៀន ប៉ុន្តែខ្ញុំត្រូវការពិនិត្យមើលដើម្បីបញ្ជាក់ថា វាឈឺយ៉ាងម៉េចតើបានឬទេ ?

| | | |
|---|---|---|
| *នាងណារុត្តី* | : | *ចាស៎, ខ្ញុំសន្មត់ថាអញ្ចឹងទៅចុះ (ឆ្លើយដោយស្ទាក់ស្ទើរក្នុងចិត្ត)* |
| *អ្នកគ្រូសុខា* | : | *មុននឹងខ្ញុំព្យាបាលណារុត្តីឯង, ខ្ញុំត្រូវតែច្បាស់ថាឈឺអីសិន* |
| *នាងណារុត្តី* | : | *វាមិនអីទេមែនទេ ?* |
| *អ្នកគ្រូសុខា* | : | *ចាស៎, ហើយយើងអាចព្យាបាលវាឱ្យជាតែម្តង ហើយនាងត្រូវតែបង្ការកុំអោយកើតម្តងទៀត, ប៉ុន្តែ ខ្ញុំនឹងប្រាប់នាងពីអ្វីត្រូវដឹង នឹងជួយឱ្យនាងសំរេចចិត្តថាតើត្រូវធ្វើយ៉ាងម៉េច ។ បានទេ ?* |
| *នាងណារុត្តី* | : | *ចាស៎, បាន ។* |

**៣.៥ លំហាត់ :**

## *លំហាត់ដើរតួសំរាប់ការស្រង់ប្រវត្តិជំងឺ*

* **គោលបំណងនៃលំហាត់គឺ :**

- *អនុវត្តនូវភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដើម្បីសំភាសន៍អ្នកជំងឺកាមរោគពិតប្រាកដ ដោយលក្ខណៈជឿជាក់លើខ្លួនឯង ។*
- *អនុវត្តនូវការប្រមូលពត៌មានដែលរៀបរាប់ក្នុងទំព័រ ២៣-២៤ ។*
- *ធ្វើឱ្យកាន់តែដឹងច្បាស់ពីសមត្ថភាពរបស់អ្នកក្នុងការប្រាស្រ័យទាក់ទង ហើយមានគំនិតកាន់តែច្បាស់នៅលើផ្នែកណាមួយដែលអ្នកនឹងចង់ធ្វើឱ្យកាន់តែល្អប្រសើរឡើង ។*

វិធីតែមួយគត់ដែលធ្វើអោយភាពស្ទាត់ជំនាញរបស់អ្នកកាន់តែមានភាពប្រសើរឡើង គឺ ការអនុវត្តនូវភាពស្ទាត់ជំនាញទាំងនោះ ។ ដូច្នេះ សកម្មភាពនេះមានសារៈសំខាន់ណាស់ ។

ដើម្បីអនុវត្តលំហាត់បែបនេះ មនុស្សម្នាក់ត្រូវដើរតួជាអ្នកជំងឺកាមរោគ, ចំណែកឯម្នាក់ទៀតត្រូវដើរតួជា អ្នកផ្តល់សេវាថែទាំ, ចំណែកអ្នកទី ៣ គឺអាចធ្វើជាអ្នកសង្កេតនូវអន្តរអំពើ និងផ្តល់នូវ

ចំលើយត្រឡប់ទៅអោយអ្នកផ្តល់សេវាថែទាំវិញ ។ អ្នកអាចប្តូរវេនគ្នាដើរតួដើម្បីអោយអ្នកទាំង ៣ មានឱកាសដើរតួនេះម្តងម្នាក់ៗ ។

* **ការដើរតួជាអ្នកជំងឺ :**

អ្នកត្រូវដើរតួជាអ្នកជំងឺកាមរោគដែលមករកការព្យាបាលនៅមណ្ឌលសុខភាព ។ ពេលនេះ សូមអ្នកសំរេចចិត្តថា តើអ្នកជាអ្នកណា ហើយត្រូវមានអាកប្បកិរិយាបែបណា ។ ចូរអ្នកចំណាយពេលឆ្លើយទៅនឹងសំណួរខាងក្រោម ដើម្បីកំណត់នូវអាកប្បកិរិយារបស់អ្នក ។ ប៉ុន្តែ សូមកុំអោយអ្នកផ្តល់សេវាថែទាំដឹងនូវកំណត់ត្រាទាំងនេះមុនអោយសោះ ។ ត្រូវប្រឹងធ្វើយ៉ាងណាអោយដូចជាអ្នកជំងឺពិតប្រាកដអញ្ចឹង : សូមព្យាយាមឆ្លើយយ៉ាងស្មោះត្រង់ទៅនឹងសំណួររបស់អ្នកផ្តល់សេវាថែទាំសុខភាព។ ចូរអ្នកព្យាយាមកុំបង្កការលំបាកពេក ឬ ស្រួលពេកសំរាប់អ្នកផ្តល់សេវាថែទាំ ។

- អ្នកឈ្មោះអ្វី ?
- អាយុ និងភេទរបស់អ្នក ?
- ចូរពិពណ៌នាអំពីជំនឿសាសនារបស់អ្នក, កំរិតវប្បធម៌របស់អ្នក, មុខរបររបស់អ្នក
- សូមប្រាប់អំពីអត្តចរិករបស់អ្នក : ចូលចិត្តដើរលេងឬមានការអៀនខ្មាស់ ។ល។
- តើអ្នកមានរោគសញ្ញាកាមរោគអ្វីខ្លះ ? តើមានបញ្ហាអ្វីផ្សេងឬទេ ?
- តើអ្នកមានដៃគូរួមភេទក្រៅពីភ្ញៀវរបស់អ្នកដែរឬទេ ?
- បើអ្នកមានដៃគូរួមភេទក្រៅពីភ្ញៀវរបស់អ្នក, តើអ្នកមានដឹងទេថាតើគាត់មានដៃគូរួមភេទផ្សេងៗឬទេ ?
- តើអ្នកយល់យ៉ាងណាអំពីមណ្ឌលសុខភាពដែលអ្នកមកពិគ្រោះជំងឺនេះ ?
- តើអ្នកមានអារម្មណ៍យ៉ាងណាពីរោគសញ្ញារបស់អ្នក, ហើយមានអារម្មណ៍យ៉ាងណានៅពេលពិភាក្សារោគសញ្ញាទាំងនេះជាមួយមនុស្សម្នាក់ផ្សេងទៀត ។

ក្រោយពីបានដើរតួហើយ សូមផ្តល់ដល់អ្នកសំភាសន៍នូវយោបល់ត្រឡប់មកវិញ ដើម្បីអោយដឹងថាតើគេធ្វើបានល្អដល់កំរិតណា ។

សំណួរមួយចំនួនខាងក្រោមនេះអាចយកមកពិចារណា ឬ ពិភាក្សា :

- អារម្មណ៍របស់អ្នកនៅពេលដើរតួជាអ្នកជំងឺ : តើអ្នកផ្តល់សេវាថែទាំបានធ្វើឱ្យអ្នកមានអារម្មណ៍ស្រួលក្នុងការឆ្លើយដែរឬទេ ? តើគាត់ធ្វើរបៀបណា ? តើអ្នកបានសួរធ្វើឱ្យអ្នកមានអារម្មណ៍ស្រួលក្នុងចិត្តឬទេ ឬក៏ធ្វើឱ្យអ្នកងាយនឹងឆ្លើយ ?

- តើអ្នកផ្តល់សេវាថែទាំទទួលបាននូវពត៌មានទាំងអស់ ស្តីអំពីអត្តចរិករបស់អ្នកដែលអ្នកបានកត់ត្រាដែរឬទេ ?
- តើបច្ចេកទេសសួរអ្វីខ្លះដែលអ្នកឆ្លើយជាវិជ្ជមាន ? តើមានបច្ចេកទេសអ្វីខ្លះដែលអ្នកឆ្លើយជាអវិជ្ជមាន ? មូលហេតុអ្វី ?

* **ការដើរតួជាអ្នកផ្តល់សេវាថែទាំសុខភាព :**

ការដើរតួនេះ ស៊ីពេលប្រហែល ៥នាទី ។ ចូរព្យាយាម ប្រើប្រាស់នូវរាល់ភាពស្ទាត់ជំនាញដោយប្រើ ឬ មិនប្រើពាក្យពេចន៍ដែលបានសិក្សារួច, ត្រូវផ្តោតទៅលើអារម្មណ៍របស់អ្នកជំងឺ និងការឆ្លើយតបនឹងភាពរំភើបទាំងនេះ។ សូមព្យាយាមផងដែរក្នុងការទទួលយកនូវពត៌មានឱ្យបានច្រើនបំផុតពីអ្នកជំងឺ ក្នុងរយៈពេលដែលផ្តល់ជូនអ្នក ។

នៅពេលដែលអ្នកជំងឺកំពុងកំណត់អំពីអត្តចរិករបស់គេ អ្នកអាចពិនិត្យមើលនូវបញ្ជីត្រួតពិនិត្យសំរាប់សង្កេត (ទំព័របន្ទាប់) ដើម្បីដឹងថាតើត្រូវយកភាពស្ទាត់ជំនាញណាមួយមកអនុវត្ត ។

នៅពេលសំភាសន៍, អ្នកនឹងយល់ឃើញថាការបើកសៀវភៅនៅទំព័រ២២នឹងមានប្រយោជន៍សំរាប់ឱ្យអ្នករំលឹកនូវពត៌មានដែលអ្នកត្រូវការ ។

ក្រោយពីសំភាសន៍ចប់, អ្នកនឹងទទួលបាននូវយោបល់ត្រឡប់វិញ ពីអ្នកជំងឺនិងពីអ្នកសង្កេតការណ៍ ។ អ្នកសង្កេត និងប្រាប់អ្នកដោយផ្តោតលើភាពស្ទាត់ជំនាញរបស់អ្នកដោយផ្ទៀងផ្ទាត់ទៅនឹងបញ្ជីរបស់គេ ចំណែកឯអ្នកជំងឺវិញ គាត់នឹងរៀបរាប់ពីអារម្មណ៍របស់គាត់នៅពេលសំភាសន៍ ។ គាត់ក៏នឹងប្រាប់អ្នកផងដែរនូវចំណុចសំខាន់ដែលអ្នកមិនបានសួរ ។ បន្ទាប់មកអ្នកត្រូវពិភាក្សាពីអ្វីដែលត្រូវកែតំរូវ ដើម្បីធ្វើឱ្យការសាកសួរលើកក្រោយកាន់តែមានប្រសិទ្ធិភាពជាងមុន ។

អ្នកអាចរៀបរាប់ពីបទពិសោធន៍របស់អ្នកក្នុងបញ្ហាមួយចំនួនខាងក្រោម :

- ការលំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកជំងឺដែលមានភេទផ្ទុយពីអ្នក
- ការលំបាកឆ្លើយទៅនឹងសំណួរមួយចំនួន
- ការលំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដែលមានអាយុក្មេងឬចាស់ជាងអ្នក។

* **ការដើរតួជាអ្នកសង្កេតការណ៍ :**

ការដើរតួជាអ្នកសង្កេតការណ៍មានសារៈសំខាន់ណាស់ ពីព្រោះអ្នកត្រូវផ្តល់អោយទៅអ្នកសំភាសន៍វិញ នូវយោបល់តបវិញលើភាពស្ទាត់ជំនាញដែលគេបានបង្ហាញនៅពេលដែលគេដើរតួ ។ នៅពេលអ្នកសង្កេត ចូរអ្នកប្រើនូវបញ្ជីត្រួតពិនិត្យនៅទំព័របន្ទាប់ ដើម្បីកត់ត្រានូវអ្វីដែលអ្នកធ្វើសំភាសន៍បានធ្វើ ។ នៅពេលផ្តល់យោបល់ត្រឡប់មកវិញ ចូរព្យាយាមយ៉ាងណាកុំឱ្យមានលំអៀង ។ អ្នកត្រូវតែបញ្ជាក់អោយបានច្បាស់ពីអ្វីដែលគេធ្វើបានល្អ ហើយពន្យល់ពីហេតុផល ។ ដូចគ្នានេះដែរ ត្រូវតែចេះរិះគន់ដល់អ្នកសំភាសន៍ ប៉ុន្តែដោយលក្ខណៈវិជ្ជមាន : ការគូសបញ្ជាក់ពីជំនាញសំភាសន៍ដែលអ្នកផ្តល់សេវាត្រូវតែកែលំអបន្ថែមទៀត ជារឿងសំខាន់ណាស់ ។

**បញ្ជីសង្កេតសំរាប់លំហាត់ ៣.៦**

| តើអ្នកសំភាសន៍ ............ | បំពេញផ្នែកសំរាប់កត់ត្រានូវរាល់ការសំគាល់របស់អ្នក |
|---|---|
| បង្ហាញនូវភាពគោរពដល់អ្នកជំងឺ ? | |
| តើគាត់មានបង្ហាញថា គាត់ស្តាប់អ្នកជំងឺនិយាយដោយប្រើជំនាញមិនចេញពាក្យសំដីបានសមស្របដែរឬទេ? | |
| ទទួលនូវការអនុញ្ញាតិពីអ្នកជំងឺមុននឹងសួរសំនួរគួរអោយអៀនខ្មាសឬសំនួរពិបាកស្តាប់ | |
| គ្រប់គ្រងការរំភើបរបស់អ្នកជំងឺបានយ៉ាងមានប្រសិទ្ធិភាព | |
| ភាគច្រើនគេប្រើសំណួរបើក, ប្រើសំណួរបិទមានចំនួនកំណត់ | |
| ប្រើប្រាស់ជំនាញប្រើពាក្យសំដីទាំង ៦ ខាងក្រោមយ៉ាងមានប្រសិទ្ធភាព<br>• ការជួយសំរួល<br>• ការតំរង់ទិស<br>• សង្ខេប និងផ្ទៀងផ្ទាត់<br>• ការបង្ហាញនូវការយល់អារម្មណ៍<br>• ការធានាគាំបំរង | |

| | |
|---|---|
| • ការបង្ហាញភាពជាដៃគូ | |
| បានសួរសំនួរទាក់ទងដល់ចំនុចទាំង៤ តាមពត៌មានដែលចង់បាន :<br>❑ ពត៌មានទូទៅ<br>❑ ជំងឺបច្ចុប្បន្ន<br>❑ ប្រវត្តិជំងឺ<br>❑ ប្រវត្តិនៃការរួមភេទ | |

## ៣.៦ គំរោងសកម្មភាពសំរាប់ការស្រង់យកប្រវត្តិជំងឺ និងការពិនិត្យជំងឺ

នៅពេលរៀនជាក្រុម ការដើរតួគឺជាវិធីដ៏មានប្រសិទ្ធភាពមួយក្នុងការអនុវត្តជំនាញ ។ អ្នកដទៃទៀតក្នុងក្រុមរបស់អ្នកមានលទ្ធភាពនឹងសង្កេតមើលការអនុវត្តរបស់អ្នក ហើយមានឳកាសនឹងអោយនូវចំលើយភ្លាមៗ ។ ការនេះនឹងជួយអ្នកអោយអាចរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយបាន ។ គំរោងសកម្មភាពនេះគឺជាវិធីមួយដ៏ប្រសើរសំរាប់អ្នកចាប់ផ្តើមអនុវត្តជំនាញទាំងនេះ ។

ដំបូងបង្អស់ សូមអ្នកធ្វើនូវលំហាត់ទាំងនេះ ។ យើងសូមជូនជាយោបល់ថា អ្នកពិភាក្សាបញ្ហាទាំងនេះជាមួយប្រធានរបស់អ្នក ឬអ្នកធ្វើការជាមួយគ្នា ។

១- បើសិនជាអ្នកធ្លាប់បានពិនិត្យអ្នកជំងឺកាមរោគហើយ, សូមអ្នករៀបរាប់នូវបញ្ហាដែលអ្នកធ្លាប់ជួបប្រទះនៅក្នុងជួរខាងឆ្វេងនៃតារាង ។ នៅផ្នែកខាងស្តាំនៃតារាង សូមអ្នករៀបរាប់ពីវិធីដោះស្រាយបញ្ហាទាំងនេះតាមតែបទពិសោធន៍កន្លងមក ឬនៅថ្ងៃអនាគតតើត្រូវដោះស្រាយវិធីណា ។ បើសិនជាអ្នកមិនធ្លាប់បានពិនិត្យអ្នកជំងឺកាមរោគ តើមានបញ្ហាអ្វីខ្លះដែលអ្នកគិតថានឹងកើតមានឡើង (ជួរខាងឆ្វេង) ហើយនិងវិធីដោះស្រាយ (ជួរខាងស្តាំ) ។

| បញ្ហា | ដំណោះស្រាយ |
|---|---|
| | |

២- ពិភាក្សាពីសំភារៈដែលមណ្ឌលសុខភាពរបស់អ្នកមាន : តើអ្នកអាចផ្តល់នូវភាពស្ងាត់ កំបាំងនិងរក្សាការសំងាត់ដល់អ្នកជំងឺកាមរោគដល់កំរិតណា ? តើអ្នកអាចធ្វើយ៉ាងណាដើម្បីអោយមានសុក្រិតភាពឡើង ?

វិធីតែមួយគត់ដើម្បីឱ្យអ្នកគ្រប់គ្រងជំនាញដែលយើងបានរៀននៅក្នុងជំពូកនេះគឺការអនុវត្ត។ លំហាត់បន្តទៀតអ្នកអាចយកវាទៅធ្វើខ្លួនឯងនៅអាទិត្យក្រោយៗទៀត ។

៣- ការអនុវត្តការស្រង់យកប្រវត្តិជំងឺ និងការពិនិត្យជំងឺនៅលើអ្នកជំងឺពិត ។ ហើយសូមជូនជាយោបល់ឱ្យអ្នកកត់ត្រាទុកនូវការស្រង់ប្រវត្តិជំងឺ និងការពិនិត្យជំងឺ យ៉ាងហោចណាស់អោយបាន ៦ នាក់ ។ បែបបទនៅទំព័រនេះ គឺជួយអ្នកឱ្យកត់ត្រាទុកនូវបទពិសោធន៍នៅពេលនោះ ហើយអាចឱ្យអ្នកសើរើឡើងវិញដោយខ្លួនឯង ឬជាមួយប្រធាន ឬអ្នកធ្វើការជាមួយគ្នា ។ គោលបំណងនៃលំហាត់នេះ គឺធ្វើឱ្យអ្នកមានទំនុកចិត្តនៅលើជំនាញក្នុងការសាកសួរ និងពិនិត្យជំងឺ ហើយនិងធ្វើឱ្យអ្នកមានទំនាក់ទំនងកាន់តែមានប្រសិទ្ធិភាព និងមានប្រយោជន៍ជាមួយអ្នកជំងឺ ។

**គំរោងសកម្មភាពសំរាប់កត់ត្រាទុកនូវការស្រង់យកប្រវត្តិជំងឺ និងការពិនិត្យជំងឺ**

| | |
|---|---|
| ឈ្មោះគ្លីនិក : ........................<br>ឈ្មោះអ្នកផ្តល់សេវាថែទាំ : ............... | |
| | ប្រើប្រាស់ជួរនេះសំរាប់កត់ត្រានូវ*បញ្ហាឬដំណោះស្រាយ* (ទាំងការធ្វើរោគវិនិច្ឆ័យ និងភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទង) |
| ការសាកសួរធ្វើនៅថ្ងៃទី ......... | |
| ១<br>២<br>៣ | |
| ការពិនិត្យជំងឺធ្វើនៅថ្ងៃទី ......... | |
| ១<br>២<br>៣ | |

**ចំលើយ :**

**៣.១ សំណួរ :**

សូមអ្នកកុំព្រួយបារម្ភបើសិនជាអ្នកយល់ថា លំហាត់នេះលំបាក ជាពិសេសនៅពេលដែលអ្នកមិនធ្លាប់បានទទួលបណ្តុះបណ្តាលពីការសំភាសន៍នេះពីមុនមក ។ យើងសូមលើកឡើងនូវចំណុចមួយចំនួន :

*នៅពេលចាប់ផ្តើមសំភាសន៍ : " ឈ្មោះ ? "*

នេះមិនមែនជាវិធីចាប់ផ្តើមសំភាសន៍ដែលមានភាពរាក់ទាក់នោះទេ ។ ជានិច្ចកាលយើងត្រូវមានសុជីវធម៌ : " *នាង / អ្នកឈ្មោះអ្វី ?* " ឬ " *សូមមេត្តាប្រាប់ឈ្មោះរបស់អ្នក* " ហើយហេតុអ្វីក៏យើងមិនណែនាំខ្លួនយើងអោយអ្នកជំងឺស្គាល់ផង ។

*" សូមប្រាប់ខ្ញុំពីប្រវត្តិជំងឺរបស់អ្នក "*

សំណួរនេះទូលំទូលាយពេក ។ អ្នកជំងឺមិនដឹងចាប់ផ្តើមពីកន្លែងណាទេ ។ អ្នកជំងឺប្រហែលជាមិនដឹងថា អ្វីទៅជាប្រវត្តិជំងឺ ហើយប្រវត្តិបែបណាដែលអ្នកចង់ដឹងនោះទេ ។ គេត្រូវសួរសំណួរនេះអោយច្បាស់លាស់ជាងនេះ ។

*" តើអ្នកធ្លាប់មានដៃគូរួមភេទប៉ុន្មាននាក់, ពីពេលណាមក, ហើយពួកគេជានរណា ? "*

នេះជាសំណួរដែល ពិបាកនឹងសួរណាស់ ។ ប៉ុន្តែនៅក្នុងករណីនេះ វាជាបញ្ហាព្រោះថាមានសំណួរបីដាច់គ្នានៅក្នុងនេះ ។ សូមសួរសំនួរមួយម្តងៗបានហើយ ។ ឬក៏អ្នកអាចចាប់ផ្តើមដោយសំណួរបើក ឧទាហរណ៍ដូចជា " *តើអ្នកអាចប្រាប់ខ្ញុំអំពីដៃគូរួមភេទរបស់អ្នកបានដែរឬទេ ?* " ហើយបន្តដោយសួរថា " *ចុះអ្នកផ្សេងៗ ទៀតយ៉ាងម៉េចដែរ ?* " ហើយនៅចាំមើលថាតើអ្នកជំងឺប្រាប់បន្ថែមពតិមានលំអិតដែរឬទេ? ។ គន្លឹះមួយទៀតគឺ : នៅពេលដែលអ្នកចាប់ផ្តើមសួរពីសំណួរផ្ទាល់ខ្លួន, សុំការអនុញ្ញាតពីអ្នកជំងឺជាមុន ។ អ្នកត្រូវដឹងថា សំនួរខ្លះពិបាកនឹងឆ្លើយណាស់ - អ្នកជំងឺនឹងមានអារម្មណ៍ថា អ្នកយល់ពីអារម្មណ៍របស់គេបានប្រសើរជាងមុន ។

*" តើអ្នកមានរួមភេទជាមួយបុរសផ្សេងៗក្រៅពីភ្ញៀវរបស់អ្នកដែរឬទេ ?*

សំណួរនេះនាំទៅរកការវិនិច្ឆ័យសីលធម៌ ។ យើងត្រូវធ្វើអោយសំនួររបស់យើងនៅក្រៅការវិនិច្ឆ័យបែបនេះ ។

*" តើរោគសញ្ញាទាំងនេះកើតឡើងតែនៅពេលមានរដូវទេ មែនទេ ? "*

សំណួរនេះហាក់ដូចជា ប្រាប់អ្នកជំងឺជាស្រេចបាត់ទៅហើយ ។ សំណួរបែបនេះហៅថា " សំនួរដឹកនាំ " ដែលគេត្រូវជៀសវាង ។ " *តើអ្នកមានបញ្ហានេះនៅពេលណា ?* " ឬ " *តើមានបញ្ហានេះកាន់តែធ្ងន់ធ្ងរទៅនៅពេលណា ?* " ការសួរបែបនេះគឺប្រសើរជាង ។ " តើអ្នកមក régles ធម្មតាទេឬ ? "

ចំណុចគន្លឹះនៅទីនេះ គឺជៀសវាងប្រើប្រាស់ពាក្យពេចន៍វេជ្ជសាស្ត្រ ពីព្រោះថាអ្នកជំងឺខ្លះមិនអាចយល់បានទេ ឬក៏យល់ខុស ។ អ្នកជំងឺអាចយល់ពីរដូវធម្មតាដោយបែបមួយផ្សេងពីអ្នកផ្តល់សេវាថែទាំ ។ ជាការល្អ បើសិនជាគេសួរអ្នកជំងឺថា តើមានបញ្ហាអ្វីខ្លះ ហើយអោយយើងជួយដោយវិធីណា ។

## **៣.៣ សំណួរ :**

ក- បើសិនជាអ្នកនៅចាំថាសំណួរបិទ គឺជាសំណួរត្រូវឆ្លើយតបវិញដោយឃ្លាយ៉ាងខ្លី ឬ ឆ្លើយ " បាទ/*ចាស៎* " ឬ " ទេ " នោះសំណួរនេះងាយស្រួលឆ្លើយទេ ។ ក្នុងនេះមានសំណួរបើកតែ ៣ ប៉ុណ្ណោះ :

| | បើក | បិទ |
|---|---|---|
| តើអ្នកមានហូរខ្ទុះឬទេ ? | ☐ | ☑ |
| តើអ្នករៀបការហើយឬនៅ ? | ☐ | ☑ |
| តើបញ្ហាអ្វីខ្លះទៅដែលរំខានដល់អ្នក ? | ☑ | ☐ |
| តើមានឈឺឬទេ ? | ☐ | ☑ |
| តើរួមភេទចុងក្រោយនេះមានប្រើស្រោមអនាម័យឬទេ ? | ☐ | ☑ |
| តើ ស នោះថ្លា ឬល្អក់ ? | ☐ | ☑ |
| តើឈឺយ៉ាងម៉េច ? | ☑ | ☐ |
| ចូរអ្នកប្រាប់ខ្ញុំពីរដូវរបស់អ្នក | ☑ | ☐ |

ខ- ខាងក្រោមនេះគឺជា អំណះអំណាងពិត ឬមិនពិតរួមជាមួយនឹងការពន្យល់ :

" *សំណួរបិទមានប្រយោជន៍ណាស់នៅពេលចាប់ផ្តើមសួរ* " *មិនពិត*

ទោះបីជាសំណួរបិទទាមទារនូវចំលើយចំៗក៏ដោយ ក៏សំណួរបិទនៅតែមិនមែនជាសំណួរមានប្រយោជន៍នៅពេលចាប់ផ្តើមសំភាសន៍ ។ ផ្ទុយទៅវិញ គេត្រូវចៀសវាងប្រើសំណួរនេះនៅពេលចាប់ផ្តើមសំភាសន៍ ។

*" សំណួរបើកនឹងជួយអ្នកជំងឺឱ្យឆ្លើយតបដោយប្រើប្រាស់ពាក្យពេចន៍ និងគំនិតផ្ទាល់ខ្លួន ហើយនឹងធ្វើឱ្យអ្នកផ្តល់សេវាថែទាំសុខភាពយល់ច្បាស់ពីអ្នកជំងឺ "* **ពិត**

នេះ គឺ ជាផលប្រយោជន៍នៃការប្រើប្រាស់សំណួរបើក នៅពេលចាប់ផ្តើមសំភាសន៍ ។ សំណួរនេះនឹងជួយអ្នកប្រមូលនូវពត៌មានបានលឿន និងមានប្រសិទ្ធិភាព, ប្រមូលនូវពត៌មានសំខាន់ៗ ដែលអ្នកអាចនឹងបាត់បង់ ហើយនឹងជួយឱ្យយើងដឹងពីការយល់ឃើញពីទស្សនៈ, ពីកង្វល់របស់អ្នកជំងឺបានច្បាស់ ។ ចំណុចទាំងនេះមានសារៈសំខាន់នៅពេលក្រោយ បើសិនជាអ្នកត្រូវការអប់រំអ្នកជំងឺ ។

*" ការស្រង់ប្រវត្តិជំងឺដែលល្អតែងចាប់ផ្តើមដោយសំណួរបើក ហើយបន្តទៅសំណួរបិទ "* **ពិត**

ចូរអ្នកចងចាំនូវដំណើរការនៃការសំភាសន៍ ហើយនឹងផលប្រយោជន៍នៃសំនួរបើកដែលយើងបានរៀបរាប់រួចហើយ ។ គំលៃនៃសំណួរបិទ គឺផ្ទៀងផ្ទាត់ ឬ ទទួលនូវពត៌មានលំអិត ។

*" សំណួរបិទនឹងជួយអ្នកអោយរកឃើញនូវរោគសញ្ញាជាក់លាក់នានា "* **ពិត**

តាមរយៈការសួរសំណួរបិទ អ្នកអាចរកឃើញនូវរោគសញ្ញា, ប៉ុន្តែអ្នកត្រូវចាំថា ត្រូវចាប់ផ្តើមសំភាសន៍ដោយសំណួរបើក ។

គ- សូមអ្នកកុំភ័យបារម្ភ ប្រសិនបើភ្លេចក៏ដោយ ។ យើងត្រូវគិតពីការសួរអ្នកជំងឺពីសំណួរដូចជា " តើមានបញ្ហាអ្វីខ្លះទៀតទេដែលរំខានដល់សុខភាពអ្នក ? " មូលហេតុដែលថាសំណួរនេះមានសារៈសំខាន់ គឺ ពីព្រោះសំណួរនោះនាំឱ្យអ្នកជំងឺដែលព្រួយបារម្ភ នោះចាប់រៀបរាប់ពីកង្វល់ជាចំបងរបស់គាត់ដោយខ្លួនគាត់ផ្ទាល់ ។ ត្រូវចងចាំថា អ្នកជំងឺកាមរោគជាច្រើននឹងមានអារម្មណ៍អៀនខ្មាសនឹងសំណួរទាំងនោះពេក រហូតដល់គាត់មិនចង់រៀបរាប់ពីរោគសញ្ញាទាំងនោះប្រាប់អ្នកដរាបណាអ្នកបង្ហាញនូវឆន្ទះរបស់អ្នកក្នុងការស្តាប់ និងសំដែងការគោរពចំពោះគាត់ ។

**៣.៤ សំណួរ**

ខាងក្រោមនេះយើងបញ្ជាក់ពីឃ្លាហើយបង្ហាញពីជំនាញសំខាន់ៗ ដែលអ្នកគ្រូពេទ្យ " សុខា " កំពុងប្រើប្រាស់ ។ សូមអ្នកពិភាក្សាការយល់ឃើញរបស់អ្នកជាមួយអ្នកធ្វើការជាមួយគ្នា ឬប្រធានរបស់អ្នក បើសិនជាអ្នកមិនច្បាស់លើចំណុចណាមួយ ។ អ្នកអាចពិភាក្សារឿងផ្សេងៗ ទៀតដែលអ្នកគ្រូពេទ្យ " សុខា " មិនបាននិយាយ ឬធ្វើជាមួយអ្នកជំងឺ ។

| | | |
|---|---|---|
| អ្នកគ្រូសុខា | : សួស្តី, សូមអញ្ជើញអង្គុយ, ខ្ញុំឈ្មោះ សុខា ចុះអ្នកឈ្មោះអីដែរ ? | សំណួរបើក : ការបង្ករការងាយស្រួល |
| នាងណារ៉ាត្រី | : ណារ៉ាត្រី | |
| អ្នកគ្រូសុខា | : នាងមានការអ្វីដែរ ? | សំណួរបើក |
| នាងណារ៉ាត្រី | : ចាស៎,ម្សិលមិញខ្ញុំមុតដៃពេលកំពុងកាប់គល់អុស ចាស់ៗ ។ មើលនែ វាជ្រៅណាស់ណ៎ា ! | |
| អ្នកគ្រូសុខា | : អូ ! ជ្រៅមែន ប៉ុន្តែនាងមកទីនេះដើម្បីឱ្យខ្ញុំលាងសំអាតវា អញ្ចឹងជាការត្រឹមត្រូវហើយណារ៉ាត្រី ។ ខ្ញុំអាចជួយលាង ហើយរុំវាបានយ៉ាងស្រួល... តើនាងនៅឆ្ងាយពីទីនេះទេ ? | កាធានាអះអាង |
| នាងណារ៉ាត្រី | : អូ ! តែ៥គីឡូម៉ែត្រតើជិតទេ ! | |
| អ្នកគ្រូសុខា | : មិនអីទេអញ្ចឹង (គាត់ក៏លាង និង រុំរបួស) ឥឡូវតើនាងមានរឿងអ្វីរំខាននាងទៀតទេ ? | ការបង្ករការងាយស្រួល |
| នាងណារ៉ាត្រី | : ចាស៎, មានរឿងផ្សេងទៀត (នាងសើចតិចៗ) | |
| អ្នកគ្រូសុខា | : ខ្ញុំយល់ថានាងដូចជាអៀនក្នុងការនិយាយរឿងនេះ | កាយល់អារម្មណ៍ |
| នាងណារ៉ាត្រី | : ពិតមែនហើយ គឺនៅនឹងទ្វាររបស់ខ្ញុំហ្នឹងណា ! (នាងអោនឡូចនិយាយខ្សឹបៗ) | |
| អ្នកគ្រូសុខា | : អញ្ចឹង ហ្ន៎ ! | ការបង្ករការងាយស្រួល |
| នាងណារ៉ាត្រី | : ចាស៎, វាដូចជាដំបៅយ៉ាងម៉េចទេ ? | |
| អ្នកគ្រូសុខា | : ហើយនាងព្រួយពីរឿងដំបៅហ្នឹងឬ ? | ការយល់អារម្មណ៍ - ផ្ទៀងផ្ទាត់ |
| នាងណារ៉ាត្រី | : ចាស៎, ខ្ញុំមានដំបៅនៅកន្លែងហ្នឹងមែន, ប៉ុន្តែវាគ្មានអ្វីឈឺទេ តែវាគ្រាន់តែមិនល្អមើលប៉ុណ្ណោះទេ។ ខ្ញុំដូចជាព្រួយដែរ ! ខ្ញុំចង់និយាយថា ខ្ញុំមានមិត្តប្រុសម្នាក់គាត់បាននិយាយប្រាប់ខ្ញុំថាគាត់មិនធ្លាប់គេងជាមួយអ្នកផ្សេងទេ... ខ្ញុំយល់ថាប្រហែលជាឆ្លងមកពីមិត្តប្រុសរបស់ខ្ញុំ ឬ ក៏ឆ្លងពីភ្ញៀវរបស់ខ្ញុំផ្សេងៗទៀតហើយមើលទៅ ។ | |

| | | |
|---|---|---|
| អ្នកគ្រូសុខា | : មើល, ឥឡូវសូមរៀបរាប់រឿងដំបៅនេះបន្ថែមទៀតមើល ! | សំណួរបើក ‑ ការតំរង់ទិស |
| នាងណាគ្រី | : និយាយពីអ្វី ? វាអត់ឈឺផងហ្នឹង ...... | |
| អ្នកគ្រូសុខា | : តើនាងមានដំបៅពីអង្កាល ? | សំណួរបិទ‑ ការបង្កការងាយស្រួល |
| នាងណាគ្រី | : អូ ! ១ខែ ហើយមើលទៅ ។ មិត្តភក្តិខ្ញុំនិយាយថា គ្មានអ្វីគួរឱ្យព្រួយទេ, ប៉ុន្តែខ្ញុំគិតថាវាឆ្លងពីមិត្តរបស់ខ្ញុំ ...... បើសិនជាខ្ញុំរកឃើញថាគាត់ឆ្លងពីស្រីណាហើយ... នោះខ្ញុំច្បាស់ជា... | |
| អ្នកគ្រូសុខា | : ណាគ្រីឯងច្បាស់ជាបារម្ភនឹងប្រភពដែលចំលងដំបៅហើយ ប៉ុន្តែខ្ញុំយល់ថា យើងត្រូវកំណត់ថាវាជាស្អីសិន ។ ហើយខ្ញុំ ក៏គិតថាយើងក៏ត្រូវនិយាយអំពី វិធីបង្ការកុំអោយវាកើតម្តងទៀតដែរ ប៉ុន្តែដំបូងខ្ញុំចង់ពិនិត្យមើលដំបៅនោះសិន ខ្ញុំដឹងហើយរឿងនេះវាជារឿងខ្មាសអៀន ប៉ុន្តែខ្ញុំត្រូវការពិនិត្យមើលដើម្បីបញ្ជាក់ថា វាឈឺយ៉ាងម៉េច តើបានឬទេ ? | ការដឹកនាំ<br>ការធានាអះអាង /<br>ការត្រួតពិនិត្យ |
| នាងណាគ្រី | : ចាស៎, ខ្ញុំសន្មត់ថាអញ្ចឹងទៅចុះ (ឆ្លើយដោយស្ទាក់ស្ទើរក្នុងចិត្ត) | |
| អ្នកគ្រូសុខា | : មុននឹងខ្ញុំព្យាបាលណាគ្រីឯង, ខ្ញុំត្រូវតែច្បាស់ថាឈឺអីសិន | ការបង្ហាញភាពជាដៃគូ |
| នាងណាគ្រី | : វាមិនអីទេមែនទេ ? | |
| អ្នកគ្រូសុខា | : ចាស៎, ហើយយើងអាចព្យាបាលវាឱ្យជាតែម្តង ហើយនាងត្រូវតែបង្ការកុំអោយកើតម្តងទៀត, ប៉ុន្តែខ្ញុំនឹងប្រាប់នាងពីអ្វីត្រូវដឹង នឹងជួយឱ្យនាងសំរេចចិត្តថាតើត្រូវធ្វើយ៉ាងម៉េច ។ បានទេ ? | ការធានាអះអាង បង្ហាញភាពជាដៃគូ<br>ការផ្ទៀងផ្ទាត់ |
| នាងណាគ្រី | : ចាស៎, បាន ។ | |

# ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល
# ជំងឺកាមរោគ

# ការគ្រប់គ្រងថែទាំជំងឺកាមរោគ

# ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា  សំរាប់ថ្នាក់មណ្ឌលសុខភាព

ជំពូកទី  ៤

# ការធ្វើរោគវិនិច្ឆ័យ  និងការព្យាបាល

# ជំងឺកាមរោគ

# ជំពូកទី៤

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺកាមរោគ

### មាតិកា


វិធីប្រើប្រាស់គំនូសបំព្រួញ........................៤

ការហូរខ្ទុះតាមបង្ហូរនោម......................  ៧

ដំបៅលើប្រដាប់បន្តពូជ.......................... ១១

ការហូរខ្ទុះតាមទ្វារមាស.......................... ១៥

ការឈឺចុកចាប់នៅផ្នែកខាងក្រោមនៃពោះស្ត្រី.......២២

ជំងឺសិរមាន់នៅលើប្រដាប់បន្តពូជ..................២៥

ការរំលឹកសាឡើងវិញ.............................៣២

សំណួរ និងលំហាត់.............................. ៣៣

ចំលើយ..........................................៤៤


ជំពូកនេះ ផ្តល់ជូនអ្នកនូវការតំរង់ទិសដៅជាក់ស្តែង (orientation) ជាជំហានៗស្តីអំពីគំនូសបំព្រួញផ្សេងៗ ។ ចំពោះគំនូសបំព្រួញនិមួយៗ មានការពិពណ៌នានូវការសំរេចចិត្តនិងការធ្វើសកម្មភាពជាបន្តបន្ទាប់ ។ បញ្ជីឱសថដែលល្អជាងគេ សំរាប់ចង្កោមរោគសញ្ញានិមួយៗ និងកំរិតប្រើប្រាស់ (dose) ដែលណែនាំឱ្យប្រើដោយសារគោលការណ៍ណែនាំជាតិ សំរាប់ព្យាបាលជំងឺកាមរោគ ក៏មានបញ្ចូលទៅក្នុងនោះដែរ ។ ប្រសិនបើអាចធ្វើបាន នឹងមានប្រាប់អំពីជំរើស ក្នុងការព្យាបាលដោយឱសថផ្សេងៗទៀត សំរាប់ស្ថានភាពដែលពុំអាចរកបាននូវឱសថល្អជាងគេមកប្រើបានឬគ្មានប្រសិទ្ធិភាព ។ អ្នកគួរ តែជ្រើសរើសការព្យាបាលដែលសមស្របជាងគេបង្អស់ សំរាប់កន្លែងរបស់អ្នកមកប្រើប្រាស់ ហើយគូសចំណាំនៅក្នុងបញ្ជីជ្រើសរើសឱសថសំរាប់ចង្កោមរោគសញ្ញានិមួយៗ ។ អ្នកនឹងកាន់តែមានភាពងាយស្រួលជាងនេះ ប្រសិនបើអ្នកបានសិក្សាជំពូកទី ២ (ការប្រើប្រាស់នូវគំនូសបំព្រួញសំរាប់គ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកចង្កោមរោគសញ្ញា) និងជំពូកទី៣ (ការស្រង់ប្រវត្តិជំងឺនិងការពិនិត្យអ្នកជំងឺ) ។ ជំពូកទាំងពីរនេះនឹងផ្តល់ជូនអ្នកនូវទិដ្ឋភាពទូទៅ (broad overview) ស្តីពីបច្ចេកទេសនិងភាពស្ទាត់ជំនាញ (skills) ដែលអ្នកត្រូវយកមកប្រើប្រាស់ដើម្បីធ្វើការគ្រប់គ្រងថែទាំករណីកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ។

ក្មេងស្រីជំទង់ម្នាក់មើលផ្ទាំងរូបភាពអប់រំសុខភាពទាក់ទងនឹងជំងឺកាមរោគ ក្នុងកំឡុងពេលដែលនាងរង់ចាំការពិនិត្យ ។



## របៀបប្រើប្រាស់គំនូសបំព្រួញ

| របៀបប្រើប្រាស់គំនូសបំព្រួញ |
|---|
| * សូមចាប់ផ្តើមពីប្រអប់លើបង្អស់នៃគំនូសបំព្រួញនៅត្រង់ប្រអប់ចាប់ផ្តើម (entry-point box) ដែលពិពណ៌នាអំពីការត្អូញត្អែររបស់អ្នកជំងឺ ។ |
| * ប្រមូលយកពត៌មាន ដែលត្រូវការសំរាប់ធ្វើការសំរេចចិត្តដើម្បីកំណត់យកចង្កោមរោគសញ្ញាណាមួយ |
| * ធ្វើការសំរេចចិត្តដោយពឹងផ្អែកលើពត៌មាន ដែលប្រមូលបានហើយប្រមូលយកពត៌មានបន្ថែម ប្រសិនបើត្រូវការ |
| * ធ្វើរោគវិនិច្ឆ័យ |
| * ជ្រើសរើសយកការព្យាបាលដែលត្រូវនឹងរោគវិនិច្ឆ័យ |
| * ផ្តល់ការអប់រំ និងជំរុញការប្រើប្រាស់ស្រោមអនាម័យ |
| * ពិនិត្យមើលលទ្ធភាពក្នុងការបញ្ជូនដៃគូរួមភេទ |

អ្នកត្រូវជ្រើសរើសយកគំនូសបំព្រួញ ដែលសមស្របណាមួយមកប្រើប្រាស់ ក្រោយពេលដែលអ្នកជំងឺពិពណ៌នា អំពីរោគសញ្ញារបស់ខ្លួនភ្លាម ។ នៅពេលដែលអ្នកបន្តអនុវត្តនូវជំហាននានានៃគំនូសបំព្រួញ អ្នកនឹងត្រូវការប្រមូលយកពត៌មានបន្ថែមទៀត ដើម្បីធ្វើរោគវិនិច្ឆ័យ ។ ពត៌មានទាំងនេះបានមកពីការស្រង់ប្រវិត្តជំងឺ និងការ ពិនិត្យអ្នកជំងឺដែលមានភាពខុសៗគ្នាសំរាប់គំនូសបំព្រួញនិមួយៗ ។

នៅចុងបញ្ចប់នៃគំនូសបំព្រួញនិមួយៗ មានប្រអប់ដែលចង្អុលប្រាប់ឱ្យ ធ្វើសកម្មភាពសមស្របណាមួយនោះ ។ ប្រអប់ទាំងនេះរួមមានរោគវិនិច្ឆ័យ និងណែនាំឱ្យអ្នកជ្រើសរើសនូវការព្យាបាលមូលហេតុមួយ ឬច្រើននៃចង្កោមរោគសញ្ញាពិសេសណាមួយ ។ នៅពេលជ្រើសរើសការព្យាបាលអ្នកអាចត្រូវការនូវពត៌មានផ្សេងៗទៀត សំរាប់ស្ត្រីមានផ្ទៃពោះ ឬបំបៅដោះកូន ។ អាចមានប្រអប់ផ្សេងៗទៀត ដែលអាចចង្អុលបង្ហាញអ្នកឱ្យប្រើប្រាស់នូវគំនូសបំព្រួញមួយផ្សេងទៀត។ ហើយក៏អាច

មានប្រអប់ដទៃទៀត ដែលណែនាំឱ្យបញ្ចូលករណីជំងឺដើម្បីពិនិត្យរកមើលនូវផលវិបាកផ្សេងៗរបស់វា (complications) និងប្រាប់ឱ្យអ្នកជំងឺត្រឡប់មកជួបវិញ ដើម្បីធ្វើការពិនិត្យតាមដានជាបន្ត (follow up examination)។ ពុំមានបញ្ចូលឱសថជាក់លាក់ទៅក្នុងគំនូសបំព្រួញទេ ពីព្រោះថានៅក្នុងករណីភាគច្រើនអ្នកត្រូវជ្រើសរើសយកឱសថមកប្រើ ដោយយោលទៅតាមលក្ខណៈនានា (characteristics) របស់អ្នកជំងឺនិងលើប្រសិទ្ធិភាពនិងតំលៃនៃឱសថ ។ ចំពោះរោគវិនិច្ឆ័យនិមួយៗ ដែលមាននៅក្នុងគំនូសបំព្រួញ យើងបានបញ្ចូលបញ្ជីឱសថដែលណែនាំឱ្យប្រើប្រាស់ដោយគោលការណ៍ណែនាំជាតិស្តីពីការថែទាំជំងឺកាមរោគ ។ គំនូសបំព្រួញទាំងអស់រួមមានបញ្ចូលទៅក្នុងនោះនូវការអប់រំក្នុងបំណងធ្វើឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត (education for behavior change) ការជំរុញការប្រើប្រាស់ស្រោមអនាម័យ និងការបញ្ជូនដៃគូរួមភេទឱ្យមកទទួលការថែទាំ ។ បញ្ហាទាំងនោះនឹងមានពិពណ៌នាលំអិតនៅក្នុងជំពូកទី ៥ និងទី ៦ ក៏ប៉ុន្តែយើងអាចធ្វើការពិពណ៌នា ដោយសង្ខេបដូចខាងក្រោមនេះ :

នៅក្នុងវគ្គសិក្សានេះ ការអប់រំសំដៅផ្តោតទៅលើបញ្ហាដូចខាងក្រោម :

- ការទូន្មានអ្នកជំងឺស្តីអំពីសារៈសំខាន់នៃការគោរពតាមវេជ្ជបញ្ជា ជាពិសេសគឺការលេបថ្នាំឱ្យបានចប់ សព្វគ្រប់ ។
- ការពន្យល់អំពីរបៀបឆ្លងនៃកាមរោគ និងផលវិបាកនានា ដែលអាចកើតមានឡើងនៃជំងឺនេះ ។
- ការណែនាំអ្នកជំងឺកុំឱ្យចូលប្រឡូកក្នុងការរួមភេទរហូតដល់ គាត់ជាសះស្បើយ និង
- ការពិភាក្សាអំពីការជ្រើសរើសនានារបស់អ្នកជំងឺ ដែលជាប្រយោជន៍ធ្វើឱ្យការប្រព្រឹត្តរួមភេទ (sexual behavior) របស់គេមានសុវត្ថិភាពជាងមុន ដូចជាការតមមិនរួមភេទ ការរក្សាទំនាក់ទំនងផ្លូវភេទជាមួយដៃគូរួមភេទតែម្នាក់ ការរួមភេទដែលមិនស៊កបញ្ចូល (non penetrative sex) ឬការប្រើប្រាស់ស្រោម អនាម័យឱ្យបានទៀងទាត់ជានិច្ច ។

នៅក្នុងស្ថានភាពខ្លះ អ្នកផ្តល់សេវាថែទាំអាចធ្វើលើសពីការផ្តល់ពត៌មានសុទ្ធសាធ ហើយជួយឱ្យអ្នកជំងឺ យល់អំពី ការជ្រើសរើសនានា ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្តរបស់ពួកគេ ។ ឧទាហរណ៍ អ្នកជំងឺខ្លះអាចមានអារម្មណ៍ថា ពុំអាចតមការរួមភេទបានឡើយ ។ ការពិភាក្សាអំពីស្ថានភាពនេះអាចជួយឱ្យគេរកមធ្យោបាយកាត់បន្ថយការប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគនាអនាគតបាន ។ គួរផ្តល់ការអប់រំដល់អ្នកទាំងឡាយណាដែលមកជួបអ្នកហើយត្អូញត្អែរអំពីបញ្ហាដែលទាក់ទង

នឹងជំងឺកាមរោគ ។ យកល្អត្រូវធ្វើការបង្ហាញ អំពីការប្រើប្រាស់ស្រោមអនាម័យជាជំហានៗសំរាប់រាល់អ្នកជំងឺទាំងអស់ ឬក៏ពិភាក្សាអំពីកន្លែងដែលអាចរកវាបានសំរាប់ប្រើប្រាស់ ។

គួរពិភាក្សាជាមួយអ្នកជំងឺកាមរោគទាំងអស់ អំពីការបញ្ជូន ដៃគូរួមភេទឱ្យមកទទួលការថែទាំ ។ ក្រោយពីបានសុំឱ្យអ្នកជំងឺកំណត់រកឱ្យឃើញដៃគូរួមភេទរបស់គេមក អ្នកត្រូវប្រើប្រាស់នូវភាពស្ទាត់ជំនាញទាំងឡាយ ដែលមាននៅក្នុងវគ្គសិក្សានេះដើម្បីថែទាំអ្នកជំងឺដែលជាដៃគូរួមភេទ របស់អ្នកជំងឺកាមរោគដែលមកពិគ្រោះជំងឺជាមួយអ្នក ។

**ចូរចងចាំ:** ត្រូវសំដែងការគួរសម និងគោរពចំពោះអ្នកជំងឺជានិច្ច ។ អ្នកត្រូវធ្វើឱ្យគេជឿនិងទុកចិត្តលើអ្នកប្រសិនបើអ្នកចង់ផ្តល់នូវការគ្រប់គ្រងថែទាំកាមរោគប្រកបដោយសុវត្ថិភាពនិងមានលក្ខណៈល្អគ្រប់ជ្រុងជ្រោយ ។

## ការហូរខ្ទុះតាមបង្ហូរនោម
**(Urethral Discharge)**

បុរសម្នាក់មកជួបពិគ្រោះជាមួយអ្នកដោយត្អូញត្អែរថាគាត់បានកត់សំគាល់ឃើញថាមានហូរខ្ទុះចេញពីលិង្គរបស់គាត់ ។ ក្នុងករណីនេះ សូមប្រើគំនូសបំព្រួញការហូរខ្ទុះពីបង្ហូរនោម ។

### គំនូសបំព្រួញសំរាប់ការហូរខ្ទុះពីបង្ហូរនោម



 

*ការហូរខ្ទុះតាមបង្ហួរនោមចំពោះបុរសដែលបង្កឡើងដោយមេរោគហ្គោណូកូក និងឬមេរោគក្លាមីឌីយ៉ា*

ស្រង់ប្រវត្តិជំងឺ និងពិនិត្យ
(ច្បូតបង្ហួរនោមបើចាំបាច់)

ប្រអប់នេះ ប្រាប់អ្នកឱ្យពិនិត្យអ្នកជំងឺដើម្បីបញ្ជាក់ឱ្យបានច្បាស់ថា អ្នកជំងឺមានការហូរខ្ទុះពីបង្ហួរនោមពិតប្រាកដមែន ហើយរកមើលក្រែងមានជំងឺកាមរោគ ដទៃៗទៀត ។

សូមពិនិត្យប្រដាប់បន្តពូជខាងក្រៅ ដោយកុំភ្លេចមើលផ្នែកខាងក្នុងនៃស្បែកស្រោបក្បាលលិង្គ និងក្បាលលិង្គ ។ ប្រសិនបើអ្នកជំងឺពុំមានការហូរខ្ទុះទេ សូមឱ្យអ្នកជំងឺច្របាច់លិង្គ និងច្បូតបង្ហួរនោម ។ ក្រោយពីការពិនិត្យអ្នកជំងឺរួច សូមបន្តអនុវត្តប្រអប់ខាងក្រោម ។

តើមានការហូរខ្ទុះពិត
ប្រាកដដែរឬទេ ?

ប្រអប់នេះសួរអ្នកថាតើមាន ឬគ្មានការហូរខ្ទុះដែរឬទេ។ ប្រសិនបើមានសូម បន្ត អនុវត្តប្រអប់ធ្វើសកម្មភាពខាងក្រោមនេះ ។ ប្រសិនបើអ្នកពុំអាចរកឃើញមានការហូរខ្ទុះពីបង្ហួរនោមទេនោះ សូមបន្តអនុវត្តតាមប្រអប់សំរាប់ធ្វើការសំរេចចិត្តដែលស្ថិតនៅខាងស្តាំ ។

- ព្យាបាលជំងឺប្រមេះទឹកបាយ និងជំងឺបង្កដោយមេរោគក្លាមីឌីយ៉ា
- អប់រំអ្នកជំងឺឱ្យផ្លាស់ប្តូរការប្រព្រឹត្ត
- ជំរុញការប្រើប្រាស់ និងផ្តល់ស្រោមអនាម័យ
- គ្រប់គ្រងថែទាំដៃគូរួមភេទ
- ប្រាប់អ្នកជំងឺឱ្យវិលត្រឡប់មកជួបវិញបើចាំបាច់

ប្រអប់នេះ ប្រាប់អ្នកឱ្យធ្វើការគ្រប់គ្រងថែទាំអ្នកជំងឺ (សូមអានការព្យាបាលនៅទំព័រទី៤) ទាំងអស់នៃប្រអប់នេះ ដើម្បីធ្វើការថែទាំអ្នកជំងឺឱ្យបានចប់សព្វគ្រប់ ។ រោគវិនិច្ឆ័យត្រូវបានរកឃើញ ហើយត្រូវផ្តល់ការព្យាបាលជំងឺនានាដែលអ្នកបានរកឃើញភ្លាម ។ សូមរំលឹកឡើងវិញផងដែរថា អ្នកត្រូវតែផ្តល់ការអប់រំជំរុញការប្រើប្រាស់ស្រោមអនាម័យ និងផ្តល់ស្រោមអនាម័យ ឬណែនាំប្រាប់កន្លែងដែលអាចរកវាបាន ។

សូមកុំភ្លេចឱ្យអ្នកជំងឺត្រលប់មកវិញក្នុងរយៈពេលមួយសប្តាហ៍ក្រោយ ប្រសិនបើរោគសញ្ញាពុំបានធូរស្រាលក្រោយពីបានទទួលការព្យាបាលចប់សព្វគ្រប់ ។

- តាមដានក្នុងរយៈពេល ៧ថ្ងៃក្រោយ
- ប្រសិនបើអ្នកជំងឺនៅតែមានរោគសញ្ញាដដែល

នៅពេលដែលអ្នកជំងឺវិលត្រឡប់មកវិញ ដើម្បីពិគ្រោះតាមដានជំងឺ សូមផ្ទៀងផ្ទាត់មើលថាតើជំងឺកាមរោគនេះ បានធូរស្រាលដែរឬទេ ។ ប្រសិនបើបានធូរស្រាលនោះ ការព្យាបាលបានទទួលជោគជ័យ ។

តើមានដំបៅដែរឬទេ ?

ប្រអប់នេះប្រាប់អ្នកធ្វើការសំរេចចិត្តថា អ្នកជំងឺមានដំបៅនៅនឹងប្រដាប់បន្តពូជដែរឬទេ ។ ប្រសិនបើគ្មានភស្តុតាងបញ្ជាក់ថាអ្នកជំងឺមានជំងឺកាមរោគណាមួយផ្សេងៗទៀតនោះ សូមបន្តទៅប្រអប់មួយទៀតនៅខាងស្តាំ ។ ប្រសិនបើមានភស្តុតាងថា មានជំងឺកាមរោគមួយផ្សេងទៀតនោះ សូមបន្តអនុវត្តប្រអប់ធ្វើសកម្មភាពដែលស្ថិតនៅខាងក្រោម ។

- អប់រំធ្វើឱ្យអ្នកជំងឺឱ្យផ្លាស់ប្តូរការប្រព្រឹត្ត
- ជំរុញការប្រើប្រាស់ និងផ្តល់ស្រោមអនាម័យ

ពេលអ្នកអនុវត្តតាមប្រអប់នេះ អ្នកពុំអាចបញ្ជាក់ថា មានវត្តមាននៃការហូរខ្ទុះតាមបង្ហួរនោម ឬជំងឺកាមរោគណាមួយផ្សេងៗទៀតទេ ។ អ្នកអាចខ្វល់ខ្វាយអំពីលទ្ធភាពដែលខ្លួនអាចកើតកាមរោគណាមួយ ដែលជាលទ្ធផលនៃការប្រកាន់នូវការប្រព្រឹត្តរូមភេទដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លង ។ ប្រអប់នេះណែនាំអ្នកធ្វើឱ្យអ្នកជំងឺបាត់ការបារម្ភ ផ្តល់ការអប់រំ និងជំរុញការប្រើប្រាស់ស្រោមអនាម័យ ដោយរួមបញ្ចូលទាំងការផ្តល់នូវស្រោមអនាម័យ ប្រសិនបើអ្នកមានលទ្ធភាព ។

ប្រើគំនូសបំព្រួញសមស្រប

ប្រសិនបើអ្នកមកដល់ប្រអប់នេះ ហើយអ្នកជំងឺមានដំបៅនៅលើប្រដាប់បន្តពូជ អ្នកគ្រាន់តែយកគំនូសបំព្រួញស្តីពីដំបៅនៅលើប្រដាប់បន្តពូជមកប្រើប្រាស់តែប៉ុណ្ណោះជាការស្រេច ។

## ការព្យាបាលការហូរខ្ទុះតាមបង្ហួរនោម

**១. ការព្យាបាលការរលាកបង្ហួរនោមដែលបង្កដោយមេរោគប្រមេះទឹកបាយ** (N. gonorrhea)

- Cefixime 400 ម.ក្រ លេបតែ ១ដងគត់

នៅមន្ទីរពេទ្យបង្អែក គេអាចប្រើប្រាស់នូវឱសថដូចខាងក្រោមនេះ

- Ceftriaxone 250 ម.ក្រ ចាក់សាច់ដុំតែ ១ដងគត់ ឬ
- Specticomycine 2 ក្រ ចាក់សាច់ដុំតែ ១ដងគត់ ។

**រួមជាមួយ**

**២. ការព្យាបាលការរលាកបង្ហួរនោមដែលបង្កដោយមេរោគក្លាមីឌីយ៉ា**

- Doxycycline 100 ម.ក្រ លេប ២ដងក្នុងមួយថ្ងៃ រយៈពេល ៧-១៤ថ្ងៃ ឬ
- Erythromycin 500 មក្រ លេប ៤ដង ក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ។

**កំណត់សំគាល់:** ក្នុងភាគច្រើននៃករណីការផ្តល់ឱសថ Doxycycline រយៈពេល៧ថ្ងៃ ជាការគ្រប់គ្រាន់សំរាប់ជំងឺរលាកបង្ហួរនោមដែលបង្កដោយមេរោគក្លាមីឌីយ៉ា ។

# ដំបៅលើប្រដាប់បន្តពូជ

**( Genital ulcer)**

អ្នកជំងឺម្នាក់មកមណ្ឌលសុខភាពរបស់អ្នកដោយត្អូញត្អែរថាគាត់បានកត់សំគាល់ឃើញថាមានដំបៅនៅលើប្រដាប់បន្តពូជរបស់គាត់ ។ ក្នុងករណីនេះ សូមប្រើគំនូសបំព្រួញដំបៅនៅលើប្រដាប់បន្តពូជ ។

## គំនូសបំព្រួញសំរាប់ដំបៅនៅលើប្រដាប់បន្តពូជ







*ដំបៅនៅលើប្រដាប់បន្តពូជ*





ស្រង់ប្រវត្តិ និងពិនិត្យអ្នកជំងឺ

ប្រអប់នេះប្រាប់អ្នកអោយពិនិត្យអ្នកជំងឺ ដើម្បីរកមើលវត្តមាននៃដំបៅនៅប្រដាប់បន្តពូជ ឬកាមរោគណាមួយផ្សេងទៀត ។ ដំបៅ គឺការស៊ីដាច់ខូចផ្ទៃស្បែក ឬភ្នាសសើម ។

- ចំពោះបុរស សូមពិនិត្យមើលប្រដាប់បន្តពូជខាងក្រៅ ។ សូមកុំភ្លេចមើលផ្ទៃខាងក្នុងនៃស្បែកគ្របក្បាលលិង្គ និងក្បាលលិង្គ ។
- ចំពោះស្ត្រី សូមពិនិត្យស្បែកនៃប្រដាប់បន្តពូជខាងក្រៅ ។ សូមញែកបបូរធំទាំងពីរ ដើម្បីពិនិត្យមើលដំបៅនៅលើភ្នាសសើម ។ នៅពេលអ្នកធ្វើការពិនិត្យសូមពាក់ស្រោមដៃ ។

តើមានដំបៅដែរឬទេ ?

ប្រសិនបើមានដំបៅនៅនឹងប្រដាប់បន្តពូជ សូមបន្តទៅប្រអប់បន្ទាប់ដែលស្ថិតនៅខាងក្រោមវា ។ ប្រសិនបើអ្នករកពុំឃើញមានដំបៅនៅប្រដាប់បន្តពូជទេ សូមបន្តទៅប្រអប់ខាងស្តាំដៃ ។

- ព្យាបាលជំងឺស្វាយ និងជំងឺ chancroid
- អប់រំឱ្យអ្នកជំងឺផ្លាស់ប្តូរការប្រព្រឹត្ត
- ជំរុញ និងផ្តល់ស្រោមអនាម័យ
- គ្រប់គ្រងថៃទាំដៃគូរួមភេទ
- ណែនាំឱ្យត្រលប់មកជួបវិញ បើចាំបាច់

ប្រអប់នេះ ប្រាប់អ្នកឱ្យព្យាបាលជំងឺស្វាយ និង chancroid ជូនអ្នកជំងឺ ។ វាក៏ប្រាប់អ្នកផងដែរ អោយអប់រំជំរុញការប្រើប្រាស់ស្រោមអនាម័យ និងប្រាប់អ្នកជំងឺវិលត្រឡប់មកជួបអ្នកវិញក្នុងរយៈពេល ៧ថ្ងៃក្រោយ បើរោគសញ្ញាពុំបានធូរស្រាលទេ ។ អ្នកគួរផ្តល់ដំបូន្មានដល់អ្នកជំងឺ អោយអនុវត្តតាមការព្យាបាល

ហើយពិភាក្សាអំពីរបៀបដែលគាត់ឆ្លង ជំងឺនេះ និងផលវិបាករបស់វា ។

- តាមដានក្នុងរយៈពេល ៧ថ្ងៃក្រោយ
- ប្រសិនបើ អ្នកជំងឺនៅតែមានរោគសញ្ញាដដែល សូមបញ្ជូនអ្នកជំងឺ

នៅពេលដែលអ្នកជំងឺវិលត្រឡប់មកវិញ ដើម្បីពិគ្រោះតាមដានជំងឺ សូមផ្ទៀងផ្ទាត់មើលថា តើអ្នកជំងឺកាមរោគនេះបានធូរស្រាលដែរឬទេ ? ប្រសិនបើបានធូរស្រាល នោះការព្យាបាលទទួលជោគជ័យ ។ ប្រសិនបើគ្មានការធូរស្រាលទេ សូមបញ្ជូនអ្នកជំងឺ ។

តើមានពងបែកដែរឬទេ?

ប្រសិនបើគ្មានដំបៅទេ ប្រអប់នេះប្រាប់អ្នកឱ្យពិនិត្យរកមើលវត្តមាននៃពងទឹក (vesicular lesions) ។ ពងទឹកទាំងនោះ ជាពងតូចៗដែលប្រមូលផ្តុំគ្នាជាកញ្ចុំៗ មុនពេលដែលវាបែកហើយបង្កជាដំបៅតូចៗ ។ ប្រសិនបើអ្នកពុំអាចរកឃើញពងទឹកទាំងនោះទេ សូមបន្តអនុវត្តតាមប្រអប់ដែលស្ថិតនៅខាងស្តាំដៃ ។ ប្រសិនបើមាន សូមបន្តអនុវត្តតាមប្រអប់ដែលស្ថិតនៅជាប់ពីខាងក្រោម ។

- អប់រំអោយអ្នកជំងឺផ្លាស់ប្តូរការប្រព្រឹត្ត
- ជំរុញការប្រើប្រាស់ និងផ្តល់ស្រោមអនាម័យ

មកដល់ចំណុចនេះអ្នកពុំអាចបញ្ជាក់ថា មានវត្តមានជំងឺកាមរោគទេ ។ ក៏ប៉ុន្តែអ្នកជំងឺអាចភ័យបារម្ភថា អាចកើតកាមរោគក្រោយពីបានប្រកាន់យកនូវការប្រព្រឹត្តរួមភេទ ដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងមេរោគ ។ ដូច្នេះ ប្រអប់នេះរំលឹកអ្នកឱ្យធ្វើឱ្យអ្នកជំងឺ បាត់នូវការភ័យបារម្ភ ផ្តល់ការអប់រំ ជំរុញការប្រើប្រាស់ និងផ្តល់ស្រោមអនាម័យ បើអ្នកអាចមានលទ្ធភាព ។

- គ្រប់គ្រងថែទាំជំងឺដំបៅពងបែកលើប្រដាប់បន្តពូជ (genital herpes)
- អប់រំឱ្យអ្នកជំងឺផ្លាស់ប្តូរការប្រព្រឹត្ត
- ជំរុញការប្រើប្រាស់ និងផ្តល់ស្រោមអនាម័យ

ប្រអប់នេះ ប្រាប់អ្នកឱ្យអប់រំអ្នកជំងឺស្តីពីការថែទាំព្យាបាលជំងឺដំបៅពងបែកនៅលើប្រដាប់បន្តពូជ ។ អ្នកគួរប្រាប់អ្នកជំងឺថា ទោះបីជាជំងឺនេះព្យាបាលពុំជាក៏ដោយក៏វានឹងបាត់ទៅវិញដោយខ្លួនឯង ហើយអាចរើឡើងវិញ ។ សូមពន្យល់អំពីសារៈសំខាន់នៃការរក្សាកន្លែងឈឺចាប់នេះ អោយស្ងួត និងស្អាត ហើយទូន្មានអ្នកជំងឺកុំឱ្យគាត់រួមភេទនៅពេលដែលដំបៅនោះមិនទាន់ជាសះស្បើយ ហើយរង់ចាំរហូតដល់វាជា ។

***កំណត់សំគាល់***: *ការបែងចែកឱ្យដាច់រវាងជំងឺស្វាយ និងជំងឺchancroid តាមរយៈទិដ្ឋភាពគ្លីនិក មានការពិបាក ។ ការឆ្លងរោគចំរុះ គឺមាន ជាញឹកញាប់ ។ វាជាការចាំបាច់ ដែលត្រូវព្យាបាលអ្នកជំងឺដែលមាន ដំបៅលើប្រដាប់បន្តពូជដោយ ពឹងផ្អែកលើចង្កោមរោគសញ្ញា ។*

## ការព្យាបាលដំបៅលើប្រដាប់បន្តពូជ

✶ **ការព្យាបាលជំងឺស្វាយ និងជំងឺ** *Chancroid*

*១- ការព្យាបាលជំងឺស្វាយ (Syphilis):*

- ☐ Benzathin Penicillin G 2,4 លាន IU ចាក់សាច់ដុំតែ ១ដង ។

ចំពោះអ្នកជំងឺដែលពុំអាចប្រើថ្នាំ Penicillin បានសូមប្រើ:

- ☐ Doxycycline 100mg លេបពីរដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ ឬ
- ☐ Tetracycline 500mg លេប៤ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ ឬ
- ☐ Erythromycin 500mg លេបពីរដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ ។

*២- ការព្យាបាលជំងឺ Chancroid*

- ☐ Cyprofloxacin 500mg លេបតែ ១ដង ឬ

ចំពោះការព្យាបាលផ្សេងៗទៀតគេអាចប្រើឱសថដូចខាងក្រោមនេះ

- ☐ Erythromycin 500mg លេបពីរដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ឬ
- ☐ Cotrimoxazole 960mg លេបពីរដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ។

✶ **ការព្យាបាលជំងឺពងបែកនៅលើប្រដាប់បន្តពូជ** *(genital herpes)*

- ☐ លាងសំអាតដំបៅជាមួយទឹកសាប៊ូដើម្បីរក្សាកន្លែងនោះឱ្យស្អាត ហើយស្ងួត ឬ
- ☐ លាប Gentian violet 0,5% ពីរដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ឬ
- ☐ Aciclovir 200mg លេប៥ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ

**ចំណាំ :** ហាមប្រើ ciprofoxacin, doxycycline, tetracycline, cotrimoxazole នៅពេលមានផ្ទៃពោះ ឬបំបៅដោះកូន ។

: Aciclovir គឺជាឱសថដែលមានតំលៃថ្លៃ ហើយត្រូវអនុញ្ញាតឱ្យប្រើប្រាស់តែទៅតាមលទ្ធភាពរបស់អ្នកជំងឺ ឬមណ្ឌលសុខភាពនិមួយៗ ។

## ការហូរខ្ទុះតាមទ្វារមាស/ធ្លាក់ស

**(Vaginal discharge)**

ចំពោះស្ត្រីការធ្លាក់សបន្តិចបន្តួចជាបញ្ហាធម្មតា ។ ស្ត្រីអាចកត់សំគាល់ឃើញថាមានធ្លាក់ស ច្រើនជាងធម្មតានៅដំណាក់កាលផ្សេងនៃវដ្តរដូវ ក្នុងពេលឬក្រោយពេលរួមភេទ ឬពេល មានគភ៌ ឬបំបៅកូន ។

### គំនូសបំព្រួញសំរាប់ការធ្លាក់ស/ការហូរខ្ទុះតាមទ្វារមាស







***ជំងឺរលាកមាត់ស្បូនដែលបង្កឡើងដោយមេរោគហ្គោណូកូក និងមេរោគក្លាមីឌីយ៉ា***







***ជំងឺរលាកទ្វារមាសដែលបង្កឡើងដោយមេរោគទ្រីកូម៉ូណាស់ ផ្សិតកង់ឌីដាស់ និង Bacterial Vaginosis***

ជារឿយៗ ស្ត្រីតែងត្អូញត្អែរថាមានធ្លាក់សនៅពេលដែលគាត់គិតថា សនោះមានលក្ខណៈមិនប្រក្រតីចំពោះគាត់ ឬនៅពេលវាបង្កឱ្យរមាស់ ឬពិបាកទ្រាំ ។ ស្ត្រីច្រើនតែមិនមកស្វែងរកការថែទាំការធ្លាក់ស ដែលខ្លួនចាត់ទុកថាជាការធ្លាក់ធម្មតានោះទេ ។ ស្ត្រីមានធ្លាក់សមិនប្រក្រតី ប្រសិនបើគាត់មានកើតជំងឺរលាកទ្វារមាស (vaginitis) ជំងឺរលាកមាត់ស្បូន (cervicitis) ឬជំងឺទាំងពីរជាមួយគ្នា ។ ការបែងចែកជំងឺទាំងពីរនេះឱ្យដាច់ពីគ្នាមានសារៈប្រយោជន៍ណាស់ ពីព្រោះជំងឺរលាកមាត់ស្បូនបង្កឱ្យមានផលវិបាកធ្ងន់ធ្ងរ ។ ដូច្នេះការព្យាបាលដៃគូរួមភេទរបស់អ្នកជំងឺ

ដើម្បីចៀសវាងការឆ្លងជំងឺឡើងវិញ គឺជាអាទិភាព ។ ភាពខុសគ្នារវាងជំងឺរលាកទ្វារមាសនិងរលាកមាត់ស្បូនមានសង្ខេបនៅតារាងខាងក្រោមនេះ ៖

| **ភាពខុសគ្នារវាងជំងឺរលាកទ្វារមាស និងជំងឺរលាកមាត់ស្បូន** | |
|---|---|
| *ជំងឺរលាកទ្វារមាស* | *ជំងឺរលាកមាត់ស្បូន* |
| ▪ ជាជំងឺដែលបង្កឡើងដោយមេរោគ ទ្រីកូម៉ូណាស់ ផ្សិតកង់ឌីដាស និងជំងឺទ្វារមាសដែលបង្កឡើងដោយបាក់តេរី (bacterial vaginosis) | ▪ បង្កដោយជំងឺប្រមេះទឹកបាយ និងជំងឺបង្កឡើងដោយមេរោគក្លាមីឌីយ៉ា |
| ▪ ជាមូលហេតុញឹកញាប់ជាងគេដែលធ្វើឱ្យធ្លាក់ស | ▪ មិនមែនជាមូលហេតុញឹកញាប់ដែលបង្កឱ្យធ្លាក់សទេ |
| ▪ ងាយធ្វើរោគវិនិច្ឆ័យ | ▪ ពិបាកធ្វើរោគវិនិច្ឆ័យ |
| ▪ មិនចាំបាច់ព្យាបាលដៃគូរួមភេទទេ | ▪ ត្រូវព្យាបាលដៃគូរួមភេទ |

ក៏ប៉ុន្តែជាអកុសល ការបែងចែកជំងឺរលាកមាត់ស្បូនឱ្យដាច់ពីជំងឺរលាកទ្វារមាសមិនមែនជារឿងងាយទេ ជាពិសេសគឺនៅពេលដែលពុំអាចពិនិត្យប្រដាប់បន្តពូជផ្នែកក្នុងបាន ។ នៅចន្លោះពេលនេះ មធ្យោបាយដ៏ល្អសំរាប់រកឃើញជំងឺរលាកមាត់ស្បូន គឺការសួរនូវសំណួរមួយចំនួន ។ ចំលើយទៅនឹងសំណួរទាំងនេះអាចបញ្ជាក់ថា តើស្ត្រីម្នាក់ទំនងជាអាចកើតជំងឺរលាកមាត់ស្បូនឬអត់នោះ ។ សំណួរដែលសួរអំពីកត្តាប្រឈមមុខនឹងការកើតជំងឺរលាកមាត់ស្បូនមានដូចខាងក្រោមនេះ ។

| តើអ្នកត្រូវសួរអំពីកត្តាប្រឈមមុខនឹងគ្រោះថ្នាក់អ្វីខ្លះ ? |
| --- |
| - តើអ្នកជំងឺមានអាយុតិចជាង ២៥ ឆ្នាំ មែនដែរឬទេ ?<br>- តើអ្នកជំងឺជាស្ត្រីមិនទាន់រៀបការ ហើយជាអ្នកមានសកម្មភាពផ្លូវភេទមែនដែរឬទេ ?<br>- តើអ្នកជំងឺមានរួមភេទជាមួយដៃគូរួមភេទលើសពីម្នាក់ ក្នុងរយៈពេល ៣ ខែ កន្លងទៅមែនដែរឬទេ ?<br>- តើអ្នកជំងឺបានរួមភេទជាមួយដៃគូរួមភេទថ្មីម្នាក់ទៀតក្នុងរយៈពេល ៣ ខែកន្លងទៅមែនដែរឬទេ ?<br>✶ ប្រសិនបើអ្នកជំងឺឆ្លើយយល់ស្របទៅនឹងសំណួរពីរ ក្នុងសំណួរទាំងនេះ គេត្រូវព្យាបាល ជំងឺទាំងពីរ គឺរលាកមាត់ស្បូន និងរលាកទ្វារមាសជូនគាត់ ។ |

ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់:
★ គួញត្អែរថាមានឈឺចាប់ផ្នែកខាងក្រោមនៃពោះ ឬ
★ ដៃគូមានរោគសញ្ញា ឬ
★ កត្តាប្រឈមមុខនឹងគ្រោះថ្នាក់វិជ្ជមាន

ដូចមានបញ្ជាក់នៅក្នុងប្រអប់នេះស្រាប់ គេពុំចាំបាច់ពិនិត្យអ្នកជំងឺទេ ។ អ្នកផ្តល់សេវាគ្រាន់តែសួរសំណួរបី ជាជំនួសវិញ គឺ :

១. តើអ្នកជំងឺមានការឈឺចាប់នៅផ្នែកខាងក្រោមនៃពោះដែរឬទេ ?
២. តើដៃគូរួមភេទរបស់អ្នកជំងឺមានរោគសញ្ញាដែរឬទេ ?
៣. តើស្ថានភាពរបស់អ្នកជំងឺវាត្រូវនឹងកត្តាប្រឈមមុខនឹងគ្រោះថ្នាក់នៃ ការកើតជំងឺរលាកមាត់ស្បូន ដែរ ឬទេ ? ( កត្តាប្រឈមមុខនឹងគ្រោះថ្នាក់វិជ្ជមាន) ។

- ព្យាបាលជំងឺរលាកទ្វារមាស
- អប់រំអ្នកជំងឺឱ្យផ្លាស់ប្តូរការប្រព្រឹត្ត
- ជំរុញការប្រើប្រាស់ និងផ្តល់ស្រោមអនាម័យ

ប្រសិនបើ អ្នកទទួលបានចំលើយបដិសេធទៅនឹងសំណួរទាំងនេះ គេត្រូវព្យាបាលជំងឺរលាកទ្វារមាសតែមួយមុខបានហើយ ។

- ព្យាបាលជំងឺរលាកទ្វារមាស និងរលាកមាត់ស្បូន
- អប់រំដើម្បីឱ្យអ្នកជំងឺផ្លាស់ប្តូរការប្រព្រឹត្ត
- ជំរុញការប្រើប្រាស់ និងផ្តល់ស្រោមអនាម័យ
- គ្រប់គ្រងថែទាំដៃគូរួមភេទ
- ប្រាប់ឱ្យវិលត្រឡប់មកជួបវិញ បើចាំបាច់

ប្រសិនបើ អ្នកជំងឺឆ្លើយស្រមទៅនឹងសំណួរពីរក្នុងចំណោមសំណួរទាំងនេះ គេត្រូវព្យាបាលជំងឺទាំងពីរ គឺរលាកមាត់ស្បូន និងរលាកទ្វារមាសជូនអ្នកជំងឺ ។

- តាមដានក្នុងរយៈពេល ៧ថ្ងៃក្រោយ
- ប្រសិនបើអ្នកជំងឺនៅតែមានរោគសញ្ញាដដែល សូមបញ្ជូនអ្នកជំងឺ

នៅពេលដែលអ្នកជំងឺវិលត្រឡប់មកវិញ ដើម្បីពិគ្រោះតាមដានជំងឺ សូមផ្ទៀងផ្ទាត់មើលថា តើជំងឺកាមរោគនេះបានធូរស្រាលដែរ ឬទេ ។ ប្រសិនបើបានធូរស្រាលនោះការព្យាបាលបានទទួលជោគជ័យ ។ ផ្ទុយទៅវិញបើគ្មានការធូរស្រាលទេ សូមបញ្ជូនអ្នកជំងឺ ។

## ការព្យាបាលជំងឺរលាកទ្វារមាស (vaginitis)

✶ **ការព្យាបាលជំងឺបង្កដោយមេរោគទ្រីកូម៉ូណាស់** (Trichomonasis) **និងជំងឺបង្កដោយមេរោគ បាក់តេរី** (bacterial vaginosis)

- ☐ Metronidazole 2g លេបតែ ១ដង ត្រូវលេបនៅមណ្ឌលសុខភាពក្រោមការត្រួតពិនិត្យពីបុគ្គលិកសុខាភិបាល ***ឬ***
- ☐ Metronidazole 500 mg លេប២ដង ក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ប្រសិនបើវិធីទី១ គ្មាន ប្រសិទ្ធិភាព ។

**ចំណាំ:** ហាមប្រើ Metronidazole ក្នុងកំឡុងត្រីមាសទី១ នៃគភ៌ ហើយត្រូវប្រាប់អ្នកជំងឺ កុំឱ្យផឹកជាតិសុរានៅពេលលេបឱសថនេះ ។

### រួមជាមួយនឹង

✶ **ការព្យាបាលជំងឺផ្សិតកង់ឌីដាស់នៅទ្វារមាស** (vaginal candidasis)

- ☐ Clotrimazole 500mg សុលទ្វារមាសតែ ១ដង ***ឬ***
- ☐ Miconazole ឬ clotrimazole 200mg សុលទ្វារមាសតែ ១ដងក្នុងមួយថ្ងៃ រយៈពេល ៣ថ្ងៃ ***ឬ***
- ☐ Nystatine 200 000IU សុលទ្វារមាសតែ ១ដង ក្នុងមួយថ្ងៃរយៈពេល ៧ថ្ងៃ ឬ
- ☐ Gentian violet 0,5% លាបទ្វារមាស ១ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ។

**ចំណាំ:** គេពុំចាំបាច់ព្យាបាលដៃគូរួមភេទរបស់អ្នកជំងឺទេ ពីព្រោះជំងឺរលាកទ្វារមាសកំរនឹងបង្កឱ្យមានផលវិបាកណាស់ ។ ចំពោះបុរស ជំងឺបង្កដោយ trichomonas នឹងបាត់ទៅវិញដោយខ្លួនឯង ។

## ការព្យាបាលជំងឺរលាកទ្វារមាស (vaginitis) និងរលាកមាត់ស្បូន (cervicitis)

✶ **ព្យាបាលជំងឺរលាកទ្វារមាស ដូចប្រអប់មុន**

**រួមជាមួយនឹង**

✶ **ព្យាបាលជំងឺរលាកមាត់ស្បូនបង្កដោយមេរោគហ្គោណូកុក** (N. gonorrhoea)

- ☐ Cefixime 400mg លេបតែ ១ដងគត់ឬ

នៅមន្ទីរពេទ្យបង្អែកគេអាចប្រើ :

- ☐ Ceftriaxone 250mg ចាក់សាច់ដុំតែ ១ដងគត់ ឬ
- ☐ Spectinomycine 2g ចាក់សាច់ដុំតែ ១ដងគត់ ។

**រួមជាមួយនឹង**

✶ **ព្យាបាលជំងឺរលាកមាត់ស្បូនបង្កដោយមេរោគក្លាមីឌីយ៉ា (Chlamydia)**

- ☐ Doxycycline 100mg លេប ២ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ទៅ១៤ថ្ងៃ ឬ
- ☐ Erythromycine 500mg លេប ៤ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ទៅ១៤ថ្ងៃ ។

**ចំណាំ:** ហាមប្រើ Doxycycline ពេលមានផ្ទៃពោះ ឬបំបៅដោះកូន ។ ក្នុងករណីភាគច្រើនការប្រើឱសថ Doxycycline ក្នុងរយៈពេល៧ថ្ងៃ ជាការគ្រប់គ្រាន់សំរាប់ព្យាបាលជំងឺរលាកមាត់ស្បូនដែលបង្កឡើងដោយមេរោគក្លាមីឌីយ៉ា ។

# ការឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះស្ត្រី
**(Lower Abdominal Pain)**

ពាក្យថា "ជំងឺរលាកប៉េលវីស" (Pelvic inflammatory Disease : PID) ចង់សំដៅទៅលើការឆ្លងមេរោគទៅប្រដាប់បន្តពូជផ្នែកខាងលើរបស់ស្ត្រីដូចជា ស្បូន ដៃស្បូន អូវ៉ែរនិងប្រហោងប៉េលវីស (pelvic cavity) ។ ជំងឺនេះកើតឡើងនៅពេលដែលមានការឆ្លងមេរោគរាលទៅលើតាមរយៈមាត់ស្បូន (cervix) ។ វាអាចបង្កឡើងដោយជំងឺប្រមេះទឹកបាយ ជំងឺដែលបង្កដោយមេរោគក្លាមីឌីយ៉ា និងមេរោគបាក់តេរីអាណាអេរ៉ូប៊ីផ្សេងៗ (anaerobic bacteria) ។



# គំនូសបំព្រួញសំរាប់ការឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះស្ត្រី



ជំងឺរលាកប៉េលវីសរួមបញ្ចូលការរលាកស្រទាប់ខាងក្នុងនៃស្បូន (endometritis) ការរលាកដៃស្បូន (salpingitis) ការកខ្ទុះនៅដៃស្បូននិងអូវែរ (tubo-ovarian abscess) និងការរលាកស្រោមពោះនៅតំបន់ប៉េលវីស (pelvic peritonitis) ។ វាក៏អាចបណ្ដាលឱ្យកើតជាការរលាកស្រោមពោះទាំងមូល (generalized peritonitis) ដែលជាលក្ខខណ្ឌមួយអាចបណ្ដាលឱ្យស្លាប់បាន ។ ជំងឺរលាកដៃស្បូនអាចបណ្ដាលឱ្យស្ទះដៃស្បូន ដែលជាហេតុបង្កឱ្យមានការថយចុះនូវសមត្ថភាពបន្តពូជ ឬពុំអាចមានសមត្ថភាពបន្តពូជបាន (total sterility) តែម្ដងប្រសិនបើមានការប៉ះពាល់ដល់ដៃស្បូនទាំងសងខាង ។ វាក៏អាចបណ្ដាលឱ្យមានជិតរន្ធដៃស្បូនមិនទាំងស្រុង (partial tubal obstruction) ដែលអាចឱ្យស្ពែម៉ាតូសូអ៊ីតដែលមានមាឌតូចៗឆ្លងកាត់បាន ។ ប៉ុន្តែពុំអាចឱ្យអូវុលដែលជួបប្រសព្វជាមួយស្ពែរម៉ាតូសូអ៊ីតរួចហើយនោះ ឆ្លងកាត់វាបានទេ ។ ផលវិបាកនោះ គឺអាចជាភាពមានគភ៌ក្រៅស្បូន (ectopic pregnancy) ឬការកកូននៅក្នុងដៃស្បូន (tubal pregnancy) ដែលអាចធ្លាយជាយថាហេតុ ហើយបណ្ដាលឱ្យមានហូរឈាមយ៉ាងច្រើននៅក្នុងពោះ និងអាចបណ្ដាលឱ្យស្លាប់បាន ។

ស្ត្រីដែលកើតជំងឺជំងឺរលាកប៉េលវីស ច្រើនតែមានប្រវត្តិឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះនិងធ្លាក់ស ។ ប្រសិនបើស្ត្រីមានរោគសញ្ញាឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ សូមប្រើប្រាស់នូវគំនូសបំព្រួញខាងលើនេះ ។

អ្នកជំងឺត្អូញត្អែរថាមានមាឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ

ចំណុចចាប់ផ្ដើមនៃគំនូសបំព្រួញនេះ គឺរោគសញ្ញាឈឺចុកចាប់ផ្នែក ខាងក្រោមនៃពោះ ។ អ្នកអាចប្រើគំនូសបំព្រួញនេះ ចំពោះអ្នកជំងឺដែលត្អូញត្អែរថា មានឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះនិងធ្លាក់សផង ។

ស្រង់ប្រវត្តិនិងពិនិត្យអ្នកជំងឺ

ប្រអប់បន្ទាប់នេះ ណែនាំអ្នកឱ្យស្រង់ប្រវត្តិនិងធ្វើការពិនិត្យអ្នកជំងឺ ។ នៅពេលស្រង់ប្រវត្តិជំងឺ អ្នកត្រូវរកមើលរោគសញ្ញាដទៃៗទៀត ដូចជាការហូរឈាមមិនទៀងទាត់ (erratic bleeding) ការក្រមករដូវឬបាត់រដូវ (overdue or missed periods) ការទើបពន្លូតកូនឬសំរាលកូនហើយការហូរឈាមមិនទៀងទាត់ អាចជារោគសញ្ញានាំមុខនៃភាពមានគភ៌ក្រៅស្បូន ។ ជាដំបូងអ្នកត្រូវសួរនូវសំណួរដូចតទៅនេះ :

- តើអ្នកមានបញ្ហាអ្វីដែលទាក់ទងនឹងការមករដូវដែរឬទេ ?
- តើអ្នកមានធ្លាក់ឈាមពីទ្វារមាសដែរឬទេ ?

- តើអ្នកទើបនឹងរលូតកូន ពន្លូតកូន ឬទើបនឹងសំរាលកូនរួច ក្នុងរយៈពេល ៦ អាទិត្យ ចុងក្រោយ នេះដែរ ឬទេ ?

| បញ្ជីសំរាប់ពិនិត្យអ្នកជំងឺដែលមានឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ |
|---|
| ❑ យកសីតុណ្ហភាពខ្លួន ។ |
| ❑ ស្ទាបពោះរកមើលការឈឺចាប់ពេលស្ទាបពោះ (tenderness) ការឈឺចាប់ពេលដកដៃដែលស្ទាបចេញភ្លាម (rebound tenderness) ការកន្ត្រាក់រឹងនៃសាច់ដុំពោះ (guarding) ដុំសាច់ (mass) ។ |
| ❑ ការហូរឈាមពីទ្វារមាស |
| ❑ ការធ្លាក់សមិនប្រក្រតី |

នៅពេលពិនិត្យអ្នកជំងឺ អ្នកត្រូវយកសីតុណ្ហភាពខ្លួនរបស់អ្នកជំងឺ ។ កំដៅខ្លួនឡើងខ្លាំង បញ្ជាក់ថា មានការឆ្លងមេរោគណាមួយហើយ (infection) ។

សូមស្ទាបពោះដើម្បីរកមើលការឈឺចុកចាប់ពេលស្ទាប (tenderness) ការឈឺចាប់ពេលដកដៃស្ទាបចេញភ្លាម (rebound tenderness) ការកន្ត្រាក់រឹងនៃសាច់ដុំពោះ (guarding) និងដុំសាច់ក្នុងពោះ (mass) ។ ដំបូងត្រូវស្ទាបពោះសើៗសិន ដើម្បីរកមើលការឈឺចាប់ ពេលស្ទាបពោះថ្នមៗនេះ (tenderness)។ បន្ទាប់មកស្ទាបពោះសង្កត់ឱ្យជ្រៅនិងដោយ ប្រុងប្រយ័ត្ន សូមសង្កត់ដៃចុះ ថ្នមៗ និងយឺតៗនៅកន្លែងដែលអ្នកឃើញថា មានការឈឺចាប់នៅពេលស្ទាបថ្នមៗនេះ ។ រួចមកដកដៃចេញវិញយ៉ាងលឿន ។ បើមានការឈឺចាប់នៅពេល នេះគេហៅថា ជាការឈឺចាប់ពេលដកដៃចេញភ្លាម (rebound tenderness) ។

នៅពេលដែលស្រោមពោះរលាក ពេលស្ទាបពោះសាច់ដុំពោះឡើងកន្ត្រាក់រឹងហើយ មិនអាចសង្កត់ចុះបានទេ ។ នេះហៅថា ការកន្ត្រាក់រឹងនៃសាច់ដុំ (guarding) ។ ការកន្ត្រាក់រឹងនៃសាច់ដុំពោះ និងការឈឺចុកចាប់នៅពេលដកដៃស្ទាបចេញភ្លាមនោះ គឺជាលក្ខណៈសំគាល់

នៃការរលាកស្រោមពោះ (peritonitis) និងការកខ្ទុះនៅក្នុងប្រហោងពោះ (intra - abdominal abscess) ។

ការស្ទាបពោះថ្មមៗក៏អាចឱ្យ អ្នករកឃើញនូវវត្តមាននៃ ដុំនៅក្នុងពោះអ្នកជំងឺបានដែរ ។ ដុំនេះហៅថា ដុំសាច់ក្នុងពោះ(mass) ។ នៅពេលស្ទាបសង្កត់ធ្ងន់នៅផ្នែកខាងឆ្វេង និងខាងស្តាំនៃផ្នែកខាងក្រោមនៃពោះ អ្នកអាចរកឃើញនូវដុំដែលឈឺស្ថិតនៅក្នុងប្រហោងប៉ែលវីស (pelvic cavity) ។ ដុំនេះ ជាការកខ្ទុះនៅក្នុងដៃស្បូន ឬអូវែ (tubo-ovarian abscess) ។



*វិធីពិនិត្យអ្នកជំងឺដោយ*

*មិនប្រើគ្រែពិនិត្យរោគស្ត្រី ឬ*

*ស្ពេគុយឡូម*

- បាត់ ឬក្រមករដូវ
- ទើបសំរាលកូនឬពន្លូតកូនថ្មីៗ ឬ
- ឈឺចាប់ពោះពេលដកដៃស្ទាប ចេញពីពោះភ្លាមឬ
- ការកន្ត្រាក់រឹងនៃសាច់ដុំពោះឬ
- ហូរឈាមពីទ្វារមាស

ប្រអប់នេះរៀបរាប់អំពីរោគសញ្ញា និងសញ្ញានានាដែលអ្នកត្រូវបញ្ជូនអ្នកជំងឺ ។ ប្រសិនបើអ្នកពិនិត្យឃើញ ឬប្រវត្តិអ្នកជំងឺប្រាប់អ្នកឱ្យដឹងអំពីសញ្ញា ឬរោគសញ្ញាណាមួយក្នុងចំណោមសញ្ញា ឬរោគសញ្ញាទាំងនេះ សូមបន្តអនុវត្តប្រអប់ “បញ្ជូន” នៅខាងក្រោមនេះ ។ ប្រសិនបើអ្នកជំងឺពុំមានរោគសញ្ញា និងសញ្ញាទាំងនេះទេ សូមបន្តអនុវត្តប្រអប់នៅផ្នែកខាងស្តាំ ។

បញ្ជូន

ប្រអប់នេះ ប្រាប់អ្នកឱ្យបញ្ជូនជាបន្ទាន់នូវអ្នកជំងឺទាំងឡាយណាដែលអាចនឹងមានជំងឺធ្ងន់ធ្ងរទៅកាន់មន្ទីរពេទ្យបង្អែកដើម្បីធ្វើការព្យាបាល :

- ផលវិបាកនៃភគ៌ក្រៅស្បូន ឬ

- ការលាកស្រោមពោះឬការករខ្ទុះនៅក្នុងដៃស្បូននិងអូវែរ ។

- សីតុណ្ហភាព ៣៨ °C ឬ
- មានការឈឺចាប់ពេលពិនិត្យឬ
- ធ្លាក់ស

ប្រអប់នេះទាមទារឱ្យអ្នកធ្វើការសំរេចចិត្តមួយទៀតដោយពឹងផ្អែកវត្តមានឬអវត្តមាននៃគ្រុនក្តៅ ។ ៣៨ °C ឬលើសពីនេះ ឬការឈឺចាប់នៅពេលស្ទាបថ្នមៗ ឬការធ្លាក់ស ។

- ប្រសិនបើអ្នកជំងឺក្តៅខ្លួន ឬមានការឈឺចាប់ពេលស្ទាបពោះ ឬធ្លាក់ស សូមព្យាបាលជំងឺរលាកប៉េលវីស (PID) ជូនគាត់ដូចក្នុងប្រអប់ខាងក្រោមនេះ ។

- ប្រសិនពុំមានរោគសញ្ញាទាំងនោះទេ សូមបន្តទៅអនុវត្តប្រអប់ដែលស្ថិតនៅផ្នែកខាងស្តាំ ។

តាមដានបន្ត ប្រសិនបើការឈឺចាប់នៅមានដដែល

ប្រសិនបើអ្នកជំងឺពុំមានរោគសញ្ញានិងសញ្ញា ដូចរៀបរាប់ក្នុងប្រអប់ពីរមុនទេនោះ សូមធ្វើឱ្យគាត់បាត់ការភ័យបារម្ភហើយសុំឱ្យគាត់វិលត្រឡប់មកជួបអ្នកវិញ ប្រសិនបើការឈឺចាប់នៅតែមានដដែល ។

- ព្យាបាលជំងឺរលាកប៉េលវីស (PID)
- អប់រំឱ្យអ្នកជំងឺឱ្យផ្លាស់ប្តូរការប្រព្រឹត្ត
- ជំរុញការប្រើប្រាស់ និងផ្តល់ស្រោមអនាម័យ
- គ្រប់គ្រងថៃទាំដៃគូរួមភេទ

សូមចងចាំថា ក្នុងការព្យាបាលជំងឺរលាកប៉េលវីស(PID) អ្នកត្រូវធ្វើការព្យាបាលជំងឺប្រមេះទឹកបាយ ជំងឺបង្កដោយមេរោគក្លាមីឌីយ៉ា និងមេរោគអាណាអេរ៉ូប៊ី ក្នុងពេលជាមួយគ្នាតែម្តង ។ អ្នកត្រូវអប់រំនិងផ្តល់ប្រឹក្សាអ្នកជំងឺផងដែរ ប្រសិនបើចាំបាច់ជំរុញការប្រើប្រាស់ស្រោមអនាម័យ ហើយពិភាក្សា អំពីការបញ្ជូនដៃគូរួមភេទមកទទួលការព្យាបាល ។

តាមដានរយៈពេល៣ថ្ងៃ ក្រោយ ឬ ឆាប់ជាងនេះ បើការឈឺចាប់នៅតែមានដដែល

ប្រអប់នេះតំរូវឱ្យអ្នកពិនិត្យអ្នកជំងឺក្នុងរយៈពេល៣ថ្ងៃ ក្រោយពីការចាប់ផ្តើមព្យាបាល ឬឆាប់ជាងនេះក៏បាន ប្រសិនបើការឈឺចាប់នៅមានដដែល ។ នៅពេលពិនិត្យលើកនេះ សូមស្រង់ប្រវត្តិ និងពិនិត្យអ្នកជំងឺម្តងទៀត ។ ប្រសិនបើ អ្នកជំងឺមាន

ការធូរស្រាលហើយនៅពេលពិនិត្យតាមដាននេះ សូមបន្តការព្យាបាល ១០ ថ្ងៃ ជាបន្តទៅទៀត ។ ក៏ប៉ុន្តែប្រសិនបើ នៅពេលពិនិត្យតាមដាននេះ អ្នកជំងឺពុំបានធូរស្រាលទេ សូមបញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យបង្អែកដើម្បីឱ្យទទួលការពិគ្រោះផ្នែករោគស្ត្រី ។ សូមពិនិត្យមើលលទ្ធភាពនៃការបញ្ជូនដៃគូរួមភេទឱ្យមកទទួលការព្យាបាល ។

## ការព្យាបាលជំងឺរលាកប៉េលវីស (PID)

✶ **ការព្យាបាលជំងឺប្រមេះទឹកបាយ :**

- Cefixime 400 mg លេបតែ ១ដងគត់ឬ
- Ceftriaxone 25omg ចាក់សាច់ដុំតែ ១ដងគត់ (សំរាប់មន្ទីរពេទ្យបង្អែក)

**រួមជាមួយ**

✶ **ការព្យាបាលជំងឺបង្កដោយមេរោគក្លាមីឌីយ៉ា :**

- Doxycycline 100mg លេបពីរដងក្នុងមួយថ្ងៃ រយៈពេល ១៤ ថ្ងៃ

**ចំណាំ** : ហាមប្រើ doxycycline នៅពេលមានផ្ទៃពោះ ឬបំបៅដោះកូន ។

**រួមជាមួយ**

✶ **ការព្យាបាលជំងឺដែលបង្កដោយបាក់តេរីអាណាអេរ៉ូប៊ី :**

- Metronidazole 500mg លេបពីរដងក្នុងមួយថ្ងៃ រយៈពេល ១៤ ថ្ងៃ

**ចំណាំ** : ហាមប្រើ metronidazole ក្នុងរយៈពេលត្រីមាសទី១នៃភគ៌ ។ ត្រូវប្រាប់អ្នកជំងឺចៀសវាងកុំផឹកជាតិសុរានៅពេលកំពុងព្យាបាល ។

# ជំងឺសិរមាន់លើប្រដាប់បន្តពូជ
(Genital Warts)

អ្នកជំងឺម្នាក់មកកាន់មណ្ឌលសុខភាពរបស់អ្នកហើយត្អូញត្អែរថា មានការដុះសាច់នៅលើប្រដាប់បន្តពូជរបស់គាត់ ។ សូមប្រើប្រាស់គំនូសបំព្រួញស្តីអំពីជំងឺសិរមាន់លើប្រដាប់បន្តពូជ ។

## គំនូសបំព្រួញសំរាប់ជំងឺសិរមាន់លើប្រដាប់បន្តពូជ



 

ជំងឺសិរមាន់នៅលើប្រដាប់បន្តពូជ

**ស្រង់ប្រវត្តិនិងពិនិត្យអ្នកជំងឺ**

ប្រអប់នេះប្រាប់អ្នកឱ្យពិនិត្យអ្នកជំងឺដើម្បី បញ្ជាក់ឱ្យច្បាស់ថា អ្នកជំងឺនេះ មានដុំសាច់លើប្រដាប់បន្តពូជនិង ដើម្បីមើលក្រែងមានរោគសញ្ញានៃកាមរោគដទៃទៀត ។ សូមពិនិត្យមើលប្រដាប់បន្តពូជខាងក្រៅរបស់អ្នកជំងឺ ។ សូមប្រើស្រោមដៃនៅពេលពិនិត្យប្រដាប់បន្តពូជរបស់អ្នកជំងឺ ។ ចំពោះបុរស សូមកុំភ្លេចពិនិត្យផ្ទៃខាងក្នុងនៃស្បែកស្រោបក្បាលលិង្គ និងផ្នែកដែលគ្របដោយស្បែកនោះ ។ ចំពោះស្ត្រី សូមញែកបបូរទាំងពីរ ដើម្បីមើលផ្ទៃភ្នាសសើមខាងក្នុងប្រដាប់បន្តពូជ ។

**តើមានដុំពកដែរឬទេ? (papules)**

ប្រសិនបើមានដុំពកមែន សូមបន្តទៅប្រអប់ស្ថិតនៅខាងក្រោម ។ ប្រសិនបើ អ្នករកមិនឃើញដុំពកទេសូមបន្តទៅប្រអប់ខាងស្តាំដែលប្រាប់អ្នករកមើលរោគសញ្ញាដទៃៗទៀត ហើយធ្វើសកម្មភាពដែលសមស្រប ។

**ដុំពកមានដុះបន្លា ឬ ដុំសាច់មានសណ្ឋានដូចផ្កាខាត់ណា**

ប្រអប់នេះប្រាប់អ្នកឱ្យត្រូតពិនិត្យរកមើលថា តើដុំពកឬដុំសាច់នោះ មានដុំបន្លា ឬសណ្ឋានដូចផ្កាខាត់ណាដែរឬទេ ? ប្រសិនបើដូច្នេះមែន សូមបន្តអនុវត្តតាមប្រអប់នៅខាងក្រោម ។ ប្រសិនបើដុំពកនោះមានសណ្ឋានខុសពីនេះ សូមបញ្ជូនអ្នកជំងឺ ។

- មានភគ៌
- ឬដុំពកដុះនៅមាត់រន្ធបង្ហូរនោមឬលើជញ្ជាំងទ្វារមាស
- ឬមានការឈឺចាប់
- ឬក្តៅខ្លួនឬ
- មានការហូរឈាម

ប្រអប់នេះ ប្រាប់អ្នកឱ្យត្រួតពិនិត្យរកមើលថា តើស្ត្រីដែលជាអ្នកជំងឺមានគភ៌ ដុំពកស្ថិតនៅមាត់រន្ធបង្ហូរនោម លើជញ្ជាំងនៃទ្វារមាស និងរកមើលថា តើដុំពកនោះឈឺ ឬ មានការហូរឈាមឬតើអ្នកជំងឺ

មានក្តៅខ្លួនដែរឬទេ? ប្រសិនបើ មានលក្ខខ័ណ្ឌមួយក្នុងចំណោមលក្ខខ័ណ្ឌទាំងនេះ សូមបញ្ជូនអ្នកជំងឺ ។ ប្រសិនបើគ្មានទេ សូមបន្តអនុវត្តតាមប្រអប់ដែលស្ថិតនៅខាងស្តាំ ។

- ព្យាបាលជំងឺសិរមាន់លើប្រដាប់បន្តពូជឱ្យអ្នកជំងឺ
- អប់រំធ្វើឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត
- ជំរុញការប្រើប្រាស់និងផ្តល់ស្រោមអនាម័យ
- គ្រប់គ្រងដៃគូរួមភេទរបស់អ្នកជំងឺ

ប្រអប់នេះ ប្រាប់អ្នកពីវិធីព្យាបាលជំងឺសិរមាន់លើប្រដាប់បន្តពូជជូនអ្នកជំងឺ ។ វាក៏ប្រាប់អ្នកផងដែរ ឱ្យផ្តល់ការអប់រំដល់អ្នកជំងឺនិងដំបូន្មានអ្នកជំងឺកុំឱ្យរួមភេទមុនពេលដែល ជំងឺសិរមាន់នេះបាត់ទៅវិញ ។ ជំងឺនេះងាយឆ្លងណាស់ ដូច្នេះ ត្រូវជំរុញការប្រើប្រាស់ស្រោមអនាម័យហើយលើកទឹកចិត្តអ្នកជំងឺឱ្យនាំដៃគូរួមភេទមកពិគ្រោះជំងឺ ។ សូមប្រាប់អ្នកជំងឺឱ្យវិលត្រឡប់មកជួបនឹងអ្នកវិញក្នុងរយៈពេល ៤ សប្តាហ៍ក្រោយពីការព្យាបាល ។

- តាមដានជំងឺក្រោយពីព្យាបាលរយៈពេល ៤សប្តាហ៍
- ប្រសិនបើអ្នកជំងឺនៅតែមានរោគសញ្ញាសូមបញ្ជូន

ប្រអប់នេះប្រាប់អ្នកឱ្យពិនិត្យមើលថា តើជំងឺសិរមាន់លើប្រដាប់បន្តពូជបាត់ដែរឬទេ នៅពេលជួបពិគ្រោះតាមដានអ្នកជំងឺក្នុងរយៈពេល ៤ សប្តាហ៍ ក្រោយពីការព្យាបាល ។ ប្រសិនបើ គ្មានការធូរស្រាលទេ សូមបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យបង្អែកដើម្បីទទួលការព្យាបាលសមស្រប ។

## ការព្យាបាលជំងឺសិរមាន់

- លាបថ្នាំ podophyllin 25% លើដុំសាច់ដែលដុះដោយប្រុងប្រយ័ត្ន ។ ប្រសិនបើមាន ប្រេងវ៉ាស៊ីលីន សូមលាបវានៅជុំវិញដុំសាច់ដែលដុះនោះ មុននឹងលាប podophyllin ។
- លាងកន្លែងដុះសាច់នោះជាមួយទឹក ក្នុងពេល៤ម៉ោងក្រោយពីលាបថ្នាំ podophyllin ។
- ត្រូវប្រើថ្នាំនេះលាបលើសិរមាន់មួយដងក្នុងមួយសប្តាហ៍ ក្នុងរយៈពេល ៤ សប្តាហ៍ ។

## ការរំលឹកឡើងវិញ

### វិធីប្រើប្រាស់គំនូសបំព្រួញ

- សូមចាប់ផ្តើមពីប្រអប់លើបង្អស់នៃគំនូសបំព្រួញនៅត្រង់ប្រអប់ចាប់ផ្តើម ដែលពិពណ៌នាអំពីការត្អូញត្អែររបស់អ្នកជំងឺ ។
- សូមប្រមូលយកពត៌មានដែលត្រូវការសំរាប់ធ្វើរោគវិនិច្ឆ័យ
- ធ្វើការសំរេចចិត្តដោយឈរលើមូលដ្ឋានពត៌មានដែលប្រមូលបាន ហើយប្រមូលពត៌មានបន្ថែម ប្រសិនបើត្រូវការ ។
- ធ្វើរោគវិនិច្ឆ័យ
- ជ្រើសរើសការព្យាបាល ដែលត្រូវនឹងរោគវិនិច្ឆ័យ
- ផ្តល់ការអប់រំ និងជំរុញការប្រើប្រាស់ស្រោមអនាម័យ ។
- ពិនិត្យលទ្ធភាពក្នុងការបញ្ជូនដៃគូរួមភេទ ។

**សំណួរ**
**?**
**៤.១**

**លំហាត់**
**៤.២**

**គំនូសបំព្រួញសំរាប់ចង្កោមរោគសញ្ញាទាំង ៥**

ការណែនាំជាជំហានៗស្តីពីការប្រើប្រាស់គំនូសបំព្រួញទាំង ៥ បង្ហាញអំពីអ្វីដែលត្រូវអនុវត្តតាមគំនូសបំព្រួញនិមួយៗ ។

***ជំពូកនេះមានពត៌មានលំអិតជាច្រើន ដូច្នេះអ្នកត្រូវការពេលវេលា ដើម្បីយកអ្វីដែលអ្នកបានសិក្សាទៅអនុវត្ត ។ ផ្នែកបន្ទាប់ទៅនេះមានការសិក្សាករណីដែលមានសំណួរ និងលំហាត់ដែលជួយឱ្យអ្នកអាច ចងចាំបាននូវពត៌មានលំអិតជាក់លាក់នានា នៃគំនូសបំព្រួញនិមួយៗ និងរៀបចំខ្លួនដើម្បីអនុវត្តតាមនៅក្នុងមណ្ឌលសុខភាពរបស់អ្នក ។***

# សំណួរ និង លំហាត់

## ៤.១ សំណួរ

ក. តើនៅពេលណាដែលការធ្លាក់សម្លួយជាការធ្លាក់សធម្មតា ?

ខ. តើការវាយតំលៃកត្តាប្រឈមមុខនឹងគ្រោះថ្នាក់មានប្រយោជន៍ សំរាប់ចង្កោមរោគសញ្ញាណាមួយ ?

- ក្នុងការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់នៃជំងឺ យើងត្រូវពិចារណាលើកត្តាមួយចំនួន ។ តើកត្តាទាំង ៤ នេះមានអ្វីខ្លះ ?

- តើអ្នកត្រូវសួរសំណួរបន្ថែមអ្វីខ្លះជាបន្ថែមលើការប្រឈមមុខនឹងគ្រោះថ្នាក់ ?

គ. នៅទំព័របន្តជាបន្ទាប់ៗនេះ មានការសិក្សាករណីខ្លីៗមួយចំនួន ។ ចំពោះការសិក្សាករណីនិមួយៗ សូមធ្វើការសំរេចចិត្តជ្រើសរើសគំនូសបំព្រួញណាមួយដែលអ្នកត្រូវយកមកប្រើ បន្ទាប់មក សូមអាន នូវរឿងហេតុដែលកើតឡើងនៅពេលអ្នកស្រង់ប្រវត្តិ និង ពិនិត្យអ្នកជំងឺ ។ បន្ទាប់មក យើងនឹងសួរអ្នកអំពីរបៀបព្យាបាលអ្នកជំងឺ ។

**នាងមុំ**

នាងមុំមានអាយុ ២២ ឆ្នាំ មកកាន់គ្លីនិកផែនការគ្រួសារ ដើម្បីទទួលការពិនិត្យសុខភាពដូចធម្មតា ក្នុងពេលដែលនាងលេបថ្នាំព្យាបាលបង្ការភាពមានគភ៌ ។ នាងបានប្រាប់គិលានុបដ្ឋាយិកាអំពីការធ្លាក់សដែលមានពណ៌លឿងហើយរមាស់ ដែលកើតឡើងក្នុងរយៈពេល ៤ ថ្ងៃកន្លងមកហើយ ។

តើអ្នកត្រូវប្រើគំនូសបំព្រួញណាមួយ ?

នាងមុំនិយាយប្រាប់ថាពុំមានការឈឺចុកចាប់ពោះ ឬក៏នោមឈឺទេ ។ នាងមករដូវពីរសប្ដាហ៍កន្លងមកហើយ ហើយរដូវនោះធម្មតាទេ ។ នាងបានរួមភេទជាមួយមិត្តរួមសាលាមួយសប្ដាហ៍កន្លងមកហើយ។នាងពុំបានប្រើស្រោមអនាម័យទេ ពីព្រោះនាងបានលេបថ្នាំការពារកុំឱ្យមានគភ៌រួចហើយ ។ នាងបាន រួមភេទលើកចុងក្រោយជាមួយសង្សារពិតប្រាកដរបស់នាងតែមួយខែកន្លងមកតែប៉ុណ្ណោះ ឥឡូវនេះគេស្ថិតនៅក្រៅក្រុងនៅឡើយ ។

តើរោគវិនិច្ឆ័យជំងឺរបស់នាងមុំគឺអ្វី ?

**បូណា**

កម្មករកំពង់ផែអាយុ ១៨ ឆ្នាំ ម្នាក់ ឈ្មោះ បូណា មកកាន់គ្លីនិករបស់អ្នក ហើយត្អូញត្អែរថា គាត់មានហូរខ្ទុះចាប់តាំងពីម្សិលមិញមក ។

តើអ្នកត្រូវប្រើគំនូសបំព្រួញមួយណា ?

នៅពេលពិនិត្យ អ្នកពុំឃើញមានការហូរខ្ទុះអ្វីទេ ទោះបីក្រោយពីច្របូតបង្ហូរនោមក៏ដោយ ។ ក៏ប៉ុន្តែ អ្នកបានរកឃើញដំបៅមួយនៅលើលិង្គរបស់គាត់ ។

តើអ្នកត្រូវធ្វើអ្វី នៅពេលនេះ ?

តើអ្នកត្រូវព្យាបាលជំងឺអ្វីឱ្យអ្នកជំងឺ ?

**និមល**

និមលអាយុ ២៤ ឆ្នាំ និយាយប្រាប់ថានាងចាប់ផ្តើមមានទំនាក់ទំនងជាមួយដៃគូថ្មីរបស់នាង គឺលោកពិសិដ្ឋអស់រយៈពេល ៣ ខែ កន្លងមកហើយ ។ ឥឡូវនេះនាងមានការឈឺចុកចាប់នៅខាងក្រោមផ្ចិតស្ទុម។ ជានិច្ច នាងគិតថានេះបណ្តាលមកពីនាងមានសកម្មភាពផ្លូវភេទខ្លាំងក្លាជាមួយពិសិដ្ឋ ។

តើអ្នកត្រូវប្រើគំនូសបំព្រួញណាមួយ ?

និមលប្រាប់អ្នកថារដូវរបស់នាងមកធម្មតាទេ ហើយនាងមិនដែលធ្លាប់មានផ្ទៃពោះទាល់តែសោះ នាងកត់សំគាល់ឃើញថាមានធ្លាក់សច្រើនជាងធម្មតាបន្តិច ។ នៅពេលពិនិត្យ នាងពុំមានការឈឺចាប់ពោះនៅពេលដែលដកដៃស្ទាបចេញភ្លាម ឬការកន្ត្រាក់សាច់ដុំទេ ក៏ប៉ុន្តែនាងមានអារម្មណ៍ថាឈឺចាប់ នៅពេលអ្នកស្ទាបពោះផ្នែកខាងក្រោមរបស់នាង ។

តើអ្នកធ្វើការព្យាបាលជំងឺអ្វីឱ្យនិមល ?

តើអ្នកត្រូវពិភាក្សាអំពីអ្វីខ្លះថែមទៀតជាមួយនាង ?

ឃ. នៅចុងបញ្ចប់មានការសិក្សាករណីចំនួន៤ ដើម្បីឱ្យអ្នកអនុវត្តបន្ថែមលើការធ្វើរោគវិនិច្ឆ័យរកមូលហេតុនៃការធ្លាក់ស ។ សូមធ្វើការសំរេចចិត្តថា តើអ្នកត្រូវព្យាបាលជំងឺរលាកទ្វារមាសតែមួយមុខ ឬព្យាបាលជំងឺទាំងពីរ គឺរលាកទ្វារមាស និងរលាកមាត់ស្បូន ។

**ណារី**

នាងណារីបានរួមរស់ជាមួយដៃគូរួមភេទបច្ចុប្បន្នរបស់នាងអស់រយៈពេល ៤ ខែកន្លងមកហើយ ។ នាងមានអាយុ ២២ ឆ្នាំ ។ ក្រៅពីមានការធ្លាក់ស នាងនិយាយថា មានការឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះទៀតផង ។ ដៃគូរបស់នាងពុំមានរោគសញ្ញាទេ ។

ព្យាបាលជំងឺ :

រលាកទ្វារមាសតែមួយមុខឬ

ជំងឺរលាកទ្វារមាស និងរលាកមាត់ស្បូន

**ណារ៉េត**

ណារ៉េតត្អូញត្អែរថាមានធ្លាក់សបន្តិចបន្តួច ។ នាងមានអាយុ ២៥ ឆ្នាំ ហើយបានរៀបការបាន ៤ឆ្នាំ កន្លងមកហើយ ។ កូនទីបីរបស់នាងមានអាយុ ៨ ខែហើយ ដូច្នេះអ្នកស្រីជាប់រវល់តែនឹងកិច្ចការបីបាច់ថែទាំកូនរបស់នាង ។ ក្រៅពីការធ្លាក់ស នាងមានសុខភាពធម្មតាហើយគ្មានរោគសញ្ញាអ្វីផ្សេងទៀតទេ ។

ព្យាបាលជំងឺ :

រលាកទ្វារមាសតែមួយមុខ ឬ

រលាកទ្វារមាស និងរលាកមាត់ស្បូន

**កញ្ញា**

កញ្ញាមានអាយុ ១៧ ឆ្នាំ រស់នៅក្នុងតំបន់មួយនៃទីក្រុង ។ នាងរាយការណ៍ប្រាប់ថាមានធ្លាក់សបន្ដិចបន្ដួច ប៉ុន្ដែគ្មានរោគសញ្ញាផ្សេងទៀតទេ ។ សព្វថ្ងៃនាងកំពុងតែរួមរស់ជាមួយដៃគូបច្ចុប្បន្នរបស់នាងអស់ រយៈពេល ៩ខែ កន្លងមកហើយ ។ នាងបានដឹងថា នាពេលថ្មីៗនេះដៃគូរបស់នាងកើតជំងឺកាមរោគ ហើយពុំបានទៅពិគ្រោះជំងឺនៅឯមណ្ឌលសុខភាពទេ ។

ព្យាបាលជំងឺ :

រលាកទ្វារមាសតែមួយមុខ ឬ

រលាកទ្វារមាស និងរលាកមាត់ស្បូន

**អ្នកស្រីកូឡាប**

អ្នកស្រីកូឡាបមានអាយុ ៣៤ឆ្នាំ តួញត្អែរប្រាប់អ្នកថាមានធ្លាក់សបន្ដិចបន្ដួច ។ គាត់ពុំមានទំនាក់ទំនងផ្លូវភេទជាមួយបុរសណាផ្សេងទៀតទេ ចាប់តាំងពីប្ដីរបស់គាត់បានចាកចេញពីផ្ទះអស់រយៈពេល ៦ខែ កន្លងមក ។ គាត់ពុំមានរោគសញ្ញាអ្វីផ្សេងទៀតទេ ។

ព្យាបាលជំងឺ :

ព្យាបាលជំងឺ : រលាកទ្វារមាសតែមួយមុខ ឬ

រលាកទ្វារមាស និងរលាកមាត់ស្បូន

**លំហាត់**

**ការរៀបចំប្រើប្រាស់គំនូសបំព្រួញស្តីពីជំងឺកាមរោគនៅក្នុងមណ្ឌលសុខភាពរបស់អ្នក :**

ខាងក្រោមនេះ យើងសូមណែនាំមធ្យោបាយខ្លះៗ ដើម្បីធ្វើរោគវិនិច្ឆ័យកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ។ សូមកែសំរួលគំនូសបំព្រួញទាំងនោះឱ្យសមស្របទៅតាមតំរូវការចាំបាច់បំផុត ដែលអ្នកត្រូវការក្នុងការសិក្សា ឬក្នុងការយកទៅអនុវត្តទៅតាមបទពិសោធន៍ និងការសិក្សាដែលអ្នកបានទទួលពីមុនមក ។

១. សូមពិនិត្យមើល ឱសថដែលមានសំរាប់ប្រើប្រាស់ ហើយមានប្រសិទ្ធិភាពសំរាប់ព្យាបាលជំងឺនិមួយៗ ។

ប្រសិនបើអ្នកពុំទាន់បានធ្វើដូច្នេះទេ សូមពិនិត្យមើលនូវឱសថដែលអាចរកបាន ដើម្បីព្យាបាលចង្កោមរោគសញ្ញានិមួយៗ ។ នៅទំព័រខាងក្រោយនេះ មានទំរង់បែបបទ (forms) ដែលអ្នកអាចកត់ត្រាចុះនូវឱសថដែលត្រូវបានណែនាំឱ្យប្រើប្រាស់នៅក្នុងប្រទេស ឬមណ្ឌលសុខភាពរបស់អ្នក ។ ត្រូវធានាយ៉ាងណាឱ្យអាចរកបាននូវបញ្ជីឱសថ ដែលណែនាំឱ្យប្រើប្រាស់នៅតាមកន្លែងរបស់អ្នក។

ឧទាហរណ៍ អ្នកអាចសរសេរលើក្រដាស ឬប័ណ្ណដែលអាចដាក់នៅលើតុ ឬ ប្រើប៊ិចគូសចំណាំនៅលើកូនសៀវភៅណែនាំសំរាប់ព្យាបាល (quick reference guide) ។

២. បញ្ជាក់ឱ្យបានច្បាស់នូវកត្តាប្រឈមមុខនឹងគ្រោះថ្នាក់ដែលអ្នកនឹងត្រូវយកមកប្រើ ។ ចំពោះកន្លែងជាក់លាក់ណាមួយ គេត្រូវកែសំរួលកត្តាប្រឈមមុខនឹងគ្រោះថ្នាក់សំរាប់ការធ្លាក់ស ។ សូមពិគ្រោះ ជាមួយអ្នកបណ្តុះបណ្តាលរបស់អ្នកលើបញ្ហានេះ ប្រសិនបើអ្នកពុំបានធ្វើការកែសំរួលនៅឡើយ ។

៣. សូមអនុវត្តប្រើប្រាស់គំនូសបំព្រួញតើអ្នកអាចអនុវត្តប្រើប្រាស់គំនូសបំព្រួញជា មួយបុគ្គលិកសុខាភិបាលដទៃៗទៀតដែរឬទេ ? ខាងក្រោមនេះ គឺជាលទ្ធភាពខ្លះៗដែលត្រូវយកមកពិនិត្យពិចារណា ។

- សូមដើរតួរពីរៗនាក់ ដើម្បីដោះស្រាយចង្កោមរោគសញ្ញានានា ដោយចងចាំថាត្រូវសួរនូវសំណួរសមស្រប និងផ្តល់នូវការណែនាំណាដែលចាំបាច់ ។

- អ្នកទី ៣ ជាអ្នកសង្កេតមើលអ្នកទាំងពីរ ដោយបើកមើលនូវជំពូកទី ៤ ត្រង់កន្លែងសមស្រប ដើម្បីពិនិត្យមើលកុំឱ្យអ្នករំលងចំណុចណាមួយនោះ ។

- បើអ្នកពុំមានសហសេវិកធ្វើការអនុវត្តជាមួយអ្នកទេ សូមស្រមៃថាមានអ្នកជំងឺម្នាក់ ឬយកករណីនៃអ្នកជំងឺដែលអ្នកបានជួបកន្លងមក បន្ទាប់មកសូមគិតអំពីអ្វីដែលអ្នកត្រូវសួរឬធ្វើ ។ សូមទុកគំនូសបំព្រួញនៅមុខអ្នក ក៏ប៉ុន្តែត្រូវបិទសៀវភៅ ។ បន្ទាប់មក អ្នកអាចអានជំពូកជាក្រោយដើម្បីត្រួតពិនិត្យ មើលអំពីវិធីដែលអ្នកបានធ្វើ ។

នៅពេលដែលអ្នកទុកចិត្តថា អាចប្រើប្រាស់គំនូសបំព្រួញហើយ សូមរៀបចំលៃលកឱ្យមានការអនុវត្តការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលដោយពឹងផ្អែកលើចង្កោមរោគសញ្ញានៅមណ្ឌលសុខភាពរបស់អ្នក ។

# ការព្យាបាលដោយឱសថ (Drug Treatments)

## ការហូរខ្ទុះតាមបង្ហួរនោម

| | |
|---|---|
| ការរលាកបង្ហួរនោមដែលបង្កដោយមេរោគហ្គោណូកុក | ការព្យាបាល:________________________<br>________________________<br>________________________ |
| រួមនឹង | កំណត់សំគាល់ :________________________ |
| ការរលាកបង្ហួរនោមដែលបង្កដោយមេរោគក្លាមីឌីយ៉ា | ការព្យាបាល :________________________<br>________________________<br>________________________ |
| | កំណត់សំគាល់________________________ |

## ដំបៅលើប្រដាប់បន្តពូជ

| | |
|---|---|
| ជំងឺស្វាយ | ការព្យាបាល:________________________<br>________________________<br>________________________ |
| រួមនឹង | កំណត់សំគាល់: ________________________ |
| ជំងឺ chancroid | ការព្យាបាល :________________________<br>________________________<br>________________________ |
| | កំណត់សំគាល់: ________________________ |

## ការហូរខ្ទុះតាមទ្វារមាស / ធ្លាក់ស

*ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់អវិជ្ជមាន*

| | |
|---|---|
| ព្យាបាលជំងឺរលាកទ្វារមាសៈ | ការព្យាបាលៈ______ |
| | ______ |
| ជំងឺបង្កដោយទ្រីកូម៉ូណាស់ | ______ |
| និងជំងឺរលាកទ្វារមាសបង្ក | កំណត់សំគាល់ៈ ______ |
| ដោយបាក់តេរី | |
| រួមនឹង | |
| ជំងឺបង្កឡើងដោយផ្សិត | ការព្យាបាលៈ______ |
| | ______ |
| កង់ឌីដាស់នៅក្នុងទ្វារមាស | ______ |
| | កំណត់សំគាល់ៈ ______ |

*ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់វិជ្ជមាន*

| | |
|---|---|
| ព្យាបាលជំងឺរលាកទ្វារមាស | ការព្យាបាលៈ______ |
| (ដូចខាងលើ) | ______ |
| | ______ |
| រួមនឹង | កំណត់សំគាល់______ |
| ជំងឺរលាកមាត់ស្បូន | ការព្យាបាលៈ______ |
| | ______ |
| | ______ |
| | កំណត់សំគាល់______ |

## ការឈឺចុកចាប់នៅផ្នែកខាងក្រោមពោះស្ត្រីៈ

| | |
|---|---|
| ជំងឺប្រមេះទឹកបាយ **(gonorrhea)** | ការព្យាបាលៈ______ |
| | ______ |
| | ______ |

| | |
|---|---|
| រួមនឹង | កំណត់សំគាល់________________________________ |
| ជំងឺបង្កដោយមេរោគក្លាមីឌីយ៉ា | ការព្យាបាលៈ_________________________________ |
| | ___________________________________________ |
| | ___________________________________________ |
| រួមនឹង | កំណត់សំគាល់ៈ _______________________________ |
| ជំងឺបង្កដោយបាក់តេរីអាណាអេរូបី | ការព្យាបាលៈ_________________________________ |
| | ___________________________________________ |
| | ___________________________________________ |
| | កំណត់សំគាល់ៈ _______________________________ |
| ជំងឺសិរមាន់លើប្រដាប់បន្តពូជ | ការព្យាបាលៈ_________________________________ |
| | ___________________________________________ |
| | ___________________________________________ |
| | កំណត់សំគាល់ៈ _______________________________ |

# ចំលើយ

## ៤.១ សំណួរ

ប្រសិនបើអ្នកជាគ្រូពេទ្យព្យាបាល ឬជាអ្នកដែលបានធ្វើការថែទាំជំងឺកាមរោគកន្លងមកហើយនោះ អ្នកអាចយល់ឃើញថាសំណួរទាំងនេះងាយនឹងឆ្លើយណាស់ ។ ក៏ប៉ុន្តែ ប្រសិនបើរឿងនេះថ្មីសំរាប់អ្នក នោះវាត្រូវប្រើពេលវេលាយូរជាងនេះបន្តិច ដើម្បីឈានដល់ចំណុចដែលអ្នកមានអារម្មណ៍ថាទុកចិត្ត លើការធ្វើរោគវិនិច្ឆ័យដោយប្រើចង្កោមរោគសញ្ញា ។ ដូច្នេះសូមកុំបារម្ភប្រសិនបើអ្នកយល់ឃើញថា សំណួរទាំងនោះពិបាកសំរាប់អ្នក ។ សូមចងចាំថា គោលបំណងរបស់វាគឺចង់ជួយដល់ការសិក្សារបស់អ្នក ។

ក. ការធ្លាក់ស ជាការធ្លាក់សធម្មតា នៅពេលនិងក្រោយពេលរួមភេទ មុនពេល ឬក្រោយពេលមានរដូវ និងក្នុងពេលមានផ្ទៃពោះ ឬដំបៅដោះ ។ សូមចងចាំថា ស្ត្រីភាគច្រើននឹងមិនមកស្វែងរកការថែទាំសុខភាពទេរហូតដល់ពេលដែលគាត់ទទួលអារម្មណ៍ដឹងថា មានលក្ខណៈខុសប្លែកពីធម្មតា ឬមិនប្រក្រតី។

ខ. ការវាយតំលៃកត្តាប្រឈមមុខនឹងគ្រោះថ្នាក់ជាក់លាក់ ត្រូវធ្វើឡើងសំរាប់ការធ្លាក់ស ។ សូមចងចាំថា គោលបំណងរបស់វា គឺសំរេចចិត្តថាតើការធ្លាក់សបង្កដោយជំងឺរលាកទ្វារមាសតែឯង ឬបង្កដោយជំងឺរលាកមាត់ស្បូន និងជំងឺរលាកទ្វារមាសរួមគ្នា ។

ក្នុងការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់របស់អ្នកជំងឺ ក្នុងការកើតជំងឺរលាកមាត់ស្បូន យើងត្រូវពិចារណាលើកត្តា ៤ ដូចខាងក្រោម ៖

- អាយុតិចជាង ២៥ ឆ្នាំ
- មិនទាន់រៀបការ តែមានសកម្មភាពផ្លូវភេទ **(single)**
- មានដៃគូរួមភេទលើសពីម្នាក់ក្នុងរយៈពេលបីខែកន្លងទៅ
- មានដៃគូរួមភេទថ្មីក្នុងរយៈពេល ៣ខែ កន្លងទៅ ។

នៅតាមកន្លែងខ្លះ គេអាចរកបានពត៌មានដែលអាចយកមកប្រើប្រាស់ ដើម្បីកែតំរូវកត្តាប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លង ដើម្បីធ្វើឱ្យកាន់តែទៀងទាត់ **(sensitive)** ល្អសំរាប់កំណត់ឱ្យបានច្បាស់ថា នរណាម្នាក់ប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងកាមរោគឬអត់នោះ ។

ជាបន្ថែមលើកត្តាប្រឈមមុខនឹងគ្រោះថ្នាក់ អ្នកក៏ត្រូវសួរនូវសំណួរដូចខាងក្រោមនេះដែរៈ

- តើដៃគូរួមភេទរបស់អ្នកជំងឺមានរោគសញ្ញាដែរឬទេ ?
- តើអ្នកជំងឺមានការឈឺចាប់ផ្នែកខាងក្រោមនៃពោះដែរឬទេ ?

សូមចងចាំថា គេត្រូវព្យាបាលទាំងជំងឺរលាកទ្វារមាស និងជំងឺរលាកមាត់ស្បូនឱ្យអ្នកជំងឺ ប្រសិនបើ មានចំលើយវិជ្ជមានទៅនឹងសំណួរមួយ ឬលើសពីនេះទៅនឹងសំណួរទាំងពីរ ឬទៅនឹងកត្តាប្រឈមមុខនឹង គ្រោះថ្នាក់ ។

## គ. ការសិក្សាករណី

### នាងមុំ

គំនូសបំព្រួញត្រឹមត្រូវដែលត្រូវប្រើប្រាស់សំរាប់ករណីនាងមុំ គឺការធ្លាក់សឬការហូរខ្ទុះតាមទ្វារមាស ។

ចំលើយត្រឹមត្រូវនោះគឺអ្នកត្រូវព្យាបាលជំងឺរលាកមាត់ស្បូននិងជំងឺរលាកទ្វារមាសឱ្យនាងមុំ។ ហេតុអ្វី? ពីព្រោះនាងបានរួមភេទជាមួយដៃគូលើសពីម្នាក់ក្នុងរយៈពេលបីខែកន្លងមក ដែលជាកត្តាប្រឈមមុខនឹងគ្រោះថ្នាក់ដែលត្រូវលើកយកមកពិចារណា ។ នាងមានកត្តាប្រឈមមុខនឹងគ្រោះថ្នាក់ទីពីរទៀត គឺ រួមភេទជាមួយដៃគូថ្មីម្នាក់ទៀតក្នុងរយៈពេលបីខែកន្លងទៅ ។

### បុណ្ណា

ជាការត្រឹមត្រូវហើយ ដែលអ្នកជ្រើសរើសយកគំនូសបំព្រួញស្តីពីការហូរខ្ទុះពីបង្ហួរនោមមកប្រើមុនគេ ពីព្រោះនេះជារោគសញ្ញាដែលអ្នកជំងឺត្អូញត្អែរប្រាប់អ្នក ។

យោងតាមលទ្ធផលនៃការពិនិត្យរបស់អ្នក គំនូសបំព្រួញបានប្រាប់អ្នកឱ្យបែរមកយកគំនូសបំព្រួញ សំរាប់ដំបៅនៅនឹងប្រដាប់បន្តពូជមកប្រើប្រាស់វិញ ។ ការពិនិត្យបានបញ្ជាក់ច្បាស់ថាអ្នកជំងឺមានដំបៅ ដូច្នេះអ្នកត្រូវព្យាបាលជំងឺស្វាយ និងជំងឺ chancroid ឱ្យបូណា ។

## និមល

យោងតាមរោគសញ្ញារបស់នាងនិមល គំនូសបំព្រួញត្រឹមត្រូវដែលត្រូវយកមកប្រើប្រាស់នោះ គឺគំនូសបំព្រួញសំរាប់ការឈឺចុកចាប់ផ្នែកខាងក្រោមពោះ ។

នៅពេលពិនិត្យ ការឈឺចុកចាប់ពោះរបស់នាងនិមលបង្ហាញប្រាប់ថា នាងកើតជំងឺរលាកប៉េលវីស ។ គេត្រូវព្យាបាលជំងឺប្រមេះទឹកបាយ ជំងឺបង្កដោយក្លាមីឌីយ៉ា និងជំងឺដែលបង្កដោយបាក់តេរីអាណាអេរ៉ូប៊ីឱ្យនាង ។ វិធីព្យាបាលមានដូចតទៅ ៖

- ការព្យាបាលជំងឺប្រមេះទឹកបាយ : Cefixime 400mg លេបតែមួយគ្រាប់
- ការព្យាបាលជំងឺបង្កឡើងដោយក្លាមីឌីយ៉ា : Doxycycline 100mg លេបពីរដងក្នុងមួយថ្ងៃ រយៈពេល ១៤ ថ្ងៃ ។
- ការព្យាបាលជំងឺបង្កដោយបាក់តេរីអាណាអេរ៉ូប៊ី : Metronidozole 500mg លេបពីរដងក្នុងមួយថ្ងៃ រយៈពេល១៤ ថ្ងៃ ។

សូមចងចាំថា ការឈឺចុកចាប់នៅពេលពិនិត្យនោះពុំមែនជាសញ្ញាតែមួយគត់សំរាប់បញ្ជាក់ថា មានជំងឺរលាកប៉េលវីសនោះទេ ។ ការធ្លាក់ស ឬកំដៅខ្លួនឡើងដល់ ៣៨°C វាគ្រប់គ្រាន់ដើម្បីធ្វើឱ្យយើង ធ្វើរោគវិនិច្ឆ័យជំងឺរលាកប៉េលវីសបានហើយ ។

## ណារី :

នាងណារីនិយាយប្រាប់ថា ការឈឺចុកចាប់ផ្នែកខាងក្រោមពោះដែលជារោគសញ្ញាមួយក្នុងចំណោមរោគសញ្ញានានារបស់នាង ដូច្នេះនាងត្រូវទទួលការព្យាបាលជំងឺទាំងពីរគឺរលាកមាត់ស្បូន និងរលាកទ្វារមាស

## ណារ៉េត

ករណីណារ៉េតដូចជាពិបាកជាងមុន ។ ពត៌មានដែលយើងទទួលបានប្រាប់ឱ្យដឹងថា យើងព្យាបាលតែជំងឺរលាកទ្វារមាសមួយមុខតែប៉ុណ្ណោះជូនគាត់បានហើយ ពីព្រោះកត្តាប្រឈមមុខនឹងគ្រោះថ្នាក់អវិជ្ជមាន ។ ក៏ប៉ុន្តែ យើងពុំទាន់បានសួរថាតើដៃគូរួមភេទរបស់គាត់មានរោគសញ្ញាដែរ ឬគ្មាននោះទេ ។ ដើម្បីធ្វើការព្យាបាលឱ្យបានសមស្រប ដំបូងយើងត្រូវសួរអំពីការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់បន្ថែមសិន ។

**គញ្ញា**

យើងដឹងថានាងកញ្ញាមានអាយុតិចជាង ២៥ឆ្នាំ ។ នេះគឺជាកត្តាប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងកាមរោគមួយក្នុងចំណោមកត្តាទាំង ៤ ។ លើសពីនេះដៃគូរបស់នាងមានរោគសញ្ញាកាមរោគ ។ ដូច្នេះយើងត្រូវព្យាបាលទាំងជំងឺរលាកទ្វារមាស និងជំងឺរលាកមាត់ស្បូនឱ្យអ្នកជំងឺ ។

**កូឡាប**

នាងកូឡាប គឺជាអ្នកជំងឺដែលយើងច្បាស់ក្នុងចិត្តថាត្រូវផ្តល់ការព្យាបាលតែជំងឺរលាកទ្វារមាសតែមួយមុខគត់ឱ្យគាត់ ពីព្រោះក្នុងករណីនេះពុំមានកត្តាប្រឈមមុខនឹងគ្រោះថ្នាក់ ហើយក៏ពុំមានចំលើយស្របទៅនឹងសំណួរពីរទៀតដែរ ។

# ការអប់រំអ្នកជំងឺកាមរោគ

# ការគ្រប់គ្រងថែទាំជំងឺកាមរោគ

## ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា សំរាប់ថ្នាក់មណ្ឌលសុខភាព

**ជំពូកទី ៥**

# ការអប់រំអ្នកជំងឺកាមរោគ

# ជំពូកទី ៥

## ការអប់រំអ្នកជំងឺ

ក្នុងជំពូកនេះ យើងនឹងសិក្សាអំពីការអប់រំអ្នកជំងឺអំពីការបង្ការការចំលងជំងឺកាមរោគ ។ ការអប់រំ ជាដំណាក់កាលដែលត្រូវធ្វើក្រោយការស្រង់ប្រវត្តិជំងឺ ការពិនិត្យជំងឺ និង ការធ្វើរោគវិនិច្ឆ័យ ហើយគឺជាផ្នែកគ្រឹះមួយនៃការគ្រប់គ្រងថែទាំអ្នកជំងឺកាមរោគ ។

គោលបំណងនៃការអប់រំអ្នកជំងឺ គឺការជួយដល់អ្នកជំងឺដើម្បីដោះស្រាយបញ្ហាជំងឺបច្ចុប្បន្ន និងដើម្បីបង្ការការចំលងរោគនាអនាគត ហើយធានាយ៉ាងណាអោយដៃគូរួមភេទបានទទួលការព្យាបាលនិងអប់រំ ។ នៅតាមមណ្ឌលសុខភាពជាច្រើន បុគ្គលិកសុខាភិបាលពុំមានពេលវេលាច្រើនសំរាប់ចំណាយដើម្បីអប់រំអ្នកជំងឺទេ ។ សៀវភៅនេះ នឹងជួយអ្នកឱ្យប្រើប្រាស់ពេលវេលាដ៏មានប្រយោជន៍សំរាប់ការអប់រំប្រកបដោយប្រសិទ្ធិភាព ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

ភាពស្ទាត់ជំនាញក្នុងការធ្វើសំភាសន៍ ដែលយើងចាត់ទុកថាជាផ្នែកមួយនៃការស្រង់ប្រវត្តិជំងឺ គឺជាចំណុចចាប់ផ្តើមសំរាប់ការអប់រំអ្នកជំងឺ ។ អ្នកអាចរំលឹកឡើងវិញនូវជំនាញទាំងនោះដែលមានក្នុងជំពូកទី ៣ មុនពេលអ្នកសិក្សាជាបន្តទៀត ។

**មាតិការ**


- ហេតុអ្វីបានជាត្រូវអប់រំ ?........៤
- តើការអប់រំមានទំនាក់ទំនងទៅនឹងអ្វីខ្លះ ?.....……….......៤
- ការអប់រំដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត…..…...…..៦
- ប្រធានបទសំរាប់អប់រំអ្នកជំងឺ ……..…………..១២
- អ្នកជំងឺដែលទទួលការចំលងកាមរោគសាជាថ្មីឡើងវិញ …..២១
- តំរូវការក្នុងការព្យាបាលដៃគូរួមភេទ…………………..២១
- ការបង្កើនជំនាញក្នុងការអប់រំ....២១
- ការប្រើប្រាស់ស្រោមអនាម័យដើម្បីបង្ការខ្លួនពីការឆ្លងកាមរោគ….៣០
- ការរំលឹកសាឡើងវិញ……….៣៦
- សំនួរ និងលំហាត់…………៣៩
- ចំលើយ…………………...៥២

## ផលប្រយោជន៍នៃការផ្លាស់ប្តូរការប្រព្រឹត្តដែលធ្វើអោយបុគ្គលប្រឈមមុខទៅនឹងការឆ្លងជំងឺកាមរោគ

## ហេតុអ្វីបានជាត្រូវអប់រំ ?

ការអប់រំ ធ្វើឱ្យការព្យាបាលជំងឺកាមរោគកាន់តែមានប្រសិទ្ធិភាពខ្ពស់ ព្រោះថា :

- អ្នកជំងឺនឹងធ្វើតាមការព្យាបាល ប្រសិនជាគេបានយល់អំពីសារៈសំខាន់នៃការព្យាបាល
- ការផ្លាស់ប្តូរការប្រព្រឹត្តក្នុងបំណងបង្ការការឆ្លងជំងឺកាមរោគឡើងវិញ តំរូវឱ្យធ្វើការអប់រំ ការលើកទឹកចិត្ត និងការគាំទ្រផ្លូវចិត្ត ។

អ្នកជំងឺកាមរោគទាំងឡាយ ត្រូវធ្វើការសំរេចចិត្តសំខាន់ៗ៣យ៉ាង :

- ធ្វើការព្យាបាលឱ្យបានចប់សព្វគ្រប់
- ផ្លាស់ប្តូរការប្រព្រឹត្តផ្លូវភេទនានា ដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លង
- ពិចារណាអំពីការព្យាបាលដៃគូរួមភេទរបស់គាត់ ។

ដើម្បីអោយអ្នកជំងឺធ្វើការសំរេចចិត្តនេះដោយខ្លួនឯង និងដើម្បីធ្វើការផ្លាស់ប្តូរការប្រព្រឹត្តរបស់ពួកគេឱ្យបានយូរអង្វែង អ្នកផ្តល់សេវាថែទាំសុខភាពត្រូវតែ :

- ផ្តល់ពត៌មានស្តីអំពីជំងឺកាមរោគប្រាប់អ្នកជំងឺ
- ជួយពន្យល់អ្នកជំងឺអំពីរបៀបចំលងជំងឺកាមរោគ និងរបៀបបង្ការជំងឺនេះ និង
- ជួយពន្យល់អ្នកជំងឺអំពីសារៈសំខាន់នៃការព្យាបាលជំងឺ និងអប់រំដៃគូរួមភេទរបស់គេ ។

ការទៅពិគ្រោះជំងឺនៅមណ្ឌលសុខភាព គឺជាឱកាសដ៏ល្អមួយសំរាប់អប់រំអ្នកជំងឺ ពីព្រោះអ្នកជំងឺទាំងនោះ ចង់ដឹងអំពីជំងឺរបស់គាត់ និង ការបង្ការជំងឺនេះ ។

## តើការអប់រំមានទំនាក់ទំនងទៅនឹងអ្វីខ្លះ ?

* <u>ការអប់រំអ្នកជំងឺកាមរោគមិនមែនត្រឹមតែការផ្តល់ពត៌មានឡើយ:</u>

ការផ្តល់ពត៌មាន (information-giving) ជាធម្មតា គឺ ជាដំណើរការមួយដែលមានទិសដៅតែមួយ ។

គេត្រូវប្រាប់ការពិតដល់អ្នកជំងឺនិងត្រូវប្រាប់អំពីផលវិបាកនៃការចំលងរោគរបស់គេ។ លក្ខណៈទាំងនេះជារឿយៗ វាមិនគ្រប់គ្រាន់ដើម្បីជំរុញពួកគេឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្តរបស់ គេឡើយ ហើយវាថែមទាំងមិនបានផ្តោតទៅលើបញ្ហារបស់អ្នកជំងឺទៀតផង ។ វាក៏ធ្វើឱ្យអ្នកជំងឺមិនចង់និយាយអំពីស្ថានភាពផ្ទាល់របស់ពួកគេថែមទៀត ។ ដូច្នេះ ការផ្តល់ពត៌មានមិនទាន់គ្រប់ គ្រាន់ក្នុងការលើកទឹកចិត្តការផ្លាស់ប្តូរការប្រព្រឹត្តឡើយ ។ គេត្រូវអប់រំអ្នកជំងឺម្នាក់ៗដើម្បីអោយបានយល់

អំពីប្រភេទជំងឺរបស់គេ របៀបដែលគេឆ្លងជំងឺនេះនិងវិធីបង្ការការឆ្លងជំងឺទាំងនេះ ។ តាមការពិត ការអប់រំមានសារៈសំខាន់ណាស់ សំរាប់ជោគជ័យនៃការគ្រប់គ្រងព្យាបាលជំងឺ កាមរោគ។

បើប្រៀបធៀបទៅនឹងការផ្តល់ពត៌មានសុទ្ធសាធ ការអប់រំគឺជាដំណើរការដែលមានលក្ខណៈស៊ីជំរៅជាង ។ ឧទាហរណ៍ អ្នកជំងឺត្រូវកំណត់រកឱ្យឃើញសកម្មភាពដែលពួកគេអាចធ្វើបាន ដើម្បីបង្ការការឆ្លងជំងឺឡើងវិញ ។ ដើម្បីធ្វើការផ្លាស់ប្តូរការប្រព្រឹត្ត អ្នកជំងឺត្រូវយល់និងដោះស្រាយរាល់បញ្ហានានាផ្ទាល់ខ្លួនរបស់គេ ។ ពួកគេត្រូវតែមានឆន្ទះ និងធ្វើការសំរេចចិត្តផ្លាស់ប្តូរការប្រព្រឹត្តដោយខ្លួនគេផ្ទាល់ ។ ទាំងអស់នេះជួយអោយគេរក្សាការផ្លាស់ប្តូរការប្រព្រឹត្តអោយបានយូរអង្វែង ។

អ្នកអាចជួយជ្រោមជ្រែងដល់ដំណើរការផ្លាស់ប្តូរការប្រព្រឹត្តទាំងនេះ តាមរយៈផ្តល់ពត៌មាន និងអប់រំអ្នកជំងឺរបស់អ្នក ។ វាអាចជួយអោយអ្នកជំងឺទាំងឡាយផ្លាស់ប្តូរការប្រព្រឹត្តរបស់ពួកគេ ។ នេះព្រោះតែបុគ្គលិកសុខាភិបាលជារឿយៗ ត្រូវបានទទួលការគោរពយ៉ាងខ្លាំងហើយអ្នកជំងឺស្តាប់នូវអ្វីៗដែលអ្នកនិយាយ ជាពិសេស នៅពេលដែលអ្នកជំងឺទាំងនោះមានជំងឺកាមរោគណាមួយ ។

### ពីការផ្តល់ពត៌មានទៅការអប់រំពិតប្រាកដ

- ជារឿយៗ អ្នកជំងឺពុំបានយល់ដឹងអំពីពត៌មានគ្រឹះស្តីពីជំងឺកាមរោគ
- ការផ្តល់ពត៌មានតែមួយមុខជាធម្មតាមិនគ្រប់គ្រាន់ទេ *ដូច្នេះ គេត្រូវការនូវការអប់រំដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្តរបស់បុគ្គលណាម្នាក់នោះ*
- ការអប់រំ គឺជាផ្នែកមួយនៃដំណើរការហ្មត់ចត់មួយក្នុងការជួយមនុស្សម្នាក់ធ្វើការផ្លាស់ប្តូរការប្រព្រឹត្ត
- អ្នកជំងឺត្រូវកំណត់រកឱ្យឃើញសកម្មភាពអនុវត្តជាក់ស្តែង ដែលពួកគេអាចប្រកាន់យកបាន
- ការអប់រំតំរូវអោយអ្នកជំងឺស្វែងយល់ និងដោះស្រាយបញ្ហាទាំងឡាយដោយខ្លួនឯង ។

## ធ្វើការអប់រំដើម្បីជំរុញអោយមានការផ្លាស់ប្តូរការប្រព្រឹត្ត

| របៀបលើកទឹកចិត្តការផ្លាស់ប្តូរការប្រព្រឹត្ត |
|---|
| • ត្រូវធានាឱ្យមានការរក្សាការសំងាត់ និងភាពស្ងាត់កំបាំងពីអ្នកដទៃ<br>• បង្កើតជំនឿទុកចិត្តដល់អ្នកជំងឺ ដោយការយកចិត្តទុកដាក់ស្តាប់ និងសម្លឹងមើលចំអ្នកជំងឺ<br>• ខិតខំបង្កើតសារនានារបស់អ្នក ដែលគ្មានលក្ខណៈវិនិច្ឆ័យ សីលធម៌ទៅលើអ្នកជំងឺ<br>• ប្រើប្រាស់ភាសាសាមញ្ញ និង ច្បាស់លាស់<br>• ផ្តោតទៅលើតំរូវការពត៌មាន និងការអប់រំសំរាប់អ្នកជំងឺម្នាក់ៗ<br>• ជ្រើសរើសសារសំខាន់ៗនានា ដែលត្រូវអប់រំ<br>• ជួយអ្នកជំងឺទាំងឡាយឱ្យពិចារណាលើផលប្រយោជន៍ និង តំលៃនៃការប្រព្រឹត្តថ្មី<br>• យកចិត្តទុកដាក់លើជំរើសជាក់ស្តែងក្នុងការប្រព្រឹត្ត<br>• ស្វែងរកការយល់ព្រមពីអ្នកជំងឺនៅពេលដែលគាត់សាកល្បង ប្រកាន់យកការប្រព្រឹត្តថ្មី |

### ភាពស្ងាត់កំបាំង ការរក្សាការសំងាត់ និងការធ្វើឱ្យមានទំនុកចិត្ត

ការមានទំនុកចិត្តរវាងអ្នកផ្តល់សេវាថែទាំ និងអ្នកជំងឺកើតឡើង នៅពេលណាដែលមានភាពស្ងាត់កំបាំងពីអ្នកដទៃ និងមានការរក្សាការសំងាត់ ។ ការជឿទុកចិត្តមានសារៈសំខាន់សំរាប់ការគ្រប់គ្រងព្យាបាលអ្នកជំងឺ ពីព្រោះវាជួយធ្វើអោយមានទំនាក់ទំនងល្អរវាងអ្នកជំងឺនិងអ្នកផ្តល់សេវាថែទាំ ។ អ្នកអាចផ្តើមធ្វើឱ្យអ្នកជំងឺមានទំនុកចិត្តលើអ្នក ដោយសារការស្តាប់ពួកគេយ៉ាងប្រុងប្រយ័ត្ន ។ ការសំលឹងមើលអោយចំអ្នកជំងឺអាចជួយអ្នកបានផងដែរ ប្រសិនបើប្រពៃណីទំនៀមទំលាប់អនុញ្ញាតិឱ្យ ។

### ការជ្រើសរើសពាក្យដែលគ្មានលក្ខណៈវិនិច្ឆ័យ

ត្រូវជៀសវាងការវិនិច្ឆ័យក្នុងពេលប្រាស្រ័យទាក់ទងជាមួយអ្នកជំងឺ ឱ្យបានច្រើនបំផុតទៅតាមលទ្ធភាព ពីព្រោះវាអាចមានឥទ្ធិពលអវិជ្ជមាន ។ អ្នកត្រូវធ្វើឱ្យសំណួរទាំងឡាយ និងសំដីរបស់អ្នក ចំពោះអ្នកជំងឺគ្មានលក្ខណៈវិនិច្ឆ័យពីព្រោះអ្នកជំងឺកាមរោគតែងតែមានការអស់សង្ឃឹម ពិបាកចិត្ត និងមានអារម្មណ៍ថាមានកំហុសដោយសារការប្រព្រឹត្តរបស់ពួកគេ ឬដោយសារជំងឺកាមរោគដែលកើតលើខ្លួនគេ ។ បើសិនជាអ្នកជំងឺគិតថា មានការមើលងាយ ឬវិនិច្ឆ័យលើរូបគេ ពួកគេនឹងមានអារម្មណ៍មិនល្អចំពោះការទៅទទួលការថែទាំនៅមណ្ឌលសុខភាព ។

ប្រអប់ខាងក្រោមនេះ មានឧទាហរណ៍នៃឃ្លាទាំងឡាយដែលវិនិច្ឆ័យចំពោះអ្នកជំងឺនិងមធ្យោបាយមួយចំនួន ដើម្បីផ្លាស់ប្តូរវាឱ្យមានលក្ខណៈដែលមិនវិនិច្ឆ័យ ។

| ការប្រើសំដីដែលមានលក្ខណៈវិនិច្ឆ័យ | ការប្រើសំដីដែលគ្មានលក្ខណៈវិនិច្ឆ័យ |
|---|---|
| • តើអ្នកដឹងទេថា ការប្រព្រឹត្តដ៏អាក្រក់របស់អ្នកប្រានអ្នកអោយប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគ ? | • តើអ្នកដឹងទេថា ការប្រព្រឹត្តនេះអាចធ្វើឱ្យអ្នកប្រឈមមុខនឹងគ្រោះថ្នាក់នៃជំងឺកាមរោគ ? |
| • ដូច្នេះ ខ្ញុំគិតស្មានថា អ្នកបានរួមរស់ជាមួយបុរសដ៏ " ស្មោគគ្រោក " ណាម្នាក់ហើយ ។ | • តើអ្នកអាចប្រាប់ខ្ញុំបានទេថាហេតុដូចម្តេចបានជាអ្នកឆ្លងរោគបែបនេះ ? |
| • អ្នកគួរតែខ្មាសអៀនចំពោះការរួមភេទក្នុងវ័យដ៏ក្មេងខ្ចីរបស់អ្នក | • ការរួមភេទទាំងនៅវ័យក្មេងបែបនេះអាចធ្វើឱ្យអ្នកប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគ ។ |
| • ខ្ញុំដូចជា ភ្ញាក់ផ្អើលណាស់ ដោយឃើញនាងនៅតែរកស៊ីពេលដែលនាងកំពុងមានផ្ទៃពោះអញ្ចឹង ! | • តើអ្នកមានគំរោងរកស៊ីក្នុងរយៈពេលប៉ុន្មានទៀតក្នុងពេលនាងមានផ្ទៃពោះ ? |
| • បើសិនជា អ្នកជឿតាមសាសនារបស់យើង ហើយមិនប្រព្រឹត្តការរួមភេទជាមួយបុរសតាមរន្ធគូទ អ្នកមិនជួបបញ្ហាបែបនេះឡើយ។ | • ការរួមភេទតាមរន្ធគូទជាមួយបុរសណាម្នាក់ដោយមិនបានប្រើប្រាស់ស្រោមអនាម័យអាចធ្វើឱ្យអ្នកប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគ ។ |
| • មាននរណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ឬមួយនាង ឬ សង្សារនាងមិនមានភាពស្មោះត្រង់ទេ។ | • ជំងឺនេះឆ្លងតាមរយៈការរួមភេទតែប៉ុណ្ណោះ ។ តើអ្នកអាចប្រាប់ខ្ញុំបានទេថាហេតុដូចម្តេចបានជានាង ឬសង្សារនាងឆ្លងជំងឺនេះ ? |

## ភាសា

ជាការប្រសើរបំផុត គេត្រូវប្រើប្រាស់ភាសាសាមញ្ញហើយច្បាស់លាស់ ដើម្បីអោយអ្នកជំងឺអាចយល់ពីអ្វីដែលអ្នកចង់និយាយ ។ អ្នកមិនត្រូវប្រើប្រាស់ពាក្យបច្ចេកទេសពេទ្យ ដែលជាហេតុនាំឱ្យអ្នកជំងឺមិនអាចយល់បាននោះទេ។ ការប្រើប្រាស់ឃ្លាឬពាក្យសំរាយផ្សេងៗអាចជួយសំរួលការងារនេះបាន។

## តំរូវការអប់រំ និងផ្តល់ពត៌មាន

ដោយស្ថានភាពរបស់អ្នកជំងឺមានភាពប្លែកៗ ដូច្នេះ ការផ្តល់ពត៌មាននិងការអប់រំរបស់ពួកគេក៏តំរូវឱ្យមានការប្រែប្រួលដែរ ។ អ្នកអាចចាប់ផ្តើមដោយផ្តោតលើតំរូវការពត៌មាន និងការអប់រំនៃអ្នកជំងឺ ដោយសាកសួរពីស្ថានភាពរបស់ពួកគេ ។ បន្ទាប់មកអ្នកអាចកំណត់រកឃើញនូវសារនានា ដែលមានប្រយោជន៍បំផុតសំរាប់ពួកគេ ។ ការថ្លឹងថ្លែងទៅតាមតំរូវការរបស់អ្នកជំងឺនឹងធ្វើឱ្យសារទាំងនេះកាន់តែមានប្រសិទ្ធិភាពខ្ពស់ថែមទៀត ។

## សារសំខាន់ៗមួយចំនួនសំរាប់ផ្តល់ជាពត៌មាន

ការកំរិតសាររបស់អ្នកអោយនៅត្រឹមតែចំណុចសំខាន់ៗបំផុត គឺជាមធ្យោបាយជាក់ស្តែងមួយពីព្រោះជាធម្មតា អ្នកពុំមានពេលវេលាគ្រប់គ្រាន់សំរាប់រ៉ាយរាប់អ្វីៗទាំងអស់ប្រាប់ដល់អ្នកជំងឺឡើយ ។ អ្នកជំងឺមានការលំបាកក្នុងការទទួលយកនូវពត៌មានថ្មីៗជាច្រើនក្នុងពេលតែមួយណាស់។ ដូច្នេះ បើសិនជាអ្នកកំណត់ព្រំដែនក្នុងការផ្តល់សារអប់រំ អ្នកជំងឺនឹងអាចទទួលបាននិងចងចាំនូវពត៌មានថ្មីៗ ដែលអ្នកបានប្រាប់គាត់ ។ ការកំណត់អាទិភាពនៃការផ្តល់សារ មានន័យថាត្រូវជ្រើសរើសសារ ៣ ឬ ៤ សំខាន់ៗដែលមានប្រយោជន៍បំផុតសំរាប់អ្នកជំងឺ យោលទៅតាមស្ថានភាពពិសេសៗ តំរូវការក្នុងការអប់រំនិងការទទួលពត៌មានទាំងឡាយរបស់គាត់ ។

## អត្ថប្រយោជន៍ និង ការខាតបង់នៃការប្រព្រឹត្តថ្មី

ការជួយអ្នកជំងឺឱ្យពិចារណាអំពីអត្ថប្រយោជន៍ និងការខាតបង់នៃការប្រព្រឹត្តថ្មី គឺជាមធ្យោបាយអនុវត្តជាក់ស្តែងមួយដើម្បីលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត ។ ឧទាហរណ៍ ការបន្តនូវការប្រព្រឹត្តដែលមានពីមុនស្រាប់ រួចមកអាចអោយផលចំណេញដែលជាការសប្បាយភ្លើតភ្លើនដែលបានពីការរួមភេទរបស់គេ ប៉ុន្តែវាអាចអោយមានការខាតបង់ដោយទទួលការចំលងជំងឺកាមរោគ ។ ជាការមានប្រយោជន៍ណាស់ដែលអ្នកជំងឺត្រូវពិចារណាពីផលចំណេញ និងការខាតបង់នៃការបន្តប្រកាន់ការប្រព្រឹត្តដែលមានកន្លងមករបស់ពួកគេ ដោយប្រៀបធៀបជាមួយនឹងការផ្លាស់ប្តូរការប្រព្រឹត្ត ។ ឧទាហរណ៍មួយនៃការខាតបង់ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ស្រោមអនាម័យត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម :

| ការពិចារណាពីការខាតបង់ និងអត្ថប្រយោជន៍ នៃការប្រើប្រាស់ស្រោមអនាម័យ | | | |
|---|---|---|---|
| **ការប្រព្រឹត្តដែលមានមកពីមុនស្រាប់ (មិនបានប្រើប្រាស់ស្រោមអនាម័យ)** | | **ការផ្លាស់ប្តូរការប្រព្រឹត្ត (ការចាប់ផ្តើមប្រើប្រាស់ស្រោមអនាម័យ)** | |
| *អត្ថប្រយោជន៍* | *ការខាតបង់* | *អត្ថប្រយោជន៍* | *ការខាតបង់* |
| • គ្មានការផ្លាស់ប្តូរការប្រព្រឹត្ត<br>• ត្រេកត្រអាលក្នុងការរួមភេទ<br>• អាចមានដៃគូរួមភេទច្រើន និងប្រាក់ចំណូលខ្ពស់<br>• ការប្រព្រឹត្តនេះអាចទទួលយកដោយសង្គមទាំងមូល | • អាចឆ្លងកាមរោគសាជាថ្មីឡើងវិញនិងបណ្តាលឱ្យមានផលវិបាកនានា<br>• អាចនាំឱ្យមានការឆ្លងមេរោគអេដស៍ដែលស្លាប់នៅពេលក្រោយមក<br>• ចំពោះដៃគូរួមភេទទៀងទាត់អាចឆ្លងជំងឺកាមរោគនិងផលវិបាកនានារបស់វា<br>• ទៅអនាគតកូនដែលកើតអាចនឹងទទួលការចម្លងកាមរោគនិងផលវិបាកផ្សេងៗ | • បង្ការកាមរោគ និងមេរោគអេដស៍<br>• មិនបណ្តាលឱ្យឆ្លងដល់ដៃគូរួមភេទ<br>• មិនបណ្តាលឱ្យឆ្លងដល់កូន<br>• អាចបង្ការមិនអោយមានផ្ទៃពោះ | • ខាតបង់ស្រោមអនាម័យ<br>• តម្រូវអោយអនុវត្តជាក់ស្តែងអំពីការពិភាក្សាពីការប្រើប្រាស់ស្រោមអនាម័យ<br>• វាអាចឱ្យបន្ថយនូវអារម្មណ៍ស្រួល ឬត្រេកត្រអាល (sensation or pleasure)<br>• អាចឱ្យមានដៃគូរួមភេទតិចជាងមុនដែលនាំឱ្យរកចំណូលបានតិច |
| ➢ ស្រោមអនាម័យមានប្រសិទ្ធិភាពរហូតដល់ 95% ក្នុងការបង្ការការចំលងជំងឺកាមរោគ និងជំងឺអេដស៍ នៅពេលណាបានប្រើប្រាស់វាជាប់ជានិច្ច និងបានត្រឹមត្រូវ ។ | | | |

អ្នកអាចគិតថា ការដែលគ្រាន់តែប្រាប់អ្នកជំងឺអោយដឹងអំពីអត្ថប្រយោជន៍ និងការខាតបង់នៃការប្រព្រឹត្តផ្លូវភេទពិសេសណាមួយជាការងារមួយដែលងាយធ្វើ ។ ក៏ប៉ុន្តែ បើសិនជាអ្នកជំងឺរកឃើញនូវអ្វីៗសំរាប់ខ្លួនគេផ្ទាល់ នោះជាការប្រសើរជាង ។ ការគិតគូរពីបញ្ហាទាំងនេះជួយឱ្យអ្នកជំងឺយល់ពីផលវិបាកនៃការប្រព្រឹត្ត និងធ្វើការជ្រើសរើសដោយខ្លួនឯង។ បច្ចេកទេសល្អនោះ ត្រូវប្រើប្រាស់សំណួរនានាដើម្បីជួយឱ្យអ្នកជំងឺពិចារណាអំពីការជ្រើសរើសណាមួយ ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយនៃការជួយអ្នកជំងឺឱ្យពិចារណាអំពីការជ្រើសរើសរបស់គាត់ ។

**សំណាង** ពិចារណាពីការជ្រើសរើសរបស់គាត់

ពត៌មានមូលដ្ឋាន ៖

*នៅក្នុងដំណាក់កាលស្រង់ប្រវត្តិជំងឺ អ្នកផ្តល់សេវាថែទាំបានរកឃើញថា លោកសំណាងមានដៃគូរួមភេទសរុប ៥នាក់ ក្នុងរយៈពេល៣ខែ ចុងក្រោយនេះ ។ ក្នុងចំណោមដៃគូរួមភេទទាំងនោះ ៣នាក់ជាស្ត្រីរកស៊ីផ្លូវភេទម្នាក់ជាស្ត្រីដែលគាត់មានទំនាក់ទំនងផ្លូវភេទជិតស្និទ្ធជាយូរអង្វែង និងស្ត្រីម្នាក់ទៀតគឺជាប្រពន្ធគាត់។ លោកសំណាងបានប៉ាន់ប្រមាណថា គាត់បាន ប្រើស្រោមអនាម័យប្រហែល 50% នៅពេលដែលគាត់នៅជាមួយស្ត្រីរកស៊ីផ្លូវភេទប្រើជានិច្ចកាលនៅពេលដែលគាត់រួមភេទជាមួយ សង្សាររបស់គាត់ និងមិនដែលប្រើសោះជាមួយប្រពន្ធ របស់គាត់ ។*

**អ្នកផ្តល់សេវាថែទាំ ៖** *លោកសំណាង ខ្ញុំសុំពេលតែ ២-៣នាទីប៉ុណ្ណោះ ដើម្បីពិភាក្សាជាមួយលោកអំពីវិធីដែលអាចជួយអោយនាងជៀសវាងការចំលងរោគក្នុងពេលអនាគត ។*

**លោកសំណាង** ៖ *បាទ ខ្ញុំបានគិតគូរអំពីការបោះបង់ទំលាប់ទៅរកស្រី(មានន័យថាស្ត្រីរកស៊ីផ្លូវភេទ) ប៉ុន្តែខ្ញុំមិនប្រាកដក្នុងចិត្តថា ខ្ញុំអាចធ្វើបានឡើយ ។*

**អ្នកផ្តល់សេវាថែទាំ ៖** *ដូច្នេះ អ្នកគិតថាវាជាការលំបាកឬ ?*

**លោកសំណាង** ៖ *បាទ ពីព្រោះខ្ញុំសប្បាយនឹងរឿងនេះណាស់ ហើយចៅហ្វាយខ្ញុំតែងយកខ្ញុំទៅផ្ទះបនជាមួយគាត់ ។ ប៉ុន្តែ ខ្ញុំខ្លាចចំលងរោគទៅប្រពន្ធខ្ញុំឬសង្សារខ្ញុំណាស់ ។ រឿងនេះគួរអោយខ្លាចខ្លាំងណាស់ ។*

**អ្នកផ្តល់សេវាថែទាំ ៖** *បើសិនជាអ្នកឈប់ទៅលេងផ្ទះបន តើអ្នកគិតថាអាចមានអ្វីកើតឡើងទេ?*

**លោកសំណាង** ៖*បាទ អ្វីដែលអាក្រក់នោះគឺទំនាក់ទំនងរវាងខ្ញុំជាមួយចៅហ្វាយខ្ញុំ។ ខ្ញុំអាចបាត់បង់ការងារ។ នេះគួរតែជាមហន្តរាយមួយសំរាប់ខ្ញុំ។*

**អ្នកផ្តល់សេវាថែទាំ ៖** *បើសិនជាលោកគិតថា មិនអាចឈប់ ទៅផ្ទះបនជាមួយចៅហ្វាយអ្នកបានភ្លាមទេនោះ មានផ្លូវផ្សេងៗទៀតអាចឱ្យអ្នកជ្រើសរើសបាន ។ អ្នកអាចកុំទៅទីនោះញយពេក ឬមួយអ្នកធានាយ៉ាងណាយកស្រោមអនាម័យ ជាប់ជានិច្ចទៅកន្លែងណាដែលស្ត្រីទាំងនោះធ្លាប់ប្រើវារួចទៅហើយ។ តើអ្នកគិតយ៉ាងណាដែរ ?*

## ការជ្រើសរើសជាក់ស្តែង

ក្រោយពីការគិតអំពីអត្ថប្រយោជន៍ និងការខាតបង់នៃការប្រព្រឹត្តជាក់លាក់ណាមួយ អ្នកជំងឺត្រូវការសំរេចចិត្តថា តើគាត់នឹងត្រូវធ្វើការផ្លាស់ប្តូរអ្វីខ្លះ ។ ការលើកទឹកចិត្តអ្នកជំងឺឱ្យគិតអំពីការជ្រើសរើសណាមួយសំរាប់ផ្លាស់ប្តូរការប្រព្រឹត្តប្រកបដោយលក្ខណៈប្រាកដនិយមនោះ មានសារៈសំខាន់ណាស់ហើយវាជួយធានាឱ្យការផ្លាស់ប្តូរការប្រព្រឹត្តស្ថិតនៅយូរអង្វែង។

ការជ្រើសរើសជាក់ស្តែងទាំងនេះ គឺជាជំរើសដែលគិតគូរអំពីដំណើរជីវិតរស់នៅពិតៗរបស់អ្នកជំងឺ ដោយរាប់បញ្ចូលទាំងឧបសគ្គនានា ដែលរារាំងដល់ការផ្លាស់ប្តូរការប្រព្រឹត្តផងដែរ ។ ការថ្លែងរៀបរាប់ចុងក្រោយដោយអ្នកផ្តល់សេវាថែទាំក្នុងករណីលោកសំណាងនោះ គឺជាការផ្តល់យោបល់ប្រកបដោយភាពប្រាកដនិយមសំរាប់ស្ថានភាពលោកសំណាង។

ជាការពិតណាស់ ភាពស្មោះត្រង់នឹងគ្នាទៅវិញទៅមក ឬការតមការរួមភេទ គឺជាការជ្រើសរើសដ៏ប្រសើរបំផុតដើម្បីបង្ការការចំលងកាមរោគផ្សេងៗ ។ ប៉ុន្តែអ្នកជំងឺមួយចំនួនមិនអាច ឬមិនចង់ផ្លាស់ប្តូរការប្រព្រឹត្តរបស់ពួកគេក្នុងផ្លូវនេះឡើយ ។ ទោះជាក្នុងករណីនេះក៏ដោយ អ្នកជំងឺអាចធ្វើសកម្មភាពមួយចំនួនដើម្បីបន្ថយការប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងរោគនាអនាគត ដូចក្នុងករណីលោកសំណាងជាដើម ។



*លោកសំណាងនិងចៅហ្វាយនាយគាត់ផ្លាស់ប្តូរការប្រព្រឹត្ត ដោយការប្រើស្រោមអនាម័យបានត្រឹមត្រូវ និងទៀងទាត់ជាមួយដៃគូរួមភេទទាំងឡាយរបស់គាត់ ។*

## ការស្វែងរកការយល់ព្រមពីអ្នកជំងឺ

ក្រោយការពិភាក្សាអំពីការជ្រើសរើសជាក់ស្តែងសំរាប់ផ្លាស់ប្តូរការប្រព្រឹត្ត អ្នកជំងឺត្រូវសំរេចចិត្តលើអ្វីដែលគេនឹងត្រូវធ្វើ ។ នៅពេលអ្នកជំងឺជ្រើសរើសរួច ជាការមានប្រយោជន៍ណាស់ដែលគេត្រូវបញ្ជាក់ពីការយល់ព្រមដោយផ្ទាល់មាត់អំពីការផ្លាស់ប្តូរនានា ដែលគាត់ត្រូវធ្វើ ។ ទោះបីជាអ្នកប៉ិនប្រសព្វអប់រំយ៉ាងណាក៏ដោយ ក៏អ្នកជំងឺមួយចំនួនមិនជ្រើសរើសយកការផ្លាស់ប្តូរការប្រព្រឹត្តរបស់គេឡើយ ។ អ្នកមិនត្រូវព្យាយាមបង្ខិតបង្ខំអ្នកជំងឺទេ នៅពេលដែលមានបញ្ហានេះកើតឡើង ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកកំពុងធ្វើវិភាគទានដ៏សំខាន់មួយចំពោះដំណើរនៃការផ្លាស់ប្តូរការប្រព្រឹត្តដែរ ។ ការធ្វើសកម្មភាពរបស់អ្នកជាមួយអ្នកជំងឺនឹងមានប្រសិទ្ធិភាពក្នុងរយៈពេលមួយដ៏យូរអង្វែង ។ អ្នកដឹងថាមានកត្តាជាច្រើនដែលជះឥទ្ធិពលទៅលើការផ្លាស់ប្តូរការប្រព្រឹត្តហើយអ្នកជំងឺមួយចំនួនត្រូវការទទួលនូវបទពិសោធន៍ផ្ទាល់ខ្លួន និងបានមកពីការអប់រំដែលមានលក្ខណៈដូច ឬ ប្រហាក់ប្រហែលគ្នានេះក្នុងរយៈពេលណាមួយមុនពេលធ្វើការផ្លាស់ប្តូរការប្រព្រឹត្តរបស់ពួកគេ ។ វិភាគទានរបស់អ្នកចំពោះដំណើរការនេះជាការមានតំលៃ ទោះបីជាវាបានលទ្ធផលបែបណាក្តីពីការមកពិគ្រោះជំងឺកាមរោគរបស់អ្នកជំងឺ ។

## ប្រធានបទសំរាប់អប់រំអ្នកជំងឺ

| ប្រធានបទដែលត្រូវយកមកពិភាក្សាជាមួយអ្នកជំងឺកាមរោគ |
|---|
| • ពន្យល់អំពីជំងឺកាមរោគ<br>• ពន្យល់អំពីការព្យាបាល<br>• វាយតំលៃអំពីការប្រឈមមុខនឹងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រព្រឹត្ត<br>• វាយតំលៃអំពីឧបសគ្គដែលរារាំងដល់ការផ្លាស់ប្តូរការប្រព្រឹត្ត<br>• លើកទឹកចិត្តដល់ការជ្រើសរើសនានាដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត<br>• បញ្ជាក់ឱ្យបានច្បាស់អំពីការសំរេចចិត្តទាំងឡាយ<br>• ពិភាក្សាអំពីការថែទាំដៃគូរួមភេទ |

បើសិនជាអ្នកបានស្រង់យកនូវប្រវត្តិដែលទាក់ទងនឹងការប្រព្រឹត្តរបស់អ្នកជំងឺរួចហើយ អ្នកអាចបន្តទៅអនុវត្តដំណើរការផ្តល់ពត៌មាន និង អប់រំបានយ៉ាងឆាប់រហ័ស ។

## ការពន្យល់អំពីជំងឺកាមរោគ និងការព្យាបាលរបស់វា

នៅពេលធ្វើការពន្យល់អំពីជំងឺកាមរោគដល់អ្នកជំងឺ ការប្រសើរបំផុតនោះ គឺត្រូវប្រើភាសាសាមញ្ញ ហើយច្បាស់លាស់ជៀសវាង ការប្រើពាក្យបច្ចេកទេសពេទ្យ ។ នៅពេលសន្ទនានេះ អ្នកត្រូវផ្តល់ពេលឱ្យអ្នកជំងឺប្រាប់អំពីការយល់ដឹងរបស់គេចំពោះជំងឺកាមរោគ ។

អ្នកជំងឺត្រូវយល់អំពីរបៀបដែលគេឆ្លងរោគ ឬអាចនិយាយម្យ៉ាងទៀតថា ពួកគេឆ្លងរោគដោយសារការរួមភេទជាមួយដៃគូរួមភេទដែលមានជំងឺនេះស្រាប់ ។ អ្នកជំងឺក៏ត្រូវដឹងផងដែរអំពីផលវិបាកនានានៃការចំលងរោគរបស់គាត់ បើសិនជាជំងឺមិនត្រូវបានព្យាបាលឱ្យជាសះស្បើយទេនោះ ។ យកល្អគេត្រូវធ្វើឱ្យអ្នកជំងឺយល់ដឹងអំពីគ្រោះថ្នាក់ និងផលវិបាកនានានៃជំងឺរបស់គាត់ ប៉ុន្តែ មិនត្រូវធ្វើឱ្យគាត់ភ័យខ្លាចស្លន់ស្លោរឡើយ ។

### ការពន្យល់អំពីជំងឺកាមរោគ

- ពិពណ៌នាសង្ខេបពីជំងឺកាមរោគដែលអ្នកជំងឺមាន
- ពន្យល់អំពីរបៀបឆ្លងនៃជំងឺ និងផលវិបាករបស់វា បើសិនជាមិនព្យាបាលឱ្យជាសះស្បើយទេនោះ ។
- សំណូមពរអ្នកជំងឺឱ្យសួរអំពីចំងល់ និងកង្វល់នានារបស់គាត់ចំពោះបញ្ហានេះ ។

នៅពេលដែលអ្នកកំពុងពន្យល់ពីជំងឺកាមរោគ អ្នកគួរតែសួរអ្នកជំងឺអំពីចំងល់ និងការខ្វល់ខ្វាយផ្សេងៗរបស់គាត់ ។ ទាំងនេះនឹង ជួយដល់អ្នកឱ្យផ្ទៀងផ្ទាត់មើលថាតើអ្នកជំងឺបានយល់ហើយ ឬនៅ ។

## ការពន្យល់ណែនាំអំពីការព្យាបាលជំងឺកាមរោគ

- ពិពណ៌នាសង្ខេបអំពីការព្យាបាលចាំបាច់
- ផ្តល់ការណែនាំអំពីរបៀបព្យាបាល
- ពន្យល់អំពីផលវិបាកបន្ទាប់បន្សំនានានៃថ្នាំដែលកើតមានជាញឹកញាប់
- លើកទឹកចិត្តអ្នកជំងឺឱ្យប្រើប្រាស់ថ្នាំទាំងអស់ដែលបានផ្តល់ជូន
- សួរអ្នកជំងឺអំពីចំងល់ និង កង្វល់ផ្សេងៗរបស់គាត់

ដូចការចេញវេជ្ជបញ្ជាដទៃៗទៀតដែរ អ្នកត្រូវពិពណ៌នាពីការព្យាបាលចាំបាច់ ជារឿយៗដោយបញ្ជាក់ពីឈ្មោះថ្នាំ បន្ទាប់មកគឺ ការណែនាំអំពីរបៀបប្រើប្រាស់វានិងរយៈពេលដែលត្រូវប្រើផងដែរ ។ ត្រូវសរសេរនូវពត៌មានលំអិតសំខាន់ៗ អំពីការព្យាបាលសំរាប់ឱ្យអ្នកជំងឺយកទៅជាមួយខ្លួន ។ បើសិនជា អ្នកជំងឺមិនអាចអានបានអ្នកអាចប្រើនិមិត្តសញ្ញានានាសំរាប់ជាបញ្ជាក់គំនិតសំខាន់ៗ ។ អ្នកអាចសង្កត់ធ្ងន់ថាដើម្បីឱ្យគេជាសះស្បើយពីជំងឺកាមរោគរបស់គេ អ្នកជំងឺត្រូវតែប្រើប្រាស់ថ្នាំទាំងអស់របស់គេ ហើយធ្វើការព្យាបាលឱ្យបានចប់សព្វគ្រប់ ទោះបីជារោគសញ្ញារបស់គេបាត់ទៅវិញ ឬពួកគេហាក់ដូចជាធូរស្រាលឡើងវិញក៏ដោយ ។ ការពន្យល់អំពីឥទ្ធិពលបន្ទាប់បន្សំញឹកញាប់របស់ថ្នាំ ជួយឱ្យអ្នកជំងឺចេះចាត់វិធានការណ៍ឆ្លើយតបវិញបានយ៉ាងសមស្រប ។ សូមសួរអ្នកជំងឺអំពីចំងល់របស់គាត់និងកង្វល់នានាដែលគាត់មាន ដើម្បីផ្ទៀងផ្ទាត់មើលថាតើគេបានយល់ដែរឬទេ ។ អ្នកក៏អាចសុំឱ្យអ្នកជំងឺឱ្យនិយាយឡើងវិញនូវការណែនាំក្នុងការព្យាបាលផងដែរ ។

## ការវាយតំលៃពីកំរិតប្រឈមមុខនឹងគ្រោះថ្នាក់នៃអ្នកជំងឺ

ក្រោយពីបានរំលឹកនូវពត៌មានដែលអ្នកបានសិក្សាពីការស្រង់ប្រវត្តិជំងឺរួចមក អ្នកត្រូវសាកសួរអ្នកជំងឺអំពីរបៀបដែលនាំអោយគេឆ្លងជំងឺកាមរោគ ។ បើសិនជាអ្នកបានទទួលពត៌មានទាំងនេះរួចហើយ អ្នកអាចសាកសួរអំពីការប្រឈមមុខនឹងគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រព្រឹត្តអោយបានលំអិតថែមទៀតដើម្បីឱ្យបានដឹងច្បាស់អំពីស្ថានភាពនិងតំរូវការនានារបស់អ្នកជំងឺ ។ នៅពេលដែលយើងសំបូរពេល អ្នកអាចប្រមូលពត៌មានឱ្យបានច្រើនដើម្បីធ្វើអោយការអប់រំរបស់អ្នកមានលក្ខណៈសមរម្យសំរាប់ស្ថានភាពរបស់អ្នកជំងឺម្នាក់ៗ ។ នៅពេលដែល ពេលវេលាមានកំណត់

អ្នកប្រហែលជាអាចកំណត់រកកត្តាប្រឈមមុខនឹងគ្រោះថ្នាក់សំខាន់ៗ មួយចំនួនដោយផ្អែកលើការយល់ដឹងនិងបទពិសោធន៍របស់អ្នក ។

| វិធីវាយតំលៃអំពីកត្តាប្រឈមមុខនឹងគ្រោះថ្នាក់របស់អ្នកជំងឺ |
|---|
| • រំលឹកឡើងវិញនូវពត៌មានដែលបានមកពីការស្រង់ប្រវត្តិជំងឺ<br>• ប្រសិនបើចាំបាច់សួរអ្នកជំងឺអំពីរបៀបដែលនាំឱ្យគេឆ្លងជំងឺ<br>• សួរការប្រព្រឹត្តជាក់លាក់នានា ។<br>• វាយតំលៃអំពីការប្រព្រឹត្ត(តើធ្វើឱ្យអ្នកជំងឺប្រឈមមុខនឹងការឆ្លងកាមរោគដែរឬទេ?។<br>• កំណត់រកអោយឃើញនូវការផ្លាស់ប្តូរការប្រព្រឹត្តនានាដែលអាចឱ្យបន្ថយនូវការប្រឈមមុខនឹងគ្រោះថ្នាក់ក្នុងការឆ្លងកាមរោគនាអនាគត ។<br>• ត្រួតពិនិត្យមើលការភ័ន្តច្រឡំស្តីអំពីការចំលងជំងឺកាមរោគនិងបង្ការជំងឺកាមរោគ ។ |

## ការប្រព្រឹត្តនាំឲ្យដែលប្រឈមមុខនឹងគ្រោះថ្នាក់ និង ការប្រព្រឹត្តដែលអាចបង្ការខ្លួនពីការឆ្លងជំងឺកាមរោគ

### ការប្រព្រឹត្តដែលប្រឈមមុខនឹងគ្រោះថ្នាក់

- *ការប្រព្រឹត្តផ្លូវភេទរបស់បុគ្គល :*

- មានដៃគូរួមភេទច្រើនក្នុងឆ្នាំកន្លងទៅ
- រួមភេទជាមួយដៃគូរួមភេទថ្មី ក្នុងរយៈពេល៣ខែកន្លងទៅ
- កើតជំងឺកាមរោគផ្សេងៗទៀត កាលពីក្នុងឆ្នាំមុនៗ
- ការដោះដូរការរួមភេទដើម្បីប្រាក់ ឬវត្ថុនានា ឬគ្រឿងញៀន
- ការប្រើប្រាស់នូវសារធាតុផ្សេងៗដើម្បីធ្វើអោយ "ទ្វារមាសស្ងួត" (dry sex)

- *ការប្រព្រឹត្តដែលប្រឈមមុខនឹងគ្រោះថ្នាក់របស់បុគ្គលផ្សេងៗទៀត :*

- ការចោះទំលោះស្បែក
- ការបញ្ចូលឈាម
- ការចាក់គ្រឿងញៀន
- ការផឹកសុរា

- *ការប្រព្រឹត្តផ្លូវភេទដែលប្រឈមមុខនឹងគ្រោះថ្នាក់នានាផ្សេងទៀតរបស់ដៃគូរួមភេទ :*

  - រួមភេទដោយមិនប្រើមធ្យោបាយ បង្ការជាមួយអ្នកផ្សេងៗទៀត
  - ចាក់គ្រឿងញៀន
  - ដៃគូរួមភេទជាបុរសបានរួមភេទជាមួយបុរសផ្សេង

### ការប្រព្រឹត្តដែលអាចបង្ការខ្លួនពីការឆ្លងជំងឺកាមរោគ

- ការប្រើប្រាស់ស្រោមអនាម័យ
- ការរួមភេទដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ក្នុង ការឆ្លងកាមរោគ
- មានទំនាក់ទំនងផ្លូវភេទស្មោះស្ម័គ្រតែជាមួយដៃគូរួមភេទ តែម្នាក់គត់ ។

យើងត្រូវវាយតំលៃអំពីការប្រព្រឹត្តដែលអ្នកបានដឹងនិងសំរេចចិត្តថា វាអាចប្រឈមមុខនឹងគ្រោះថ្នាក់ដែរឬទេ ។ ជាទូទៅការប្រព្រឹត្តទាំងឡាយដែលប្រឈមមុខនឹងគ្រោះថ្នាក់ គឺជាការប្រព្រឹត្តទាំងឡាយដែលធ្វើឱ្យមនុស្សប៉ះពាល់ជាមួយឈាម ទឹកកាម ទឹករំអិលទ្វារមាស ឬការប៉ះទង្គិច ឬការដាច់ដោចលើប្រដាប់បន្តពូជដែលមានមេរោគ ។ ក៏ប៉ុន្តែ ចំពោះមនុស្សមួយចំនួនការប្រឈមមុខនឹងគ្រោះថ្នាក់នៃកាមរោគរបស់ពួកគេ ផ្អែកលើការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់នានានៃដៃគូរួមភេទទៀងទាត់របស់ពួកគេ ។

ថ្វីបើ ការប្រព្រឹត្តប្រកបដោយគ្រោះថ្នាក់មួយចំនួនអាចមានឥទ្ធិពលលើការឆ្លងជំងឺកាមរោគ នាអនាគតកាលខ្លាំងលើសពីកត្តាផ្សេងៗក៏ដោយ អ្នកជំងឺទាំងអស់ដែលអ្នកបានធ្វើរោគវិនិច្ឆ័យថាមានជំងឺកាមរោគ អាចទទួលផលចំណេញសំរាប់ខ្លួនដោយសំរេចចិត្តជ្រើសរើសនូវការប្រព្រឹត្តផ្លូវភេទនានា ដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ ។ លើសពីនេះទៅទៀត អ្នកជំងឺណាដែលបារម្ភថា ខ្លួនអាចកើតជំងឺកាមរោគហើយពុំមានរោគសញ្ញានោះ ជារឿយៗ តែងតែទទួលស្គាល់ថាអាចមានកត្តាប្រឈមមុខនឹងការឆ្លងជំងឺកាមរោគដែលខ្លួនអាចជ្រើសរើសផងដែរ ដើម្បីធ្វើការផ្លាស់ប្តូរការប្រព្រឹត្ត ។

អ្នកគួរតែកំណត់រកឱ្យឃើញនូវការផ្លាស់ប្តូរការប្រព្រឹត្តនានា ដែលអាចបន្ថយគ្រោះថ្នាក់នៃជំងឺកាមរោគនាអនាគត ដោយប្រើប្រាស់ការយល់ដឹងអំពីការប្រព្រឹត្តដែលប្រឈមមុខនឹងគ្រោះថ្នាក់នានារបស់អ្នកជំងឺ ។

## ការជំរុញការកាត់បន្ថយការប្រឈមមុខនឹងគ្រោះថ្នាក់

### ការជ្រើសរើសការរួមភេទដែលគ្មានគ្រោះថ្នាក់

- កំរិតចំនួនដៃគូរួមភេទមកត្រឹមទំនាក់ទំនងស្មោះស្ម័គ្រតែ ជាមួយដៃគូម្នាក់គត់
- ប្រើប្រាស់ស្រោមអនាម័យអោយបានទៀងទាត់ និងត្រឹមត្រូវ
- ជំនួសការរួមភេទដោយស៊កបញ្ចូលដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ដោយការរួមភេទដោយមិនស៊កបញ្ចូលដែលប្រឈមមុខនឹងគ្រោះថ្នាក់ទាប

នៅពេលដែលអ្នកបានវាយតំលៃនូវកំរិតប្រឈមមុខនឹងគ្រោះថ្នាក់នៃអ្នកជំងឺ រួចជំហានបន្ទាប់គឺត្រូវជួយអ្នកជំងឺឱ្យពិនិត្យពិចារណាលើការរួមភេទមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ ។ គោលបំណងនៃការរួមភេទដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ គឺការពារអ្នកជំងឺកុំឱ្យប៉ះពាល់ទឹកកាមទឹករំអិលក្នុងទ្វារមាស ឈាម ឬ របួសដាច់ដោចលើប្រដាប់បន្តពូជ ។

ក្នុងការពិភាក្សាអំពីការរួមភេទដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ជាមួយអ្នកជំងឺ ជាការប្រសើរណាស់ដែលត្រូវផ្តើមឡើងដោយចង្អុលបង្ហាញអំពីការជ្រើសរើសយកការរួមភេទណាមួយ ដែលអ្នកជំងឺបានកំពុងអនុវត្ត ។ ក្រោយពីនេះ អ្នកអាចសំណូមពរឱ្យជ្រើសរើសយកមធ្យោបាយពិសេសនានា ដើម្បីបន្ថយនូវការប្រឈមមុខនឹងគ្រោះថ្នាក់របស់ពួកគេ ។ អ្នកជំងឺមួយចំនួនអាចពិចារណាជ្រើសរើសយកការកាត់បន្ថយចំនួនដៃគូរួមភេទ ថែមទាំងអាចស្មោះស្ម័គ្រតែជាមួយដៃគូរួមភេទត្រឹមម្នាក់បាន ។

ឧបមាថា មានអ្នកជំងឺប្រុសម្នាក់បានប្រាប់អ្នកថា យូរៗម្តងគេបានរួមភេទតាមទ្វារមាស ឬតាមទ្វារលាមកដោយមធ្យោបាយបង្ការ ។ បើសិនជា អ្នកសំណូមពរឱ្យគាត់បញ្ឈប់នូវការប្រព្រឹត្តទាំងនេះភ្លាមតែម្តងគាត់អាចគិតថា សំណូមពររបស់អ្នកមិនមានលក្ខណៈប្រាកដនិយមទេ ប៉ុន្តែគាត់គួរតែស្តាប់យោបល់អ្នក បើសិនជាអ្នកអាច ពិភាក្សាពីលទ្ធភាពនៃការចាប់ផ្តើមប្រើប្រាស់ស្រោមអនាម័យរបស់គាត់ជាជំនួសមធ្យោបាយផ្សេងៗទៀត ដែលធ្វើឱ្យខ្លួនគេប្រឈមមុខនឹងគ្រោះថ្នាក់ទាប ដូចជាការប្រឆឹកប្រដាប់បន្តពូជគ្នាទៅវិញទៅមក (mutual masturbation) ។ អ្នកជំងឺមួយចំនួន អ្នកអាចពិភាក្សាផងដែរអំពីទំនាក់ទំនងរវាងការរួមភេទដែលប្រឈមមុខនឹងគ្រោះថ្នាក់ ដើម្បីការពារការចំលងជំងឺ ការធ្វើផែនការគ្រួសារជាមួយអ្នកជំងឺជាច្រើន ។ ស្រោមអនាម័យគឺ ជាវិធីដ៏ល្អមួយសំរាប់ការបង្ការភាពមានគភ៌និងការចំលងជំងឺកាមរោគ ប៉ុន្តែក្នុងពេលជាមួយគ្នា អ្នកគួរតែសង្កត់ធ្ងន់ថា បែបបទផែនការគ្រួសារមួយចំនួនដែលនិយមចូលចិត្ត (រាប់បញ្ចូលទាំងថ្នាំគ្រាប់ការពារភាពមានគភ៌ កង និងការចងដៃស្បូន) មិនអាចបង្ការការចំលងកាមរោគបានទេ ។

រាល់ពេលដែលអ្នកត្រូវពិភាក្សាពីការប្រព្រឹត្តផ្លូវភេទជាមួយអ្នកជំងឺ សូមផ្ទៀងផ្ទាត់រកការភ័ន្តច្រឡំនានា ។ ពត៌មានត្រឹមត្រូវអំពី មូលហេតុនៃជំងឺកាមរោគ ឬ វិធីបង្ការជំងឺទាំងនោះ ជារឿយៗច្រើនតែច្របូកច្របល់លាយឡំជាមួយជំនឿអរូបី ឬ ពាក្យចចាមអារាមទាំងឡាយផងដែរ ។ ត្រូវកែតំរូវពត៌មានមិនត្រឹមត្រូវអំពីជំងឺកាមរោគ ធ្វើយ៉ាងណាឱ្យអ្នកជំងឺអាចជ្រើសរើសយកនូវមធ្យោបាយដ៏មានប្រសិទ្ធិភាពដើម្បីការពារខ្លួនគេពីការឆ្លងមេរោគ ។

## ឧបសគ្គនានាដែលរាំងដល់ការផ្លាស់ប្តូរការប្រព្រឹត្ត

| កត្តានានាដែលជាឧបសគ្គរាំងដល់ការផ្លាស់ប្តូរការប្រព្រឹត្ត |
| --- |
| • ភេទ (ប្រុស ឬ ស្រី)<br>• អាយុ<br>• ការប្រកាន់ទំនៀមទំលាប់នានា<br>• សាសនា<br>• ភាពក្រីក្រ វិបរិត និងអស្ថិរភាពក្នុងសង្គម |

ជារឿយៗ សារអប់រំសុខភាពពុំទាន់គ្រប់គ្រាន់ដើម្បីធ្វើឱ្យមនុស្សផ្លាស់ប្តូរការប្រព្រឹត្តទេ ។ មានឧបសគ្គជាច្រើនដែលអាចធ្វើឱ្យមនុស្សមានការលំបាកក្នុងការពិចារណាការផ្លាស់ប្តូរការប្រព្រឹត្ត ។ ឧបសគ្គទាំងនេះប្រហែលអាចកើតឡើងបណ្តាលមកពីស្ថានភាពជីវភាព និងបទពិសោធន៍នានាដែលអ្នកជំងឺមាន ។




ឧទាហរណ៍មួយនៃឧបសគ្គរាំងដល់ការប្រើប្រាស់ស្រោមអនាម័យ ។

**ភេទ**

ស្ត្រីជារឿយៗមានម្ចាស់ការតិចតួចណាស់លើសកម្មភាពផ្លូវភេទ ទាំងលើរបៀប ពេលវេលា ដៃគូរួមភេទ និងស្ថានភាពនានាដែលពួកគេរួមភេទ ។ ជារឿយៗ ពួកគេមិនមានលទ្ធភាពដើម្បីបង្ការខ្លួនទេ ទោះបីជាគេមានបំណងក៏ដោយ ។ ឧទាហរណ៍ ស្ត្រីមួយចំនួនអាចរកស្រោមអនាម័យមកប្រើប្រាស់បានប៉ុន្តែនៅតែមិនអាចជំរុញអោយបុរសប្រើស្រោមអនាម័យបាន ។ ឧបសគ្គទាក់ទងនឹងបញ្ហាភេទក៏មានឥទ្ធិពលផងដែរទៅលើបុរស ។ ឧទាហរណ៍ បុរសអាចគិតថាគេត្រូវតែមានស្រីកំណាន់ ឬសង្សារដើម្បីឱ្យបុរសដទៃទៀតចាត់ទុកគេថាជាបុរសពិតប្រាកដ ។ ចំពោះទំនៀមទំលាប់មួយចំនួនការប្រើប្រាស់ស្រោមអនាម័យពុំត្រូវបានគេចាត់ទុកថាមានលក្ខណៈជាប្រុសពិតប្រាកដទេ។

**អាយុ**

យុវជន យុវនារីក្មេងៗ ជាញឹកញាប់មានការលំបាកក្នុងការទៅទទួលយកអត្ថប្រយោជន៍អំពីសេវាថែទាំសុខភាពដែលរួមបញ្ចូលទាំងការបង្ការភាពមានគភ៌ និងសេវាថែទាំកាមរោគផងដែរ ។ ពួកគេអាចទទួលផងដែរនូវការអប់រំផ្លូវភេទមិនបានត្រឹមត្រូវ ។

**ការប្រកាន់ទំនៀមទំលាប់នានា**

ការប្រកាន់ទំនៀមទំលាប់នានា អាចជួយជំរុញ ឬ បង្អាក់លទ្ធភាពរបស់អ្នកជំងឺក្នុងការផ្លាស់ប្តូរការប្រព្រឹត្ត ។ ភាពខុសគ្នារវាងអាយុរបស់បុរស និងស្រីនៅពេលរៀបការ ការប្រារព្ធពិធីនានានៅពេលពេញវ័យ (puberty rites) សកម្មភាពផ្លូវភេទ ការចិញ្ចឹមបីបាច់ថែរក្សាកូន ឬការឱ្យតំលៃរបស់គ្រួសារនិងសហគមន៍ ក៏អាចជះឥទ្ធិពលដល់ការប្រព្រឹត្តផងដែរ ។

**សាសនា**

ការកាន់សាសនានានាអាចមានឥទ្ធិពលលើការជ្រើសរើស និងការរក្សាខ្ជាប់នូវការរួមភេទដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ ។ សាសនាជាច្រើនពុំអនុញ្ញាតិឱ្យមានការពិភាក្សាជាចំហអំពីសកម្មភាពផ្លូវភេទ (sexuality) និងស្រោមអនាម័យទេ ហើយអាចជាឧបសគ្គដែលរារាំងដល់ការផ្លាស់ប្តូរការប្រព្រឹត្ត ។

**ភាពក្រីក្រ ទិបរិត អស្ថិរភាពក្នុងសង្គម**

ក្នុងកាលៈទេសៈដែលស្ត្រី យុវជន យុវនារី គ្មានភាពម្ចាស់ការលើខ្លួនគេ អ្នកទាំងនោះអាចនឹងធ្លាក់ចូលក្នុងការជួញដូរភេទដើម្បីប្រាក់ ចំណីអាហារ ឬការរស់រានមានជីវិត ។ ស្ត្រីខ្លះអាចត្រូវបង្ខិតបង្ខំឱ្យមានដៃគូរួមភេទច្រើនដើម្បីទ្រទ្រង់ពួកគេ និងកូនរបស់គេ ។

## អ្នកជំងឺដែលទទួលការចំលងជំងឺកាមរោគសាជាថ្មីឡើងវិញ

អ្នកជំងឺទាំងឡាយណាដែលឆ្លងជំងឺកាមរោគសាជាថ្មី តំរូវឱ្យមានការយកចិត្តទុកដាក់និងការផ្តល់ការអប់រំពិសេស ។ អ្នកជំងឺទាំងនេះមានការប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ក្នុងការឆ្លងមេរោគអេដស៍ ហើយពួកគេងាយទទួលរងនូវផលវិបាកដ៏ធ្ងន់ធ្ងរនៃកាមរោគដែលកើតលើខ្លួនគេ ក្នុងរយៈពេលយូរអង្វែង ប្រសិនបើគ្មានការព្យាបាលទេនោះ ។

ជាការសំខាន់ណាស់ដែលគេចំណាយពេលឱ្យកាន់តែច្រើនសំរាប់អ្នកជំងឺទាំងអស់នេះ ។ ពួកគេមានអារម្មណ៍ថាមិនអាចធ្វើការផ្លាស់ប្តូរការប្រព្រឹត្ត ដើម្បីបន្ថយនូវការប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងកាមរោគបានឡើយ ។ អ្នកត្រូវជួយពួកគេឱ្យស្វែងរកការផ្លាស់ប្តូរការប្រព្រឹត្តងាយស្រួលទាំងឡាយ ដែលពួកគេអាចធ្វើបាននិងត្រូវប្រកាន់ខ្ជាប់ក្នុងរយៈពេលយូរអង្វែង ។ ក្រោយពីទទួលជោគជ័យក្នុងការផ្លាស់ប្តូរការប្រព្រឹត្តខ្លះៗមក ពួកគេអាចផ្លាស់ប្តូរការប្រព្រឹត្តជាបន្តទៀតដើម្បីបន្ថយនូវការប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគនាអនាគត ។

## តំរូវការក្នុងការព្យាបាលដៃគូរួមភេទ

នេះគឺជាខ្លឹមសារនៃជំពូកទី៦ ដូច្នេះយើងនឹងមិនពិភាក្សាវែកញែកឱ្យល្អិតល្អន់ក្នុងជំពូកនេះទេ ។ ចូរចងចាំថា ជានិច្ចកាលអ្នកគប្បីប្រាប់អ្នកជំងឺរបស់អ្នកអំពីសារសំខាន់ក្នុងការព្យាបាលដៃគូរួមភេទទាំងអស់របស់គាត់ ។ អ្នកជំងឺរបស់អ្នកអាចឆ្លងជំងឺសាជាថ្មីឡើងវិញ បើសិនជាដៃគូទាំងនេះមិនបានទទួលការព្យាបាល លើកលែងតែមានការប្រើប្រាស់ស្រោមអនាម័យគ្រប់ពេលវេលា ។ សូមពិភាក្សាជាមួយអ្នកជំងឺរបស់អ្នកអំពីមធ្យោបាយទាំងឡាយ ដើម្បីបញ្ចុះបញ្ចូលដៃគូរួមភេទរបស់គេឱ្យមកទទួលការព្យាបាល ។ ធានាអះអាងដល់អ្នកជំងឺថា អ្នកនឹងរក្សាការសំងាត់ជូនគាត់ ។

## ការបង្កើនភាពស្ទាត់ជំនាញក្នុងការអប់រំ

ឥឡូវនេះ យើងបានសិក្សាអំពីមូលបញ្ហានានាដែលអ្នកត្រូវយកមកពិភាក្សាជាមួយអ្នកជំងឺរបស់អ្នកអំពីសារៈសំខាន់ក្នុងការពិភាក្សាអំពីការផ្លាស់ប្តូរការប្រព្រឹត្ត ។ អ្នកបានដឹងថា អ្នកជំងឺទាំងឡាយដែលត្រូវធ្វើការសំរេចចិត្តសំខាន់ៗបី ៖

- ទទួលការព្យាបាលអោយបានចប់សព្វគ្រប់
- ផ្លាស់ប្តូរការប្រព្រឹត្ត និង
- ត្រូវព្យាបាលដៃគូរួមភេទ

ផ្នែកនេះផ្តោតលើបច្ចេកទេសអនុវត្តន៍មួយចំនួនសំរាប់ធ្វើការផ្តល់ពត៌មានទៅអ្នកជំងឺ ។

## ភាពស្ទាត់ជំនាញផ្នែកអប់រំទាំង៦យ៉ាង ដែលសំរាប់ប្រើជំរុញអោយមានការផ្លាស់ប្តូរការប្រព្រឹត្ត

- ការពន្យល់ និងការបង្ហាត់បង្ហាញ
- ធ្វើការផ្តល់ជាគំរូ
- ធ្វើការពង្រឹងចំណុចខ្លាំងដែលអ្នកជំងឺមាន
- ធ្វើការជួយជ្រោមជ្រែងដល់អ្នកជំងឺឱ្យពិចារណាលើការជ្រើសរើសនានា
- ប្រាប់ឱ្យអ្នកជំងឺរំលឹកឡើងអំពីអ្វីដែលគាត់ត្រូវនិយាយ ឬ ធ្វើ
- ការពង្រឹងការសំរេចចិត្តរបស់អ្នកជំងឺ

តើយើងត្រូវលើកទឹកចិត្តដល់ការសំរេចចិត្តរបស់អ្នកជំងឺ ដើម្បីធ្វើការផ្លាស់ប្តូរការប្រព្រឹត្តនោះយ៉ាងដូចម្តេច ? ជាដំបូង សារៈសំខាន់នោះគឺត្រូវប្រើប្រាស់ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដែលយើងបានសិក្សារួចមកហើយនៅក្នុងជំពូកទី ៣ : សំណួរបើក ការជួយសំរួល ការសង្ខេប និងការពិនិត្យផ្ទៀងផ្ទាត់ ការធានាអះអាង ការតំរង់ទិស និងការបង្ហាញភាពជាដៃគូ ។ សូមរំលឹកឡើងវិញ ឬអនុវត្តនូវភាពស្ទាត់ជំនាញទាំងនេះម្តងទៀត បើសិនជាអ្នកហាក់ដូចជាមិនច្បាស់អំពីចំណុចទាំងនេះ ។

អ្នកនឹងយល់ឃើញថាភាពស្ទាត់ជំនាញទាំងនេះដែលមានសារៈសំខាន់សំរាប់ការអប់រំ និងការជំរុញអោយមានការផ្លាស់ប្តូរការប្រព្រឹត្ត ។ វានឹងជួយដល់អ្នកក្នុងការលើកទឹកចិត្តអ្នកជំងឺអោយធ្វើការជ្រើសរើសផ្សេងៗ និងធ្វើការសំរេចចិត្តនានា ។ ជំនាញទាំងនេះនឹងជួយ ប្រឈមមុខដោះស្រាយបញ្ហា និង ការតក់ស្លុត (shock) ដែលអ្នកជំងឺមាននៅពេលដែលដឹងថា ពួកគេមានជំងឺកាមរោគ និងពីរបៀបដែលគេឆ្លងជំងឺនេះ ។

## ការពន្យល់ និង ការបង្ហាត់បង្ហាញ

ការពន្យល់ មានន័យថានិយាយប្រាប់អ្នកជំងឺពីវិធីធ្វើអ្វីមួយ ឬ អំពីមូលហេតុរបស់វា ។ ការបង្ហាត់បង្ហាញមានន័យថា និយាយប្រាប់អ្នកជំងឺអំពីអ្វីដែលត្រូវធ្វើ ហើយត្រូវធ្វើយ៉ាងដូចម្តេច ដូចជា ការប្រើប្រាស់ស្រោមអនាម័យ ឬ ការប្រើប្រាស់ថ្នាំ ។ ទាំងនេះ គឺជាជំនាញដែលអ្នកផ្តល់ការថែទាំប្រើប្រាស់ជារឿយៗ ។

***ការពន្យល់ និង ការបង្ហាត់បង្ហាញ***

***ការពន្យល់*** :

" អ្នកមានការឈឺចាប់នៅផ្នែកក្រោមនៃពោះ ពីព្រោះមានចំលងរោគដល់អ្នកក្នុងកំឡុងពេលរួមភេទ "

***ការបង្ហាត់បង្ហាញ*** :

" សូមកុំភ្លេចលេបថ្នាំឱ្យបានគ្រប់គ្រាន់តាមរយៈពេល កំណត់រហូតដល់គ្រាប់ចុងក្រោយ "

អ្នកអាចធ្វើឱ្យភាពស្ទាត់ជំនាញទាំងនេះកាន់តែមានភាពល្អប្រសើរ ដោយ :

- សួរអ្នកជំងឺនូវអ្វីដែលពួកគេបានយល់មុនពេលធ្វើការពន្យល់អំពីបញ្ហាអ្វីមួយឱ្យបានល្អិតល្អន់ ។
- ពិភាក្សាអំពីយោបល់ផ្ទាល់ខ្លួនរបស់អ្នកជំងឺ
- ប្រើប្រាស់សំដីសាមញ្ញ ហើយច្បាស់លាស់ទៀតផង
- សំរបសំរួលសំដីរបស់អ្នក និងល្បឿនក្នុងពេលនិយាយតំរូវតាមតំរូវការរបស់អ្នកជំងឺ
- សួរ តើអ្នកជំងឺបានយល់នូវអ្វីដែលអ្នកបាននិយាយដែរឬទេ ។

**សុផានី**

| | | |
|---|---|---|
| *អ្នកផ្តល់សេវាថែទាំ* | : | *សូមកុំបារម្ភអីសុផានី ខ្ញុំនឹងជួយអ្នកអោយអស់ពីសមត្ថភាព ។ ជំងឺរបស់អ្នកបណ្តាលមកពីឆ្លងមេរោគម៉្យាង ។ តើអ្នកដឹងទេថាហេតុដូចម្តេចបានជាអ្នកឆ្លងរោគនេះ ?* |
| *សុផានី* | : | *ចាស, ខ្ញុំមិនច្បាស់ទេ ប៉ុន្តែ ...អឺ...* |
| *អ្នកផ្តល់សេវាថែទាំ* | : | *ចាស ?* |
| *សុផានី* | : | *ប្រហែលមកពីខ្ញុំបានញុំាចំណីខុសហើយមែនទេ ?* |
| *អ្នកផ្តល់សេវាថែទាំ* | : | *មិនមែនទេ ។ នេះជាដំណឹងមិនល្អសំរាប់អ្នក ។ អ្នកមានរលាកប៉ែលវីស វាគឺជាជំងឺកាមរោគមួយបែប ។ តើអ្នកយល់អំពីអត្ថន័យនៃពាក្យនេះទេ ?* |

| | | |
|---|---|---|
| *សុផានី* | *:* | *អឺ !... វាមកពីការប៉ះពាល់មនុស្សកខ្វក់... ប៉ុន្តែ វាមិនអាចទៅជាអញ្ចឹងបានទេ ។* |
| *អ្នកផ្តល់សេវាថែទាំ* | *:* | *ពិតជាអញ្ចឹងមែនហើយ វាមិនដូចដែលអ្នកយល់ឃើញនោះទេ ។ ជំងឺបែបនេះបណ្តាលមកតែពី ការរួមភេទដោយមិនប្រើមធ្យោបាយបង្ការជាមួយនរណាម្នាក់ ហើយដែលមានជំងឺដូចគ្នាអញ្ចឹងដែរ ។ ការរួមភេទដោយមិនប្រើមធ្យោបាយការពារ មានន័យថា រួមភេទដោយមិនប្រើស្រោមអនាម័យ ។* |
| *សុផានី* | *:* | *ប៉ុន្តែ ខ្ញុំរួមភេទតែជាមួយប្តីខ្ញុំម្នាក់គត់។ គាត់មិនឈឺអ្វីទេ...* |
| *អ្នកផ្តល់សេវាថែទាំ* | *:* | *គាត់មិនចាំបាច់ត្រូវតែមានឈឺចាប់នោះទេសុផានី ។ មនុស្សយើងជារឿយៗ គ្មានឈឺទេ ។ ប៉ុន្តែបើសិនជា អ្នកគេងតែជាមួយគាត់នោះ គាត់ច្បាស់ជាអ្នកចំលងរោគមកអ្នក ។ ហើយគាត់ច្បាស់ជាមានជំងឺនេះ ។* |
| *សុផានី* | *:* | *មកពីគាត់រួមភេទជាមួយអ្នកណាផ្សេងឬ? ទេ... ទេ...* |
| *អ្នកផ្តល់សេវាថែទាំ* | *:* | *ខ្ញុំយល់ថាអ្នកពិបាកចិត្តខ្លាំងណាស់ដោយបានដឹងដំណឹងអាក្រក់នេះ ។ អ្នកត្រូវការពេលវេលាដើម្បីគិតអំពីរឿងនេះ ។* |

សូមកត់សំគាល់យ៉ាងប្រុងប្រយ័ត្នអំពីរបៀបដែលអ្នកផ្តល់សេវាថែទាំ ប្រាប់ដំណឹងដល់សុផានី ។ អ្នកផ្តល់សេវាថែទាំកំពុងបំបែកការពន្យល់ឱ្យចូលក្នុងផ្នែកតូចៗ ដោយសំរបខ្លួនតាមអារម្មណ៍របស់សុផានី ។

## ការផ្តល់គំរូ

ការផ្តល់គំរូមានន័យថា ផ្តល់ឧទាហរណ៍ការប្រព្រឹត្តដែលអ្នកដទៃបានធ្វើប្រកបដោយជោគជ័យ ហើយដែលស្ថិតនៅក្នុងស្ថានភាពប្រហាក់ប្រហែលនឹងអ្នកជំងឺដែរ ។ ប្រអប់ខាងក្រោមនេះ បង្ហាញអំពីការប្រើប្រាស់នូវភាពស្ទាត់ជំនាញនេះ របស់អ្នកផ្តល់សេវាថែទាំម្នាក់ក្នុងការសំភាសន៍នាងផល្លី ។

**ណារិទ្ធ**

*ណារិទ្ធ : ខ្ញុំមិនសប្បាយចិត្ត ដោយមិនបាច់ប្រឈមមុខនឹងគ្រោះថ្នាក់ទាំងនេះទៀតមែនទេ ?*

*អ្នកផ្តល់សេវាថែទាំ : ពិតហើយអ្នកអាចសប្បាយបាន។ វាខុសគ្នាបន្តិចតែប៉ុណ្ណោះ ។ វាពិបាកនឹងផ្លាស់ប្តូរណាស់ ដូច្នេះចូរយើងនិយាយអំពីអ្វីទៅដែលអាចធ្វើឱ្យមានសុវត្ថិភាពជាងមុន ។*

*ណារិទ្ធ : អ្នកចង់និយាយថា ការផឹកស្រាមុនពេលរួមភេទពុំមែនជាការល្អទេ មែនទេ ?*

*អ្នកផ្តល់សេវាថែទាំ : នេះមកពីការផឹកស្រាមានទំនោរធ្វើឱ្យមនុស្សភ្លេចភ្លាំងច្រើន ជាហេតុនាំឱ្យមានការលំបាកក្នុងការប្រើប្រាស់ស្រោមអនាម័យ ។ ប្រសិនបើអ្នកស្រវឹងហើយ អ្នកនឹងពុំនឹកនាដល់ការប្រើប្រាស់ស្រោមអនាម័យបានទេ ។ហើយខ្ញុំបានកត់សំគាល់ឃើញថា ប្រុសៗ កាន់តែច្រើនមានការប្រុងប្រយ័ត្នហើយគេនៅតែមានការសប្បាយដដែល ។ ក្នុងពេល ថ្មីៗនេះ ខ្ញុំបានឃើញថា ប្រុសៗជាច្រើនបានសំរេចចិត្តផឹកស្រា តិចជាងមុនហើយ ប្រើប្រាស់ស្រោមអនាម័យ ។*

*ណារិទ្ធ : អញ្ចឹង, ខ្ញុំគិតថា ខ្ញុំពិតជាអាចខំប្រឹងប្រែងរកស្រោមអនាម័យទុកជាប់ខ្លួន និងមិនផឹកស្រាច្រើនពេកទេដែលជាហេតុនាំឱ្យខ្ញុំបាត់បង់ម្ចាស់ការ ។*

អ្នកអាចប្រើការផ្តល់ជាគំរូ ដើម្បីអោយជាឧទាហរណ៍ដែលបានពី បទពិសោធន៍របស់អ្នកផ្ទាល់ "ឆ្លងតាមការងារដែលខ្ញុំធ្លាប់ធ្វើកន្លងមក / ខ្ញុំយល់ថា..." ឬ "ខ្ញុំបានកត់សំគាល់ឃើញថា... "។

ហេតុអ្វីបានជាការផ្តល់ឧទាហរណ៍វិជ្ជមានមានសារៈសំខាន់ណាស់ ? យើងដឹងហើយថា មនុស្សមួយចំនួនមានសេចក្តីភ័យខ្លាចខ្លាំងពេក គេទំនងជាមិនផ្លាស់ប្តូរការប្រព្រឹត្តរបស់ពួកគេឡើយ ។ ការផ្តោតទៅលើការផ្តល់គំរូជាវិជ្ជមានអំពីការផ្លាស់ប្តូរ គឺជាប្រសិទ្ធិភាពកាន់តែខ្ពស់សំរាប់ជួយដល់អ្នកជំងឺឱ្យផ្លាស់ប្តូរការប្រព្រឹត្តរបស់ពួកគេ ។

## ការពង្រឹងចំណុចខ្លាំងដែលអ្នកជំងឺមាន

ការពង្រឹងចំណុចខ្លាំងត្រូវធ្វើនៅពេលដែលយើងចង់ចង្អុលប្រាប់អំពីចំណុចខ្លាំងដែលអ្នកជំងឺមាន ។ វានឹងជួយគាត់ឱ្យរក្សាខ្លួនបានជាស្រួលបួលឡើងវិញឬបង្ការការឆ្លងជំងឺកាមរោគសាជាថ្មីឡើងវិញ ។ វាជួយលើកទឹកចិត្តអ្នកជំងឺឱ្យដឹងថា ពួកគេអាចជួយខ្លួនឯងបាន ។

**ណារិទ្ធ**

*ណារិទ្ធ : បាទ ! ដូចដែលខ្ញុំបានដឹង វាមានសារៈសំខាន់ណាស់ តែ...ខ្ញុំមិនគិតថា ខ្ញុំមិនអាចទំលាប់ប្រើវិធីនេះបានទេ ។*

*អ្នកផ្តល់សេវាថែទាំ : ខ្ញុំដឹងថា វាលំបាកណាស់ ប៉ុន្តែខ្ញុំបាន សំគាល់ឃើញថា អ្នកខំប្រឹងធ្វើដំណើរចំងាយ ១០គីឡូម៉ែត្រ មកទីនេះដើម្បីទទួលការព្យាបាលជំងឺរបស់អ្នក ។ ការប្តេជ្ញាចិត្ត និងកង្វល់របស់នាងនឹងជួយអ្នកឱ្យមានសុវត្ថិភាព ។*

**សុផានី**

*សុផានី : ខ្ញុំមានអារម្មណ៍ថា ជីវិតខ្ញុំត្រូវក្លាយជាអត់ន័យ ។ ខ្ញុំមិនអាចលៃលកដោះស្រាយរឿងទាំងអស់នេះអស់ទេ...*
*តើខ្ញុំត្រូវធ្វើដូចម្តេចទៅ ?*

*អ្នកផ្តល់សេវាថែទាំ : ខ្ញុំយល់ពីអារម្មណ៍នាងហើយសុផានី សេចក្តីទុកចិត្តរបស់នាងបានរលាយសាបសូន្យហើយ ។ នាងខ្វល់ខ្វាយអំពីសង្សារនាងនិងក្រុមគ្រួសាររបស់នាងខ្លាំងណាស់ ហើយអារម្មណ៍អាក្រក់ទាំងនេះរបស់នាងនឹងរលាយក្នុងពេលឆាប់នេះមិនខាន... ប៉ុន្តែ ជាដំបូងយើងត្រូវពិភាក្សាគ្នារកមធ្យោបាយដោះស្រាយបញ្ហារបស់នាងជាមុនសិន ។*

*សុផានី : ចាស ចាស... អ្នកគ្រូនិយាយនេះពិតជាត្រូវមែន ខ្ញុំត្រូវគិតពីរឿងនេះសិន ។ តើអ្នកគ្រូនឹងអោយថ្នាំខ្ញុំខ្លះដែរឬទេ ?*




## ការពិនិត្យមើលការជ្រើសរើសនានារបស់អ្នកជំងឺ

នៅពេលពិនិត្យមើលការជ្រើសរើសរបស់អ្នកជំងឺ អ្នកអាចចង្អុលបង្ហាញពីជំរើស ឬ ជំហាននានា ដែលអ្នកជំងឺអាចយកទៅប្រើប្រាស់ដើម្បីធ្វើឱ្យជាសះស្បើយពីជំងឺកាមរោគបច្ចុប្បន្នរបស់គាត់ និង បង្ការជំងឺផ្សេងៗទៀត ។ បន្ទាប់មកអ្នកអាចជួយអ្នកជំងឺឱ្យសំរេចចិត្តយកជំរើសណាមួយដែលល្អ បំផុតសំរាប់គាត់ ។ ការធ្វើបែប នេះជួយឱ្យអ្នកជំងឺធ្វើការសំរេចចិត្តដោយខ្លួនឯងដើម្បីធ្វើការ ផ្លាស់ប្តូរការប្រព្រឹត្តដែលជាគន្លឹះដ៏សំខាន់សំរាប់រក្សាខ្ជាប់នូវការប្រព្រឹត្តថ្មីនេះបានយូរអង្វែង ។

**ណារិទ្ធ**

*ណារិទ្ធ : ដូច្នេះខ្ញុំត្រូវប្រើស្រោមអនាម័យជាប្រចាំ ឬ មានដៃគូរួមភេទតែម្នាក់ ឬក៏រួមភេទដោយមិនស៊កបញ្ចូលមែនទេ ?*

*អ្នកផ្តល់សេវាថែទាំ : ត្រូវហើយ អ្នកអាចកសាងអនាគតគ្រួសារដោយមានដៃគូរួមភេទតែម្នាក់ ឬមួយបើអ្នកមិនទាន់រៀបចំខ្លួនចំពោះរឿងនេះទេ សូមបង្ការខ្លួននាងដោយប្រើស្រោមអនាម័យ ឬ រួមភេទដោយមិនបាច់ស៊កបញ្ចូល។ តើមធ្យោបាយណាមួយងាយស្រួលបំផុតសំរាប់អ្នក ?*

*ណារិទ្ធ : គឺ ការប្រើស្រោមអនាម័យ ។ ខ្ញុំមិនទាន់ចង់កសាងគ្រួសារទេ ។*

*សុផានី*

*អ្នកផ្ដល់សេវាថែទាំ : ឥឡូវនេះខ្ញុំចង់ឱ្យអ្នកធ្វើការសំរេចចិត្ត ។ តើនាងពេញចិត្តនឹងជៀសវាងការរួមភេទ រហូតដល់អ្នកទទួលការព្យាបាលចប់សព្វគ្រប់ ឬអ្នកសុំឱ្យប្ដីអ្នកប្រើប្រាស់ស្រោមអនាម័យ ?*

*សុផានី : ការមិនរួមភេទរយៈពេលខ្លីជាការងាយទេ ។ វាមិនជាបញ្ហាអ្វីទេ ពីព្រោះគាត់ដឹងថាខ្ញុំមិនស្រួលខ្លួនដែរ ។ ខ្ញុំអាចយកពេលវេលានេះទៅពិចារណាអំពីរឿងខ្ញុំ ។*

*អ្នកផ្ដល់សេវាថែទាំ : អញ្ចឹង ល្អហើយ ។*

## ធ្វើការហាត់សមការសំរេចចិត្ត

នៅពេលដែលអ្នកជំងឺសំរេចចិត្តដោយខ្លួនឯងដើម្បីកែប្រែការប្រព្រឹត្ត សំខាន់គឺត្រូវសុំឱ្យអ្នកជំងឺពិនិត្យមើលការសំរេចចិត្តរបស់គាត់ឡើងវិញ ។ នេះបានន័យថា អ្នកត្រូវស្នើសុំអ្នកជំងឺឱ្យគិតយ៉ាងដូចម្ដេច ដើម្បីឱ្យជាក់ការសំរេចចិត្តឱ្យចេញជាការអនុវត្តជាក់ស្ដែង ។

**ណារិទ្ធ**

*អ្នកផ្ដល់សេវាថែទាំ : ល្អណាស់ណារិទ្ធ ។ តើអ្នកនឹងពន្យល់ បញ្ហានេះប្រាប់សង្សារនាងយ៉ាងដូចម្ដេចខ្លះ?*

*ណារិទ្ធ : បាទ ខ្ញុំអាចចាប់ផ្ដើមដោយនិយាយរ៉ាយរ៉ាប់ ថាមានជំងឺដ៏អាស្រូវមួយចំនួនកំពុងកើតហើយ យើងត្រូវតែប្រុងប្រយ័ត្នដើម្បីជៀសវាងវា ។*

*អ្នកផ្ដល់សេវាថែទាំ : ស្ដាប់ទៅដូចជាសមហើយ ។ សូមនិយាយ* បន្តទៀតមើល ។

**សុផានី**

*អ្នកផ្តល់សេវាថែទាំ :ដូច្នេះ អ្នកមានគំរោងដើម្បីនឹងជៀសវាងការរួមភេទរហូតដល់បានលេបថ្នាំចប់ ។ ប្តីនាងក៏ត្រូវការព្យាបាលផងដែរ តើនាងគិតរកវិធីណាដើម្បីនិយាយប្រាប់គាត់អំពីបញ្ហានេះ ?*

*សុផានី : ខ្ញុំចង់និយាយអំពីរឿងហ្នឹងខ្លះៗប្រាប់គាត់ តើត្រូវប្រាប់ថា នេះជាបញ្ហាធ្ងន់ធ្ងរ ឬ គាត់គិតតែលេងសើចនឹងស្រីញី ? ឬខ្ញុំអាចសុំឱ្យគាត់មកជួបអ្នកគ្រូនៅទីនេះ... ដើម្បីឱ្យអ្នកគ្រូជួយគាត់ ។*

ការហាត់សមនេះមានសារៈសំខាន់ នៅពេលដែលអ្នកចង់ផ្ទៀងផ្ទាត់មើលថា តើអ្នកជំងឺបានយល់ការណែនាំរបស់អ្នកស្តីអំពីការព្យាបាល ឬទេ ។

**ណារិទ្ធ**

អ្នកផ្តល់សេវាថែទាំ : ណារិទ្ធ ខ្ញុំយល់ថា យើងបានពិភាក្សាជាមួយនាងចប់សព្វគ្រប់ហើយ។ សូមប្រាប់ខ្ញុំម្តងទៀតថា តើអ្នកមានបំណងប្រើប្រាស់ថ្នាំទាំងអស់នេះយ៉ាងដូចម្តេច ?

ណារិទ្ធ : ខ្ញុំនឹងលេបថ្នាំទាំងអស់ឱ្យដូចការបញ្ជាក់ក្នុងវេជ្ជបញ្ជានេះ ។ ខ្ញុំនឹងរក្សាទុកក្រដាសនេះក្នុងហោប៉ៅខ្ញុំ ហើយខ្ញុំនឹងមិនរួមរក័្យជាមួយសង្សារខ្ញុំទេរហូតដល់លេបថ្នាំអស់ ប៉ុន្តែខ្ញុំនឹងរកស្រោមអនាម័យក្នុងករណីខ្លះដែល...

**សុផានី**

អ្នកផ្តល់សេវាថែទាំ : អ្នកមានសេចក្តីក្លាហានណាស់ ។ សូមពិនិត្យមើលគំរោងការរបស់អ្នកជាមួយខ្ញុំម្តងទៀត ។

សុផានី : ខិតខំរក្សាខ្លួនឱ្យជាសះស្បើយ លេបថ្នាំឱ្យបានគ្រប់គ្រាន់ រកពេលនិយាយជាមួយប្តីខ្ញុំ អំពីបញ្ហាមួយចំនួនហើយប្រាប់គាត់ថា គាត់ក៏ត្រូវការទទួលការព្យាបាលដែរ...

អ្នកផ្តល់សេវាថែទាំ : ចាស៎, ល្អណាស់ ។ អ្នកអាចមកជួបខ្ញុំម្តងទៀតប្រសិនបើនាងត្រូវការ ។

សុផានី : ចាស៎ ! អរគុណណាស់ ! ខ្ញុំនឹងមក

## ការពង្រឹងការសំរេចចិត្ត

មកដល់ពេលនេះអ្នកបានជួយអ្នកជំងឺឱ្យយល់អំពីបញ្ហាមួយចំនួន ។ អ្នកបានជួយរៀបចំពួកគេឱ្យធ្វើអ្វីដែលត្រូវធ្វើក្រោយពេលចាកចេញពីគ្លីនិកកាមរោគ ។ ធ្វើការពង្រឹងការសំរេចចិត្ត គឺជាមធ្យោបាយដ៏មានអត្ថប្រយោជន៍មួយដើម្បីធ្វើការសង្ខេបការធ្វើសំភាសន៍ផង ។ ចូរសុំឱ្យអ្នកជំងឺនិយាយប្រាប់អំពីការសំរេចចិត្តរបស់គាត់ចំពោះមុខអ្នកឡើងវិញ ។ ដោយអ្នកបានជួយពង្រឹងការសំរេចចិត្តពួកគេ អ្នកជំងឺទំនងជាធ្វើការផ្លាស់ប្តូរការប្រព្រឹត្តរបស់ពួកគេបានច្រើនជាង ។

## ការប្រើប្រាស់ស្រោមអនាម័យដើម្បីបង្ការខ្លួនពីការឆ្លងកាមរោគ

ស្រោមអនាម័យជួយអោយមនុស្សទាំងឡាយអាចជៀសវាងការឆ្លងជំងឺកាមរោគបាន ដោយការពារមិនឱ្យប៉ះពាល់ផ្ទាល់ជាមួយទឹករំអិលទ្វារមាស ទឹកកាម ឬ ឈាម ។ អ្នកគួរណែនាំឱ្យអ្នកជំងឺប្រើប្រាស់ស្រោមអនាម័យ បើសិនគាត់រួមភេទជាមួយដៃគូច្រើន ហើយវាក៏មានសារៈសំខាន់ផងដែរនៅពេលដៃគួរួមភេទរបស់អ្នកជំងឺមានដៃគួរួមភេទច្រើនទៀត ។ ប៉ុន្តែការគ្រាន់តែដឹងថាស្រោមអនាម័យមានសារៈសំខាន់នោះមិនទាន់គ្រប់គ្រាន់ទេ ។ អ្នកជំងឺត្រូវប្រើប្រាស់វាអោយបានទៀងទាត់នឹងត្រឹមត្រូវផងដែរ ។ មនុស្សម្នាជាច្រើនប្រឆាំងនឹងការប្រើប្រាស់ស្រោមអនាម័យ ។ បញ្ហានេះកើតឡើងមកពីពួកគេខ្វាសអៀនក្នុងការរកទិញ ឬ ការប្រើប្រាស់ស្រោមអនាម័យ ឬមួយមកពីពួកគេខ្វល់ខ្វាយអំពីតំលៃរបស់វា ។ មនុស្សមួយចំនួនគិតថា ស្រោមអនាម័យធ្វើឱ្យការរួមភេទបន្ថយនូវការសប្បាយ ឬត្រេកត្រអាល ថាស្រោមអនាម័យវាធំពេកឬតូចពេក ។ ហើយជា

រឿយៗមានរឿងមិនពិតអំពីស្រោមអនាម័យ ដោយរាប់បញ្ចូលផងដែរនូវពាក្យចចាមអារាមដែលថាស្រោមអនាម័យមិនមានប្រសិទ្ធិភាពអ្វីទេ ឬក៏ថាស្រោមអនាម័យទាំងនោះប្រឡាក់ដោយមេរោគដែលបង្កកាមរោគ ។ មនុស្សម្នាទាំងឡាយអាចប្រើស្រោមអនាម័យតែនៅពេលដែលរួមភេទជាមួយអ្នករកស៊ីផ្លូវភេទ ហើយអាចប្រើតិចតួចក្នុងពេលដែលរួមភេទជាមួយដៃគូទៀងទាត់របស់ខ្លួន ។ ការសំខាន់ គឺត្រូវដឹងអំពីគំនិតមិនល្អចំពោះស្រោមអនាម័យក្នុងតំបន់របស់អ្នក ។ គំនិតនេះអាចជាឧបសគ្គរារាំងដល់ការប្រើប្រាស់ស្រោមអនាម័យ ។

## ការលើកទឹកចិត្តដល់ការប្រើប្រាស់ស្រោមអនាម័យ

| **ការលើកទឹកចិត្តដល់ការប្រើប្រាស់ស្រោមអនាម័យទាក់ទងនៅនឹង :** |
|---|
| • ស្វែងយល់អំពីចំណេះដឹងរបស់អ្នកជំងឺអំពីស្រោមអនាម័យ និងការប្រើប្រាស់វា ។<br>• ពន្យល់អំពីអត្ថប្រយោជន៍នៃស្រោមអនាម័យ<br>• ធ្វើការកែតំរូវនូវជំនឿខុសឆ្គងនានារបស់ពួកគេដែលរារាំងដល់ការប្រើប្រាស់ស្រោមអនាម័យ |

ជំនាញក្នុងការប្រាស្រ័យទាក់ទងនានា ដែលអ្នកបានសិក្សាក្នុងការសាកសួរអំពីប្រវត្តិជំងឺ និងការអប់រំ ជាឧបករណ៍ដ៏សំខាន់សំរាប់ការលើកទឹកចិត្តឱ្យអ្នកជំងឺប្រើប្រាស់ស្រោមអនាម័យ ។ អ្នកអាចចាប់ផ្តើមដោយសាកសួរអ្នកជំងឺនូវការយល់ឃើញរបស់គាត់ស្តីអំពីស្រោមអនាម័យ ។ យើងត្រឡប់ទៅសិក្សាករណីរបស់ផល្លីម្តងទៀត ដើម្បីបង្ហាញឱ្យឃើញអំពីការប្រើប្រាស់នូវភាពស្ទាត់ជំនាញទាំងនេះ ។



**សំណាង**

សំណាង : ឯងបាននិយាយថា ការប្រើប្រាស់ស្រោមអនាម័យគឺជាមធ្យោបាយមួយក្នុងការរក្សាសុវត្ថិភាព, ប៉ុន្តែ ខ្ញុំមិនចង់ប្រើប្រាស់វាទេ ។

អ្នកផ្តល់សេវាថែទាំ : ហេតុអ្វីមិនប្រើ ?

សំណាង : បាទ វាគឺជាវត្ថុសៅហ្មងក្នុងចិត្តខ្ញុំ ខ្ញុំចង់និយាយថា ពួកគេជ្រើសរើសយកវាជាមធ្យោបាយប្រើប្រាស់ ។ អ្នកយល់ នូវអ្វីដែលខ្ញុំចង់ជំរាបនោះហើយ ។

អ្នកផ្តល់សេវាថែទាំ :អញ្ចឹង អ្នកសាកល្បងប្រើប្រាស់វាពីមុនមកឬ ?

សំណាង : អឺ, ទេ, ប៉ុន្តែខ្ញុំបានប្រាប់ដូច្នេះ ។

អ្នកផ្តល់សេវាថែទាំ : បាទ ពួកគេមិនចង់ជ្រើសរើសយកមធ្យោបាយនេះទេ ។ ខ្ញុំអាចនឹងបង្ហាញអ្នកអំពីរបៀបប្រើប្រាស់វា ។ ខ្ញុំដឹងថា ប្រុសៗជាច្រើនមានការត្រេកត្រអាលនៅពេលដែលគេប្រើប្រាស់វា ពីព្រោះគេស្នើសុំអោយដៃគូរបស់គេពាក់ស្រោមអនាម័យនេះអោយពួកគេ ។

សំណាង : បាទ, តែហេតុអ្វីបានជាវាចេះតែរបូតចេញ ?

អ្នកផ្តល់សេវាថែទាំ : វានឹងមិនរបូតចេញទេបើសិនជាគាត់ ប្រើប្រាស់វាបានត្រឹមត្រូវ ខ្ញុំសូមសន្យានឹងនាង ។ តើនៅមានហេតុផលអ្វីទៀតទេដែលថាមិនចូលចិត្តវានោះ ?

សំណាង : បាទ, នោះហើយគឺជារឿងធំនោះ ។

អ្នកផ្តល់សេវាថែទាំ : បុរសមួយចំនួននិយាយថា ស្រោមអនាម័យពិតជាធ្វើឱ្យការរួមភេទប្រព្រឹត្តទៅក្នុងរយៈពេលយូរ ។ តើអ្នកមានគិតអំពីរឿងនេះឬទេ ?

| | |
|---|---|
| សំណាង | : (សើចហើយអៀនប្រៀន) អញ្ចឹងមែនហើយ |
| អ្នកផ្តល់សេវាថែទាំ | : តើអ្នកគួរនឹងល្បងប្រើប្រាស់ស្រោមអនាម័យឬទេ ? |
| សំណាង | : បាទ ខ្ញុំគួរតែល្បងប្រើវា ។ |
| អ្នកផ្តល់សេវាថែទាំ | : ល្អហើយ តែចូរចងចាំថា បើអ្នកមិនប្រើប្រាស់ស្រោមអនាម័យទេ អ្នកគួរតែប្រកាន់ខ្ជាប់យកដៃគូរួមភេទតែមួយ ឬ អនុវត្តការរួមភេទដោយមិនបញ្ចូលប្រដាប់បន្តពូជ ។ ខ្ញុំសូមបង្ហាញអ្នកអំពីការប្រើប្រាស់ស្រោមអនាម័យ។ |

ចំពោះអ្នកជំងឺនិមួយៗ អ្នកត្រូវពន្យល់អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ស្រោមអនាម័យ ដែលជាមធ្យោបាយសមស្របបំផុតសំរាប់អ្នកជំងឺនោះ ។

## ការបង្ហាញអំពីការប្រើប្រាស់ស្រោមអនាម័យ

អ្នកមិនត្រឹមតែត្រូវពិភាក្សាពីការប្រើប្រាស់ស្រោមអនាម័យជាមួយអ្នកជំងឺប៉ុណ្ណោះទេ ប៉ុន្តែគឺត្រូវអនុវត្តបង្ហាញពីវិធីត្រឹមត្រូវដើម្បីប្រើប្រាស់ស្រោមអនាម័យផងដែរ ។ ប្រជាជនជាច្រើនជឿជាក់ខ្លួនឯងថា ពួកគេដឹងអំពីរបៀបប្រើប្រាស់ស្រោមអនាម័យហើយ ប៉ុន្តែតាមពិតទៅ គេអាចពាក់វាមិនបានត្រឹមត្រូវដែលធ្វើឱ្យស្រោមអនាម័យក្លាយជាមិនសូវមានប្រសិទ្ធិភាព ក្នុងការបង្ការកាមរោគទៅវិញ ។ មនុស្សទាំងពីរភេទត្រូវយល់ដឹងអំពីរបៀបប្រើប្រាស់ស្រោមអនាម័យឱ្យបានត្រឹមត្រូវ ។

## ការបង្ហាញអំពីការប្រើប្រាស់ស្រោមអនាម័យ

- ធ្វើការបង្ហាញការពាក់ស្រោមអនាម័យអោយបានល្អិតល្អន់ដល់អ្នកជំងឺនិមួយៗ
- សុំឱ្យអ្នកជំងឺអនុវត្តសកម្មភាពពាក់ស្រោមអនាម័យដោយខ្លួនឯងនៅចំពោះមុខអ្នក
- សង្កត់ធ្ងន់លើការចាំបាច់ក្នុងការរក្សាខ្ចប់ស្រោមអនាម័យជាប់ ខ្លួនគ្រប់ពេលវេលា ។
  ចំណុចគន្លឹះបន្ថែមពីរទៀត :
  * ប្រេងរំអិលដែលធ្វើអំពីជាតិទឹកមានសុវត្ថិភាពសំរាប់ប្រើប្រាស់ជាមួយស្រោមអនាម័យ ។ ថ្នាំសំលាប់ស្ពែម៉ាតូស្ស៊ីត ក៏មានប្រសិទ្ធិភាពផងដែរ ។ មិនត្រូវប្រើប្រេងរំអិល ឬ ប្រេងខាប់ដែលធ្វើពីជាតិប្រេងទេ ពីព្រោះធ្វើឱ្យខូចខាតដល់កៅស៊ូ ។
  * ស្រោមអនាម័យអាចប្រើបានត្រឹមតែមួយដងប៉ុណ្ណោះ ។

បើសិនជាអ្នកជំងឺនិយាយថាគាត់បានដឹងអំពីរបៀបប្រើប្រាស់ស្រោមអនាម័យហើយនោះ វាមានប្រយោជន៍ណាស់ដែលយើងត្រូវសុំឱ្យគាត់ធ្វើបង្ហាញប្រាប់យើង ។ ដូច្នេះ អ្នកអាចប្រាកដក្នុងចិត្តថា គាត់ប្រើប្រាស់ស្រោមអនាម័យបានត្រឹមត្រូវឬទេ ហើយបើសិនជា ចាំបាច់អ្នកអាចកែតំរូវកំហុសនានាបាន ។

សូមមើលរូបភាពខាងក្រោម ដើម្បីរំលឹកឡើងវិញពីជំហានសំខាន់ៗ ក្នុងការប្រើប្រាស់ស្រោមអនាម័យឱ្យបានត្រឹមត្រូវ ។ ដើម្បីធ្វើការបង្ហាញពីការពាក់ស្រោមអនាម័យ អ្នកត្រូវការនូវស្រោមអនាម័យ និងប្រដាប់បន្តពូជសិប្បនិម្មិត ឬ អ្វីផ្សេងជំនួសក៏បាន (ឧទាហរណ៍ : ផ្លែចេក ឬដងអំបោស) ។

**មួយជំហានម្តងៗ   ណែនាំពីការប្រើប្រាស់ស្រោមអនាម័យអោយបានត្រឹមត្រូវ**



***១.  ពន្យល់ណែនាំថា  ស្រោមអនាម័យអាចហួសពេលកំណត់,  មានក្លិនអាក្រក់,  ស្ងិត  ឬ  ពិបាកលាត  ឬ  រលា***



***២.  ពន្យល់ណែនាំពីរបៀបហែកកញ្ចប់ដោយប្រុងប្រយ័ត្ន  (ជៀសវាងមុតរហែកស្រោមដោយរបស់មុតស្រួច  ដូចជាចិញ្ចៀនជាដើម)***



***៣.  បង្ហាញពីផ្នែកខាងត្រូវរបស់ស្រោមអនាម័យដែលត្រូវពាក់លើប្រដាប់បន្តពូជពន្យល់ថាវានឹងមិនរលាចុះក្រោមទេបើសិនជាពាក់ត្រឡប់នៅផ្នែកម្ខាងទៀត***



***៤.  បង្ហាញថាត្រូវកាន់ផ្នែកខាងចុងរបស់ស្រោមអនាម័យដើម្បីច្របាច់បញ្ចេញខ្យល់មុនពេលច្បូត  ឬពន្លាវាចុះក្រោមលើប្រដាប់បន្តពូជដែលឡើងរឹងស្រាប់  ។ បញ្ជាក់ប្រាប់ថាគេត្រូវពន្លូតស្បែកចុះក្រោមបើសិនជាគេមិនកាត់ចុងទេនោះ  ។***



***៥.  សង្កត់ធ្ងន់ថា  ស្រោមអនាម័យត្រូវតែពន្លាចុះក្រោមលើប្រដាប់បន្តពូជឱ្យបានវែងដូចដែលអាចធ្វើទៅបាន  ហើយក្នុងពេលដែលគេច្បូតវាចេញនោះប្រហោងនៅត្រង់ចុងកំពូលរបស់ស្រោមអនាម័យនឹងរក្សាទុកទឹកកាម  ។***



***៦.  ពន្យល់ថាស្រោមអនាម័យអាចរបូតមុនពេលប្រដាប់បន្តពូជទន់ហើយគេគួរតែជួយទប់ដោយប្រុងប្រយ័ត្ននៅត្រង់គល់និងរំកិលវាចុះពីប្រដាប់បន្តពូជយ៉ាងយឺតៗ***



***៧.  ពន្យល់ថា  ផ្នែកចុងកំពូលនៃស្រោមអនាម័យដែលយើងបានប្រើប្រាស់ហើយនោះគួរតែចងភ្ជិតទុកទឹកកាមឱ្យនៅខាងក្នុងមុនពេលបោះវាចោល  ។***

## ការរំលឹកសាឡើងវិញ

### ហេតុអ្វីត្រូវអប់រំ ?

អ្នកជំងឺកាមរោគត្រូវការនូវការអប់រំ ដើម្បីជួយពួកគេអោយធ្វើការសំរេចចិត្ត ៣សំខាន់ៗ :

- ទទួលការព្យាបាលរបស់ពួកគេឱ្យបានចប់សព្វគ្រប់
- ផ្លាស់ប្តូរការប្រព្រឹត្តផ្លូវភេទដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លង
- ពិចារណាលើការព្យាបាលដៃគូរួមភេទរបស់ពួកគេ

ការអប់រំលើកទឹកចិត្តអ្នកជំងឺឱ្យផ្លាស់ប្តូរការប្រព្រឹត្ត វាក៏ជាផ្នែកមួយនៃការគ្រប់គ្រងថែទាំកាមរោគ ដោយពឹងផ្អែកលើចង្កោមរោគសញ្ញាដែរ ។

ការអប់រំមិនមែនត្រឹមតែផ្តល់ពត៌មានប៉ុណ្ណោះទេ វាជាដំណើរការទ្វេទិសដែលជួយអ្នកជំងឺអោយធ្វើការសំរេចចិត្តបានត្រឹមត្រូវដោយខ្លួនឯង ។

### ការអប់រំដើម្បីលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត

វិធីលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្តរួមមាន :

- ការធានាភាពស្ងាត់កំបាំង និងការរក្សាការសំងាត់ជូនអ្នកជំងឺ
- ការស្វែងរកទំនុកចិត្តដោយយកចិត្តទុកដាក់ស្តាប់ និងមើលទៅអ្នកជំងឺឱ្យចំមុខ
- ការរៀបរៀងសំដីរបស់អ្នកធ្វើយ៉ាងណាកុំឱ្យមានការវិនិច្ឆ័យ
- ការប្រើប្រាស់ភាសាសាមញ្ញហើយច្បាស់លាស់
- ការផ្តោតទៅលើតំរូវការពត៌មាន និងការអប់រំសំរាប់អ្នកជំងឺម្នាក់ៗ
- កំណត់ព្រំដែន និងផ្តល់អាទិភាពសំរាប់សាររបស់អ្នក
- ជួយអ្នកជំងឺឱ្យពិចារណាអំពីអត្ថប្រយោជន៍ និង តំលៃនៃការប្រព្រឹត្តថ្មី
- ផ្តោតទៅលើជំរើសក្នុងការផ្លាស់ប្តូរការប្រព្រឹត្តនានា ដែលមានលក្ខណៈប្រាកដនិយម ។
- ស្វែងរកការព្រមព្រៀងជាមួយអ្នកជំងឺនៅពេលដែលគាត់សុខចិត្ត សាកល្បងប្រតិបត្តិតាមការប្រព្រឹត្តថ្មីណាមួយរួចហើយ ។

## បញ្ហាដែលត្រូវយកមកអប់រំអ្នកជំងឺ

បញ្ហាដែលត្រូវលើកយកមកពិភាក្សាជាមួយអ្នកជំងឺកាមរោគរួមមានៈ

- ការពន្យល់ពីកាមរោគ
- ការពន្យល់ពីការព្យាបាល
- ការវាយតំលៃអំពីការប្រឈមមុខនឹងគ្រោះថ្នាក់បណ្តាលមកពីការប្រព្រឹត្ត
- ការវាយតំលៃអំពីឧបសគ្គរាំងដល់ការផ្លាស់ប្តូរការប្រព្រឹត្ត
- លើកទឹកចិត្តអោយមានការផ្លាស់ប្តូរការប្រព្រឹត្ត
- បញ្ជាក់ពីការសំរេចចិត្តឡើងវិញ
- ពិភាក្សាអំពីបញ្ហាដៃគូរួមភេទ

## ការបង្កើនភាពស្ទាត់ជំនាញក្នុងការអប់រំ

ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងរួមជាមួយភាពស្ទាត់ជំនាញ ក្នុងការអប់រំនឹងជួយអ្នកជំងឺអោយផ្លាស់ប្តូរ និងរក្សាខ្ជាប់នូវការផ្លាស់ប្តូរការប្រព្រឹត្ត ។ ភាពស្ទាត់ជំនាញក្នុងការអប់រំដែលអ្នកផ្តល់សេវាថែទាំត្រូវយកមកប្រើប្រាស់រួមមាន :

- ធ្វើការពន្យល់ និងបង្ហាត់បង្ហាញ
- ការផ្តល់ជាគំរូ
- ធ្វើការពង្រឹងចំណុចខ្លាំងដែលអ្នកជំងឺមាន
- ការពិនិត្យមើលជំរើសនានា
- ការប្រាប់អោយអ្នកជំងឺបញ្ជាក់អំពីការសំរេចចិត្តឡើងវិញ
- ការពង្រឹងការសំរេចចិត្ត

## ប្រើប្រាស់ស្រោមអនាម័យដើម្បីបង្ការជំងឺកាមរោគ

ការជំរុញប្រើប្រាស់ស្រោមអនាម័យទាក់ទងទៅនឹង :

- ស្វែងយល់អំពីការយល់ដឹង និងអារម្មណ៍ដែលគេមានចំពោះស្រោមអនាម័យ

- ពន្យល់អំពីអត្ថប្រយោជន៍របស់ស្រោមអនាម័យ
- ធ្វើការកែតំរូវអំពីជំនឿខុសឆ្គងរបស់អ្នកជំងឺ ដែលអាចរារាំងដល់ការប្រើប្រាស់ស្រោមអនាម័យរបស់ពួកគេ

ត្រូវបង្ហាញអំពីរបៀបប្រើប្រាស់ស្រោមអនាម័យដល់រាល់អ្នកជំងឺកាមរោគទាំងអស់ ។ គេត្រូវសុំអោយអ្នកជំងឺទាំងឡាយណាដែលនិយាយថា ពួកគេចេះប្រើស្រោមអនាម័យហើយនោះ ឱ្យបង្ហាញអំពីសមត្ថភាពរបស់ពួកគេ ដើម្បីធានាឱ្យមានការប្រើប្រាស់ត្រឹមត្រូវ ។

## សំណួរ និង លំហាត់

### ៥.១ លំហាត់

នៅក្នុងតំបន់របស់អ្នក តើពាក្យអ្វីខ្លះដែលគេយកមកប្រើប្រាស់ជាទូទៅដើម្បីពណ៌នាពីចង្កោមរោគសញ្ញាទាំងនេះ ហើយតើប្រជាជនជឿថាមានមូលហេតុអ្វីខ្លះដែលបង្កអោយទៅជាជំងឺនេះ ? ។ អ្នកអាចត្រឡប់ទៅមើលចំលើយរបស់អ្នកនៅលំហាត់ <u>៣.២</u> ដើម្បីរំលឹកអំពីពាក្យតាមតំបន់ដែលអ្នកបានរកឃើញរួចមកហើយ ។

| ចង្កោមរោគសញ្ញា | ពាក្យតាមតំបន់ | មូលហេតុ ឬការអធិប្បាយ |
|---|---|---|
| ការធ្លាក់ស/ហូរខ្ទុះតាមទ្វារមាស | | |
| ការហូរខ្ទុះតាមបង្ហួរនោម | | |
| ដំបៅលើប្រដាប់បន្តពូជ | | |
| ការឈឺចុកចាប់ផ្នែកក្រោមនៃពោះ | | |
| ជំងឺសិរមាន់លើប្រដាប់បន្តពូជ | | |

### ៥.២ សំណួរ

ចូរសន្មត់ថាអ្នកបានស្រង់ប្រវត្តិជំងឺ និង វាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់នានាសំរាប់ជំងឺកាមរោគទាំង៣ ខាងក្រោមនេះ ។ ដោយពឹងផ្អែកលើពត៌មានដែលទទួលបាន សូមឆ្លើយទៅនឹងសំណួរទាំង ២ ខាងក្រោមនេះ :

- តើអ្នកជំងឺគប្បីជៀសវាងនូវការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់អ្វីខ្លះនាពេលអនាគត ?
- តើនៅក្នុងស្ថានភាពនិមួយៗ មានឧបសគ្គអ្វីខ្លះដែលរារាំងដល់ការផ្លាស់ប្តូរការប្រព្រឹត្តរបស់អ្នកជំងឺ ?

**កែវ**

*កែវ ជាស្ត្រីរកស៊ីផ្លូវភេទអាយុ ១៩ឆ្នាំ រស់នៅក្នុងតំបន់ក្រីក្រមួយនៃទីក្រុង ។ នាងមានកូនតូចមួយដែលឈឺជារឿយៗ ។ កែវយកប្រាក់ដែលនាងរកបានដើម្បីជួយផ្គត់ផ្គង់ដល់គ្រួសារនាងផងដែរ ដែលកំពុងរស់នៅភូមិដាច់ស្រយាលមួយ ។ សមាជិកគ្រួសារនាងមិនពេញចិត្តនឹងមុខរបររបស់នាងទេ ប៉ុន្តែចង់បានប្រាក់ដែលនាងផ្ញើរមកផ្ទះ ។ នាងខ្លាចកើតជំងឺអេដស៍ណាស់ ប៉ុន្តែភ្ញៀវរបស់នាងជាច្រើនបដិសេធមិនប្រើប្រាស់ស្រោមអនាម័យ ។ នាងបានត្រូវធ្វើរោគវិនិច្ឆ័យថា នាងមានដំបៅលើប្រដាប់បន្តពូជ ។*

*ការប្រព្រឹត្តដែលប្រឈមមុខនឹងគ្រោះថ្នាក់ :*

*ឧបសគ្គរាំង :*

**គន្ធា**

*គន្ធា អាយុ ៣៥ឆ្នាំ រៀបការរួចហើយមានកូនជំទង់ៗ៣នាក់ ។ នាងពឹងផ្អែកលើចំណូលប្តីនាងដែលធ្វើការនៅរោងចក្រដើម្បីទ្រទ្រង់គ្រួសារ។ ក្នុងពេលសំភាសន៍ នាងនិយាយថា នាងរួមភេទតែជាមួយប្តីនាងប៉ុណ្ណោះ ។ នាងបានឆ្លើយតបទៅនឹងសំនួររបស់អ្នកដោយនិយាយថា ប្តីនាងក្រមកពីធ្វើការនៅរោងចក្រជារឿយៗ។ ហើយជួនកាលគាត់ទៅស៊ីផឹកជាមួយមិត្តភ័ក្រ្តគាត់។ ជួនកាលនាងធំក្លិនសុរាពីដង្ហើមរបស់គាត់ ។ ទោះជាយ៉ាងណាក៏ដោយ នាងបានជឿជាក់លើភាពស្មោះត្រង់របស់ប្តីនាង ។ អ្នកបានឱ្យគាត់មកពិគ្រោះជំងឺនៅឯ មណ្ឌលសុខភាពដោយមិនយល់អំពីមូលហេតុដែលធ្វើឱ្យនាងមានការឈឺចុកចាប់ពោះទេ ។ អ្នកបានធ្វើរោគវិនិច្ឆ័យឱ្យគាត់ថា មានជំងឺរលាកប៉េលវីស ។*

*ការប្រព្រឹត្តដែលប្រឈមមុខនឹងគ្រោះថ្នាក់ :*

*ឧបសគ្គរាំង :*

## ៥.៣ លំហាត់

### ល្បែងដើរតួអំពីការវាយតំលៃលើការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងកាមរោគ :

គោលបំណងនៃល្បែងដើរតួនេះ គឺដើម្បីអនុវត្តភាពស្ទាត់ជំនាញនានា សំរាប់ធ្វើការអប់រំអ្នកជំងឺ ចាប់ពីកន្លែងដែលអ្នកជំងឺយល់អំពីតំរូវការនៃការផ្លាស់ប្តូរការប្រព្រឹត្តផ្លូវភេទ ដោយរាប់បញ្ចូលទាំងការប្រព្រឹត្តផ្លូវភេទដែលប្រឈមមុខនឹងគ្រោះថ្នាក់ និងការប្រព្រឹត្តដែលមានសុវត្ថិភាព ។ ទាំងអស់នេះវាត្រូវគ្នានឹងមូលបញ្ហាដំបូងបីដែលមាននៅក្នុងទំព័រទី ១៥ ។ នៅចុងបញ្ចប់នៃលំហាត់នេះ អ្នកនឹងមានលទ្ធភាព :

- ប្រើប្រាស់ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធិភាពសំរាប់អប់រំអ្នកជំងឺ អំពីកាមរោគ និង
- បញ្ជាក់ឱ្យច្បាស់ អំពីផ្នែកដែលអ្នកត្រូវអនុវត្តបន្ថែមដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពស្ទាត់ជំនាញរបស់អ្នក ។

### ការណែនាំទូទៅ :

1. សូមអានករណីសិក្សាទាំង ២ នៅទំព័រទី ៣៨ ។ វាប្រាប់អ្នកអំពីការពណ៌នារបស់អ្នកជំងឺនិមួយៗ ។ ចូរគិតថា យើងបានស្រង់ប្រវត្តិជំងឺ និងធ្វើរោគវិនិច្ឆ័យកាមរោគ ដូចដែលបានចង្អុលបង្ហាញក្នុងករណីសិក្សានិមួយៗ រួចហើយ ។
2. សូមសំរេចចិត្តថា ជ្រើសរើសអ្នកដើរតួជាអ្នកជំងឺ, អ្នកផ្តល់សេវាថែទាំ និងអ្នកសង្កេតការណ៍
3. អ្នកដើរតួជាអ្នកជំងឺត្រូវជ្រើសរើសករណីសិក្សាណាមួយក្នុងចំណោមករណីសិក្សាទាំង ២ ។ សូមជ្រើសរើសយកករណីជាច្រើន ដែលអ្នកបានឃើញញឹកញាប់ក្នុងកន្លែងអនុវត្តការងាររបស់អ្នក ឬ ករណីណាដែលបង្ហាញពីបញ្ហាដែលចង់អោយអ្នកសិក្សាវែកញែកដោះស្រាយអោយមានប្រសិទ្ធិភាពខ្ពស់ ។ អ្នកជំងឺត្រូវប្រាប់អ្នកផ្តល់សេវាថែទាំ និងអ្នកសង្កេតការណ៍ពីករណីសិក្សាណាមួយដែលត្រូវបានជ្រើសរើស ។

4. អ្នកដែលដើរតួជាអ្នកជំងឺ, អ្នកផ្តល់សេវាថែទាំ និង អ្នកសង្កេតការណ៍ ត្រូវអានការណែនាំអំពីតួនាទីនីមួយៗ ដែលមាននៅទំព័របន្ទាប់នេះ ។

5. នៅពេលល្បែងដើរតួបានបញ្ចប់ ម្នាក់ៗត្រូវផ្តល់ ឬ បានទទួលយោបល់ត្រឡប់មកពីអ្នកដទៃឱ្យបានច្រើនគ្រប់គ្រាន់, ការផ្លាស់ប្តូរការដើរតួ និងអនុវត្តឡើងវិញពីដំណាក់កាលទី២ ដល់ទី៤ ដូចខាងលើ ធ្វើយ៉ាងណាឱ្យសិក្ខាកាមនិមួយៗ មានឱកាសអនុវត្តភាពស្ទាត់ជំនាញក្នុងការអប់រំ ហោចណាស់ឱ្យបានម្តងដែរ ។

**ការដើរតួជាអ្នកជំងឺ :**

សូមអានករណីសិក្សាដែលអ្នកបានជ្រើសរើសដោយប្រុងប្រយ័ត្ន ព្រោះទិសដៅរបស់អ្នកគឺ ឆ្លើយតបឱ្យបានត្រឹមត្រូវ និងប្រកបដោយលក្ខណៈប្រាកដនិយមតាមដែលអាចធ្វើទៅបាន ទៅនឹងអ្វីដែលអ្នកផ្តល់សេវាបានសួរ និងបានធ្វើ ។ ពុំគប្បីព្យាយាមបង្កលក្ខណៈងាយស្រួល ឬក៏លំបាកពេកដល់គេទេ ។

1. ផ្អែកលើពត៌មានដែលអ្នកបានពីការពណ៌នាពីអ្នកជំងឺ ចូរសំរេចចិត្តជាមុនថា ពត៌មានអ្វីខ្លះដែលអ្នកត្រូវឆ្លើយទៅនឹងសំណួររបស់អ្នកផ្តល់សេវាថែទាំ ។ សំណួរនានាអាចជាសំណួរអំពីចំនួនដៃគូរួមភេទទាំងឡាយដែលអ្នកមានអំពីការប្រើប្រាស់ស្រោមអនាម័យបានទៀងទាត់របស់អ្នក ហើយការយល់ដឹងរបស់អ្នកអំពីការចំលងជំងឺកាមរោគ ។
2. ចូរកត់សំគាល់ អ្នកត្រូវធ្វើឱ្យអារម្មណ៍របស់អ្នកឱ្យដូចអ្នកជំងឺនេះអញ្ចឹង ។ ឧទាហរណ៍ : តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចក្នុងពេលកំពុងរង់ចាំរោគវិនិច្ឆ័យ ? តើអ្នកមានសំណួរអ្វីខ្លះដែលត្រូវឆ្លើយនឹងអ្នកផ្តល់សេវាថែទាំ ប្រសិនបើមាន ? តើអ្វីខ្លះដែលធ្វើឱ្យអ្នកព្រួយបារម្ភ ?

3. ក្នុងពេលលេងល្បែងដើរតួ សូមខិតខំធ្វើឱ្យដូចជាឥរិយាបថរបស់អ្នកជំងឺនេះ ។ សូមប្រើប្រាស់នូវការយល់អារម្មណ៍ដើម្បីស្វែងយល់អំពីអារម្មណ៍ដែលអ្នកជំងឺមាននៅក្នុងស្ថានភាពបែបនេះ ។

4. ក្រោយពេលចប់ល្បែងដើរតួ សូមពន្យល់អំពីអារម្មណ៍របស់អ្នកចំពោះការសំភាសន៍នេះ ។ ជាការសំខាន់អ្នកត្រូវផ្តល់យោបល់ត្រឡប់មកវិញអំពីអ្វីដែលបានប្រព្រឹត្តទៅល្អ និងមិនល្អ ។ ឧទាហរណ៍ : អ្នកអាចប្រាប់អ្នកផ្តល់សេវាថែទាំថា អ្នកបាត់បង់នូវការភ័យបារម្ភ ដោយសារសំដីទន់ភ្លន់របស់គាត់និយាយទៅកាន់អ្នក ធ្វើឱ្យអ្នកដទៃពុំអាចស្តាប់ឮបាន ហើយអ្នកមាន

អារម្មណ៍ថា ជាការប្រថុចញ្ចឹច ហើយចង់ឱ្យគាត់ផ្តល់នូវពេលវេលាច្រើនដើម្បីពិភាក្សាអំពីជំងឺកាមរោគ ។ ការផ្តល់យោបល់ត្រឡប់ទៅវិញក្នុងលក្ខណៈជាក់លាក់ ក៏មានអត្ថប្រយោជន៍ណាស់ដែរសំរាប់អ្នកផ្តល់សេវាថែទាំសុខភាព ដូចជា " ខ្ញុំមិនដឹងច្បាស់ទេ ថាតើពេលណាដែលត្រូវពាក់ស្រោមអនាម័យនោះ...ពាក់ភ្លាមៗតែម្តង ឬ ពាក់មុនពេលរួមភេទ ឬ យ៉ាងដូចម្តេចទៅវិញ ? "

5. នៅពេលដែលអ្នកផ្តល់សេវាថែទាំនិងអ្នកសង្កេតការណ៍កំពុងធ្វើការពិនិត្យឡើងវិញលើលំហាត់ អ្នកអាចបន្ថែមនូវទស្សនៈដ៏មានសារៈប្រយោជន៍នានា ដែលអ្នកមានចំពោះឥរិយាបថអ្នកផ្តល់សេវាថែទាំនោះ ។ សូមធ្វើយ៉ាងណាឱ្យការជូនយោបល់របស់អ្នកមានលក្ខណៈជាវិជ្ជមានដែលជួយអោយអ្នកផ្តល់សេវាថែទាំពង្រឹកសមត្ថភាពជំនាញរបស់ពួកគេ ។

## ការដើរតួជាអ្នកផ្តល់សេវាថែទាំ

គោលបំណងនៃលំហាត់នេះគឺ ចង់ឱ្យអ្នកទទួលបាននូវការផ្តល់យោបល់ត្រឡប់មកវិញពីអ្នកដទៃលើភាពស្ទាត់ជំនាញដែលអ្នកមាននាបច្ចុប្បន្ន ហើយជួយអោយអ្នកធ្វើការហាត់សម ឬ ក៏ធ្វើអោយវាមានភាពប្រសើរឡើង ។

ក្នុងពេលដើរតួ សូមខិតខំធ្វើឱ្យអ្នកជំងឺគោរពតាមការណែនាំស្តីពីការព្យាបាល និងធ្វើឱ្យគេយល់អំពីការរួមភេទដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ ដើម្បីបង្ការការឆ្លងជំងឺនាអនាគត ។ និយាយម្យ៉ាងទៀត អ្នកមិនចាំបាច់បញ្ជាក់ប្រាប់អំពីឧបសគ្គរាំងដល់ការផ្លាស់ប្តូរការប្រព្រឹត្តទេ ទូន្មានគេពីការបន្ថយការប្រឈមមុខនឹងគ្រោះថ្នាក់ ឬ បង្ហាញពីការពាក់ស្រោមអនាម័យ ពីព្រោះមានល្បែងដើរតួមួយផ្សេងទៀតក្នុងសៀវភៅនេះដែលនិយាយអំពីផ្នែកនេះ ។

សូមកុំភ្លេច ប្រើប្រាស់ភាពស្ទាត់ជំនាញផ្សេងៗ ក្នុងការអប់រំ និង បំផុសអ្នកជំងឺឱ្យធ្វើការជ្រើសរើស និងបញ្ជាក់បន្ថែមពីការសំរេចចិត្តទាំងនោះ ។

1. ចូរអានយ៉ាងយកចិត្តទុកដាក់ នូវបញ្ជីត្រួតពិនិត្យសំរាប់អ្នកសង្កេតការណ៍ដែលស្ថិតនៅខាងលើបន្ទាប់ពីផ្នែកស្តីអំពីតួនាទីរបស់អ្នកសង្កេតការណ៍ដើម្បីពិនិត្យមើលភាពស្ទាត់ជំនាញផ្សេងៗ និងចំណុចនានាដែលអ្នកសង្កេតការណ៍នឹងសង្កេតមើលក្នុងការធ្វើសំភាសន៍របស់អ្នក ។

2. សូមអានឡើងវិញនូវករណីសិក្សាដែល " អ្នកជំងឺ " បានជ្រើសរើសដើម្បីអោយដឹងអំពីពត៌មានដែលបានរៀនរួចមកហើយក្នុងពេលស្រង់ប្រវត្តិជំងឺរបស់អ្នកទាំងនេះ ។ សូមកត់ចុះនូវសំណួរទាំងឡាយដែលអ្នកចង់សួរទៅអ្នកជំងឺ ប្រសិនបើអ្នកចង់ធ្វើ ។

3. ចំណាយពេលប្រហែល ៥នាទី សំរាប់ធ្វើការសំភាសន៍ ដោយផ្តើមធ្វើការសន្ទនាអំពីការធ្វើរោគវិនិច្ឆ័យតាមរោគរបស់អ្នក ហើយបញ្ឈប់ការសន្ទនានៅពេលណាដែលអ្នកច្បាស់ក្នុងចិត្តថាអ្នកជំងឺយល់អំពីការប្រព្រឹត្តផ្លូវភេទប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ និង ការប្រព្រឹត្តដែលមានសុវត្ថិភាព ឬ ក្រោយពេលវេលាមួយដែលបានកំណត់ ។

4. ក្រោយពេលធ្វើល្បែងដើរតួ ត្រូវអនុញ្ញាតអោយអ្នកជំងឺផ្តល់យោបល់ត្រឡប់មកវិញអំពីអារម្មណ៍ដែលគាត់មានចំពោះការសំភាសន៍ ។ បន្ទាប់មក សូមប្រាប់អំពីយោបល់ និងអារម្មណ៍អ្នកផ្ទាល់អំពីដំណើរប្រព្រឹត្តនៃការអប់រំ ។ ចុងបញ្ចប់ អ្នកសង្កេតការណ៍ត្រូវផ្តល់មកវិញនូវយោបល់របស់គេ ដោយផ្អែកលើបញ្ជីត្រួតពិនិត្យមាននៅទំព័របន្ទាប់ ។ សូមសួរអ្នកជំងឺនិងអ្នកសង្កេតការណ៍ ឱ្យបំភ្លឺអំពីអ្វីដែលពួកគេបាននិយាយ ។ ជាការមានប្រយោជន៍បំផុតសំរាប់អ្នក បើសិនជាអ្នកអាចទទួលបាននូវការផ្តល់យោបល់ច្បាស់លាស់ និងការបញ្ជាក់ច្បាស់ពីអ្នកដទៃអំពីភាពស្ទាត់ជំនាញដែលអ្នកធ្វើបាន ។

## ការដើរតួជាអ្នកសង្កេតការណ៍

ក្រោយពីល្បែងដើរតួបានបញ្ចប់ អ្នកមានភារកិច្ច ផ្តល់ឱ្យអ្នកផ្តល់សេវានូវយោបល់អ្នកត្រឡប់ទៅវិញដែលមានសភាពច្បាស់លាស់ និង មិនលំអៀងចំពោះរបៀបដែលគាត់រៀបចំការធ្វើសំភាសន៍ ។ អ្នកត្រូវស្វែងរកអោយឃើញ នូវជោគជ័យរបស់អ្នកផ្តល់សេវាថែទាំដែលទាក់ទងទៅនឹងការអប់រំអ្នកជំងឺ ។

1. ចូរអានបញ្ជីត្រួតពិនិត្យខាងក្រោមនេះ ដើម្បីអោយដឹងអំពីភាពស្ទាត់ជំនាញ និងបញ្ហាផ្សេងៗដែលអ្នកផ្តល់សេវាថែទាំយកមកប្រើប្រាស់ ។

2. កំណត់ពេលវេលាសំរាប់ការសំភាសន៍និងបញ្ឈប់វាក្រោយពេលដែលបានកំណត់ទុកបន្តិចដូចជាក្រោយ ៥នាទី ។

3. នៅពេលដែលអ្នកសង្កេត សូមកត់ត្រាទុកនូវភាពស្ទាត់ជំនាញផ្សេងៗ ដែលអ្នកផ្តល់សេវាប្រើប្រាស់ និងប្រសិទ្ធិភាពក្នុងការប្រើប្រាស់ ។ បើសិនជាអាចធ្វើទៅបាន គួរកត់សំគាល់ទុកនូវ

ឧទាហរណ៍ផ្សេងៗ ដែលគាត់បាននិយាយ ឬបានធ្វើក្នុងពេលធ្វើសំភាសន៍ ដើម្បីធ្វើអោយការផ្តល់យោបល់ត្រឡប់មកវិញរបស់អ្នកមានលក្ខណៈជាក់ស្តែងបំផុតតាមដែលអាចធ្វើទៅបាន ។

4. សុំឱ្យអ្នកជំងឺ រួចអ្នកផ្តល់សេវាថែទាំពិនិត្យមើលការសំភាសន៍ឡើងវិញ ។ ក្រោយពេលពួកគេបានដើរតួរួច សូមផ្តើមយោបល់របស់អ្នកប្រាប់ពួកគេវិញ ដោយឆ្លើយតបយ៉ាងសង្ខេបទៅនឹងស្ទ័យទិតៀនរបស់អ្នកផ្តល់សេវាថែទាំ រួចហើយផ្តល់ការផ្តល់យោបល់ត្រឡប់ទៅវិញរបស់អ្នកផ្ទាល់មួយចំណុចម្តងៗ ឬប្រាប់អ្វីៗផ្សេងៗទៀតដែលអ្នកគិតថាសមរម្យ ។ គួរតែធ្វើការទិទៀននៅលើចំណុចផ្សេងៗបើសិនជាចាំបាច់ ក៏ប៉ុន្តែសូមទិតៀន “ នៅពេលដែលអ្នកជំងឺនិយាយថា...អ្នក... ” “ ប្រសិនបើនិយាយថា...នោះប្រហែលជាសមរម្យជាង ” ។ល។ ជានិច្ចកាល ត្រូវផ្តោតទៅលើគុណសម្បត្តិរបស់អ្នកផ្តល់សេវាថែទាំហើយត្រូវធ្វើឱ្យមានលក្ខណៈជាក់ស្តែងទៅតាមលទ្ធភាពដែលអ្នកអាចធ្វើទៅបាន ។ ឧទារហណ៍ អ្នកអាចសំណូមពរអោយមានមធ្យោបាយផ្សេងទៀតដែលអ្នកផ្តល់សេវាអាចយកមកប្រើប្រាស់ ដើម្បីបញ្ចូលបញ្ហាពិសេសផ្សេងៗ ឬក៏សុំគាត់អោយកំណត់រកជំនាញណាមួយដែលសមរម្យ ជាងជំនាញដែលបានយកមកប្រើរួច ។

5. ចុងបញ្ចប់ ត្រូវដឹកនាំការពិភាក្សាអំពីអ្នកទាំង ៣នាក់ បានរៀនសូត្រពីល្បែងដើរតួនេះ ។ អាចមានបញ្ហាសំខាន់ផ្សេងៗ មួយចំនួនដែលពុំមានបញ្ចូលក្នុងជំពូកនេះ ។

## បញ្ជីត្រួតពិនិត្យសំរាប់ប្រើប្រាស់ក្នុងការសង្កេតក្នុងលំហាត់ ៥.៥

| តើអ្នកផ្តល់សេវាថែទាំមាន : | សូមប្រើផ្នែកនេះសំរាប់កត់ត្រា |
|---|---|
| ***លើកនូវបញ្ហាទាំងនេះដែរឬទេ ?***<br>❑ ជំងឺកាមរោគ ផលវិបាក និងការព្យាបាលរបស់វា សារៈសំខាន់ក្នុងការគោរពតាមវេជ្ជបញ្ជា<br>❑ ហានិភ័យប្រឈមមុខនឹងគ្រោះថ្នាក់របស់អ្នកជំងឺ<br>❑ តំរូវការក្នុងការផ្លាស់ប្តូរការប្រព្រឹត្តផ្លូវភេទ និងការរួមភេទដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ | |
| ***ប្រើប្រាស់ភាពស្ទាត់ជំនាញអប់រំទាំងនេះឬទេ ?***<br>❑ ការពន្យល់ និងការបង្ហាត់បង្រៀន<br>❑ ការលើកជាគំរូ<br>❑ ការពង្រឹងចំណុចខ្លាំង<br>❑ ការពិនិត្យមើលការជ្រើសរើស<br>❑ ការនិយាយរំលឹកអំពីការសំរេចចិត្តឡើងវិញ<br>❑ ការបញ្ជាក់អោយបានច្បាស់អំពីការសំរេចចិត្ត | |
| ប្រើភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងមកអនុវត្តដែរឬទេ ?<br>❑ សំណួរបើក<br>❑ ការជួយសំរួល<br>❑ ការសង្ខេបឡើងវិញ និងការពិនិត្យផ្ទៀងផ្ទាត់<br>❑ ការធានាអះអាង<br>❑ ការដឹកនាំ<br>❑ ការយល់អារម្មណ៍<br>❑ បង្ហាញភាពជាដៃគូ | |

## ៥.៤ លំហាត់

### ល្បែងដើរតួសំរាប់គាំទ្រឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត :

ចំពោះល្បែងដើរតួនេះ អ្នកនឹងមានឱកាសដើម្បីអនុវត្តការអប់រំអ្នកជំងឺលើបញ្ហាផ្សេងៗទៀតដែលនៅសល់ ដោយរួមបញ្ចូលទាំងការប្រើប្រាស់ស្រោមអនាម័យផងដែរ ។ មានបញ្ហាមួយប៉ុណ្ណោះដែលមិនបានបញ្ចូលទៅក្នុងជំពូកនេះគឺ ចំណុចចុងក្រោយបញ្ហា គឺ ការព្យាបាលដៃគូរួមភេទដែលនឹងត្រូវសិក្សានៅក្នុងជំពូកទី ៦ ។

ចំពោះល្បែងដើរតួនេះ យើងនឹងប្រើប្រាស់ករណីសិក្សាដូចគ្នាលំហាត់មុនដែរ(លំហាត់៥.៣) ដោយគ្រាន់តែបន្តពីកន្លែងដែលល្បែងដើរតួបានបញ្ចប់ គឺ នៅត្រង់ចំណុចដែលអ្នកជំងឺបានយល់ថា អ្វីជាការប្រព្រឹត្តរួមភេទមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់នោះ ។ ភារកិច្ចរបស់អ្នកផ្តល់សេវាថែទាំសុខភាពគឺ :

- កំណត់រកឃើញនូវឧបសគ្គនានា ដែលអ្នកជំងឺមានក្នុងការផ្លាស់ប្តូរការប្រព្រឹត្តបច្ចុប្បន្នរបស់ខ្លួន
- ជួយអោយអ្នកជំងឺកំណត់រកឃើញនូវការផ្លាស់ប្តូរការប្រព្រឹត្តដ៏សមស្រប និងធ្វើការសំរេចចិត្តជ្រើសរើសយកការប្រព្រឹត្តណាមួយដែលត្រូវសាកល្បងប្រកាន់យក ។ ពត៌មានអំពីការផ្លាស់ប្តូរការប្រព្រឹត្តគប្បីបញ្ចូលការប្រើប្រាស់ស្រោមអនាម័យផងដែរ ។ អ្នកផ្តល់សេវាថែទាំសុខភាពគួរតែអប់រំអ្នកជំងឺអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ស្រោមអនាម័យសំរាប់គាត់ ព្រមទាំងការបង្ហាញអំពីការប្រើប្រាស់ជាជំហានៗផងដែរ ។

ចូររៀបចំអនុវត្តល្បែងដើរតួអោយដូចលើកមុន លើកលែងតែនៅពេលនេះអ្នកផ្តល់សេវាថែទាំត្រូវផ្តោតទៅលើការកែលំអភាពស្ទាត់ជំនាញរបស់ខ្លួន ដោយបានរកឃើញក្នុងពេលធ្វើល្បែងដើរតួ និងការផ្តល់យោបល់ត្រឡប់មកវិញនៅពេលមុន ។ អ្នកសង្កេតការណ៍គប្បីពិនិត្យរកមើលភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងក៏ដូចជាក្នុងការអប់រំ ដែលត្រូវផ្តោតទៅលើបញ្ហាខាងលើទាំងប៉ុន្មាន ។

## បញ្ជីត្រួតពិនិត្យសំរាប់ប្រើប្រាស់ក្នុងការសង្កេតក្នុងលំហាត់ ៥.៥

| តើអ្នកផ្តល់សេវាថែទាំមាន : | សូមប្រើផ្នែកនេះសំរាប់កត់ត្រា |
|---|---|
| ***លើកនូវបញ្ហាទាំងនេះដែរឬទេ ?***<br>❑ ជំងឺកាមរោគ ផលវិបាក និងការព្យាបាលរបស់វា សារៈសំខាន់ក្នុងការគោរពតាមវេជ្ជបញ្ជា<br>❑ ការិតប្រឈមមុខនឹងគ្រោះថ្នាក់របស់អ្នកជំងឺ<br>❑ តំរូវការក្នុងការផ្លាស់ប្តូរការប្រព្រឹត្តផ្លូវភេទ និងការរួមភេទដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ | |
| ***ប្រើប្រាស់ភាពស្ទាត់ជំនាញអប់រំទាំងនេះឬទេ ?***<br>❑ ការពន្យល់ និងការបង្ហាត់បង្រៀន<br>❑ ការលើកជាគំរូ<br>❑ ការពង្រឹងចំណុចខ្លាំង<br>❑ ការពិនិត្យមើលការជ្រើសរើស<br>❑ ការនិយាយរំលឹកអំពីការសំរេចចិត្តឡើងវិញ<br>❑ ការបញ្ជាក់អោយបានច្បាស់អំពីការសំរេចចិត្ត | |
| ប្រើភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងមកអនុវត្តដែរឬទេ ?<br>❑ សំណួរបើក<br>❑ ការជួយសំរួល<br>❑ ការសង្ខេបឡើងវិញ និងការពិនិត្យផ្ទៀងផ្ទាត់<br>❑ ការធានាអះអាង<br>❑ ការដឹកនាំ<br>❑ ការយល់អារម្មណ៍<br>❑ បង្ហាញភាពជាដៃគូ | |

## ៥.៥ សំណួរ

ខាងក្រោមនេះគឺសំណួរដែលទាក់ទងនឹងស្រោមអនាម័យ ។ មានការយល់ខុសជាច្រើនអំពីការប្រើប្រាស់ស្រោមអនាម័យ ។ សូមគូសសញ្ញាក្នុងប្រអប់ ដើម្បីបញ្ជាក់ថា តើឃ្លាណាមួយជាឃ្លាត្រឹមត្រូវ ឬ ខុស ។

### សំណួរទាក់ទងនឹងស្រោមអនាម័យ

| | ត្រូវ | ខុស |
|---|---|---|
| - ស្រោមអនាម័យអាចរបូតបាត់ក្នុងខ្លួនស្ត្រី ។ | ☐ | ☐ |
| - ស្រោមអនាម័យមិនអាចបង្ការការចំលងជំងឺកាមរោគដោយរាប់បញ្ចូលមេរោគអេដស៍បានទេ ។ | ☐ | ☐ |
| - គេអាចរក្សាស្រោមអនាម័យក្នុងហោប៉ៅ ឬកាបូបដោយមិនបាច់កំណត់ពេលវេលា ។ | ☐ | ☐ |
| - គេអាចប្រើប្រាស់ប្រេងគ្លីសេរីន ឬប្រេងរំអិលដែលធ្វើអំពីជាតិទឹកលាបលើស្រោមអនាម័យ | ☐ | ☐ |
| - គេត្រូវរុញស្រោមអនាម័យទៅមុខឱ្យជាប់នឹងក្បាលលិង្គដើម្បីធានាឱ្យវាជាប់ល្អ ។ | ☐ | ☐ |
| - ត្រូវច្របាច់ខ្យល់ចេញពីចុងស្រោមអនាម័យនៅពេលអ្នកពាក់វា | ☐ | ☐ |
| - គេត្រូវរក្សាទុកស្រោមអនាមម័យក្នុងទីកន្លែងត្រជាក់ ងងឹត និងស្ងួត | ☐ | ☐ |

ប្រសើរបំផុតនោះ គឺនិកកាមរោគគួរតែផ្តល់ស្រោមអនាម័យដោយឥតគិតថ្លៃដល់អ្នកជំងឺ ។ បើសិនជាមិនអាចធ្វើទៅបានទេ សូមឆ្លើយនឹងសំណួរទាំងឡាយខាងក្រោមនេះ ដើម្បីឱ្យអ្នកអាចផ្តល់ដំបូន្មានដល់អ្នកជំងឺរបស់អ្នកឱ្យស្របទៅតាម :

- តើអ្នកជំងឺអាចរកទិញស្រោមអនាម័យបាននៅទីណា ?
- តើស្រោមអនាម័យតំលៃប៉ុន្មាន ?
- ស្រោមអនាម័យនោះមានគុណភាពល្អដែរឬទេ ?

## ៥.៦ សំហាត់

គ្លីនិកកាមរោគ ឱ្យផ្តល់ឱកាសច្រើនសំរាប់ការអប់រំអ្នកជំងឺ ។ ការអប់រំទាំងនេះត្រូវផ្តល់ដោយសមាជិកនានានៃគ្លីនិកកាមរោគក៏ដូចជា ដោយសំភារៈអប់រំសុខភាពជាច្រើន ដូចជា មានខិតប័ណ្ណ ផ្ទាំងរូបភាព ឬ ឯកសារផ្សេងៗទៀត ។

**គំនិតការអប់រំអ្នកជំងឺនៅតាមមណ្ឌលសុខភាព**

***នរណា ?*** បុគ្គលិកទាំងអស់ពេលជួបផ្ទាល់ជាមួយអ្នកជំងឺ អាចជួយផ្តល់ការអប់រំដល់អ្នកជំងឺបាន ។ ឧទាហរណ៍ បុគ្គលិកនៅកន្លែងទទួលអ្នកជំងឺ អាចចូលរួមដោយសំដែងការគោរព ការយល់អារម្មណ៍និងការធ្វើឱ្យអ្នកជំងឺបាត់ការបារម្ភ ។ ការជួយនេះរក្សាបាននូវ សេចក្តីថ្លៃថ្នូរអ្នកជំងឺនិងបន្ថយការភ័យខ្លាច ឬក៏សេចក្តីខ្មាសអៀនដែលអ្នកជំងឺមាន ។

***ទីណា ?*** ការអប់រំអ្នកជំងឺអាចធ្វើទៅនៅដំណាក់កាលនិមួយៗ ដែលអ្នកជំងឺឆ្លងកាត់ នៅពេលដែលគាត់ទៅពិគ្រោះជំងឺនៅក្នុងមណ្ឌលសុខភាពចាប់តាំងពីកន្លែងចុះឈ្មោះ រហូតបន្ទប់រង់ចាំពេលពិនិត្យអ្នកជំងឺ ឬនៅបន្ទប់សំភាសន៍ និងនៅក្នុងកន្លែងចែកឱសថ ។

***ដូចម្តេច ?*** គ្លីនិកកាមរោគអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មាននានាក្នុងការអប់រំអ្នកជំងឺ ។ មធ្យោបាយទាំងនោះមាន :

- ផ្ទាំងរូបភាព
- ខិតប័ណ្ណ
- ការចាក់កាសែតសំលេង
- ការបញ្ចាំងកាសែតវីដេអូ
- ការពិភាក្សាជាក្រុមតូចៗ ឬការពិភាក្សាជាផ្លូវការ
- ការបង្ហាញពីរបៀបប្រើប្រាស់ស្រោមអនាម័យ
- ការសំដែងសិល្បៈ

អ្នកបានកត់សំគាល់រួចហើយនូវឱកាសផ្សេងៗជាច្រើនសំរាប់ធ្វើការអប់រំអ្នកជំងឺនៅក្នុងគ្លីនិកកាមរោគរបស់អ្នក ។

ចំពោះលំហាត់នេះ ដំបូងអ្នកត្រូវដើរជុំវិញមណ្ឌលសុខភាពរបស់អ្នក ធ្វើខ្លួនអ្នកដូចជាអ្នកជំងឺម្នាក់ដែលកំពុងតែចូលមកទទួលការព្យាបាលរោគ ។ បន្ទាប់មក សូមឆ្លើយទៅនឹងសំណួរខាងក្រោម :

1. មណ្ឌលសុខភាព ប្រើប្រាស់ឱកាសណាខ្លះដើម្បីអប់រំអ្នកជំងឺ ?

2. តើមណ្ឌលសុខភាព អាចជ្រើសរើសឱកាសណាខ្លះសំរាប់ធ្វើការអប់រំអ្នកជំងឺ ?

3. តើអ្នកមានសំណូមពរជាក់ស្តែងអ្វីខ្លះ ដើម្បីកែលំអការអប់រំអ្នកជំងឺនៅតាមមណ្ឌលសុខភាព?

4. តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការរៀបចំអនុវត្តនូវសំណូមពររបស់អ្នក ?

5. តើមានតំរូវការប្រភពធនធានអ្វីខ្លះ ?

បើសិនជាអ្នកអាចធ្វើបាន សូមយកសំណូមពររបស់អ្នកទៅពិភាក្សាជាមួយប្រធានអ្នក ដើម្បីពិនិត្យមើលអំពីលទ្ធភាពក្នុងការអនុវត្តរបស់វា ។

## ចំលើយ

### ៥.២ សំណួរ

សូមកុំព្រួយបារម្ភ បើសិនជាអ្នកលំបាករកវិធីដោះស្រាយលំហាត់នេះ ឬ បើសិនជាចំលើយរបស់អ្នកខុសពីចំលើយរបស់យើងបន្តិចបន្តួចនោះ ។ អ្នកអាចធ្វើការពិចារណាអំពីបញ្ហាទាំងឡាយដែលមានសារៈសំខាន់សំរាប់កន្លែងបំរើការងាររបស់អ្នក ។

**កែវ**

ការប្រព្រឹត្តដែលប្រឈមមុខនឹងគ្រោះថ្នាក់មួយដែលយើងបានដឹងនោះ គឺមុខរបររបស់នាងកែវដែលពាក់ព័ន្ធនឹងការរួមភេទជាមួយដៃគូច្រើននាក់ ។

កែវមានឧបសគ្គធំៗពីរ ដែលរារាំងដល់ការផ្លាស់ប្តូរការប្រព្រឹត្ត គឺ ការពឹងពាក់របស់នាងលើមុខរបរផ្លូវភេទដែលចាត់ទុកជាប្រភពចំណូលមួយសំរាប់ទ្រទ្រង់គ្រួសារ និងកូនរបស់នាង ហើយនាងគ្មានលទ្ធភាពដើម្បីបញ្ចុះបញ្ចូលភ្ញៀវអោយប្រើប្រាស់ស្រោមអនាម័យទេ ។ បើតាមស្មាន នាងខ្លាចបាត់បង់ភ្ញៀវ ដោយសារការទទូចអង្វរអោយគេប្រើប្រាស់ស្រោមអនាម័យ ។

**គន្ធា**

ការប្រឈមមុខនឹងគ្រោះថ្នាក់របស់នាងគន្ធាខុសពីអ្នកដទៃ ពីព្រោះ ក្រៅពីការប្រឈមមុខទៅនឹងការទទួលភ្ញៀវ គឺសង្សាររបស់នាងដែលជាអ្នកពាក់ព័ន្ធ ក្នុងការរួមភេទប្រឈមមុខនឹងគ្រោះថ្នាក់មិនមែនមកពីនាងទេ ។ យើងក៏ពុំបានដឹងច្រើនពី ការប្រឈមមុខនឹងគ្រោះថ្នាក់របស់សង្សាររបស់នាងឱ្យបានល្អិតល្អន់ទេ ។

តើឧបសគ្គអ្វីខ្លះទៅដែលរារាំងនាងក្នុងការផ្លាស់ប្តូរការប្រព្រឹត្ត ? ក្រុមគ្រួសាររបស់នាងពឹងផ្អែកលើប្រាក់ដែលនាងរកបាន ។ លើសពីនេះទៅទៀត មុនពេលសំរេចចិត្តប្រកាន់យកការប្រព្រឹត្តថ្មីឱ្យបានយូរអង្វែងនេះ នាងត្រូវតែពុះពារជំនះឧបសគ្គធំៗពីរ : ការស្លុតចិត្តរបស់នាងនៅពេលបានដឹងអំពីការប្រព្រឹត្តខុសឆ្គងរបស់សង្សារនាង និងការជះឥទ្ធិពលរបស់វាទៅលើជីវិតគ្រួសារនាង ។

## ៥.៥ សំណួរ

### សំណួរដែលទាក់ទងនឹងស្រោមអនាម័យ

សូមផ្ទៀងផ្ទាត់ចំលើយរបស់អ្នកជាមួយចំលើយខាងក្រោមនេះ ?

***ស្រោមអនាម័យអាចរបូតក្នុងខ្លួនស្ត្រី ។ ខុស***

វាអាចកើតមានតិចតួចណាស់ លុះត្រាតែបុរសនោះប្រើប្រាស់ស្រោមអនាម័យមិនបានត្រឹមត្រូវ វាអាចរអិលរបូតមុនពេលដកលិង្គចេញដែរ ប៉ុន្តែវាមិនអាចរបូតជ្រុះក្នុងខ្លួនស្ត្រីបានទេ ។

***ស្រោមអនាម័យមិនបានបង្ការជំងឺកាមរោគ និងអេដស៍បានទេ ។ ខុស***

បើសិនជាប្រើប្រាស់បានត្រឹមត្រូវ ស្រោមអនាម័យអាចបង្ការការចំលងជំងឺកាមរោគរួមទាំងជំងឺអេដស៍ផងដែរ ។

***គេអាចរក្សាទុកស្រោមអនាម័យនៅក្នុងហោប៉ៅ ឬកាបូបជារៀងរហូតដោយគ្មានពេលកំណត់។ ខុស***

កាបូប ឬ ហោប៉ៅ គឺជាកន្លែងដែលក្តៅសំរាប់រក្សាទុកស្រោមអនាម័យក្នុងរយៈពេលយូរ ។ សូមទូន្មានអ្នកជំងឺកុំអោយប្រើស្រោមអនាម័យដែលស្ងួត កខ្វក់ ផុយស្រួយ ប្រែពណ៌ទៅជាលឿង ស្អិត រលាយ ខូចគុណភាព ។

***គេអាចប្រើប្រេងគ្រីសេរីន ឬ ប្រេងមានជាតិទឹកលាបលើស្រោមអនាម័យបាន ។ ត្រូវ***

ទោះជាយ៉ាងណាក៏ដោយ ចូរទូន្មានអ្នកជំងឺឱ្យចងចាំថា អាចមានគ្រោះថ្នាក់នៅពេលប្រើប្រាស់ខ្លាញ់, ប្រេង ថ្នាំលាប (lotions) ផ្សេងៗ ឬក្រែមដែលធ្វើអំពីជាតិប្រេង ដើម្បីធ្វើឱ្យស្រោមអនាម័យរអិល ។ ប្រេងជាមូលហេតុធ្វើអោយស្រោមអនាម័យរហែកបាន ។

***ត្រូវរុញស្រោមអនាម័យទៅមុខឱ្យអិបជាប់ក្បាលលិង្គ ដើម្បីធានាជាប់ល្អ ។ ខុស***

បើសិនជានរណាម្នាក់ធ្វើដូច្នេះ នោះស្រោមអនាម័យអាចនឹងបែក ។ ជានិច្ចកាល ចូរទុកចន្លោះមួយសំរាប់អោយទឹកកាមដក់នៅត្រង់ចុងស្រោមអនាម័យ ។

***ត្រូវច្របាច់ខ្យល់ចេញពីចុងស្រោមអនាម័យនៅពេលដែលអ្នកពាក់វា ។ ត្រូវ***

ធ្វើដូច្នេះ វានឹងទុកចន្លោះមួយសំរាប់អោយទឹកកាមដក់នៅក្នុងនោះ ។

***ត្រូវរក្សាទុកស្រោមអនាម័យនៅក្នុងទីកន្លែងត្រជាក់ ងងឹត និងស្ងួត ។ ត្រូវ***

ពន្លឺថ្ងៃ សំណើម និងកំដៅធ្វើអោយស្រោមអនាម័យខូចគុណភាព ហេតុដូច្នេះហើយគេមិនគួររក្សាទុកវាក្នុងហោប៉ៅ ឬ កាបូបយួរពេកទេ ។

# ការបញ្ជូននិងការថែទាំដៃគូរួមភេទ របស់អ្នកជំងឺកាមរោគ

## ការគ្រប់គ្រងថែទាំជំងឺកាមរោគ

### ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា សំរាប់ថ្នាក់មណ្ឌលសុខភាព

**ជំពូកទី ៦ :**

# ការបញ្ជូននិងការថែទាំដៃគូរួមភេទ របស់អ្នកជំងឺកាមរោគ

# ជំពូកទី៦

## ការបញ្ជូន និងថែទាំដៃគូរួមភេទរបស់អ្នកជំងឺកាមរោគ

ក្រោយពីបញ្ចប់ជំពូកទី៥ អ្នកដឹងថាការបញ្ជូនដៃគូរួមភេទរបស់អ្នកជំងឺ គឺជាជំហានចុងក្រោយក្នុងការអប់រំអ្នកជំងឺកាមរោគ ។ តាមពិត វាជាផ្នែកសំខាន់មួយនៃការគ្រប់គ្រងថែទាំជំងឺកាមរោគ ប្រកបដោយប្រសិទ្ធិភាព ។ ជំពូកនេះពិភាក្សាអំពីការបញ្ជូន និងការថែទាំដៃគូរួមភេទរបស់អ្នកជំងឺ ។

**មាតិកា**


- គោលការណ៍នៃការគ្រប់គ្រងថែទាំដៃគូរួមភេទ .............. ៣
- ការហៅដៃគូរួមភេទឱ្យមកទទួលការព្យាបាល.............. ៤
- ការបញ្ជូនដៃគូរួមភេទរបស់អ្នកជំងឺកាមរោគ................ ៦
- ការព្យាបាលដៃគូរួមភេទ....... ១៧
- ការរំលឹកសារឡើងវិញ......... ១៨
- សំណួរ និងលំហាត់..........២១
- ចំលើយ....................... ២៩


**សំខាន់ !**

*យើងបានពិពណ៌នាអំពីភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងជាមូលដ្ឋាននៅក្នុងជំពូកទី៣និងទី៥រួចមកហើយ ។ ប្រសិនបើអ្នកពុំទាន់បានសិក្សាជំពូកទាំងពីរនេះទេ សូមសិក្សាវាជាមុនសិន ។*

## គោលការណ៍នៃការគ្រប់គ្រងថែទាំដៃគូរួមភេទរបស់អ្នកជំងឺ

ការគ្រប់គ្រងនិងថែទាំដៃគូរួមភេទរបស់អ្នកជំងឺកាមរោគមានបំណងព្យាបាល និងអប់រំដៃគូរួមភេទទាំងអស់របស់អ្នកជំងឺដែលអ្នកជួបជាលើកដំបូង ។

ការគ្រប់គ្រង និង ថែទាំដៃគូរួមភេទរបស់អ្នកជំងឺមានសារៈសំខាន់ណាស់ ព្រោះថាវាអាចកាត់ផ្តាច់វដ្តនៃការចំលងនៃកាមរោគ។ ជារឿយៗ អ្នកជំងឺទទួលបាននូវការព្យាបាលដែលមានប្រសិទ្ធិភាព ប៉ុន្តែនៅពេលដែលគាត់ចេញពីគ្លីនិក គាត់ទៅរួមភេទដោយមិនប្រើមធ្យោបាយបង្ការ ជាមួយអ្នកដែលបានចំលងកាមរោគមកគាត់ ជាហេតុនាំទៅរកការឆ្លងជំងឺសាជាថ្មីទៅអ្នកជំងឺ ។

ការកំណត់រកបុគ្គល ដែលជាប្រភពនៃការឆ្លង ជួបនឹងការលំបាកយ៉ាងខ្លាំង ឬពុំអាចធ្វើទៅបានផង ។ បើនិយាយអំពីការគ្រប់គ្រងថែទាំករណីកាមរោគវិញ ការនេះពុំមានសារៈសំខាន់ទេ ។ គេត្រូវព្យាបាលដៃគូរួមភេទទាំងអស់ ដែលអ្នកជំងឺបានជួបរួមរស់ជាមួយក្នុងរយៈពេលពីរខែមុន ទោះបីជាពួកគេពុំមានរោគសញ្ញាក៏ដោយ ។

*ការបញ្ជូនដៃគូរួមភេទរបស់អ្នកជំងឺឱ្យមកទទួលការព្យាបាលអាចកាត់ផ្តាច់វដ្តនៃការចំលងកាមរោគបាន ។ ការរក្សាការសំងាត់របស់អ្នកជំងឺនិងការសុំឱ្យអ្នកជំងឺចូលរួមសហការ ដោយស្ម័គ្រចិត្តគឺជាគន្លឹះនៃការបញ្ជូនដៃគូរួមភេទរបស់អ្នកជំងឺឱ្យមកទទួលការព្យាបាល ។*

នៅពេលដែលអ្នកថែទាំអ្នកជំងឺណាម្នាក់ អ្នកត្រូវដឹងអំពីផលប៉ះពាល់ដែលកាមរោគអាចមានទៅលើគ្រួសាររបស់គេ ។ តើជំងឺនេះអាចជះឥទ្ធិពលទៅលើជីវភាពគ្រួសារ ប្រាក់ចំណូលឬសុវត្ថិភាពរបស់ពួកគេដែរឬទេ ? ដូចគ្នានេះដែរ នៅពេលអ្នកជំងឺប្រាប់ដៃគូរួមភេទរបស់ពួកគេថាខ្លួនអាចកើតកាមរោគណាមួយនោះ ប្រតិកម្មរបស់ដៃគូរួមភេទអាចបង្កជាបញ្ហាបាន ។ អ្នកផ្តល់សេវាថែទាំត្រូវធ្វើយ៉ាងណាឱ្យបញ្ហាទាំងនោះមានកំរិតតិចជាអប្បបរមា ដោយធានាឱ្យបាននូវការរក្សាការសំងាត់ និងធ្វើយ៉ាងណាឱ្យអ្នកជំងឺយល់ព្រមបញ្ជូនដៃគូរួមភេទរបស់ខ្លួនដោយស្ម័គ្រចិត្ត ។ ក្នុងការអនុវត្តជាក់ស្តែង អ្នកត្រូវធ្វើការព្យាបាលដៃគូរួមភេទឱ្យបានច្រើនបំផុតដោយពិចារណាលើកាលៈទេសៈនៃករណីនិមួយៗ ។

| ការបញ្ជូន និងថែទាំដៃគូរួមភេទនាក់ទងនឹង: |
| --- |
| • ការផ្តល់ការព្យាបាលដៃគូរួមភេទទាំងអស់នៃអ្នកជំងឺ<br>• ការព្យាបាលកាមរោគឱ្យដៃគូរួមភេទទាំងនោះដូចគ្នានឹងជំងឺដែលអ្នកជំងឺមាន |

## ការហៅដៃគូរួមភេទឱ្យមកទទួលការព្យាបាល (Contacting Partners)

គោលបំណងនៃការបញ្ជូនដៃគូរួមភេទ ឱ្យមកទទួលការព្យាបាល (partnersreferral) គឺព្យាបាលដៃគូរួមភេទរបស់អ្នកជំងឺ ឱ្យបានច្រើនបំផុតទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ។ មានវិធីពីរយ៉ាងដើម្បីហៅដៃគូរួមភេទអ្នកជំងឺគឺ: ការបញ្ជូនដោយអ្នកជំងឺ និងកាបញ្ជូនដោយអ្នកផ្តល់សេវាថែទាំ ។

ការបញ្ជូនដោយអ្នកជំងឺមានន័យថា អ្នកជំងឺជាអ្នកទទួលខុសត្រូវ ក្នុងការហៅដៃគូរួមភេទរបស់ខ្លួន ហើយសុំឱ្យដៃគូទាំងនោះមកទទួលការព្យាបាល ។ ការផ្តល់ជូនអ្នកជំងឺនូវយោបល់ (suggestion) ស្តីអំពីវិធីដែលត្រូវខិតជិតដៃគូ (approach) របស់ខ្លួនជាការមួយ មានសារៈសំខាន់ ។ ជំរើសនានាដែលអ្នកអាចយកមកពិភាក្សា ជាមួយអ្នកជំងឺមានសង្ខេបនៅក្នុងប្រអប់ខាងក្រោមនេះ។ យើងនឹងពិនិត្យមើលបញ្ហាជាក់ស្តែងនានាដែលជាប់ទាក់ទងនឹងវិធីទាំងនេះនៅក្នុងផ្នែកបន្ទាប់ ។

អ្នកជំងឺមានអារម្មណ៍ថាមិនចង់ ឬមិនអាចពិភាក្សាអំពីជំងឺកាមរោគ ជាមួយដៃគូរួមភេទរបស់ខ្លួនដោយសារមូលហេតុជាច្រើន ។ ការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំ មានន័យថាសមាជិកម្នាក់នៃក្រុមថែទាំសុខភាព ចុះទៅជួបផ្ទាល់ជាមួយដៃគូរួមភេទជាជំនួសអ្នកជំងឺតែម្តង ។

**វិធីពីរយ៉ាងសំរាប់ហៅ**
**ដៃគូរួមភេទរបស់អ្នកជំងឺឱ្យមកទទួលការព្យាបាល**

- <u>ការបញ្ជូនដោយអ្នកជំងឺ</u>: អ្នកជំងឺប្រាប់ដៃគូរួមភេទរបស់ខ្លួន
- <u>ការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំ</u>: អ្នកផ្តល់សេវាថែទាំប្រាប់ដៃគូរួមភេទរបស់អ្នកជំងឺ ។

តើវិធីណាមួយជាវិធីល្អជាងគេ? វិធីគ្រប់គ្រងថែទាំដៃគូរួមភេទទាំងពីរមានសារៈប្រយោជន៍ដូចគ្នា ប៉ុន្តែការបញ្ជូនដោយអ្នកជំងឺមានភាពជាក់ស្តែងជាង (practical) ។ នេះមកពីការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំមានតំលៃថ្លៃ គឺអ្នកត្រូវតែបង់សោហ៊ុយឱ្យបុគ្គលិកដែលបំរើការងារនេះ ហើយមកពីអាចកើតមានទូវបញ្ហាដែលទាក់ទងនឹងការរក្សាការសំងាត់របស់អ្នកជំងឺ ។ ការបញ្ជូនដោយអ្នកជំងឺដែលធ្វើឡើងដោយស្ម័គ្រចិត្ត គឺជាវិធីដែលអង្គការសុខភាពពិភពលោកណែនាំឱ្យប្រើប្រាស់ ។

**សំណួរ**
**៦.១**

## ការបញ្ជូនដៃគូរួមភេទដោយអ្នកជំងឺដែលប្រកបដោយប្រសិទ្ធិភាព

**ជំរើសនានាសំរាប់ការបញ្ជូនដោយអ្នកជំងឺ**

- *អ្នកជំងឺអាចមានលទ្ធភាពពន្យល់អំពីកាមរោគ និងតំរូវការក្នុងការព្យាបាលទៅកាន់ដៃគូរួមភេទរបស់គាត់ដោយផ្ទាល់ ។*
- *អ្នកជំងឺអាចមានលទ្ធភាពទៅកាន់មណ្ឌលសុខភាពជាមួយដៃគូរួមភេទរបស់គាត់ឬសុំឱ្យដៃគូនោះទៅដោយខ្លួនឯង ដោយមិនចាំបាច់ប្រាប់អំពីមូលហេតុអ្វីឡើយ ។*
- *អ្នកជំងឺប្រគល់ប័ណ្ណមួយទៅដៃគូរួមភេទដោយសុំឱ្យគាត់ទៅកាន់មណ្ឌលសុខភាព ។*

ជោគជ័យនៃការបញ្ជូនដោយអ្នកជំងឺ ពឹងផ្អែកលើភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងរបស់អ្នក ៖

- អ្វីដែលអ្នកត្រូវនិយាយទៅកាន់អ្នកជំងឺ
- របៀបដែលយើងត្រូវនិយាយទៅកាន់គាត់
- របៀបសួរ និងឆ្លើយតបទៅកាន់អ្នកជំងឺ ។

នៅក្នុងផ្នែកនេះ សូមអ្នកយកនូវភាពស្ទាត់ជំនាញនានា ដែលបានសិក្សានៅក្នុងជំពូកមុនៗ មកប្រើប្រាស់ក្នុងបំណងថែទាំ ព្យាបាលដៃគូរួមភេទរបស់អ្នកជំងឺ ។

## ការបញ្ជូនដៃគូរួមភេទរបស់អ្នកជំងឺ





## បញ្ហាដែលអ្នកត្រូវយកមកពិភាក្សាជាមួយអ្នកជំងឺ

| បញ្ហាដែលត្រូវលើកយកមកពិភាក្សាជាមួយអ្នកជំងឺ |
|---|
| • សារៈសំខាន់នៃការព្យាបាលដៃគូរួមភេទទាំងអស់របស់អ្នកជំងឺ<br>• វិធីជៀសវាងការឆ្លងរោគឡើងវិញ<br>• វិធីដែលអ្នកជំងឺអាចយកមកពិភាក្សាយ៉ាងស្រួលក្នុងអារម្មណ៍ជាមួយដៃគូរួមភេទរបស់គាត់<br>• ឈ្មោះដៃគូរួមភេទរបស់អ្នកជំងឺ ប្រសិនបើដៃគូទាំងនោះចង់ប្រាប់ ។ |

នៅពេលដែលអ្នកជំងឺចាប់ផ្ដើមគិតអំពីអ្វីដែលខ្លួននឹងត្រូវនិយាយប្រាប់ដៃគូរបស់ខ្លួនស្ដីពីបញ្ហាកាមរោគ ពួកគេពុំមានអារម្មណ៍ស្រួលក្នុងចិត្តទេ មិនខុសពីអារម្មណ៍របស់គេនៅពេលដឹងថាកើតកាមរោគជាលើកដំបូងនោះទេ ។ អ្នកអាចប្រើប្រាស់នូវភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដែលអ្នកបានសិក្សាដើម្បីជួយ ឱ្យអ្នកជំងឺដោះស្រាយនូវបញ្ហាសតិអារម្មណ៍ ក៏ដូចជាជួយកំណត់រកនូវមធ្យោបាយប្រាប់ដៃគូរបស់ខ្លួនដឹង ។

យើងអាចវិលត្រលប់ទៅមើលការសិក្សាករណីដែលមានក្នុង ជំពូកទី ៥ ដើម្បីបង្ហាញអំពីវិធីបញ្ចប់នូវការជួបនេះ ។ នៅពេលដែលអ្នកអានករណីនេះ សូមកត់សំគាល់អំពីការអធិប្បាយរបស់យើងនៅរឹមទំព័រខាងស្ដាំ ។ អ្នកនឹងកត់សំគាល់ឃើញថា អ្នកផ្ដល់សេវាថែទាំប្រើប្រាស់នូវភាពស្ទាត់ជំនាញខ្លះ (មិនមែនទាំងអស់នោះទេ) ដែលមានបង្ហាញជូននៅក្នុងវគ្គបណ្ដុះបណ្ដាលនេះ ។

**ណារិទ្ធ**

| | | |
|---|---|---|
| អ្នកផ្តល់សេវាថែទាំ | : ណារិទ្ធ ពីមុនខ្ញុំបានប្រាប់ហើយថា យើងត្រូវព្យាបាលសង្សាររបស់លោកផងដែរ ។ តើលោកមានអារម្មណ៍យ៉ាងដូចម្តេចចំពោះការនិយាយបញ្ហានេះប្រាប់នាង ? | អ្នកផ្តល់សេវាថែទាំចាប់ផ្តើមដោយសួរសំណួរបើក ដើម្បីស្វែងយល់អំពីអារម្មណ៍របស់ណារិទ្ធនិងកំណត់អំពីការជំទាស់ក្នុងការបញ្ជូនដៃគូដោយអ្នកជំងឺ ។ |
| ណារិទ្ធ | : និយាយរឿងនេះប្រាប់នាង ? ......អ៊ឺ...... | |
| អ្នកផ្តល់សេវាថែទាំ | : លោកប្រហែលជាពិបាកនិយាយបញ្ហានេះជាមួយនាងណាស់មែនទេ ? | អ្នកផ្តល់សេវាថែទាំ កំពុងប្រើនូវការយល់អារម្មណ៍ដើម្បីលើកទឹកចិត្តណារិទ្ធឱ្យសំដែងចេញនូវអារម្មណ៍របស់គាត់។ |
| ណារិទ្ធ | បាទ......ខ្ញុំអាចនិយាយអំពីអ្វីដែលត្រូវធ្វើ ដើម្បីរក្សាឱ្យមានសុវត្ថិភាព ក៏ប៉ុន្តែបើនិយាយអំពីបញ្ហាហួរខ្ទុះនោះ នោះពិតជាលំបាកហើយ ។ | |
| អ្នកផ្តល់សេវាថែទាំ | : ខ្ញុំយល់ហើយថា បញ្ហានេះពិតជាលំបាកសំរាប់លោក។ ក៏ប៉ុន្តែលោកបានយល់ហើយអំពីរបៀបដែលលោកមានកើតការហួរខ្ទុះនោះ ។ ខ្ញុំជឿជាក់ថាលោកពិតជាអាចនិយាយរឿងនេះប្រាប់សង្សាររបស់លោកបាន ។ | អ្នកផ្តល់សេវាថែទាំកំពុងធ្វើការធានារ៉ាប់រងអ្នកជំងឺ ហើយពង្រឹងនូវចំណុចខ្លាំង ដើម្បីជួយឱ្យណារិទ្ធមានអារម្មណ៍ល្អចំពោះអ្វីដែលគាត់ត្រូវធ្វើ ។ |
| ណារិទ្ធ | យ៉ាងម្តេច ? តើត្រូវពន្យល់ប្រាប់ថាគេអាចកើតកាមរោគនៅពេលដែលដេកជាមួយអ្នកណាម្នាក់ដោយមិនប្រើស្រោមអនាម័យមែនដែរឬទេ ? តើនេះមិនទាក់ទងនឹងបញ្ហាស្មោកគ្រោកទេឬ ? | |
| អ្នកផ្តល់សេវាថែទាំ | : ត្រូវហើយគឺមិនមែនទេ ។ វាទាក់ទងនឹងការរួមភេទដែលមិនបានប្រើប្រាស់នូវមធ្យោបាយបង្ការជំងឺជាមួយមនុស្សលើសពីម្នាក់ឡើងទៅ ។ | អ្នកផ្តល់សេវាថែទាំបញ្ជាក់សំដីណារិទ្ធដោយនិយាយឡើងវិញនូវគំនិតរបស់គាត់ ហើយផ្តល់នូវការពន្យល់ដើម្បី |

| | | |
|---|---|---|
| | | បំភ្លឺនូវអ្វីដែលគាត់បាន និយាយ ។ |
| ណារិទ្ធ | : ក៏ប៉ុន្តែនាងពុំមានធ្លាក់សឬរោគសញ្ញាអ្វីផ្សេងទៀតទេ។ | |
| អ្នកផ្តល់សេវាថែទាំ | : ជារឿយៗស្ត្រីពុំមានរោគសញ្ញាទេ ណារិទ្ធអើយ ។ ក៏ប៉ុន្តែជំងឺកាមរោគអាចមានសភាពធ្ងន់ធ្ងរជាងបុរសទៅទៀត ។ ខ្ញុំត្រូវការឱ្យលោកជួយខ្ញុំដើម្បីធានាឱ្យយ៉ាងណាឱ្យនាងពិតជាបានទទួលនូវការព្យាបាលឱ្យបានត្រឹមត្រូវ ។ | ការលើកជាគំរូនូវអាកប្បកិរិយា ដែលអ្នកផ្តល់សេវាថែទាំចង់ឱ្យណារិទ្ធជ្រើសរើសយក ។ |
| ណារិទ្ធ | : ដូច្នេះខ្ញុំត្រូវនិយាយថា ...... | |

**សំណួរ**
**៦.២**

# ប័ណ្ណសំរាប់បញ្ជូនអ្នកជំងឺ
# (Partners Referral Cards)

**បញ្ហា:**

*យុវជនម្នាក់បានប្រាប់អ្នកថា សង្សាររបស់គាត់សុំឱ្យគាត់មកកាន់គ្លីនិករបស់អ្នក ដើម្បីព្យាបាលកាមរោគ ។ គាត់ពុំដឹងថាមានចង្កោមរោគសញ្ញាកាមរោគណាមួយទេ ហើយក៏គ្មានរោគសញ្ញាជំងឺអ្វីមួយទេ។ ឈ្មោះសង្សាររបស់យុវជនពុំមានចុះនៅក្នុងបញ្ជីនៃសំរង់ពត៌មានរបស់អ្នក ។ អ្នកពុំមានមធ្យោបាយអ្វីនឹងកំណត់អំពីចង្កោមរោគសញ្ញាដែល ត្រូវព្យាបាលឱ្យបុរសនោះទេ ។*

ស្ថានភាពខាងលើនេះគឺជាឧទាហរណ៍មួយនៃបរាជ័យក្នុងការបញ្ជូន និងថែទាំដៃគូរួមភេទរបស់អ្នកជំងឺ ។ ជាញឹកញាប់ដៃគូរួមភេទមកកាន់គ្លីនិកសុខភាព ដោយគ្មានបង្ហាញរោគសញ្ញាទេ។ ដោយគ្មានរោគសញ្ញា ឬសញ្ញានៃកាមរោគ ហើយក៏ពុំដឹងអំពីចង្កោមរោគសញ្ញានៃអ្នកជំងឺសន្ទស្សន៍ (index patient's syndrome) នោះ យើងពុំអាចព្យាបាលដៃគូរួមភេទបានទេ ។

ប័ណ្ណបញ្ជូនដៃគូរួមភេទ អាចមានសារៈប្រយោជន៍យ៉ាងខ្លាំង នៅក្នុងស្ថានភាពបែបនេះ ។ ខាងក្រោមនេះគឺជាគំរូពីរនៃរបៀបរៀបចំពត៌មាននៅលើប័ណ្ណបញ្ជូនអ្នកជំងឺ ។ មុននឹងអានគំរូទាំងនេះ សូមគិតអំពីពត៌មានដែលអ្នកត្រូវសរសេរនៅលើប័ណ្ណទាំងនេះ ។

**គំរូទី១នៃប័ណ្ណបញ្ជូនដៃគូរួមភេទ**

| | |
|---|---|
| ប័ណ្ណលេខ .....................<br>កាលបរិច្ឆេទចេញប័ណ្ណ...........<br>លេខកូដនៃរោគនិច្ឆ័យ ...........<br>ឈ្មោះនិងពត៌មានលំអិតរបស់អ្នកជំងឺ<br>...............................<br>...............................<br>មណ្ឌលសុខភាព................. | ប័ណ្ណលេខ ...................................<br>កាលបរិច្ឆេទចេញប័ណ្ណ.........................<br>មណ្ឌលសុខភាពដែលចេញប័ណ្ណ:................<br>ឈ្មោះ.......................................<br>អាស័យដ្ឋាន លេខទូរស័ព្ទ និងពេលម៉ោងធ្វើការរបស់មណ្ឌលសុខភាពយើងខ្ញុំមាននៅផ្នែកម្ខាងទៀតនៃប័ណ្ណ<br><br>លេខកូដសំគាល់រោគវិនិច្ឆ័យ.................... |

ប័ណ្ណខាងលើនេះ មានផ្នែកខាងឆ្វេងសំរាប់រក្សាទុកគល់បញ្ជីនៅមណ្ឌលសុខភាព និងផ្នែកមួយទៀតនៅខាងស្តាំសំរាប់ផ្តល់ឱ្យអ្នកជំងឺ ។ បន្ទាប់មកអ្នកជំងឺត្រូវប្រគល់ផ្នែកនេះទៅឱ្យដៃគូរបស់គាត់ ។ ប្រសិនបើអ្នកជំងឺមានដៃគូលើសពីម្នាក់ គេអាចផ្តល់ប័ណ្ណច្រើនជូនគាត់ ។ ប្រសិនបើអ្នកជំងឺពុំអាចបញ្ជូនដៃគូរួមភេទបានហើយ អនុញ្ញាតអ្នកផ្តល់សេវាថែទាំជាអ្នកទៅហៅវិញ នោះប័ណ្ណនេះមានពត៌មានសំរាប់អនុវត្តវិធីបញ្ជូនដោយអ្នកផ្តល់សេវារួចជាស្រេច ។

គុណសម្បត្តិនៃប័ណ្ណប្រភេទនេះ គឺមណ្ឌលសុខភាពអាចកត់ត្រាទុកនូវ ដៃគូរួមភេទរបស់អ្នកជំងឺ ហើយអាចតាមដានមើលថា តើអ្នកទាំងនេះមកឬមិនមកទទួលការព្យាបាល ។ ពត៌មានទាំងនេះ នឹងមានប្រយោជន៍នៅពេលក្រោយក្នុងការកំណត់ថា តើការបញ្ជូនដៃគូមកទទួលការព្យាបាលប្រព្រឹត្តទៅរួចដែរឬទេ ។

**គំរូទី២នៃប័ណ្ណសំរាប់បញ្ជូនដៃគូរួមភេទ**

**មណ្ឌលសុខភាព**

ផ្ទះលេខ......ផ្លូវលេខ......ទីរួមខេត្ត:

ទូរស័ព្ទលេខ : ០១២ ៤៤៤-៤៥៦

ម៉ោងធ្វើការ

| | |
|---|---|
| ច័ន្ទ | ម៉ោង ៨:០០ព្រឹក ដល់ ៣ រសៀល |
| អង្គារ | ម៉ោង ៩:០០ព្រឹក ដល់ ៩ យប់ |
| ពុធ | ម៉ោង ៩:០០ព្រឹក ដល់ ៣ រសៀល |
| ព្រហស្បតិ | ម៉ោង ៩:០០ព្រឹក ដល់ ៩ យប់ |
| សុក្រ | ម៉ោង ៩:០០ព្រឹក ដល់ ៣ រសៀល |

4/3/97

បណ្ណទី២មានលក្ខណៈងាយជាងមុន ក៏ប៉ុន្តែវា ក៏មានពត៌មានដែលគេត្រូវការដើម្បីព្យាបាលដៃគូរួមភេទដែរ ។ អ្នកផ្តល់សេវាថែទាំចុះកាលបរិច្ឆេទ និងលេខកូដ “UD” ដែលសំគាល់ការហូរខ្ទុះតាមបង្ហួរនោម ដែលជារោគវិនិច្ឆ័យជំងឺរបស់អ្នកជំងឺសន្ទស្សន៍ ។ អ្នកផ្តល់សេវាថែទាំអាចបង្កើតលេខកូដសំគាល់ផ្ទាល់ខ្លួនបានសំរាប់រោគវិនិច្ឆ័យផ្សេងៗនោះ ។ បណ្ណនេះមានលក្ខណៈសម្បត្តិមួយ គឺគេអាចយកវាមកប្រើប្រាស់ក្នុងគោលបំណងផ្សេងៗទៀត ក្រៅពីការបញ្ជូនដៃគូរួមភេទរបស់អ្នកជំងឺកាមរោគ ហើយវាមិនបណ្តាលឱ្យមានការមាក់ងាយអ្នកដែលកាន់វាទេ ។ ពុំមានគុណវិបត្តិអ្វីចំពោះបណ្ណ នេះទេលើកលែងតែករណីដែលគេប្រើបណ្ណនេះ ដើម្បីចុះបញ្ជីនៅមណ្ឌលសុខភាពតាមវិធីណាមួយនោះ ។

ចំពោះប្រព័ន្ធប្រើប្រាស់បណ្ណបញ្ជូនប្រភេទណាក៏ដោយ ការសំខាន់គឺត្រូវពិចារណាលើការរំលោភលើការសំងាត់របស់អ្នកជំងឺ និងការមាក់ងាយអ្នកជំងឺ ។

## ករណីដែលបញ្ជូនដៃគូដោយអ្នកជំងឺពុំអាចធ្វើទៅបាន

ទោះបីជាអ្នកខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាក៏ដោយ ក៏ជួនកាលអ្នកជំងឺមួយចំនួនបដិសេធមិនព្រមបញ្ជូនដៃគូរបស់គាត់ឱ្យមកទទួលការព្យាបាលទេ ។ ពួកគេអាចមានហេតុផលជាច្រើនដើម្បីធ្វើការបដិសេធ ។ នៅតាមមណ្ឌលសុខភាពខ្លះការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំ គឺជាជំរើសតែមួយគត់។

## ជំរើសនានាក្នុងករណី
## ដែលការបញ្ជូនដោយអ្នកជំងឺពុំអាចធ្វើទៅបាន

***នៅពេលដែលអ្នកជំងឺយល់ឃើញថាពួកគេពុំអាចបញ្ជូនដៃគូបាន:***

- ត្រូវសុំការអនុញ្ញាតិពីអ្នកជំងឺដើម្បីបន្តធ្វើការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំ

ឬ

- ផ្តល់ការព្យាបាលដូចគ្នានឹងអ្នកជំងឺដល់ដៃគូរបស់គាត់

***ប្រសិនបើដៃគូមិនមកទទួលការព្យាបាល***

- សូមពិនិត្យមើលថាតើដៃគូនោះមានទៅទទួលការព្យាបាលនៅកន្លែងដទៃទៀតដែរឬទេ

និង

- ប្រើប្រាស់អ្នកផ្តល់សេវាថែទាំឱ្យចុះជួបផ្ទាល់ ដើម្បីហៅដៃគូនោះ

ជំរើសមួយផ្សេងទៀតនោះ គឺត្រូវផ្តល់នូវការព្យាបាលដូចគ្នានឹងអ្នកជំងឺជូនដល់ដៃគូរបស់គាត់ ។ ការផ្តល់ការព្យាបាលដូចគ្នានេះត្រូវផ្តល់ជូនតែក្នុងករណីដែលមានឧបសគ្គធំធេងក្នុងការអនុវត្តវិធីបញ្ជូនដោយអ្នកជំងឺ និងនៅពេលដែលអ្នកផ្តល់សេវាថែទាំស្គាល់អ្នកជំងឺតែប៉ុណ្ណោះ ។ ដើម្បីឱ្យមណ្ឌលសុខភាពរបស់អ្នកអាចតាមដានដៃគូរួមភេទដែលមិនមកទទួលការព្យាបាល មណ្ឌលសុខភាពត្រូវការនូវធនធានជាច្រើន ដូចជា ពេលវេលា និងបុគ្គលិក ។ ប្រអប់ខាងក្រោមនេះមានសង្ខេបប្រភពធនធានដែលត្រូវការដើម្បីធ្វើឱ្យគេអាចធ្វើការតាមដានប្រភេទនេះបាន ។

***ប្រភពធនធានដែលត្រូវការ***
***សំរាប់អនុវត្តការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំ***

- ឈ្មោះនឹងអំពីពត៌មានស្តីអំពីដៃគូ និងការអនុញ្ញាតអំពីអ្នកជំងឺសន្មស្សន៍ក្នុងការធ្វើការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំ

- បុគ្គលិកចុះអប់រំផ្ទាល់ដែលបានទទួលការបណ្តុះបណ្តាល

- ប្រព័ន្ធកត់ត្រាដែលរក្សាបាននូវការរក្សាការសំងាត់របស់ជំងឺ និងអាចកំណត់ដៃគូរួមភេទដែលមិនបានទទួលការព្យាបាលក្រោយរយៈពេលមួយខ្លី ឧទាហរណ៍ក្រោយរយៈពេល ២ សប្តាហ៍ ។

- ការប្រាស្រ័យទាក់ទងល្អជាមួយអ្នកផ្តល់សេវាថែទាំកាមរោគផ្សេងៗទៀតទៅតាមមណ្ឌលសុខភាពផ្សេងៗទៀតដែលដៃគូនោះទៅស្វែងរកការព្យាបាល (ជារឿយៗបុរសច្រើនតែទៅស្វែងរកការព្យាបាលនៅកន្លែងផ្សេងពីស្ត្រី) ។

**លំហាត់**
**៦.៣**



ការបញ្ជូនដៃគូរួមភេទដោយ
អ្នកផ្តល់សេវាថែទាំ



## ការព្យាបាលដៃគូរួមភេទ
## (Treating Partners)

គោលបំណងនៃការគ្រប់គ្រងថែទាំដៃគូរួមភេទរបស់អ្នកជំងឺ គឺព្យាបាលជំងឺកាមរោគ ដូចគ្នានឹងជំងឺដែលអ្នកជំងឺមាន ឱ្យដៃគូរួមភេទរបស់គាត់ ។ ពិនិត្យដៃគូរួមភេទពុំចាំបាច់ទេ ទោះបីជាអ្នក ឬ ដៃគូរួមភេទចង់ធ្វើការត្រួតពិនិត្យរកមើលសញ្ញាផ្សេងៗទៀតក៏ដោយ។

យើងក៏ត្រូវយកចិត្តទុកដាក់ដល់អ្នកជំងឺផងដែរ ដោយស្រង់ប្រវត្តិជំងឺព្យាបាលនិងអប់រំអ្នកជំងឺ ។ សូមកុំភ្លេចថា អ្នកត្រូវសួរអ្នកជំងឺថ្មីទាំងនេះ អំពីដៃគូរួមភេទរបស់ពួកគេផងដែរ ហើយអ្នកត្រូវបន្តធ្វើការបញ្ជូនដៃគូរួមភេទឱ្យមកទទួលការព្យាបាលសាជាថ្មីទៀត ។

**រោគវិនិច្ឆ័យនិងការព្យាបាលដៃគូរួមភេទដោយពឹងផ្អែកលើអ្នកជំងឺដំបូង**

| ***ចង្កោមរោគសញ្ញារបស់អ្នកជំងឺ*** | ***ការព្យាបាលដៃគូរួមភេទ*** |
|---|---|
| ការហូរខ្ទុះតាមបង្ហួរនោម | ព្យាបាលជំងឺប្រមេះទឹកបាយ និងជំងឺបង្កដោយក្លាមីឌីយ៉ាជូនដៃគូរួមភេទ |
| ដំបៅនៅលើប្រដាប់បន្តពូជ | ព្យាបាលជំងឺស្វាយនិង chancroid ជូនដៃគូរួមភេទ |
| ការធ្លាក់ស /ហូរខ្ទុះតាមទ្វារមាសៈ | |
| • អ្នកជំងឺទទួលការព្យាបាលជំងឺរលាកទ្វារមាសនិងរលាកមាត់ស្បូន | ព្យាបាលប្រមេះទឹកបាយនិងជំងឺបង្កដោយក្លាមីឌីយ៉ាជូនដៃគូរួមភេទ |
| • អ្នកជំងឺទទួលការព្យាបាលជំងឺរលាកទ្វារមាសតែមួយមុខ | មិនចាំបាច់ព្យាបាលដៃគូរួមភេទទេលើកលែងតែការធ្លាក់សនោះកើតសាជាថ្មីឡើងវិញ ។ |
| • ជំងឺរលាកប៉េលវីស | ព្យាបាលប្រមេះទឹកបាយនិងជំងឺបង្កដោយក្លាមីឌីយ៉ាជូនដៃគូរួមភេទ |
| • ជំងឺសិរមាន់ | ព្យាបាលជំងឺសិរមាន់ជូនដៃគូរួមភេទ |

**សំខាន់:**

*ប្រសិនបើស្ត្រីដែលធ្លាក់សកើតជំងឺរលាកទ្វារមាសតែមួយមុខនោះ គេពុំចាំបាច់ព្យាបាលដៃគូរួមភេទរបស់គាត់ទេ លើកលែងតែការធ្លាក់សនោះកើតឡើងសាចុះសាឡើង ។*

## ការរំលឹកសាឡើងវិញ

## គោលការណ៍នៃការគ្រប់គ្រងថែទាំដៃគូរួមភេទ

ការគ្រប់គ្រងថែទាំដៃគូរួមភេទរបស់អ្នកជំងឺមានសារៈសំខាន់ណាស់ ពីព្រោះវាអាចកាត់ផ្តាច់វដ្តនៃការចំលងនៃជំងឺកាមរោគបាន។

ការកំណត់រកឱ្យឃើញប្រភពជំងឺពុំអាចប្រព្រឹត្តទៅបានទេ ក៏ប៉ុន្តែចំពោះការគ្រប់គ្រងថែទាំករណីកាមរោគវាពុំមានសារៈសំខាន់ទេ (គេត្រូវព្យាបាលដៃគូរួមភេទទាំងអស់ដែលអ្នកជំងឺមានក្នុងរយៈពេលពីរខែមុន) ។

ការគ្រប់គ្រងថែទាំដៃគូរួមភេទ ត្រូវពិចារណាលើឥទ្ធិពលដែលកាមរោគអាចមានទៅលើការរស់នៅរបស់អ្នកជំងឺ និងពិនិត្យមើលថាតើអ្នកជំងឺមានការងាយស្រួលក្នុងករណីពិភាក្សាអំពីកាមរោគប្រាប់ដៃគូរួមភេទរបស់គាត់បានដល់កំរិតណា ។

ការគ្រប់គ្រងថែទាំដៃគូរួមភេទរួមមានៈ

- ព្យាបាលដល់គ្រប់ដៃគូរួមភេទទាំងអស់របស់អ្នកជំងឺ និង
- ផ្តល់ការព្យាបាលជំងឺកាមរោគដូចគ្នានឹងការព្យាបាលកាមរោគដែលអ្នកជំងឺកំពុងមាន។

## ការហៅដៃគូរួមភេទឱ្យមកទទួលការព្យាបាល

គេអាចហៅដៃគូរួមភេទរបស់អ្នកជំងឺបានតាមរយៈ

- ការបញ្ជូនដោយអ្នកជំងឺ ពេលនោះអ្នកជំងឺប្រាប់ដៃគូរួមភេទ របស់គាត់ថាពួកគេត្រូវស្វែងរកការព្យាបាល ។
- ការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំក្នុងពេលនោះអ្នកសេវាថែទាំសុខភាពជាអ្នកហៅដៃគូរួមភេទដែលប្រាប់ឱ្យដឹងដោយអ្នកជំងឺ ។
- ការបញ្ជូនដៃគូរួមភេទដោយអ្នកជំងឺដោយស្ម័គ្រចិត្ត គឺជាវិធីមួយដែលមានលក្ខណៈល្អជាងគេ ។

បញ្ហាដែលត្រូវលើកយកមកពិភាក្សាជាមួយអ្នកជំងឺសន្ទស្សន៍រួមមានៈ

- សារៈសំខាន់នៃការព្យាបាលដៃគូរួមភេទទាំងអស់របស់គាត់

- វិធីបង្ការការឆ្លងជំងឺសាជាថ្មី
- របៀបដែលអ្នកជំងឺត្រូវប្រាស្រ័យទាក់ទងជាមួយដៃគូរបស់គាត់ដោយអារម្មណ៍សុខស្រួល
- ឈ្មោះដៃគូរបស់អ្នកជំងឺ ប្រសិនបើអ្នកជំងឺចង់ប្រាប់ ។

ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងមានសារៈសំខាន់ណាស់ នៅពេលពិភាក្សាជាមួយដៃគូរួមភេទ និងការបញ្ជូន ។

គេអាចប្រើប្រាស់នូវប័ណ្ណបញ្ជូន ដើម្បីធ្វើឱ្យការបញ្ជូនមានលក្ខណៈងាយស្រួលជាងមុន ជាពិសេសប្រសិនបើអ្នកជំងឺពុំនិយាយ អំពីតំរូវការក្នុងការព្យាបាលប្រាប់ដៃគូរបស់ខ្លួន ។

នៅពេលដែលការបញ្ជូនដោយអ្នកជំងឺពុំអាចធ្វើទៅបានគេមានការជ្រើសរើសនានាដូចតទៅៈ
- សុំការអនុញ្ញាតអំពីអ្នកជំងឺក្នុងការឈានទៅរក ការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំ ឬ
- ផ្តល់ជូននូវការព្យាបាលដូចគ្នានឹងអ្នកជំងឺសំរាប់ដៃគូ ។

នៅពេលដែលដៃគូរួមភេទមិនព្រមមកទទួលការព្យាបាលការជ្រើសរើសផ្សេងៗមាន :
- ពិនិត្យមើលថាតើដៃគូនោះមានទៅពិគ្រោះជំងឺ នៅមណ្ឌលសុខភាពផ្សេងៗទៀតដែរ ឬទេ?
- ប្រើប្រាស់នូវអ្នកចុះអប់រំផ្ទាល់ឱ្យខិតខំទាក់ទងហៅដៃគូរួមភេទ របស់អ្នកជំងឺឱ្យមកទទួលការព្យាបាល ។

## ការព្យាបាលដៃគូរួមភេទ

ការពិនិត្យដៃគូដែលត្រូវបានបញ្ជូនមកពុំចាំបាច់ទេ ។ ក្រៅអំពី ការពិនិត្យអ្នកអនុវត្តធ្វើតាមជំហាននានាចំពោះដៃគូ ដូចគ្នាក្នុងពេលដែលអ្នកធ្វើចំពោះអ្នកជំងឺផងដែរ គឺការស្រង់ប្រវត្តិជំងឺ ការអប់រំ និងការបញ្ជូនដៃគូរួមភេទ ។

រោគវិនិច្ឆ័យដែលណែនាំអំពីការជ្រើសរើសការព្យាបាល សំរាប់ដៃគូដែលត្រូវបញ្ជូនគឺដូចគ្នានឹងអ្នកជំងឺដែរ លើកលែងតែដៃគូរបស់អ្នកជំងឺដែលទទួលនូវការព្យាបាលជំងឺរលាកទ្វារមាស ។ ក្នុងករណីទាំងនេះគេពុំចាំបាច់ព្យាបាលដៃគូរួមភេទទេ លើកលែងតែ ជំងឺរលាកទ្វារមាសនេះកើតសាចុះសាឡើង ។

## សំណួរ និងលំហាត់

### ៦.១ សំណួរ

ក. តើគោលការណ៍ណាខ្លះដែលណែនាំដល់អ្នកផ្តល់សេវាថែទាំប្រកាន់យកនៅពេលដែលគេពិភាក្សាអំពីការគ្រប់គ្រងថែទាំដៃគូរួមភេទ ដើម្បីឱ្យអ្នកជំងឺរបស់គាត់អាចទទួលបាននូវការការពារកិត្តិយសបាន ?

ខ. តើក្នុងចំណោមវិធីទាំងពីរៈគឺការបញ្ជូនដោយអ្នកជំងឺនិងការបញ្ជូនដោយសារអ្នកផ្តល់សេវាថែទាំ វិធីមួយណាជាវិធីល្អជាងគេ ? បើពិនិត្យមើលត្រួសៗ វិធីគ្រប់គ្រងថែទាំដៃគូរួមភេទទាំងពីរហាក់ដូចជាមានផលប្រយោជន៍ដូចគ្នា ។ ដោយចង់ចាំទុកក្នុងចិត្តនូវសារៈសំខាន់ នៃការយល់ព្រមដោយស្ម័គ្រចិត្តរបស់អ្នកជំងឺក្នុងការប្រាប់ដៃគូរបស់ខ្លួន សូមកត់ត្រាចុះនៅក្នុងតារាងខាងក្រោមនេះនូវគុណសម្បត្តិនិងគុណវិបត្តិនៃវិធីនិមួយៗដែលអ្នកយល់ឃើញ ។

| | ***គុណសម្បត្តិ*** | ***គុណវិបត្តិ*** |
|---|---|---|
| ការបញ្ជូនដោយអ្នកជំងឺ | | |
| ការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំ | | |

## ៦.២ សំណួរ

សូមខិតខំរកឱ្យឃើញនូវភាពស្ទាត់ជំនាញនានា ដែលអ្នកផ្តល់សេវាថែទាំប្រើប្រាស់នៅក្នុងការសិក្សាករណីខាងក្រោមនេះ ។ សូមគូសបន្ទាត់ពីក្រោមអ្វីដែលអ្នកផ្តល់សេវាថែទាំនិយាយហើយដែលអ្នកយល់ឃើញថាឆ្លុះបញ្ចាំងអំពីភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងរវាងបុគ្គល និងបុគ្គល ហើយកត់ត្រានូវភាពស្ទាត់ជំនាញទាំងនោះទៅតាមការយល់ឃើញរបស់អ្នក ។ ចំណុចទី១នៃលំហាត់ ត្រូវបានបំពេញជាស្រេចសំរាប់អ្នក ។ អ្នកអាចគិតអំពីភាពខុសគ្នារវាងការសិក្សាករណីនេះជាមួយការសិក្សាករណីដែលអ្នកទើបតែនឹងអានរួចស្តីអំពីលោកណារិទ្ធនៅក្នុងម៉ូឌុលនេះ ។

**គន្ធា**

**ពត៌មានទូទៅ** : គន្ធាមានសេចក្តីតក់ស្លុតយ៉ាងខ្លាំងចំពោះពត៌មានអំពីការផិតក្បត់ដែលប្តីនាងអាចមានចំពោះនាង ជាហេតុធ្វើឱ្យនាងត្រូវចំណាយពេលដើម្បីសញ្ជឹងគិតអំពីបញ្ហាទាំងនេះ ។ ជាច្រើនថ្ងៃក្រោយមក នាងក៏បានវិលត្រលប់មកវិញ ។ នាងប្រាប់អ្នកផ្តល់សេវាថែទាំថានាងកំពុងតែលេបថ្នាំដោយត្រឹមត្រូវ ក៏ប៉ុន្តែនាងពុំបាននិយាយអ្វីប្រាប់ប្តីនាងឡើយ ។ ប្អូនថ្លៃគន្ធា បានរាយការណ៍ថា នាងបានឮគេនិយាយថាមានគេបានឃើញប្តីរបស់គន្ធាចេញពីរង្គសាលជាមួយស្ត្រីរកស៊ីផ្លូវភេទជាច្រើនដង ។

គន្ធា : ខ្ញុំពុំអាចនិយាយអ្វីប្រាប់គាត់បានទេ ។ គាត់នឹងស្តីបន្ទោសឱ្យខ្ញុំ... ខ្ញុំដឹងច្បាស់ណាស់ថាគាត់នឹងស្តីបន្ទោសឱ្យខ្ញុំ ។ ប៉ុន្តែខ្ញុំត្រូវគិតអំពីអនាគតគ្រួសារខ្ញុំ... គាត់នឹងបន្ទោសឱ្យខ្ញុំ ទោះបីជាការកើតជំងឺថៃទាំនេះពុំមែនជាកំហុសរបស់ខ្ញុំក៏ដោយ

អ្នកផ្តល់សេវាថែទាំ: <u>លោកស្រីមានការភ័យខ្លាចណាស់</u> ក្នុងការប្រាប់គាត់អំពីអំពើដែលគាត់បានប្រព្រឹត្ត ។

*អ្នកផ្តល់សេវាផ្ទៀងផ្ទាត់មើលថាគាត់យល់អារម្មណ៍របស់គន្ធាដែរឬទេ ។*

គន្ធា : ចាស់...... ត្រូវហើយ ។

អ្នកផ្តល់សេវាថែទាំ: ខ្ញុំឃើញហើយថាអ្នកស្រីមានការអស់សង្ឃឹមយ៉ាងខ្លាំងចំពោះរឿងនេះ ហើយខ្ញុំសូមគាំទ្រអ្នកស្រី ។ អ្នកស្រីគិតត្រូវហើយក្នុងការមកជួបខ្ញុំម្តងទៀត អ្នកស្រីហាក់ដូចជាមានបំណងដោះស្រាយបញ្ហានេះធ្វើយ៉ាងណា ដើម្បីឱ្យប្តីអ្នកស្រីមកទទួលការព្យាបាល ។

គន្ធា : ក៏ប៉ុន្តែខ្ញុំពុំអាចនិយាយអ្វីប្រាប់គាត់បានទេ ......

អ្នកផ្តល់សេវាថែទាំ: អញ្ចឹងមានរឿងពីរដែលអ្នកធ្វើបាន ។ អ្នកស្រីអាចសុំឱ្យគាត់មកកាន់គ្លីនិក ពីព្រោះគាត់អាចមានជំងឺដូចអ្នកស្រីដែរ ឬអ្នកស្រីអាចសុំឱ្យអ្នកណាម្នាក់ទៀត ទៅនិយាយប្រាប់គាត់ ។ តើអ្នកស្រីពេញចិត្តការជ្រើសរើសណាមួយ ?

គន្ធា : តើខ្ញុំគ្រាន់តែនិយាយប្រាប់គាត់ថាគាត់គួរតែមកទីនេះដើម្បីធ្វើការត្រួតពិនិត្យសុខភាពបានដែរឬ ?

អ្នកផ្តល់សេវាថែទាំ: ចាស់ គ្រាន់តែធ្វើប៉ុណ្ណឹងបានហើយ ។ ចាំខ្ញុំធ្វើអ្វីផ្សេងៗទៀតជាបន្ត ។ ប្រសិនបើខ្ញុំឱ្យប័ណ្ណនេះទៅអ្នកស្រី តើអ្នកស្រីអាចប្រាប់គាត់ឱ្យយកវាមកជាមួយបានដែរ ឬទេ?

គន្ធា : ហើយអ្នកអាចព្យាបាល រួចប្រាប់គាត់អំពីមូលហេតុដែលតំរូវឱ្យគាត់ទទួលការព្យាបាលឬ?

អ្នកផ្តល់សេវាថែទាំ: ចាស់ ខ្ញុំប្រាកដជានឹងធ្វើរឿងនេះហើយប្រាប់គាត់ ។ តើអ្នកស្រីនឹងនិយាយអ្វីខ្លះប្រាប់គាត់?

គន្ធា : អ៊ឺ:ខ្ញុំនឹងនិយាយថាគាត់អាចកើតកាមរោគដូចខ្ញុំដែរ ហើយសួរគាត់ថាតើគាត់អាចកាន់ប័ណ្ណនេះទៅកាន់គ្លីនិកជាមួយគាត់បានដែរឬទេ ?

## ៦.៣ លំហាត់

សូមពិចារណាមើលថាតើមណ្ឌលសុខភាពរបស់អ្នកអាចមានបុគ្គលិកចុះអប់រំផ្ទាល់ដែលអាចធ្វើការបញ្ជូនដោយអ្នកផ្ដល់សេវាថែទាំបានដែរឬទេ ។ ក្នុងករណីចាំបាច់ សូមខិតខំប្រឹងស្វែងយល់អំពីពត៌មានលំអិត និងបែបបទក្នុងការបញ្ជូនដោយអ្នកផ្ដល់សេវាថែទាំ ដែលកំពុងតែមានដំណើរការស្រាប់ ។

## ៦.៤ សំណួរ

យុវនារីម្នាក់ប្រាប់អ្នកថា សង្សាររបស់នាងបានផ្ដល់យោបល់ឱ្យបានទៅទទួលការត្រួតពិនិត្យសុខភាពនៅមណ្ឌលសុខភាពរបស់អ្នក ។ នាងហុចឱ្យអ្នកនូវប័ណ្ណមួយដែលអ្នកមើលទៅឃើញមានសរសេរលេខកូដសំគាល់ដំបៅនៅនឹងប្រដាប់បន្តពូជនៅលើនោះ ។

ក. តើអ្នកគួរព្យាបាលជំងឺអ្វីខ្លះឱ្យនាង ?

ខ. តើអ្នកគួរពិនិត្យនាងដែរឬទេ ? ហេតុអ្វីបានជាត្រូវ ឬមិនត្រូវពិនិត្យ ?

## ៦.៥ លំហាត់

### ការដើរតួក្នុងការគ្រប់គ្រងថែទាំដៃគូរួមភេទរបស់អ្នកជំងឺ

នៅក្នុងជំពូកទី៥ អ្នកបានអនុវត្តនូវវិធីអប់រំ និងផ្ដល់ការគាំទ្រដល់អ្នកជំងឺកាមរោគ ។ លំហាត់ដើរតួរនេះ នឹងជួយអ្នកឱ្យបង្កើនភាពស្ទាត់ជំនាញនៅក្នុងដំណាក់កាលចុងក្រោយនៃការធ្វើសំភាសន៍ ដោយអនុវត្តនូវការបញ្ជូនដៃគូរួមភេទឱ្យមកទទួលការថែទាំ ។

នៅទំព័រក្រោយៗនេះ មានការសិក្សាករណីមួយចំនួន ។ ករណីដំបូងគឺដូចគ្នានឹងករណីដែលបានប្រើប្រាស់សំរាប់ការដើរតួរក្នុងជំពូកទី ៥ ហើយករណីដែលនៅសល់ ៤ទៀតគឺជាករណីថ្មី ។

**កែវ**

**កែវ** ជាស្រ្តីរកស៊ីផ្លូវភេទអាយុ ១៩ ឆ្នាំ រស់នៅក្នុងតំបន់ក្រីក្រមួយនៃទីក្រុង ។ នាងមានកូនតូចមួយដែលតែងតែឈឺជានិច្ច ។ កែវ ក៏តែងតែយកប្រាក់កំរៃដែលនាងរកបានផ្តល់ឱ្យគ្រួសារនាងដែលរស់នៅឯភូមិនាតំបន់ដាច់ស្រយាលមួយ ។ គ្រួសារនាងមិនពេញចិត្តនឹងមុខរបររបស់នាងទេ ក៏ប៉ុន្តែត្រូវការប្រាក់ដែលនាងផ្ញើមកផ្ទះ ។ នាងគ្មានភ័យខ្លាចអំពីជំងឺអេដស៍ តែភ្ញៀវនាងជាច្រើនបដិសេធមិនព្រមប្រើស្រោមអនាម័យទេ ។ នាងក៏ពុំសូវយល់ដឹងអំពីកាមរោគដែរ ។ អ្នកធ្វើរោគវិនិច្ឆ័យថា នាងមានដំបៅនៅនឹងប្រដាប់បន្តពូជ ។ កែវបារម្ភថាដំបៅនេះគឺជាជំងឺកាមរោគ ។

**សំណាង**

**សំណាង** គឺជាកំលោះអាយុ ២៤ ឆ្នាំ ដែលមានការងារល្អ និងមានផ្ទះផ្ទាល់ខ្លួន ។ គាត់មិនទាន់ចង់រកគូស្រករទេ ដោយធ្វើខ្លួនជាអ្នកដែលចូលចិត្តស្វែងរកការសប្បាយ ។ គាត់មានដៃគូរួមភេទ ៣ នាក់ ហើយជួនកាលក៏មានដៃគូដែលជួបដោយចៃដន្យដែរ ក៏ប៉ុន្តែគាត់និយាយថាគាត់ជ្រើសរើសយកតែស្រីណាដែលស្អាតស្អំ ឬមានប្តីហើយ ។ គាត់មិនអាចយល់ថា ហេតុអ្វីបានជាគាត់មានហូរខ្ទុះតាមបង្ហួរនោម ។ នៅពេលធ្វើសំភាសន៍ គាត់ទទួលស្គាល់ថាគាត់សេព សុរា ជាមួយដៃគូរួមភេទម្នាក់របស់គាត់មុនពេលរួមភេទ ។ អ្នកផ្តល់សេវាថែទាំ បានបញ្ជាក់ថាគាត់មានការហូរខ្ទុះតាមបង្ហួរនោមមែន ។

**គន្ធា**

**អ្នកស្រីគន្ធា** គឺជាស្រ្តីម្នាក់មានអាយុ ៣៥ ឆ្នាំ ហើយមានកូនស្រីជំទង់ៗបីនាក់ ។ គាត់ពឹងផ្អែកលើប្រាក់ចំណូលរបស់ប្តីគាត់ ដែលធ្វើការនៅរោងចក្រដើម្បីទ្រទ្រង់គ្រួសារ ។ គាត់បានយល់ថា ជារឿយៗប្តីរបស់គាត់ក្រមកពីរោងចក្រវិញ ហើយទៅផឹកស៊ីជាមួយមិត្តភក្តិម្តងម្កាលជួនកាលគាត់ធុំក្លិនស្រាចេញពីមាត់របស់គាត់ ។ ក៏ប៉ុន្តែគាត់មានអារម្មណ៍ ជឿជាក់លើការស្មោះត្រង់របស់ប្តីគាត់ចំពោះគាត់ ។ គាត់មកកាន់មណ្ឌលសុខភាព ដោយគិតមិនយល់អំពីមូលហេតុដែលធ្វើឱ្យមានការចុកចាប់ពោះទាល់តែសោះ ។ អ្នកផ្តល់សេវាថែទាំបានធ្វើរោគវិនិច្ឆ័យថា គាត់កើតជំងឺរលាកប៉ែលវីស ។

**សុភាព**

**សុភាព** មានអាយុ ៣៥ ឆ្នាំ មានកូន ៤នាក់ ហើយរស់នៅឯជនបទ ។ គាត់មកគ្លីនិកមួយនៅក្នុងទីក្រុង ពីព្រោះ គាត់ហើមក្រលៀនដែលអ្នកផ្តល់សេវាថែទាំធ្វើរោគវិនិច្ឆ័យថា គាត់មានរោគសញ្ញាហើមក្រលៀន ។ នៅពេលឆ្លើយនឹងសំណួររបស់ផ្តល់សេវាថែទាំ គាត់ឆ្លើយទាំងស្ទាក់ស្ទើរក្នុងចិត្តថា គាត់បានរួមភេទជាមួយដៃគូរួមភេទមួយចំនួន ដែលភាគច្រើនគឺគាត់ជួបដោយចៃដន្យ នៅពេលដែលគាត់កំពុងរកការងារធ្វើ ។ គាត់តែងតែធ្វើដំណើរទៅទីក្រុង ដើម្បីធ្វើការឆ្ងាយពីផ្ទះអស់រយៈពេល ៣ ខែ ម្តង ។ គាត់និយាយថាប្រពន្ធគាត់សព្វថ្ងៃនេះមានផ្ទៃពោះ ៦ ខែ ហើយ ។ គាត់មិនបានមកផ្ទះអស់រយៈពេល ២ ខែ កន្លងមកហើយ ទោះបីជាគាត់ផ្ញើប្រាក់មកផ្ទះជាទៀងទាត់ក៏ដោយ ។ សព្វថ្ងៃគាត់កំពុងរស់នៅជាមួយដៃគូបណ្តោះអាសន្នម្នាក់នៅក្នុងទីក្រុង ។

**ហៀង**

**ហៀង** គឺជាយុវជនមានអាយុ ២២ ឆ្នាំ នៅលីវ ហើយរស់នៅតំបន់ក្រីក្រមួយនៃទីក្រុងធំមួយ ។ គាត់បានបញ្ចប់ការ សិក្សានៅមធ្យមសិក្សា ប៉ុន្តែពុំអាចរកនូវការងារជាក់លាក់ណាមួយធ្វើបាន ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ ។ គាត់ធ្វើការងារបណ្តោះអាសន្នណាដែលគាត់អាចរកបានធ្វើ ដើម្បីសន្សំប្រាក់ដើម្បីប្រកបមុខរបរ ជំនួញតូចតាចមួយ ។ មិត្តភក្តិភាគច្រើនរបស់គាត់ក៏ស្ថិតនៅក្នុងស្ថានភាពដូចគ្នាដែរ ។ ពួកគេទៅកំសាន្តនៅ វង្គសាលមួយក្នុងតំបន់ ។ ហៀង តែងតែផឹកស្រា ពីរ បី កែវ ហើយជួនកាលគាត់នាំស្រីដែលបំរើការក្នុងវង្គសាល ទៅដេកឯផ្ទះគាត់ទៀតផង ។ គាត់ធ្លាប់កើតកាមរោគជាច្រើនដងហើយ ក៏ប៉ុន្តែដោយសារតែគាត់ត្រូវបានទទួល ការព្យាបាលបានទាន់ចិត្តនៅមណ្ឌលសុខភាពនោះ គាត់ក៏ពុំព្រួយបារម្ភអំពីបញ្ហាហូរខ្ទុះតាមបង្ហូរនោមឡើយ ។

**សុរិយា**

**សុរិយា** មានអាយុ ៣៨ ឆ្នាំ ហើយមានកូន ៤ នាក់ ។ គាត់និងគ្រួសារគាត់រស់នៅក្នុងតំបន់អ្នកមានទ្រព្យធន មធ្យមនៃទីក្រុង ។ គាត់និងប្តីរបស់គាត់ខិតខំធ្វើការដើម្បីយកប្រាក់មកផ្គត់ផ្គង់កូនៗឱ្យទៅសាលា ។ អស់រយៈពេល ពីរខែកន្លងទៅហើយ សុរិយាបានចាប់ផ្តើមមានទំនាក់ទំនងផ្លូវភេទជាមួយបុរសដែលជាសហការីវ័យក្មេងរបស់គាត់ ។ នៅពេលដែល គាត់កត់សំគាល់ថាមានកើតដំបៅនៅនឹងប្រដាប់បន្តពូជ គាត់យល់ច្បាស់ថា វាគឺជាទណ្ឌកម្មលើរូប គាត់ ដោយសារគាត់ផឹតក្បត់ប្តី ហើយក៏បានបញ្ឈប់ទំនាក់ទំនងផ្លូវភេទនោះទៅ គាត់បានមកកាន់មណ្ឌលសុខភាព ទាំងអារម្មណ៍ថាមានកំហុសនិងព្រួយបារម្ភ ។

**សេដ្ឋា**

**សេដ្ឋា** គឺជាកុមារីដែលមានអាយុ ១៥ ឆ្នាំ មកធ្វើជាអ្នករៀបចំផ្ទះឱ្យឪពុកមានាង ។ ចាប់ពីពេលដែលនាងមក ស្នាក់នៅក្នុងផ្ទះគាត់ភ្លាម សេដ្ឋាត្រូវឪពុកមាចាប់រំលោភ ហើយបន្ទាប់ពីពេលនោះមក មានាងទទូចស្នំរួមភេទជាមួយ នាងយ៉ាងទៀងទាត់ ។ នាងបានសាកល្បងរត់ចេញពីផ្ទះ ដើម្បីទៅរួមរស់ជាមួយគ្រួសារដែរ ប៉ុន្តែត្រូវឪពុកមានាង តាមទាន់ចាប់ខ្លួនមកវិញរួចវាយដុំនាង ។ ឪពុកមានាងនាំនាងមកពិនិត្យសុខភាព ពីព្រោះនាងត្អូញត្អែរថាឈឺចុកចាប់ ផ្នែកខាងក្រោមនៃពោះ ។

**ឆាយ**

**ឆាយ** មានអាយុ២៦ ឆ្នាំ បានសំរេចចិត្តរកគូរស្រករ ។ គាត់បានភ្ជាប់ពាក្យជាមួយអ្នកគ្រូបង្រៀនម្នាក់ដែលមាន អាយុ ២៤ ឆ្នាំ ។ គូសង្សារទាំងពីរនាក់ស្រលាញ់គ្នាខ្លាំងណាស់ ។ នាងបានសុំឱ្យឆាយទៅកាន់មណ្ឌលសុខភាព ពីព្រោះ នាងយល់ថា ឆាយ អាចកើតជំងឺ ។ គាត់ក៏បានហុចប័ណ្ណមួយសន្លឹកឱ្យទៅគ្រូពេទ្យ ។ លេខកូដសំគាល់នៅ លើប័ណ្ណបញ្ជាក់ថា គូសង្សាររបស់គាត់មានធ្លាក់ស ដែលបង្កអោយមានការរលាកទ្វារមាស និងរលាកមាត់ស្បូន ។

## ការដើរតួជាអ្នកជំងឺ

សូមរំលឹកឡើងវិញនូវតួនាទីដែលអ្នកបានដើរតួនៅក្នុងលំហាត់ដើរតួចុងក្រោយ ឬ ជ្រើសរើសយកករណីថ្មីមួយពីករណីនានា ដែលមាននៅក្នុងទំព័រមុនៗ ។ សូមប្រាប់អ្នកផ្តល់សេវាថែទាំ និង អ្នកសង្កេតការណ៍អំពីករណីដែលអ្នកបានជ្រើសរើស ។ ដូចពេលមុនដែរអ្នកត្រូវ ឆ្លើយតបទៅនឹងអ្វីដែលអ្នកផ្តល់សេវាថែទាំសួរអ្នកឱ្យបានដូចជារឿងពិត និងស្មោះត្រង់ជាទីបំផុត ទៅតាមលទ្ធភាព ។ សូមកុំបង្កលក្ខណៈងាយ ឬលំបាកពេកសំរាប់គាត់ ។

ក្រោយពីដើរតួរួច អ្នកគឺជាអ្នកទី១ដែលត្រូវផ្តល់ពត៌មានត្រលប់ទៅអ្នកផ្តល់សេវាថែទាំវិញ។ សូមចាប់ផ្តើមពីការប្រាប់គាត់អំពីអារម្មណ៍ដែលអ្នកមាន នៅពេលនេះ និងមុនពេលធ្វើសំភាសន៍ ហើយ សូមរំលឹកឡើងវិញនូវចំណុចសំខាន់ៗនៅពេលធ្វើលំហាត់ ពេលដែលមតិយោបល់របស់អ្នកផ្តល់សេវាថែទាំជួយឬបន្ទុចបង្អាក់ដល់ការឆ្លើយតបរបស់អ្នកដោយប្រការណាមួយ ។

នៅពេលដែលអ្នកផ្តល់សេវាថែទាំ និងអ្នកសង្កេតការណ៍ពិនិត្យមើលឡើងវិញនូវលំហាត់នេះ សូមបន្ថែមនូវគំនិតសំខាន់ៗនានាដែលអ្នកមានចំពោះអាកប្បកិរិយារបស់អ្នកផ្តល់សេវាថែទាំ ។ មកដល់ត្រង់នេះ ត្រូវលៃយ៉ាងណាឱ្យការផ្តល់យោបល់របស់អ្នកមានលក្ខណៈវិជ្ជមាន ហើយអាចជួយអ្នកផ្តល់សេវាថែទាំឱ្យបង្កើននូវភាពស្ទាត់ជំនាញរបស់គាត់ផងដែរ ។

## ការដើរតួជាអ្នកផ្តល់សេវាថែទាំ

ដូចក្នុងជំពូកទី៥ដែរ តួនាទីរបស់អ្នកគឺត្រូវផ្តល់ពត៌មានត្រលប់មកវិញលើភាពស្ទាត់ជំនាញដែលអ្នកមាននាពេលបច្ចុប្បន្ន និងចំណុចដែលអ្នកធ្វើបានកាន់តែល្អប្រសើរជាងមុន ។

ក្នុងពេលដើរតួ សូមប្រើប្រាស់នូវភាពស្ទាត់ជំនាញដូចគ្នានឹងពេលមុនដែរ ដើម្បីលើកទឹកចិត្តអ្នកជំងឺឱ្យបញ្ជូនដៃគូរួមភេទរបស់គាត់មកទទួលការព្យាបាល ។ អ្នកអាចពិនិត្យឡើងវិញនូវបញ្ជីវាយតំលៃសំរាប់អ្នកសង្កេតការណ៍ដែលមាននៅក្នុងទំព័រទី២៩ ដើម្បីជួយឱ្យចងចាំនូវអ្វីដែលអ្នកត្រូវសង្កេត ។

ក្រោយពេលដើរតួ សូមឱ្យអ្នកជំងឺផ្តល់ឱ្យអ្នកនូវយោបល់ត្រលប់មកវិញ ស្តីអំពីអារម្មណ៍ដែលគាត់មានក្នុងពេលសំភាសន៍ ។ បន្ទាប់មក សូមប្រាប់អំពីមតិ និងអារម្មណ៍របស់អំពីដំណើរការនៃការអប់រំ ។

នៅទីបញ្ចប់ អ្នកសង្កេតការណ៍ត្រូវផ្តល់នូវយោបល់ត្រលប់មកវិញ ដោយពឹងផ្អែកលើបញ្ជីត្រួតពិនិត្យដែលគាត់ប្រើប្រាស់ ។ សូមកុំខ្លាចក្នុងការសុំឱ្យអ្នកជំងឺនិងអ្នកសង្កេតការណ៍បំភ្លឺអំពីអ្វីដែលគាត់បាននិយាយ ។ អ្នកមានបំណងបញ្ចប់ល្បែងដើរតួដោយមានកម្មវត្ថុ ដែលមានសារៈប្រយោជន៍ និងការបញ្ជាក់ឱ្យដឹងអំពីចំណុចខ្លាំងរបស់អ្នក ។

## ការដើរតួជាអ្នកសង្កេតការណ៍

តួនាទីរបស់អ្នកគឺត្រូវសង្កេតមើលផ្នែកចុងក្រោយនៃបទសំភាសន៍ដោយប្រុងប្រយ័ត្នធ្វើយ៉ាងណា ឱ្យអ្នកអាចផ្តល់មតិយោបល់ច្បាស់លាស់ឥតលំអៀងមកអ្នកផ្តល់សេវាថែទាំវិញលើអ្វីដែលគាត់សំរេចបាន ។

សូមអានបញ្ជីត្រួតពិនិត្យនៅទំព័រទី ៣០ ដើម្បីឱ្យដឹងអំពីភាពស្ទាត់ជំនាញ និងបញ្ហានានាដែលអ្នកផ្តល់សេវាថែទាំត្រូវយកមកប្រើ ។

កំណត់ពេលវេលានៃការធ្វើសំភាសន៍ ដោយបញ្ចប់វាក្នុងរយៈពេលបីនាទី ក្រោយពីមានការពិភាក្សាអំពីការបញ្ជូនដៃគូរួមភេទឱ្យមកទទួលការព្យាបាលរួច ។ នៅពេលដែលអ្នកសង្កេតមើល សូមកត់ត្រាទុកនូវភាពស្ទាត់ជំនាញនានា ដែលអ្នកឃើញអ្នកផ្តល់សេវាថែទាំយកមកប្រើប្រាស់ និងប្រសិទ្ធិភាពក្នុងការប្រើប្រាស់ភាពស្ទាត់ជំនាញទាំងនោះ ។

សូមឱ្យអ្នកជំងឺពិនិត្យមើលការសំភាសន៍មុនគេ ហើយបន្ទាប់មកសូមឱ្យអ្នកផ្តល់សេវាមានយោបល់ ។ សូមចាប់ផ្តើមផ្តល់មតិរបស់អ្នកត្រលប់ទៅវិញដោយឆ្លើយតបដោយសង្ខេបទៅនឹងស្វ័យទិទៀនរបស់អ្នកផ្តល់សេវាថែទាំ ហើយបន្ទាប់មក អ្នកត្រូវផ្តល់នូវយោបល់ផ្ទាល់ខ្លួនរបស់អ្នកត្រលប់ទៅវិញ (អាចផ្តល់គំនិតមួយម្តងឬតាមរបៀបផ្សេងទៀតធ្វើយ៉ាងណាមួយបានសមស្រប) ។ សូមផ្តល់នូវការទិទៀនដែលមានលក្ខណៈអវិជ្ជមាន បើចាំបាច់ក៏ប៉ុន្តែសូមធ្វើការសង្កត់ធ្ងន់លើសមិទ្ធិផលល្អៗ របស់អ្នកផ្តល់សេវាថែទាំ និងធ្វើយ៉ាងណាឱ្យមានលក្ខណៈជាក់ស្តែងអាចយកទៅអនុវត្តបានទៅតាមលទ្ធភាពរបស់អ្នក ។

នៅទីបញ្ចប់ សូមដឹកនាំការពិភាក្សាអំពីបទពិសោធន៍អ្វីដែលអ្នកទទួលបានអំពីល្បែងដើរតួនេះ ។ បញ្ហាសំខាន់ៗដែលពុំបានលើកឡើងមកពិភាក្សានៅក្នុងម៉ូឌុលនេះអាចលេចចេញមកនៅពេលនេះ ។

| បញ្ជីត្រួតពិនិត្យសំរាប់ប្រើប្រាស់ក្នុងការសង្កេតក្នុងលំហាត់ទី៦.៥ | |
|---|---|
| **តើអ្នកផ្តល់សេវាថែទាំមានៈ** | **សូមប្រើផ្នែកនេះសំរាប់កត់ត្រា** |
| ***លើកនូវបញ្ហាទាំងនេះដែរឬទេ ?***<br>• ជំងឺកាមរោគ ផលវិបាកនិងការព្យាបាលរបស់វា សារៈសំខាន់ក្នុងការគោរពតាមវេជ្ជបញ្ជា<br>• កំរិតប្រឈមមុខនឹងគ្រោះថ្នាក់របស់អ្នកជំងឺ<br>• តំរូវការក្នុងការផ្លាស់ប្តូរប្រព្រឹត្តរួមភេទ និងការរួមភេទ ដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ | |
| ***ប្រើប្រាស់នូវភាពស្ទាត់ជំនាញទាំងនេះដែរឬទេ ?***<br>• ការពន្យល់ និងបង្ហាត់បង្ហាញ<br>• ការលើកជាគំរូ<br>• ការពង្រឹងចំណុចខ្លាំង<br>• ការពិនិត្យមើលការជ្រើសរើស<br>• ការនិយាយរំលឹកអំពីការសំរេចចិត្តឡើងវិញ<br>• ការបញ្ជាក់ឱ្យបានច្បាស់អំពីការសំរេចចិត្ត | |
| ***ប្រើភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងមកអនុវត្តដែរឬទេ ?***<br>• សំណួរបើក<br>• ការជួយសំរួល<br>• ការសង្ខេបឡើងវិញ និងការពិនិត្យផ្ទៀងផ្ទាត់<br>• ការធានាអះអាង<br>• ការដឹកនាំ<br>• ការយល់អារម្មណ៍<br>• បង្ហាញភាពជាដៃគូ | |

## ចំលើយ

### ៦.១ សំណួរ

ក. គោលការណ៍ទាំងពីរដែលយើងត្រូវយកមកគិតនោះគឺការគ្រប់គ្រងថៃទាំដៃគូរួមភេទ ត្រូវមានលក្ខណៈ*រក្សាការសំងាត់និងស្ម័គ្រចិត្ត* ។ ត្រូវរក្សាការសំងាត់ឱ្យអ្នកជំងឺ និងដៃគូរបស់គាត់ មិនត្រូវបង្ខំឱ្យធ្វើអ្វីមួយដែលគេមិនចង់ធ្វើទេ ។ គោលការណ៍ទាំងពីរនេះមានសារៈសំខាន់ណាស់សំរាប់វិធីគ្រប់គ្រងថៃទាំដៃគូរួមភេទរបស់អ្នកជំងឺ ។

ខ. ចំលើយរបស់អ្នកអាចខុសពីចំលើយដែលផ្តល់ជូននៅទីនេះ ជាពិសេសគឺនៅពេលដែលមណ្ឌលសុខភាពរបស់អ្នកបានប្រើវិធីមួយ ឬទាំងពីររួចស្រេចទៅហើយនេះ ។ ប្រសិនបើដូច្នេះមែន សូមប្រើប្រាស់នូវគំនិតខាងក្រោមនេះជាមូលដ្ឋាននៃការពិភាក្សា ។

| | **គុណសម្បត្តិ** | **គុណវិបត្តិ** |
|---|---|---|
| ការបញ្ជូនដោយអ្នកជំងឺ | • អ្នកជំងឺម្ចាស់ការលើការបញ្ជូន (ដូច្នេះមានការរក្សាការសំងាត់ និងស្ម័គ្រចិត្ត)<br>• មណ្ឌលសុខភាពពុំបាច់ចំណាយលើការបញ្ជូនទេ ។ ប្រសិនបើបានជោគជ័យនោះ គេអាចហៅដៃគូបានកាន់តែច្រើនឱ្យមកទទួលការព្យាបាល(ដូច្នេះកាន់តែមានប្រសិទ្ធិភាព) ។ | • ក្នុងករណីខ្លះដៃគូរួមភេទពុំអាចត្រូវបានបញ្ជូនមកឱ្យបានរហ័សទេ ។ |
| ការបញ្ជូនដោយអ្នកផ្តល់សេវាថៃទាំ | • មិនពឹងផ្អែកទៅលើសមត្ថភាពក្នុងការបញ្ជូនដៃគូរួមភេទរបស់អ្នកជំងឺទេ ។<br>• អ្នកផ្តល់សេវាថៃទាំផ្តល់នូវការគាំទ្រភ្លាមៗដល់អ្នកជំងឺ | • ពឹងផ្អែកលើឆន្ទៈរបស់អ្នកជំងឺក្នុងការប្រាប់ឈ្មោះដៃគូ<br>• ត្រូវចំណាយពេលវេលាប្រាក់កាស ហើយមានបញ្ហាក្នុងការបញ្ជូនដៃគូក្នុងការអនុវត្តជាក់ស្តែង<br>• អ្នកអាចយល់ថាជាការប៉ះពាល់ដល់ការរក្សាការសំងាត់ |

អ្នកប្រហែលជាយល់ស្របថាផ្នែកលំបាកបំផុតនៃសំណួរនេះគឺការកំណត់អំពីផលប្រយោជន៍ល្អៗនៃការបញ្ជូនដោយអ្នកផ្ដល់សេវាថែទាំ ។ ការបញ្ជូនដោយអ្នកផ្ដល់សេវាថែទាំអាចហៅដៃគូបានច្រើនឱ្យមកទទួលការការព្យាបាល ក៏ប៉ុន្តែវាអាចប៉ះពាល់ដល់ការរក្សាសំងាត់ ។ ការរកឱ្យឃើញដៃគូរួមភេទរបស់អ្នកជំងឺអាចជួបនឹងការលំបាក ទោះបីជាគេស្គាល់ឈ្មោះអ្នកទាំងនោះក្ដី ហើយអ្នកផ្ដល់សេវាថែទាំដែលខិតខំស្វែងរកអ្នកជំងឺណាម្នាក់នោះនឹងត្រូវបានគេស្គាល់យ៉ាងឆាប់ នៅក្នុងសហគមន៍មួយដែលមនុស្សគ្នា យ៉ាងជិតស្និទ្ធនោះ ។ បន្ទាប់មកគឺមានបញ្ហាលិខិតស្នាមទៀត ។

## ៦.២ សំណួរ

យើងសង្ឃឹមថា អ្នកច្បាស់ជាយល់ឃើញថាការរំលឹកសាជាថ្មីឡើងវិញ ពិតជាមានសារៈប្រយោជន៍ ។ កំណត់ត្រារបស់យើងខាងក្រោមនេះពន្យល់អំពីភាពស្ទាត់ជំនាញនានាដែលយើងយល់ថាអ្នកផ្ដល់សេវាថែទាំត្រូវយកមកប្រើប្រាស់ ។ សូមពិភាក្សាអំពីការវិភាគរបស់អ្នកជាមួយសហសេវិក ឬអ្នកបណ្ដុះបណ្ដាលរបស់អ្នក ប្រសិនបើអ្នកមិនយល់ច្បាស់លើបញ្ហាណាមួយនោះ ។

| | | |
|---|---|---|
| គន្ធា ៈ | ខ្ញុំពុំអាចនិយាយអ្វីប្រាប់គាត់បានទេ ។ គាត់នឹងស្តីបន្ទោសឱ្យខ្ញុំ... ខ្ញុំដឹងច្បាស់ណាស់ថាគាត់នឹងស្តីបន្ទោសឱ្យខ្ញុំ ។ ប៉ុន្តែខ្ញុំត្រូវគិតអំពីអនាគតគ្រួសារខ្ញុំ... គាត់នឹងបន្ទោសឱ្យខ្ញុំ ទោះបីជាការកើតជំងឺនេះពុំមែនជាកំហុសរបស់ខ្ញុំក្តី ... | |
| អ្នកផ្តល់សេវាថែទាំៈ | លោកស្រីមានការភ័យខ្លាចណាស់ ក្នុងការប្រាប់គាត់អំពីអំពើដែលគាត់បានប្រព្រឹត្ត ។ | *អ្នកផ្តល់សេវាថែទាំផ្ទៀងផ្ទាត់មើលថាគាត់យល់អារម្មណ៍របស់គន្ធាដែរឬទេ។* |
| គន្ធា ៈ | ចាស៎ ...... ត្រូវហើយ ។ | |
| អ្នកផ្តល់សេវាថែទាំៈ | ខ្ញុំឃើញហើយថាអ្នកស្រីមានការអស់សង្ឃឹមយ៉ាងខ្លាំងចំពោះរឿងនេះ ហើយខ្ញុំសូមគាំទ្រអ្នកស្រី ។ អ្នកស្រីគិតត្រូវក្នុងការមកជួបខ្ញុំម្តងទៀត អ្នកពិតជាមានបំណងដោះស្រាយបញ្ហានេះធ្វើយ៉ាងណាដើម្បីឱ្យប្តីអ្នកស្រីមកទទួលការព្យាបាល ។ | អ្នកផ្តល់សេវាបង្ហាញពីការយល់អារម្មណ៍ ។ គាត់ធ្វើការពង្រឹងចំណុចខ្លាំងដែលគន្ធាមាន ដោយសរសើរអំពីការគិតត្រឹមត្រូវនិងការយល់ដឹងអំពីកាមរោគ ។ គាត់ជួយឱ្យគន្ធាមានសុទិដ្ឋិនិយមក្នុងការដោះស្រាយបញ្ហា ។ |
| គន្ធា ៈ | ក៏ប៉ុន្តែខ្ញុំពុំអាចនិយាយអ្វីប្រាប់គាត់បានទេ ...... | |
| អ្នកផ្តល់សេវាថែទាំៈ | អញ្ចឹងមានរឿងពីរដែលអាចធ្វើបាន ។ អ្នកស្រីសុំឱ្យគាត់មកកាន់គ្លីនិក ពីព្រោះគាត់ អាចមានជំងឺដូចអ្នកស្រីដែរ ឬអ្នកស្រីអាចសុំឱ្យអ្នកណាម្នាក់ទៀតទៅនិយាយប្រាប់គាត់ ។ តើអ្នកស្រីពេញចិត្តការជ្រើសរើសណាមួយ ? | គឺជាការពិនិត្យមើលជំរើសនានា ដើម្បីជួយឱ្យគន្ធាជ្រើសរើសយកដំណោះស្រាយដែលសមស្របបំផុត ។ |
| គន្ធា ៈ | តើខ្ញុំគ្រាន់តែនិយាយប្រាប់គាត់ថាគាត់គួរតែមកទីនេះដើម្បីធ្វើការត្រួតពិនិត្យសុខភាពបានដែរឬទេ ? | |
| អ្នកផ្តល់សេវាថែទាំៈ | ចាស៎ គ្រាន់តែធ្វើប៉ុណ្ណឹងបានហើយ ។ ចាំខ្ញុំធ្វើអ្វីផ្សេងៗទៀតជាបន្ត ។ ប្រសិនបើខ្ញុំឱ្យប័ណ្ណនេះទៅអ្នកស្រី តើអ្នកស្រីអាចប្រាប់គាត់ឱ្យយកវាមកជាមួយបានដែរ ឬទេ? | អ្នកផ្តលសេវាថែទាំបង្ហាញពីភាពជាដៃគូដើម្បីដោះស្រាយបញ្ហា ។ |
| គន្ធា ៈ | ហើយអ្នកអាចព្យាបាល រួចប្រាប់គាត់អំពីមូលហេតុដែលតំរូវឱ្យគាត់ទទួលការព្យាបាលឬ? | |
| អ្នកផ្តល់សេវាថែទាំៈ | ចាស៎ ខ្ញុំប្រាកដជានឹងធ្វើរឿងនេះហើយប្រាប់គាត់ ។ តើអ្នកស្រីនឹងនិយាយអ្វីខ្លះប្រាប់គាត់? | អ្នកផ្តល់សេវាថែទាំឱ្យគន្ធានិយាយឡើងវិញនូវអ្វីដែលនាងត្រូវនិយាយធ្វើរបៀបនេះនាងអាចគិតទុកជាមុនដែលនាងនឹងត្រូវនិយាយប្រាប់ដៃគូរបស់គាត់ ។ |
| គន្ធា ៈ | អ៊ី...ខ្ញុំនឹងនិយាយថាគាត់អាចកើតកាមរោគដូចខ្ញុំដែរ ហើយសួរគាត់ថាតើគាត់អាចកាន់ប័ណ្ណនេះទៅកាន់គ្លីនិកជាមួយគាត់បានដែរឬទេ ? | |

សូមគត់សំគាល់ថាដំណោះស្រាយបញ្ហានៃការសិក្សាករណីនៅទំព័រទី ១០ ខុសប្លែកពីការសិក្សាករណីនេះ ។ នៅក្នុងការសិក្សាករណីលោក ណារិទ្ធ មានការលើកទឹកចិត្តឱ្យគាត់និយាយប្រាប់ដៃគូរបស់គាត់ដោយខ្លួនឯង មានការពិភាក្សាអំពីអ្វីដែលគាត់ចង់ធ្វើ ក្រោយពីអ្នកផ្តល់សេវាថែទាំបានជួយគាត់ឱ្យជំនះឧបសគ្គខ្មាសអៀនរួចមក ។ អ្នកជំងឺជាច្រើននឹងមានឆន្ទៈធ្វើដូចគ្នានេះដែរ ប្រសិនបើអ្នកធ្វើការអប់រំ និងគាំទ្រពួកគេបានត្រឹមត្រូវនោះ ដូច្នេះការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំនឹងមានប្រសិទ្ធិភាព ។

ក៏ប៉ុន្តែ អ្នកជំងឺខ្លះដូចជានាងគន្ធាជាដើម យល់ថាពុំអាចពិភាក្សាអំពីជំងឺកាមរោគ ឬការរួមភេទដែលមានសុវត្ថិភាពជាមួយដៃគូរួមភេទរបស់ខ្លួនបានទេ ។ ក្នុងស្ថានភាពបែបនេះមានជំរើសមួយទៀតក្នុងការទុកឱ្យអ្នកផ្តល់សេវាថែទាំធ្វើការអប់រំជំនួស ឬការសុំឱ្យមិត្តភក្តិ ឬសមាជិកគ្រួសារណាម្នាក់និយាយប្រាប់ដៃគូនោះ ទើបអាចមានប្រសិទ្ធិភាព ។

## ៦.៤ សំណួរ

### តើត្រូវព្យាបាលជំងឺអ្វីឱ្យស្ត្រីវ័យក្មេងនោះ ?

ក៏ដូចករណីដៃគូរួមភេទដទៃៗទៀតដែរ គេត្រូវផ្តល់ការព្យាបាលជំងឺឱ្យស្ត្រីវ័យក្មេងនោះដូចការព្យាបាលសង្សាររបស់គាត់ដែលជាអ្នកជំងឺដើមដំបូងដែរ ។ ក្នុងករណីនេះ សង្សាររបស់នាងមានដំបៅនៅនឹងប្រដាប់បន្តពូជ ដូច្នេះគេត្រូវព្យាបាលដំបៅនៅនឹងប្រដាប់បន្តពូជឱ្យនាងដែរ ។

### តើគួរពិនិត្យស្ត្រីវ័យក្មេងនោះដែរឬទេ ?

ការពិនិត្យពុំចាំបាច់ទេ ពីព្រោះអ្នកមានបំណងព្យាបាលនាង ទោះជាក្នុងករណីណាក៏ដោយ ។ ក៏ប៉ុន្តែ អ្នកអាចពិចារណាឃើញថា ជាការសំខាន់គឺត្រូវពិនិត្យរកមើលក្រែងមានសញ្ញាកាមរោគផ្សេងៗទៀត ហើយអ្នកជំងឺក៏អាចចង់ឱ្យអ្នកធ្វើការពិនិត្យផងដែរ ។

ការគ្រប់គ្រងថែទាំជំងឺកាមរោគ
សំរាប់ស្ត្រីរកស៊ីផ្លូវភេទ

# អក្ខរានុក្រមនៃជំងឺកាមរោគ
# ( STD GLOSSARY )

# អក្ខរានុក្រមនៃជំងឺកាមរោគ ( STD GLOSSARY )

| | |
|---|---|
| AIDS/ ជំងឺអេដស៍ | ចង្កោមរោគសញ្ញាទាំងឡាយដែលកើតឡើងក្រោយពេលដែលប្រព័ន្ធភាពស៊ាំសារពាង្គកាយចុះខ្សោយ ។ |
| Amniotic sac/ ថង់ទឹកភ្លោះ | គឺជាភ្នាសម្យ៉ាងដែលស្រោបពីក្រៅទឹកភ្លោះនិងទារកក្នុងផ្ទៃដែលស្ថិតនៅក្នុងស្បូន ។ |
| Anaerobic bacteria/ បាក់តេរីអាណាអេរ៉ូប៊ី | គឺជាមូលហេតុដែលបង្កជំងឺរលាកប៉េលវីស (PID); បាក់តេរី ( ជាធម្មតាគឺជំពូកបាក់តេរ៉ូអ៊ីត ) នេះមិនត្រូវការអុកស៊ីហ្សែនដើម្បីរស់ ។ |
| *Candida albicans* / *ផ្សិតកង់ឌីដាស់* | ឈ្មោះវិទ្យាសាស្ត្រនៃផ្សិតម៉្យាង ។ វាគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុទាំងឡាយដែលបង្កជាជំងឺរលាកទ្វារមាស ។ |
| Candidiasis | គឺជាទំរង់មួយនៃជំងឺរលាកទ្វារមាសបណ្តាលមកពីពពួកផ្សិតម៉្យាងហៅថា *Candida albicans* ។ |
| Cervicitis / ការរលាកមាត់ស្បូន | គឺជាជំងឺរលាកមាត់ស្បូន ដែលជាញឹកញាប់បណ្តាលមកពីមេរោគហ្គោណូកូក ឬមេរោគ Chlamydia ។ |
| Cervix / មាត់ស្បូន | គឺជាផ្នែកក្រោមនៃស្បូន ដែលលយចូលទៅក្នុងទ្វារមាស ។ |
| Chancroid / ជំងឺសង់មូ ( Chancre mou ) | គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុទាំងឡាយ ដែលបង្កឱ្យមានដំបៅលើប្រដាប់បន្តពូជ ។ ជំងឺកាមរោគនេះបណ្តាលមកពីបាក់តេរីឈ្មោះ *Haemophilus ducreyi* ។ |
| Chlamydia | គឺជាពាក្យទូទៅរួមមួយសំរាប់សំគាល់ការចំលងរោគដោយមេរោគ *Chlamydia trachomatis* ( សូមមើលពាក្យ *Chlamydia trachomatis* ) |
| *Chlamydia trachomatis* | ជាពាក្យវិទ្យាសាស្ត្រសំរាប់សំគាល់មេរោគម្យ៉ាងដែលបង្កជាជំងឺដែលបង្កដោយមេរោគក្លាមីឌីយ៉ា ( *Chlamydia* ) ។ វាជាមូលហេតុមួយក្នុងចំណោមមូលហេតុទាំងឡាយដែលបង្កឱ្យមានការហូរខ្ទុះតាមទ្វារមាស ហូរខ្ទុះតាមបង្ហួរនោម និង ហូរខ្ទុះតាមភ្នែកទារកទើបនឹងកើត ។ |
| Clinical diagnosis / រោគវិនិច្ឆ័យគ្លីនិក | គឺការប្រើប្រាស់បទពិសោធន៍គ្លីនិកដើម្បីរកឱ្យឃើញជំងឺកាមរោគ ។ |

| | |
|---|---|
| Clinical box / ប្រអប់គ្លីនិក | គឺជាប្រភេទនៃប្រអប់ក្នុងគំនូសបំព្រួញស្តីពីការព្យាបាលជំងឺកាមរោគ ដែលប្រាប់អំពីរោគសញ្ញាមួយចំនួននៃចង្កោមរោគសញ្ញាពិសេសណាមួយ ។ |
| Closed questions / សំណួរបិទ | គឺជាសំណួរដែលទាមទារឱ្យឆ្លើយតែមួយ ឬ ពីរម៉ាត់ ឧទាហរណ៍: តើអ្នករៀបអាពាហ៍ពិពាហ៍ហើយឬនៅ ? (សូមប្រៀបធៀបជាមួយសំណួរបើក ) ។ |
| Complications / ផលវិបាក | គឺជាលក្ខខណ្ឌមួយផ្សេងដែលកើតមានឡើង ក្រោយពេលដែលគេពុំព្យាបាលជំងឺដើម ។ |
| Comprehensive care / ការថែទាំដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ | គឺការព្យាបាលជំងឺកាមរោគដោយរួមបញ្ចូលទាំងការអប់រំ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបទបញ្ជូន និង ការថែទាំជំងឺឱ្យដៃគូរួមភេទ ។ |
| Congenital syphilis / ជំងឺស្វាយពីកំណើត | គឺជាជំងឺស្វាយឆ្លងពីម្តាយទៅកូនក្នុងពេលមានផ្ទៃពោះ ។ |
| Conjunctivitis | គឺការរលាកភ្នាសស្តើងនៃភ្នែក និង ត្របកភ្នែក ។ |
| Culture techniques / បច្ចេកទេសបណ្តុះមេរោគ | គឺការបណ្តុះមេរោគក្នុងឧបករណ៍បណ្តុះមេរោគដែលបានរំងាប់មេរោគត្រឹមត្រូវ ហើយដែលអាចឱ្យគេរកឃើញមេរោគដែលត្រូវបណ្តុះនោះ ។ |
| Direction / ការដឹកនាំ | គឺជាភាពស្ទាត់ជំនាញម្យ៉ាង ក្នុងចំណោមភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងក្នុងការនិយាយស្តីតាំង ៦ ដែលសុំឱ្យអ្នកជំងឺផ្តោតទៅលើគំនិតមួយម្តងៗ ។ |
| Dysuria / ការពិបាកនោម | គឺជាការឈឺចាប់ ឬ ពិបាកបន្ទោរបង់ទឹកនោម ។ |
| Ectopic pregnancy / គភ៌ក្រៅស្បូន | គឺការមានផ្ទៃពោះក្រៅស្បូន (ជាធម្មតាច្រើនកើតនៅក្នុងដៃស្បូន; ជាកាយលក្ខណៈមួយគំរាមកំហែងអាយុជីវិតហើយដែលអាចបណ្តាលឱ្យមានហូរឈាមខ្លាំងក្លានៅក្នុងពោះ ។ |
| Efficacy / ប្រសិទ្ធិភាព | គឺជាកំរិតនៃភាពសក្តិសិទ្ធិនៃព្យាបាល |
| Efficacy of transmission / ប្រសិទ្ធិភាពចំលងរោគ | គឺជាលទ្ធភាពដែលការប៉ះពាល់ជាមួយភ្នាក់ងារចំលងមេរោគណាមួយ ធ្វើឱ្យកើតមានជាជំងឺ ។ |
| Empathy / ការយល់អារម្មណ៍ | គឺជាភាពស្ទាត់ជំនាញមួយ ក្នុងចំណោមភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដោយការនិយាយស្តីតាំង៦យ៉ាង ដែលសំដែងអំពីការយល់ពីស្ថានភាពអ្នកជំងឺហើយចាត់ទុកថាជាមធ្យោបាយមួយជួយលើកទឹកចិត្តគាត់ឱ្យសំដែងនូវភាពខ្វល់ខ្វាយទាំងឡាយ ។ |

| | |
|---|---|
| Endometritis / ការរលាកស្រទាប់ខាងក្នុងនៃស្បូន | គឺជាការរលាកស្រទាប់ខាងក្នុងបង្អស់នៃស្បូនដែលហៅថា endometrium ។ |
| Epidemiology / អេពីដេមីសាស្ត្រ | គឺជាការសិក្សាអំពីអត្រាអាំងស៊ីដង់ ការបែងចែក និង មូលហេតុផ្សេងៗនៃជំងឺ ឬ ការចំលងរោគណាមួយនៅក្នុងចំណោមប្រជាជន។ |
| Epididymis / អេពីឌីឌីម | គឺជាបំពង់មួយនៅផ្នែកខាងក្រោយពងស្វាសដែលតភ្ជាប់ពងស្វាសទៅបំពង់ទឹកកាម។ |
| Epididymitis / ការរលាកអេពីឌីឌីម | គឺការរលាកអេពីឌីឌីម ដែលជាធម្មតាបណ្តាលមកពីជំងឺប្រមេះទឹកបាយ(Gonorrhoea) ឬ ជំងឺរលាកបង្ហូរនោមដោយមេរោគក្លាមីឌីយ៉ា (Chlamydia infection )។ |
| Etiologies / មូលហេតុនៃជំងឺ | គឺជាភ្នាក់ងារចំលងរោគ ។ |
| Facilitation / ការជួយសំរួល | គឺជាភាពស្ទាត់ជំនាញមួយ ក្នុងចំណោមភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដោយការនិយាយស្តីទាំង៦យ៉ាង ដោយប្រើប្រាស់ពាក្យពេជន៍ ឃ្លាប្រយោគ ឬ សំលេងដើម្បីជួយលើកទឹកចិត្តដល់អ្នកជំងឺឱ្យបន្តអធិប្បាយជាបន្តទៀត ។ |
| Fallopian tubes / ដៃស្បូន | គឺជាបំពង់ដៃស្បូន ដែលនាំអូវុលពីអូវែទៅកាន់ស្បូន ។ |
| Fistula / ការធ្លាយ | គឺជាដំណើរឆ្លងកាត់មិនប្រក្រតីនៃសរីរាង្គប្រហោងចេញមកកាន់ផ្ទៃស្បែក។ |
| Flow-chart / គំនូសបំព្រួញ | គឺជារូបភាពដែលបង្ហាញពីជំហាននានា ដែលត្រូវអនុវត្តតាមដើម្បីបំពេញនូវភារៈកិច្ចអ្វីមួយ។ |
| *Gardnerella vaginalis* | គឺជាឈ្មោះមេរោគម្យ៉ាងបង្កឱ្យរលាកទ្វារមាស ( vaginitis ) ។ |
| Genital lesions | គឺជាស្នាមដំបៅលើស្បែក ឬ របួសនៅតំបន់ប្រដាប់បន្តពូជ ។ |
| Genital ulcer disease (GUD) / ជំងឺដំបៅនៅលើប្រដាប់បន្តពូជ | គឺជាឈ្មោះចង្កោមរោគសញ្ញាមួយដែលមានដំបៅនៅតំបន់ប្រដាប់បន្តពូជហើយជារឿយៗ វាបណ្តាលមកពីជំងឺស្វាយ ( Syphilis ) និងជំងឺ Chancroid ។ |
| Glans penis / ក្បាលលិង្គ | គឺជាផ្នែករាងមូល បង្កើតបានជាចុងលឹង្គ ។ |
| Glycerin / ប្រេងគ្លីសេរីន | ជាប្រេងមានជាតិទឹក គ្មានពណ៌ និងអាចយកទៅប្រើលាបស្រោមអនាម័យ ។ |
| Gonorrhoea / ជំងឺប្រមេះទឹកបាយ | គឺជាពាក្យទូទៅប្រើចំពោះជំងឺដែលបង្កឡើងដោយមេរោគ Neisseria gonorrhoeae |

Gram stain / ការបំពាក់ពណ៌ក្រាម

គឺជាបច្ចេកទេសមន្ទីរពិសោធន៍ប្រើប្រាស់ដើម្បីស្រាវជ្រាវរកមេរោគបាក់តេរី ។

Guarding / ការកន្ត្រាក់រឹងនៃសាច់ដុំពោះ

នៅពេលធ្វើការពិនិត្យស្ត្រីដែលមានការឈឺចាប់ផ្នែកខាងក្រោមនៃពោះភាពរឹងនៃពោះ គឺជាលក្ខខណ្ឌមួយដែលគេរកឃើញនៅពេលសាច់ដុំពោះឡើងរឹង ហើយមិនអាចឱ្យអ្នកសង្កត់ពោះបាន ។ ជាធម្មតាវាជាសញ្ញានៃការរលាកស្រោមពោះឬសញ្ញានៃការបង្កខ្ទុះក្នុងពោះ ។ ជំងឺទាំងពីរនេះគឺជាលក្ខខណ្ឌដ៏ធ្ងន់ធ្ងរដែលអាចគំរាមកំហែងដល់អាយុជីវិត ។

GUS

គឺជាអក្សរកាត់សំរាប់ចង្កោមរោគសញ្ញាដំបៅលើប្រដាប់បន្តពូជ ។ ជួនកាលគេហៅថាជំងឺដំបៅលើប្រដាប់បន្តពូជ GUD ។

Herpes / ជំងឺដំបៅពងបែក

គឺជាមូលហេតុញឹកញាប់មួយនៃការបង្កឱ្យមានពងទឹក និង ដំបៅនៅលើប្រដាប់បន្តពូជ វាគឺជាជំងឺកាមរោគមួយបែបដែលបណ្តាលមកពីមេរោគវីរុស *Herpes simplex virus ( HSV )* ។

HIV / មេរោគអេដស៍

គឺជាអក្សរកាត់សំគាល់មេរោគវីរុសដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយ ហើយ ជាមូលហេតុនៃជំងឺអេដស៍ ។

Inguinal bubo(es) / ការហើមក្រលៀន

គឺជាឈ្មោះនៃចង្កោមរោគសញ្ញាដែលក្នុងនោះអ្នកជំងឺត្អូញត្អែរថាមានការឈឺចាប់យ៉ាងខ្លាំង កន្លែងហើមប៉ោងត្រង់ផ្នែកលើក្រលៀនបន្តិច ជាធម្មតាបណ្តាលមកពីជំងឺទាមឡា ឬ Chancroid ។

Inguinal hernia / ក្លូន

គឺការរហែកជញ្ជាំងសាច់ដុំនៅតំបន់គ្រលៀនធ្វើឱ្យសរីរាង្គនៅខាងក្នុងពោះផ្លាស់ប្តូរទីកន្លែងចូលទៅតាមកន្លែងដែលរហែកនោះ ។

K-Y Jelly

គឺជាប្រេងមានជាតិទឹកមានសភាពខាប់ដូចចាហួយ ហើយអាចយកវាទៅប្រើដើម្បីលាបលើស្រោមអនាម័យដោយគ្មានគ្រោះថ្នាក់ ។

Lympho-granuloma venereum (LGV) / ជំងឺទាមឡា

គឺជាជំងឺកាមរោគបង្កដោយបាក់តេរីឈ្មោះ *Chlamydia trachomatis* ។ វាគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុទាំងឡាយនៃជំងឺដំបៅលើប្រដាប់បន្តពូជ និងនៃការហើមក្រលៀន ។

Lower abdominal pain/ ការឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ

គឺជាឈ្មោះចង្កោមរោគសញ្ញា ក្នុងនោះស្ត្រីត្អូញត្អែរពីការឈឺចាប់នៅផ្នែកក្រោមនៃពោះ ហើយការឈឺចាប់កើតមានជាញឹកញាប់ តែមិនជាប់ជានិច្ចទេ គឺបណ្តាលមកពីជំងឺរលាកប៉ែលវិស (PID) ។

| | |
|---|---|
| Lymph nodes / កូនកណ្តុរ | គឺជាបណ្តុំតូចៗជាច្រើននៃជាលិកាដែលបង្កើតជាផ្នែកមួយនៃប្រព័ន្ធទឹករងៃ ។ |
| Mass / ដុំសាច់ | គឺជាបណ្តុំនៃជាលិកា ( ជារឿយៗ ជាប្រភេទមហារីក) ។ |
| Menses / ការមានរដូវ | គឺជាការធ្លាក់ឈាមលាយជាមួយកំទេចកំទីជាលិកាស្បូនដែលហូរមកពីស្បូននៅពេលធ្លាក់ឈាមរដូវ ។ |
| Mucous membrane | គឺជាជាលិកាអាចបញ្ចេញជាតិរំអិលខាប់ៗដូចសំបោរដែលពាសរន្ធ ឬ ប្រហោងជាច្រើន និងសរីរាង្គ ដែលមានសណ្ឋានដូចបំពង់ ។ |
| *Neisseria gonorrhoea* | គឺជាឈ្មោះវិទ្យាសាស្ត្រនៃបាក់តេរីដែលជាមូលហេតុនៃជំងឺប្រមេះទឹកបាយ ។ បាក់តេរីនេះគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុទាំងឡាយនៃការហូរខ្ទុះតាមប្រដាប់បន្តពូជស្ត្រី នៃការហូរខ្ទុះតាមបង្ហួរនោមលើបុរស ឬ នៃជំងឺឈឺចាប់ផ្នែកក្រោមនៃពោះស្ត្រី ជំងឺហើមពងស្វាស និងនៃជំងឺរលាកភ្នែកទារកទើបនឹងកើត ។ |
| Neonatal conjunctivitis/ ជំងឺរលាកភ្នែកទារកទើបនឹងកើត | គឺជាជំងឺរលាកភ្នាសស្តើងនៃភ្នែក និង ត្របកភ្នែកលើទារកទើបនឹងកើត បណ្តាលមកពីមេរោគហ្គោណូក្កូក ឬ Chlamydia ហើយរាលដាលទៅភ្នែកទារក នៅពេលទារកឆ្លងកាត់មាត់ស្បូន និងទ្វារមាសក្នុងពេលប្រសូត្រ ។ ខ្ទុះនេះហូរមកយ៉ាងជាក់ច្បាស់នៅក្នុងភ្នែកទារក ។ |
| Oil-based lubricants / ប្រេងរំអិលធ្វើពីជាតិប្រេង | គឺជាប្រេងរំអិលដែលមិនបានណែនាំឱ្យប្រើប្រាស់លាបលើស្រោមអនាម័យទេ ។ |
| Open questions / សំណួរបើក | គឺជាសំណួរដែលតំរូវឱ្យមានចំលើយលំអិតជាធម្មតាផ្តើមឡើងដោយ “ហេតុដូចម្តេច?” “អ្វីខ្លះ?” “ ឯណា?” ឬ “ ហេតុអ្វី?” ។ |
| Ophthalmia neonatorum / ជំងឺភ្នែកក្រហម | គឺជាជំងឺរលាកភ្នែកកើតឡើងនៅលើទារកអាយុតិចជាងមួយខែ ជាធម្មតាបណ្តាលមកពីមេរោគហ្គោណូក្កូក ឬ Chlamydia ។ |
| Ovum / ova / អូវុល | ពងដែលបង្កើតឡើងដោយអូវែរ ហើយធ្វើឱ្យមានការបង្កកំណើតនៅពេលដែលជួបជាមួយ ស្ពែរម៉ាតូហ្សូអ៊ិត ។ |
| Palpation / ការស្ទាប | គឺជាការពិនិត្យជំងឺដោយការប្រើដៃស្ទាប ។ |

| | |
|---|---|
| Partner referral and care / ការបញ្ជូនដៃគូរួមភេទដោយអ្នកជំងឺ | គឺធ្វើការជួបពិភាក្សា ធ្វើការព្យាបាល និង ធ្វើការអប់រំដល់រាល់ដៃគូរួមភេទតាមតារាងរាយនាមអ្នកជំងឺដែលបានព្យាបាលជំងឺកាមរោគ ។ |
| Partnership / ការបង្ហាញភាពជាដៃគូ | គឺជាភាពស្ទាត់ជំនាញមួយក្នុងចំណោមភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដោយការនិយាយស្តីតាំង ៦ យ៉ាងដែលលើកទឹកចិត្តអ្នកជំងឺប្តេជ្ញាចិត្តចូលរួមជាមួយនិងក្រុមបុគ្គលិកសុខាភិបាលក្នុងការណែនាំឱ្យប្រើប្រាស់ក្នុងការដោះស្រាយបញ្ហាថែទាំ ។ |
| Patient referral / ការបញ្ជូនដោយអ្នកជំងឺ | គឺជាវិធីសាស្រ្តមួយអង្គការសុខភាពពិភពលោក ណែនាំឱ្យប្រើប្រាស់ក្នុងការថែទាំដៃគូរួមភេទ។ វិធីនេះពឹងផ្អែកលើអ្នកជំងឺផ្ទាល់ដែលត្រូវផ្តល់ពត៌មានដល់ដៃគូរបស់គាត់។ |
| Patient referral card / ប័ណ្ណបញ្ជូនអ្នកជំងឺ | គឺជាប័ណ្ណដែលអ្នកជំងឺត្រូវផ្តល់ឱ្យដៃគូរួមភេទរបស់គាត់សំរាប់ជយយលើកទឹកចិត្តឱ្យគាត់មកកាន់មណ្ឌលសុខភាពដើម្បីទទួលការព្យាបាល ។ ប័ណ្ណបញ្ជូនអ្នកជំងឺនោះអាចប្រើជាឯកសាររដ្ឋបាលសំរាប់មណ្ឌលសុខភាព ។ |
| Pelvic inflammatory disease (PID) / ជំងឺរលាកប៉េលវិស | គឺជាពាក្យទូទៅមួយបញ្ជាក់ការចំលងរោគទាំងឡាយលើប្រដាប់បន្តពូជស្រ្តីដែលជារឿយៗបណ្តាលឱ្យអ្នកជំងឺមានចង្កោមរោគសញ្ញាឈឺចាប់ផ្នែកខាងក្រោមនៃពោះ ។ ជាធម្មតាវាបណ្តាលមកពីមេរោគប្រមេះទឹកបាយ Chlamydia និង បាក់តេរីមិនត្រូវការខ្យល់អុកស៊ីហ្សែន ( anaerobic bacteria ) ។ |
| Pelvic masses / សាច់ដុំនៅតំបន់ប៉េលវិស | គឺការរកកើតដុំនៅក្នុងផ្នែកក្រោមនៃពោះ ។ |
| Perinatal/ ជុំវិញការសំរាល | ដែលទាក់ទងនឹងពេល មុន ក្នុងពេល ឬក្រោយពេលដែលទារកទើបនឹងកើតភ្លាមៗ ។ |
| Perineum / ប៉េរីណេ | គឺជាតំបន់ជុំវិញទ្វារលាមក និង ពងស្វាស ឬ យោនី (vulva) ។ |
| Period of infectiousness / រយៈពេលចំលង | គឺជារយៈពេលមួយដែលស្ថិតនៅចន្លោះពេលអ្នកជំងឺទទួលឆ្លងជំងឺកាមរោគរហូតដល់ពេលដែលគាត់ទទួលការព្យាបាល។ ចំពោះការបញ្ជូនអ្នកជំងឺមកទទួលការព្យាបាលនោះយើងសន្មតថារយៈពេលនេះ គឺ ២ ខែ ។ |
| Peritoneum / ស្រោមពោះ | ស្រទាប់ខាងក្នុងដែលស្រោបប្រហោងពោះ ។ |
| PID / ជំងឺរលាកប៉េលវិស | ជាអក្សរកាត់សំគាល់ជំងឺរលាកប៉េលវិស (សូមអាននិយមន័យខាងលើ) ។ វាគឺជា |

មូលហេតុមួយ ក្នុងចំណោមមូលហេតុទាំងឡាយនៃការឈឺចាប់ផ្នែកក្រោមនៃពោះ។

| | |
|---|---|
| | មូលហេតុមួយ ក្នុងចំណោមមូលហេតុទាំងឡាយនៃការឈឺចាប់ផ្នែកក្រោមនៃពោះ។ |

Plasma / ប្លាស្មា — ជាវត្ថុរាវគ្មានពណ៌ ហើយជាចំណែកមួយនៃឈាម នៃទឹករងៃ ឬ នៃទឹកដោះ ។

Provider referral / ការបញ្ជូនដោយអ្នកផ្តល់សេវាថែទាំ — គឺជាវិធីសាស្ត្របញ្ជូនដៃគូរួមភេទឱ្យមកទទួលការព្យាបាលដែលក្នុងនោះគេបានបណ្តុះបណ្តាលយ៉ាងពិសេសដល់បុគ្គលិកសុខាភិបាលហើយឱ្យបុគ្គលិកនោះចុះជួបពិភាក្សាជាមួយដៃគូរួមភេទរបស់អ្នកជំងឺដំបូង ។

Reassurance / ការធានាអះអាង — គឺជាភាពស្ទាត់ជំនាញមួយ ក្នុងចំណោមភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងការនិយាយស្តីទាំង៦យ៉ាងដែលសំដែងឱ្យអ្នកជំងឺឃើញថាអ្នកព្រមទទួលយកនូវអារម្មណ៍ការសំរេចចិត្តស្របតាមគំនិតណាមួយរបស់គាត់ហើយដែលឱ្យគាត់យល់ថាបញ្ហាទាំងឡាយ នឹងត្រូវបានដោះស្រាយរួចទាន់ពេលវេលា ។

Rebound tenderness — នេះគឺជាសញ្ញាមួយនៃជំងឺរលាកស្រោមពោះ ឬ ការបង្កខ្ទុះក្នុងពោះ ហើយជាសញ្ញាមួយដែលអ្នកត្រូវស្វែងរកក្នុងពេលពិនិត្យជំងឺនិងមានក្នុងចង្កោមរោគសញ្ញាឈឺចាប់ផ្នែកក្រោមនៃពោះ ។ អ្នកជំងឺមានការឈឺចាប់យ៉ាងខ្លាំងពេលអ្នកសង្កត់យ៉ាងថ្នមៗនិងយឺតៗលើតំបន់ដែលមានការឈឺចាប់បន្ទាប់មកដកដៃចេញភ្លាមៗ ។ ជាមួយនឹងភាពកន្ត្រាក់រឹងសាច់ដុំពោះ វាគឺជាសញ្ញាដ៏ធ្ងន់ធ្ងរបំផុតចំពោះអាយុជីវិត ។

RPR — ជាអក្សរកាត់សំគាល់ " rapid plasma reagin " គឺជាតេស្តមួយក្នុងចំណោមតេស្តមន្ទីរពិសោធន៍ដែលគេប្រើសំរាប់ធ្វើរោគវិនិច្ឆ័យ។

Scrotal swelling / ការហើមពងស្វាស — គឺជាចង្កោមរោគសញ្ញាជំងឺដែលកើតមានលើបុរស, សញ្ញាទាំងនោះមានហើម ក្តៅ និងឈឺចាប់យ៉ាងខ្លាំងនៅលើពងស្វាស ។ ជារឿយៗ វាបណ្តាលមកពីជំងឺប្រមេះទឹកបាយ និង Chlamydia ។

Serum / សេរ៉ូម — គឺជាសារធាតុរាវ អាចញែកបានពីឈាមក្រោយពីធ្វើឱ្យឈាមកក ។

Sexually transmitted diseases (STDs) / ជំងឺកាមរោគ — គឺជាជំងឺឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត តាមរយៈការរួមភេទ ។

Sign / សញ្ញា — គឺជាបញ្ហាគ្លីនិកដែលអ្នកឃើញតាមរយៈការពិនិត្យជំងឺ ។

Spermatozoa/ មេជីវិតបុរស — គឺជាកោសិកាទឹកកាមដែលមានវ័យចំណាស់ដែលអាចធ្វើចលនាដោយឯកឯងបាន ។

| | |
|---|---|
| Spermicidal foam / ក្រែមសំរាប់សំលាប់ស្ពែម៉ាតូហ្សូអ៊ីត | គឺជាពពុះម្យ៉ាងអាចសំលាប់ទឹកកាមបាន ជារឿយៗគេប្រើវាជាមួយស្រោមអនាម័យ ទុកដូចជាការការពារបន្ថែម ។ |
| STDs / ជំងឺកាមរោគ | ជាពាក្យកាត់មកពី Sexually transmitted diseases (សូមអាននិយមន័យខាងលើ) |
| Summarizing and checking / ការសង្ខេប និង ផ្ទៀងផ្ទាត់ | គឺជាភាពស្ទាត់ជំនាញមួយក្នុងចំណោមភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដោយការនិយាយស្តីទាំង៦យ៉ាងដោយធ្វើការសង្ខេបអ្វីដែលអ្នកជំងឺបាននិយាយដើម្បីត្រួតពិនិត្យមើលថាតើអ្នកបានយល់ត្រឹមត្រូវដែរឬទេ ។ |
| Susceptibility to infection / ភាពងាយទទួលការឆ្លងរោគ | កំរិតប្រឆាំងតបតរបស់សរីរាង្គទៅនឹងការចំលងរោគ ឧទាហរណ៍: ឆ្លើយតបរបស់រាងកាយ មានកំរិតចំពោះជំងឺមានន័យថា អ្នកជំងឺងាយរងទទួលការចំលងរោគខ្ពស់ ។ |
| Symptom / រោគសញ្ញា | គឺជាបញ្ហាគ្លីនិកដែលអ្នកជំងឺត្អូញត្អែរប្រាប់ ។ |
| Syndrome / ចង្កោមរោគសញ្ញា | គឺជាការប្រមូលផ្តុំនូវសញ្ញា នឹង រោគសញ្ញានៃជំងឺ ។ |
| Syndromic case management / ការគ្រប់គ្រងថែទាំកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា | គឺជាការគ្រប់គ្រងថែទាំអ្នកជំងឺ ដោយផ្អែកលើចង្កោមរោគសញ្ញាជំងឺកាមរោគដែលមិនមែនជាការរុករកមូលហេតុជាក់លាក់ណាមួយនៃជំងឺ ។ គឺជាការព្យាបាលចំពោះគ្រប់ភ្នាក់ងារចំលងរោគទាំងអស់ ។ |
| Syphillis / ជំងឺស្វាយ | គឺជាពាក្យទូទៅសំគាល់ជំងឺដែលបណ្តាលមកពីមេរោគ *Treponema pallidum* ។ |
| Testis / ពងស្វាស | គឺជាពាក្យវេជ្ជសាស្ត្រសំរាប់ពងស្វាស (testes គឺជាពហុវចនៈ) ។ |
| Trauma / ការប៉ះទង្គិច | គឺជាដំបៅឬរបួសផ្លូវកាយ ជួនកាលគេប្រើប្រាស់វាផងដែរដើម្បីពិពណ៌នាអំពីការប៉ះទង្គិច (shock) ដែលបណ្តាលឱ្យមានរបួស ឬ ដំបៅ ។ |
| *Treponema pallidum* / មេរោគដែលបណ្តាលឱ្យកើតជំងឺស្វាយ | គឺជាឈ្មោះបែបវិទ្យាសាស្ត្រសំគាល់បាក់តេរីដែលជាមូលហេតុនៃជំងឺស្វាយ ។ គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុទាំងឡាយនៃដំបៅលើប្រដាប់បន្តពូជ។ |
| *Trichomoniasis vaginalis* | គឺជាឈ្មោះបែបវិទ្យាសាស្ត្រសំគាល់បាក់តេរីបង្កជំងឺ Trichomonas។ គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុទាំងឡាយនៃជំងឺដំបៅហូរខ្ទុះតាមទ្វារមាសស្ត្រី។ |

| | |
|---|---|
| Tubal pregnancy / ការកគភ៌នៅដៃស្បូន | គឺការមានគភ៌នៅដៃស្បូន ដែលមានគ្រោះថ្នាក់ដល់អាយុជីវិត ។ |
| Tubo-ovarian abscess / ការកខ្ទុះនៅដៃស្បូននិងអូវែរ | គឺជាការបង្កខ្ទុះក្នុងដៃស្បូន និងក្នុងអូវែរដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត ។ |
| Ulcers / ដំបៅ | គឺជាដំបៅបើកមុខ ។ |
| Ulcerative STD | គឺជំងឺកាមរោគទាំងឡាយណាដែលបង្កើតឱ្យមានដំបៅ ។ |
| *Ureaplasma urealyticum* | គឺជាពាក្យវិទ្យាសាស្ត្រសំគាល់បាក់តេរីម្យ៉ាងដែលបណ្តាលឱ្យមានចង្កោមរោគសញ្ញាហូរខ្ទុះតាមទ្វារមាស ។ |
| Urethra / បង្ហួរនោម | គឺជាបំពង់មួយបង្ហួរទឹកនោមពីផ្លោកនោម ។ |
| Urethral discharge / ការហូរខ្ទុះពីបង្ហួរនោម | គឺជាឈ្មោះនៃចង្កោមរោគសញ្ញាដែលក្នុងនោះអ្នកជំងឺ (ជាបុរស) មានហូរខ្ទុះតាមលិង្គជាធម្មតា បណ្តាលមកពីមេរោគប្រមេះទឹកបាយ ឬ chlamydia ។ |
| Urethral stricture / ការរួមតូចនៃបង្ហួរនោម | គឺការរួមតូចនៃបង្ហួរនោម ដែលបណ្តាលមកពីជំងឺណាមួយ ។ |
| Urethritis / ការរលាកបង្ហួរនោម | គឺការរលាកបង្ហួរនោមជាធម្មតាបណ្តាលមកពីមេរោគប្រមេះទឹកបាយឬChlamydia ។ |
| Uterine cavity / ប្រហោងស្បូន | គឺជាប្រហោងមួយដែលមានតួស្បូននៅក្នុងនោះ ។ |
| Vaginal bacteriosis / ជំងឺទ្វារមាសបង្កដោយបាក់តេរី | គឺជាពាក្យទូទៅសំគាល់ជំងឺលើប្រដាប់បន្តពូជស្ត្រីដែលបណ្តាលមកពីបាក់តេរី ។ គឺជាទំរង់មួយនៃការរលាកទ្វារមាសបណ្តាលមកពីមីក្រូសារពាង្គកាយឈ្មោះ *Gardnerella vaginalis* ។ |
| Vaginal discharge / ការហូរខ្ទុះពីទ្វារមាសឬធ្លាក់ស | គឺជាឈ្មោះចង្កោមរោគសញ្ញាកើតលើអ្នកជំងឺ(ជាស្ត្រី) ដែលមានការហូរខ្ទុះពីប្រដាប់បន្តពូជស្ត្រីហើយជាធម្មតាបណ្តាលមកពីមេរោគប្រមេះទឹកបាយ ឬ chlamydia ។ |
| Vaginitis / ការរលាកទ្វារមាស | គឺការរលាកទ្វារមាសដែលបណ្តាលមកពីជំងឺ bacterial vaginosis ឬ vaginal bacterosis, ឬមេរោគទ្រីកូម៉ូណាស់ ឬ ពពួកផ្សិត candidiasis ។ |

| | |
|---|---|
| Vas deferens | គឺជាបំពង់នាំទឹកកាមពីពងស្វាសទៅបង្ហូរនោម (urethra) (គេអាចហៅដែរ ថាជា spermatic cord) ។ |
| VDRL | ជាអក្សរកាត់នៃ " Venereal Disease Research Laboratory " ដែលជាឈ្មោះតេស្តមន្ទីរពិសោធន៍ដែលប្រើដើម្បីធ្វើរោគវិនិច្ឆ័យជំងឺស្វាយ (សូមមើល RPR)។ |
| Vesicular lesions / ដំបៅពងបែក | គឺជាពងទឹកតូចៗ ដែលបែករួចបង្កើតបានជាដំបៅតូចៗ ដែលជារឿយៗមានមូលហេតុមកពីវីរុស *Herpes Simplex virus* (HSV) ។ ពងទឹកតូចៗ ដូចជាដំបៅដែលជាសញ្ញាពិសេសសំគាល់ជំងឺ Herpes ។ |
| Vulva / យោនី | គឺជាប្រដាប់បន្តពូជផ្នែកខាងក្រៅរបស់ស្ត្រី ។ |
| Water-based lubricants / ប្រេងរំអិលដែលធ្វើពីជាតិទឹក | គឺជាប្រេងរំអិល មានសារធាតុគ្រឹះជាជាតិទឹកគ្មានគ្រោះថ្នាក់ ពេលប្រើប្រាស់ជាមួយស្រោមអនាម័យ ។ |

